# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# របាយការណ៍
# សមិទ្ធផលវិស័យសុខាភិបាល ឆ្នាំ២០២៥
# និង ទិសដៅការងារឆ្នាំ២០២៦ និងឆ្នាំបន្ត




ខែមករា ឆ្នាំ២០២៦

# សមិទ្ធិផលទាំងឡាយក្នុងវិស័យសុខាភិបាល
# គឺជាការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល
# និងមិនអាចកាត់ផ្តាច់បាន
# ពីការចូលរួមចំណែកគាំទ្ររបស់ ដៃគូអភិវឌ្ឍន៍

ក្រសួងសុខាភិបាល
នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល
ខែមករា ឆ្នាំ២០២៦



ព្រះរាជពិធីពន្លត់ទៀនជ័យ

នៃទិវាបុណ្យឯករាជ្យជាតិខួបលើកទី៧២

( ៩ វិច្ឆិកា ១៩៥៣-៩ វិច្ឆិកា ២០២៥ ) ក្រោមព្រះរាជាធិបតី

ដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេច**

**ព្រះបរមនាថ នរោត្តម សីហមុនី**

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ



# ព្រះករុណា ព្រះបាទ
# សម្តេច ព្រះនរោត្តម សីហមុនី ព្រះមហាក្សត្រ

ទ្រង់បានសព្វព្រះរាជហឫទ័យ យាងសួរសុខទុក្ខវីរកងទ័ពសមរភូមិជួរមុខ
ដែលកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលា។




**« បែកបាក់ គឺស្លាប់ សាមគ្គីរឹងមាំ គឺរស់**
យើងត្រូវយកការលំបាកនៅពេលនេះ ធ្វើជាឱកាស ដើម្បីខ្មែរគ្រប់រូបចេះពួតដៃគ្នា
កសាងជាតិខ្មែរយើងឱ្យកាន់តែរឹងមាំ និងកាន់តែប្រសើរឡើង ប្រកបដោយភាពធន់
នៅក្រោមម្លប់ដ៏សែនត្រជាក់នៃអង្គព្រះមហាក្សត្រជាទីគោរពសក្ការៈនៃយើង។ »

(ដកស្រង់ចេញពីសារពិសេសរបស់
**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ជូនបងប្អូនវីរកងទ័ព និងវីរនគរបាល ដ៏អង់អាចក្លាហាន
និងបងប្អូន ជនរួមជាតិ ជាទីគោរព និងជាទីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត
នាថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៥)



« ក្រសួងសុខាភិបាល និងផ្នែកសេវាថែទាំសុខភាពឯកជន ត្រូវបន្តការកែទម្រង់
ប្រព័ន្ធសិក្សា ដោយផ្អែកលើកម្មវិធីសិក្សាផ្តោតលើសមត្ថភាព ជំនាញបច្ចេកទេស
ទាំងបំណិន ផ្នែករឹង និងផ្នែកទន់ ហើយត្រូវយកចិត្តទុកដាក់លើការបំពេញ
ការងារជាក្រុម មានវិន័យហើយប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ
នៅពេលបម្រើសេវាជូនប្រជាពលរដ្ឋ។ »

( ដកស្រង់ចេញពីអនុសាសន៍របស់

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ក្នុងពិធីបញ្ចុះបឋមសិលាសាងសង់មន្ទីរពេទ្យសាកលវិទ្យាល័យ
វិទ្យាសាស្ត្រសុខាភិបាល  ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៤ )





**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**
**និងលោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត**

អញ្ជើញសួរសុខទុក្ខប្រជាជនដែលកំពុងសម្រាកព្យាបាល
នៅមន្ទីរពេទ្យកាល់ម៉ែត




សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ប្រគល់សៀវភៅផែនការជាតិ
ប្រយុទ្ធនឹងជំងឺមហារីក ២០២៥-២០៣០
ជូនឯកឧត្តមសាស្ត្រាចារ្យ **ឈាង រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល




**ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី**

រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ក្នុងពិធីប្រកាសបើកយុទ្ធនាការ
ចុះធ្វើជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធ
នៃគ្រឹះស្ថានសិក្សាសាធារណៈ និងអង្គភាពសុខាភិបាលមូលដ្ឋាន
នៅរាជធានីភ្នំពេញ



ឯកឧត្តមសាស្ត្រាចារ្យ **ឈាន រ៉ា** រដ្ឋមន្ត្រីក្រសួងសុខាភិបាល
បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសបញ្ចូលវ៉ាក់សាំងការពារជំងឺរាកធ្ងន់ធ្ងរ
និងមានក្អួតលើកុមារតូច (អាយុពី១ខែ ដល់២ឆ្នាំ) ដែលបង្កដោយវីរុសរ៉ូតា
ទៅក្នុងកម្មវិធីជាតិផ្តល់ថ្នាំបង្ការ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា



« ការពារ និងលើកកម្ពស់សុខភាព ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប គឺជាបេសកកម្ម ប្រកបដោយកិត្តិយស និងសេចក្តីថ្លៃថ្នូរ របស់អ្នកវិជ្ជាជីវៈសុខាភិបាលគ្រប់រូប »

# អារម្ភកថា

ឆ្នាំ២០២៥ ត្រូវបានកត់ត្រា ជាឆ្នាំដែលប្រជាជាតិកម្ពុជាទាំងមូលបានពូតផ្តុំស្មារតីសាមគ្គីជាតិដ៏រឹងមាំ និងមនសិការជាតិដ៏ជ្រាលជ្រៅ ជាមួយរាជរដ្ឋាភិបាល ដែលមានភារកិច្ចការពារប្រជាពលរដ្ឋ និងការពារបូរណភាពទឹកដីក្នុងដែនអធិបតេយ្យភាពកម្ពុជា នៅក្នុងដំណាក់កាលវិបត្តិនៃការឈ្លានពានតាមបណ្តោយព្រំដែនជាង ៨០០ គ.ម នៅភាគខាងលិចប្រទេសកម្ពុជា។

ឈរលើស្មារតីសាមគ្គីភាពដ៏ស្អិតរមួត ឆន្ទៈមោះមុត ករុណាធម៌ដ៏ជ្រាលជ្រៅ ភាពក្លាហាន និងការប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ មន្ត្រី បុគ្គលិកសុខាភិបាល គ្រប់ជំនាញ និងគ្រប់លំដាប់ថ្នាក់ ទូទាំងប្រទេស ជាពិសេស ក្រុមគ្រូពេទ្យ បុគ្គលិកថែទាំ ព្យាបាល និងក្រុមរថយន្តគិលានសង្គ្រោះ បានឧទ្ទិសការតស៊ូយ៉ាងខ្លាំងក្លារបស់ខ្លួន ជំនះរាល់ឧបសគ្គ ការលំបាកនិងការគម្រាមកំហែងដល់អាយុជីវិត ក្នុងការបម្រើសេវាថែទាំអប់រំ បង្ការ ថែទាំព្យាបាល និងសេវាគាំទ្រសារវន្ត ជូនប្រជាពលរដ្ឋភៀសសឹក និងវីរកងទ័ពយើង។

ការឆ្លើយតបទាន់ពេល និងប្រកបដោយប្រសិទ្ធភាព ចំពោះការគំរាមកំហែងសុខភាពសាធារណៈ និងតម្រូវការបន្ទាន់ផ្នែកវេជ្ជសាស្ត្រ នៅក្នុងដំណាក់កាលដ៏តឹងតែងនោះ បានឆ្លុះបញ្ចាំងពីកម្រិតភាពធន់នៃប្រព័ន្ធសុខាភិបាលយើង។ ប្រព័ន្ធសុខាភិបាលដែលមានភាពធន់មិនគ្រាន់តែការពារអាយុជីវិតប្រជាពលរដ្ឋយើង នាពេលបច្ចុប្បន្នប៉ុណ្ណោះទេ ប៉ុន្តែក៏ជាគ្រឹះនៃអនាគតសុខភាព និងសុខុមាលភាពដ៏ល្អប្រសើររបស់ប្រជាពលរដ្ឋយើងផងដែរ។ ក្នុងន័យនេះ យើងទាំងអស់គ្នាត្រូវបន្តរក្សាការប្រុងប្រយ័ត្ន ក្នុងភាពបុរេសកម្ម សកម្ម និងអន្តរសកម្ម ព្រមទាំងជំរុញនវានុវត្តន៍ក្នុងការស្តារស្ថានការណ៍ឡើងវិញក្រោយពេលវិបត្តិឱ្យបានឆាប់រហ័ស និងការបន្តពង្រឹងភាពធន់នៃប្រព័ន្ធសុខាភិបាលឱ្យកាន់តែរឹងមាំថែមទៀត និងឱ្យមានចីរភាពយូរអង្វែង។

ទោះបីផលវិបាកនៃព្រឹត្តិការណ៍ខាងលើ បានធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលរងការបំផ្លិចបំផ្លាញ និងធ្វើឱ្យប៉ះពាល់ដល់ការបម្រើសេវាថែទាំសុខភាពជូនប្រជាពលរដ្ឋ ក្នុងសហគមន៍

តាមព្រំដែនក្តី ជារួម នៅក្នុងឆ្នាំ២០២៥ សមិទ្ធផល និងវឌ្ឍនភាពជាច្រើននៅក្នុងវិស័យសុខាភិបាល ត្រូវបានកត់សម្គាល់ ក្នុងនោះរួមមាន៖ **ទី១. ការពង្រឹងការថែទាំសុខភាពបឋម** នៅតាមមូលដ្ឋានសុខាភិបាល ជាពិសេសសុខភាពមាតា ទារក និងកុមារ ការធ្វើសមាហរណកម្ម ការផ្តល់សេវាបង្ការ និងព្យាបាលជំងឺមិនឆ្លង និងការគ្រប់គ្រងជំងឺឆ្លងចម្បងៗ **ទី២. ការកែលម្អគុណភាពសេវា និងសុវត្ថិភាពអ្នកជំងឺ** ដែលជាអន្តរាគមន៍ចាំបាច់ សំដៅបង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋមកលើប្រព័ន្ធសុខាភិបាល ទាំងសាធារណៈ និងឯកជន **ទី៣. វឌ្ឍនភាពឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា** នៅក្នុងក្របខ័ណ្ឌនៃការពង្រឹងប្រព័ន្ធគាំពារសុខភាពតាមរយៈកិច្ចសហការអន្តរវិស័យ និងពហុវិស័យ **ទី៤. ការពង្រឹងភាពធន់ប្រព័ន្ធសន្តិសុខសុខភាព** ក្នុងការឆ្លើយតបទាន់ពេល និងប្រកបដោយប្រសិទ្ធភាពនឹងជំងឺឆ្លងរាតត្បាត ការគំរាមកំហែង ឬគ្រោះអាសន្ន សុខភាព និង **ទី៥. ការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល** ដែលឆ្លើយតបនឹងតម្រូវការថែទាំបង្ការ ការធ្វើរោគវិនិច្ឆ័យ ការថែទាំ ព្យាបាល ឱ្យកាន់តែមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់ ស្របតាមនិន្នាការវិវត្តនៃបន្ទុកជំងឺ និងភាពជឿនលឿននៃបច្ចេកវិទ្យាវេជ្ជសាស្ត្រ។

របាយការណ៍សមិទ្ធផលក្នុងវិស័យសុខាភិបាល ឆ្នាំ២០២៥ បានគូសបញ្ជាក់ផងដែរ នូវបញ្ហាប្រឈមចំពោះមុខ បញ្ហាប្រឈមក្នុងរយៈពេលខ្លីទៅរយៈមធ្យម និងទៅរយៈពេលវែង ដែលយើងត្រូវធ្វើការពិនិត្យឡើងវិញឱ្យបានម៉ត់ចត់ថែមទៀត ព្រមទាំងរិះរកមធ្យោបាយដោះស្រាយប្រកបដោយនវានុវត្តន៍ ដើម្បីលើកកម្ពស់ការអនុវត្តផែនការសកម្មភាពឆ្នាំ២០២៦ ឱ្យសម្រេចបានលទ្ធផលល្អថែមទៀត នៅក្នុងក្របខ័ណ្ឌធនធានដែលមាន ឬដែលអាចរកបាន ស្របតាមទិសដៅការងារឆ្នាំ២០២៦ និងឆ្នាំបន្ត ព្រមទាំងមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រទាំងឡាយ ដែលដាក់ចេញឱ្យអនុវត្ត នៅក្នុងវិស័យសុខាភិបាល និងកម្មវិធីគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។

ខ្ញុំមានជំនឿមុតមាំថា ការប្តេជ្ញាចិត្តដ៏រឹងមាំរបស់យើងចំពោះចក្ខុវិស័យរួម «**ប្រជាពលរដ្ឋគ្រប់រូបរស់នៅប្រកបដោយសុខភាព និងសុខុមាលភាព ដើម្បីចូលរួមក្នុងការអភិវឌ្ឍមូលធនមនុស្ស និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព**» តាមរយៈការអនុវត្តសកម្មភាពប្រចាំថ្ងៃរបស់ថ្នាក់ដឹកនាំ មន្ត្រីគ្រប់គ្រង គ្រូពេទ្យ បុគ្គលិកសុខាភិបាលគ្រប់រូបនៃអង្គភាពសុខាភិបាលទាំងអស់ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ តាមតួនាទី និងភារកិច្ចរបស់ខ្លួន ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ និងឈរលើគោលការណ៍ប្រតិបត្តិរបស់យើង «**សកលភាព ភាពជឿទុកចិត្ត សុចរិតភាព គុណភាព នវានុវត្តន៍ ការសហការ**» នឹងនាំមកនូវអត្ថប្រយោជន៍បន្ថែម ទាំងគុណភាព ទាំងបរិមាណ ដល់ការកែលម្អស្ថានភាពសុខភាព និងការលើកស្ទួយសមធម៌សុខភាព សម្រាប់ប្រជាពលរដ្ឋកម្ពុជាយើងគ្រប់រូបនាពេលបច្ចុប្បន្ន និងសម្រាប់ប្រជាពលរដ្ឋជំនាន់ក្រោយៗ៕

ថ្ងៃសុក្រ ១៣រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

ព្រះរាជាណាចក្រកម្ពុជា

ក្រសួងសុខាភិបាល

សាស្ត្រាចារ្យ **ឈាន រ៉ា**

# មាតិកា


០១

**សេចក្តីផ្តើម** **១**

១.១. សារបាន ២

១.២. សនិទានកម្ម ២

១.៣. ប្រភពទិន្នន័យ ៣

០២

**ការទទួលបានសេវាថែទាំសុខភាព និងការគ្រប់ដណ្តប់** **៤**

២.១. ការប្រើប្រាស់សេវាថែទាំសុខភាពទូទៅ ៥

២.២. ការលើកកម្ពស់ឥរិយាបថល្អដើម្បីសុខភាព ១១

២.៣. ការពង្រីកការគ្របដណ្តប់នៃសេវាថែទាំសុខភាព ១២

២.៤. ការចូលរួមរបស់សហគមន៍ដើម្បីសុខភាព ១២

២.៥. លើកកម្ពស់សុខភាពបន្តពូជ មាតា ទារក កុមារ និងអាហារូបត្ថម្ភ ១៣

២.៦. ការបង្ការ និងការគ្រប់គ្រងជំងឺឆ្លង ៣២

២.៧. ការបង្ការ និងការគ្រប់គ្រងជំងឺមិនឆ្លង និងបញ្ហាសុខភាពចម្បងដទៃទៀត ៤១

០៣

**គុណភាព និងសុវត្ថិភាពនៃសេវាថែទាំសុខភាព** **៤៨**

៣.១. ការគ្រប់គ្រងរំហូរអ្នកជំងឺ ៥០

៣.២. សុវត្ថិភាពអ្នកជំងឺ និងការកាត់បន្ថយហានិភ័យ ៥០

៣.៣. ការបញ្ជូនអ្នកជំងឺ ៥១

៣.៤. ការកែលម្អគុណភាពសេវា ៥២

០៤

**សមធម៌ក្នុងការទទួលបានសេវាថែទាំសុខភាព** **៥៩**

៤.១. ការគ្របដណ្តប់ប្រជាជន ៦០

៤.២. ការគ្របដណ្តប់នៃសេវាសុខភាព ៦១

៤.៣. ការកាត់បន្ថយបន្ទុកហិរញ្ញវត្ថុ ៦៤

០៥

**ភាពធន់ប្រព័ន្ធសន្តិសុខ សុខភាព** **៦៦**

៥.១. ការបង្ការ និងគ្រប់គ្រងជំងឺឆ្លងដែលលេចឡើង និងលេចឡើងសាជាថ្មី ៦៧

៥.២. ការបង្ការ និងការគ្រប់គ្រងហានិភ័យសុខភាពតែមួយ ៧០

៥.៣. សេវាមន្ទីរពិសោធន៍សុខាភិបាល ៧១

៥.៤. សេវាផ្តល់ឈាម ៧២

០៦

**ការពង្រឹងភាពធន់ និងការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល** **៧៥**

៦.១. ការអភិវឌ្ឍស្ថាប័ន និងអភិបាលកិច្ចសុខាភិបាល ៧៦

៦.២. ការអភិវឌ្ឍធនធានមនុស្ស ៨៩

៦.៣. ការគ្រប់គ្រងហិរញ្ញវត្ថុ ៩៧

៦.៤. ការផ្គត់ផ្គង់ឱសថ ឧបករណ៍ពេទ្យនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ១០០

៦.៥. ការអភិវឌ្ឍទិន្នន័យ ប្រព័ន្ធព័ត៌មានសុខាភិបាល និងសុខាភិបាលឌីជីថល ១០២

០៧

**ទិសដៅការងារឆ្នាំ២០២៦ និងឆ្នាំបន្ត** **១០៨**

៧.១. បង្កើនការទទួលបាន និងការគ្របដណ្តប់នៃសេវាថែទាំសុខភាព ១០៩

៧.២. ការលើកកម្ពស់គុណភាព និងសុវត្ថិភាពនៃការថែទាំសុខភាព ១០៩

៧.៣. ការគាំពារហិរញ្ញវត្ថុ ១១០

៧.៤. ការពង្រឹងសន្តិសុខសុខភាព ១១០

៧.៥. ការពង្រឹងសមត្ថភាព និងការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល ១១១

៧.៦. ក្របខ័ណ្ឌសូចនាករសម្រាប់ការតាមដាន និងការវាយតម្លៃ ១១៣

០៨

**៨. សេចក្តីសន្និដ្ឋាន** **១១៨**

**ឧបសម្ព័ន្ធ** **១២១**

# ១ សេចក្តីផ្តើម

គំនូសបំព្រួញស្តីពី «យុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី ១»
ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព: កសាងមូលដ្ឋានគ្រឹះ
ឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០




១.១. សារបាន
១.២. សនិទានកម្ម
១.៣. ប្រភពទិន្នន័យ

# ១. សេចក្តីផ្តើម

## ១.១. សារបាន

ក្រសួងសុខាភិបាលរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីសមិទ្ធផលក្នុងវិស័យសុខាភិបាលជាប្រចាំ។របាយការណ៍ត្រូវបានផ្សព្វផ្សាយ នៅក្នុងសន្និបាតសុខាភិបាល ដែលប្រារព្ធធ្វើឡើងជាទូទៅនៅក្នុងខែមីនា រៀងរាល់ឆ្នាំ នៅរាជធានីភ្នំពេញ ប៉ុន្តែបានអាក់ខាននៅឆ្នាំ២០២១ និងឆ្នាំ២០២២ បណ្តាលមកពីការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ដោយក្រសួងរៀបចំត្រឹមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងកំណត់ទិសដៅការងារឆ្នាំបន្តនៅថ្នាក់ក្រសួងប៉ុណ្ណោះ។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាអតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ ជានិច្ចកាល នៅក្នុងពិធីបើក ឬពិធីបិទសន្និបាតសុខាភិបាលប្រចាំឆ្នាំ រហូតដល់សន្និបាតសុខាភិបាលលើកទី៤២ ដែលបានប្រព្រឹត្តទៅនៅខែមីនា ឆ្នាំ២០២៣ និងបានផ្តល់មតិសំណេះសំណាល ព្រមទាំងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ដល់សមាជិក សមាជិកានៃអង្គសន្និបាត។ ការណ៍នេះសបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់របស់ **សម្តេចតេជោ** ចំពោះសុខភាព និងសុខុមាលភាពប្រជាពលរដ្ឋកម្ពុជា។

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនីតិកាលទី៧ នៃសភា បានអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ នៅក្នុងពិធីបិទសន្និបាត លើកទី ៤៣ ដែលបានប្រព្រឹត្តទៅនៅ ថ្ងៃទី ១៨-១៩ ខែមីនា ឆ្នាំ២០២៤ និងបានផ្តល់មតិសំណេះសំណាល និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ ដល់សមាជិកសមាជិកាអង្គសន្និបាត ៦០២នាក់។ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមបិទសន្និបាតសុខាភិបាលលើកទី ៤៤ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ៣-៤ ខែមីនា ឆ្នាំ២០២៥។

## ១.២. សនិទានកម្ម

**របាយការណ៍ស្តីពីសមិទ្ធផលក្នុងវិស័យសុខាភិបាលប្រចាំឆ្នាំ និងទិសដៅការងារឆ្នាំបន្ត** គឺជាឯកសារកត់ត្រានូវលទ្ធផលក្នុងឆ្នាំនីមួយនៃរបាយការណ៍ ក្នុងការអនុវត្តកម្មវិធីគោលនយាបាយរបស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រក្នុងវិស័យសុខាភិបាល ព្រមទាំងអន្តរាគមន៍ និងសកម្មភាពអាទិភាព ដែលត្រូវអនុវត្តក្នុងឆ្នាំបន្ត ដោយរក្សាសង្គតិភាពជាមួយអាទិភាពជាតិនិងអាទិភាពវិស័យសុខាភិបាល។ ក្នុងន័យនេះ របាយការណ៍សមិទ្ធផលក្នុងវិស័យសុខាភិបាលឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ ត្រូវបានរៀបចំឡើង ក្នុងគោលបំណង ដូចខាងក្រោម៖

- វាស់វែងកម្រិត និងនិន្នាការនៃវឌ្ឍនភាព ចំណុចខ្លាំង និងបញ្ហាប្រឈមចម្បងៗ ក្នុងឆ្នាំ២០២៥ ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាល ២០២៥-២០៣៤ និងផែនការយុទ្ធសាស្ត្រដទៃទៀត ក្នុងវិស័យសុខាភិបាល កម្មវិធីគោលនយោបាយអាទិភាពទី១ (ការពង្រីកសេវាសុខាភិបាលឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកល) ការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល និងក្របខ័ណ្ឌគោលនយោបាយពាក់ព័ន្ធដទៃទៀត របស់រាជរដ្ឋាភិបាល។

- **ពង្រឹងមុខងារតាមដានត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មក្នុងប្រព័ន្ធសុខាភិបាល៖** ការអភិវឌ្ឍចំណេះដឹង និងសមត្ថភាពជំនាញ និងការពង្រឹងវប្បធម៌ធ្វើការជាក្រុមពហុជំនាញ គឺជាតម្រូវការចាំបាច់សម្រាប់ការពិនិត្យតាមដាន និងការវាយតម្លៃលទ្ធផលការងារ ទាំងនៅកម្រិតប្រព័ន្ធទាំងកម្រិតអង្គភាព ដោយផ្អែកលើការប្រមូល ការចងក្រង ការវិភាគ/បកស្រាយ ទិន្នន័យនិងព័ត៌មាន ការរាយការណ៍ និងការប្រើប្រាស់លទ្ធផល ដើម្បីគាំទ្រដល់ការសម្រេចចិត្ត ជាពិសេសសម្រាប់ការលើកកម្ពស់ការផ្តល់សេវាថែទាំសុខភាព និងអន្តរាគមន៍សុខភាពសាធារណៈ។

## ១.៣. ប្រភពទិន្នន័យ

របាយការណ៍ស្តីពីសមិទ្ធផលក្នុងវិស័យសុខាភិបាលឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ ត្រូវបានចងក្រងឡើង ដោយប្រើប្រាស់ទិន្នន័យ/ព័ត៌មានសុខាភិបាល ឬពាក់ព័ន្ធសុខាភិបាល ដែលមានលក្ខណៈជាគុណភាពផង និងជាបរិមាណផង ហើយដែលមានប្រភពច្បាស់លាស់ អាចជឿទុកចិត្តបាន ដូចជា៖

- ប្រព័ន្ធទិន្នន័យឌីជីថលដែលគ្រប់គ្រងដោយក្រសួងសុខាភិបាល ដូចជា៖ ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល ប្រព័ន្ធអង្កេតតាមដានជំងឺ ប្រព័ន្ធគ្រប់គ្រងបុគ្គលិក ប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលធនធានមនុស្ស ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ/ផ្គត់ផ្គង់ និងប្រព័ន្ធដទៃទៀត។
- របាយការណ៍សមិទ្ធផលឆ្នាំ២០២៥ របស់អង្គភាពសុខាភិបាលថ្នាក់ជាតិ និងមន្ទីរសុខាភិបាលរាជធានី ខេត្ត។
- របាយការណ៍ទិន្នន័យប្រជាសាស្ត្រ ឬរបាយការណ៍អង្កេតពាក់ព័ន្ធនានា របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ។
- របាយការណ៍របស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដូចជា ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ និងបេឡាជាតិសន្តិសុខសង្គម។
- របាយការណ៍របស់ទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ ដូចជា អង្គការសុខភាពពិភពលោក ជាដើម។

# ២ ការទទួលបានសេវាថែទាំសុខភាព និងការគ្របដណ្ដប់




២.១. ការប្រើប្រាស់សេវាថែទាំសុខភាពទូទៅ

២.២. ការលើកកម្ពស់ឥរិយាបថល្អដើម្បីសុខភាព

២.៣. ការពង្រីកការគ្របដណ្ដប់នៃសេវាថែទាំសុខភាព

២.៤. ការចូលរួមរបស់សហគមន៍ដើម្បីសុខភាព

២.៥. លើកកម្ពស់សុខភាពបន្តពូជ មាតា ទារក កុមារ និងអាហារូបត្ថម្ភ

២.៦. ការបង្ការ និងការគ្រប់គ្រងជំងឺឆ្លង

២.៧. ការបង្ការ និងការគ្រប់គ្រងជំងឺមិនឆ្លង និងបញ្ហាសុខភាពចម្បងដទៃទៀត

# ២. ការទទួលបានសេវាថែទាំសុខភាព និងការគ្របដណ្តប់

## គោលដៅ

«ប្រជាជនគ្រប់រូបទទួលបានការថែទាំសុខភាពពេញលេញ រួមទាំងការថែទាំសុខភាពបឋមមានគុណភាព នៅមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន ដែលជាគ្រឹះរឹងមាំសម្រាប់ការគ្របដណ្តប់សុខភាពជាសកល និងប្រព័ន្ធសុខាភិបាលមានភាពធន់» តាមរយៈការផ្លាស់ប្តូរជាយុទ្ធសាស្ត្រពីការផ្តោតលើការព្យាបាលជំងឺទៅការផ្តោតលើការបង្ការជំងឺ *(ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០២៥-២០៣៤)*។

(% បំរែបំរួលៈលទ្ធផលធៀបចំណុចដៅ)

| សូចនាករស្នូល | លទ្ធផល 2023 | 2024 | 2025 | ចំណុចដៅ 2025 | %បំរែបំរួល |
|---|---|---|---|---|---|
| 1. ការពិគ្រោះជំងឺក្រៅករណីថ្មី ក្នុងប្រជាជនម្នាក់ក្នុងមួយឆ្នាំ (ចំនួនលើក) | 0.69 | 0.79 | **0.84** | **0.80** | +0.04 |
| 2. អត្រាសម្រាកពេទ្យ ក្នុងប្រជាជន 1 000នាក់ | 63 | 74 | **92.99** | មិនកំណត់ | |
| 3. អត្រាប្រើប្រាស់គ្រែ (%) | 79.01 | 86.01 | **99.40** | **>85** | +13.39 |
| 4. គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពដែលដំណើរការពេញលេញ (%) | 88.86 | 91.42 | **91.33** | **87** | +4.33 |

ជម្លោះព្រំដែនដែលបង្កឡើងដោយប្រទេសថៃ បានធ្វើឱ្យអាក់អួលដល់ដំណើរការផ្តល់សេវាថែទាំសុខភាពនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក និងការចុះផ្តល់សេវាតាមមូលដ្ឋានភូមិ ឃុំ ដែលស្ថិតនៅក្នុងខេត្តចំនួន ៧ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ មណ្ឌលសុខភាពមួយចំនួនត្រូវរងការបំផ្លាញដោយគ្រាប់ផ្លោង និងការទម្លាក់គ្រាប់បែក ខណៈដែលមណ្ឌលសុខភាព ជាច្រើនត្រូវបានបិទ។ នៅចំពោះមុខគ្រោះអាសន្នសុខភាពដ៏ធ្ងន់ធ្ងរនេះ ក្រសួងសុខាភិបាល រដ្ឋបាលខេត្ត គ្រូពេទ្យបុគ្គលិកសុខាភិបាលខេត្តជួរមុខ ខេត្តទ្រនាប់ជួរទីពីរ ខេត្តជួរទីបី មន្ទីរពេទ្យជាតិ និងស្ថាប័នពាក់ព័ន្ធ បានខិតខំប្រឹងប្រែងយ៉ាងសកម្ម និងសហការគ្នាយ៉ាងជិតស្និទ្ធ ក្នុងការបំរើសេវាថែទាំ និងព្យាបាលវីរៈយុទ្ធជន និងប្រជាជនភៀសសឹកដែលបានមករស់នៅបណ្តោះអាសន្នតាមទីតាំងសុវត្ថិភាពនានា។

## ២.១. ការប្រើប្រាស់សេវាថែទាំសុខភាពទូទៅ

**ក. សេវាពិគ្រោះជំងឺក្រៅ៖** ករណីសរុប (ទាំងករណីចាស់ ទាំងករណីថ្មី) នៃការពិគ្រោះជំងឺក្រៅ នៅមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជនដែលបានរាយការណ៍ បានកើនឡើងពី ១៨ ៦៩៤ ៣៩៧ ករណី នៅឆ្នាំ២០២៤ ដល់ ២១ ១៧៧ ៤៦៩ ករណី នៅឆ្នាំ២០២៥ ដោយកើនឡើង ១៣,២៨% ក្នុងនោះ ការពិនិត្យនៅមណ្ឌលសុខភាពមានចំនួន ១០ ៦៨០ ០៩៤ ករណី នៅមន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣ ចំនួន ៣ ០៥៤ ១០៩ ករណី នៅមន្ទីរពេទ្យជាតិ ចំនួន ៤ ៥៦៤ ៦៤៨ ករណី និងនៅមូលដ្ឋានសុខាភិបាលឯកជនដែលបានរាយការណ៍ចំនួន ២ ៨៧៨ ៦១៨ ករណី (តារាង ២.១.)។

ដោយឡែក ការពិគ្រោះជំងឺក្រៅករណីថ្មីបានកើនឡើងពី ១៣ ៦៧២ ១៥៩ ករណី នៅឆ្នាំ២០២៤ ដល់ ១៤ ៦៨៧ ៦៩៨ករណី នៅឆ្នាំ២០២៥ ដោយកើនឡើង ៧,៤៣% ។ បើគិតជាចំនួនលើកពិនិត្យជំងឺក្រៅករណីថ្មី ក្នុងប្រជាជនម្នាក់ ក្នុងមួយឆ្នាំ បានកើនឡើងពី ០,៧៩ លើក នៅឆ្នាំ២០២៤ ដល់ ០,៨៤ លើក នៅឆ្នាំ២០២៥ ដោយសម្រេចបានលើសចំណុចដៅដែលបានកំណត់ ០,៨០ លើក (ក្រាហ្វិក ២.១.) ប៉ុន្តែប្រែប្រួលពីខេត្តដែលមានកម្រិតទាបបំផុត ០,១៥ លើក ទៅកម្រិតខ្ពស់បំផុត ១,០៥ លើក  ក្នុងនោះរាជធានី ខេត្តចំនួន ១៤ លទ្ធផលនៅក្រោមកម្រិតមធ្យមទូទាំងប្រទេស (ក្រាហ្វិក ២.២. និងតារាង ១.១. ក្នុងឧបសម្ព័ន្ធ ១)។

**តារាង ២.១.** ស្ថិតិនៃពិគ្រោះជំងឺក្រៅនៅតាមប្រភេទមូលដ្ឋានសុខាភិបាល ក្នុងឆ្នាំ២០២៥

| មូលដ្ឋានសុខាភិបាល | ករណីសរុប | | ករណីថ្មី | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| មណ្ឌលសុខភាព | 10,680,094 | 50.43% | 9,529,627 | 64.88% |
| មន្ទីរពេទ្យបង្អែកកម្រិត១ | 1,047,310 | 4.95% | 678,626 | 4.62% |
| មន្ទីរពេទ្យបង្អែកកម្រិត២ | 779,920 | 3.68% | 452,353 | 3.08% |
| មន្ទីរពេទ្យបង្អែកកម្រិត៣ | 1,226,879 | 5.79% | 681,716 | 4.64% |
| មន្ទីរពេទ្យជាតិ | 4,564,648 | 21.55% | 1,676,855 | 11.42% |
| មូលដ្ឋានសុខាភិបាលឯកជន | 2,878,618 | 13.59% | 1,668,521 | 11.36% |
| **សរុប** | **21,177,469** | **100%** | **14,687,698** | **100%** |

**ក្រាហ្វិក ២.១.** និន្នាការនៃការប្រើប្រាស់សេវាពិគ្រោះជំងឺក្រៅ ឆ្នាំ២០២១-២០២៥



**ក្រាហ្វិក ២.២.** ចំនួនលើកពិគ្រោះជំងឺក្រៅករណីថ្មី ក្នុងប្រជាជនម្នាក់ ក្នុងឆ្នាំ២០២៥ នៅសេវាសុខាភិបាលសាធារណៈតាមរាជធានី ខេត្ត




ជំងឺនាំមុខ ឬបញ្ហាសុខភាពចម្បង ១០ នៃការពិគ្រោះជំងឺក្រៅ ក្នុងឆ្នាំ២០២៥ ធៀបនឹងឆ្នាំ២០២៤ ត្រូវបានកត់សម្គាល់ថា ជំងឺរលាកផ្លូវដង្ហើមលើស្រួចស្រាល់ រលាកក្រពះស្រួចស្រាល់ លើសសម្ពាធឈាមដំបូង រាកគ្មានខ្សោះជាតិទឹក ជំងឺទឹកនោមផ្អែមប្រភេទទី២ ស្ថិតនៅលេខរៀងទី១ ទៅទី៥ ដដែល ប៉ុន្តែ ជំងឺរលាកបំពង់កស្រួចស្រាល់ និងរលាកសន្លាក់គ្មានខ្ទុះ បានឡើងមកលេខរៀងទី៨ និងទី១០ នៅក្នុងឆ្នាំ២០២៥ (តារាង ២.២.)។

**តារាង ២.២.** ជំងឺនាំមុខ/បញ្ហាសុខភាពចម្បង ១០ នៃការពិគ្រោះជំងឺក្រៅករណីថ្មី ឆ្នាំ២០២៥

| មូលដ្ឋានសុខាភិបាល | ឆ្នាំ2024 | | ឆ្នាំ2025 | |
|---|---|---|---|---|
| | ចំណាត់ថ្នាក់ | ករណី | ចំណាត់ថ្នាក់ | ករណី |
| 1. រលាកផ្លូវដង្ហើមលើស្រួចស្រាល់ | ① | 2,190,315 | ❶ | 2,366,596 |
| 2. រលាកក្រពះស្រួចស្រាល់ | ② | 726,393 | ❷ | 811,113 |
| 3. ឡើងសម្ពាធឈាមដំបូង | ③ | 307,997 | ❸ | 327,034 |
| 4. រាកគ្មានខ្សោះជាតិទឹក | ④ | 274,488 | ❹ | 279,809 |
| 5. ជំងឺទឹកនោមផ្អែមប្រភេទទី២ | ⑤ | 213,113 | ❺ | 274,653 |
| 6. រលាកសួត | ⑥ | 196,426 | ❼ | 204,907 |
| 7. រលាកក្រពះរ៉ាំរ៉ៃ | ⑦ | 187,158 | ❻ | 218,432 |
| 8. រលាកផ្លូវដង្ហើមផ្នែកខាងក្រោមផ្សេងៗទៀត | ⑧ | 143,791 | ❾ | 150,278 |
| 9. រាកមួល | ⑨ | 128,296 | | 126,783 |
| 10. រលាកសន្លាក់គ្មានខ្ទុះ | ⑩ | 121,109 | ❿ | 143,081 |
| 11. ជំងឺរលាកបំពង់កស្រួចស្រាល់ | | 93,805 | ❽ | 150,549 |
| **សរុប** | | **4,489,086** | | **5,053,235** |

## ខ. សេវាសម្រាកព្យាបាល

អ្នកជំងឺសម្រាកព្យាបាលនៅមន្ទីរពេទ្យសាធារណៈ និងមណ្ឌលសុខភាពមានគ្រែទូទាំងប្រទេស បានកើនឡើងពី ១ ២៧៦ ៣១៩ នាក់ នៅឆ្នាំ២០២៤ ដល់ ១ ៦៣៤ ៦៣១ នាក់ នៅឆ្នាំ២០២៥ ដោយកើនឡើង ២៨,០៧% ក្នុងនោះការសម្រាកព្យាបាលនៅមណ្ឌលសុខភាពមានគ្រែ ៦៦កន្លែង មានចំនួន ៦៥ ៥៦៤នាក់ ឬស្មើនឹង ៤,០១% នៃអ្នកជំងឺសម្រាកព្យាបាលសរុបទូទាំងប្រទេស នៅមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ២៥៥ ៣៩១ នាក់ ឬស្មើនឹង ១៥,៦២% នៅមន្ទីរពេទ្យបង្អែកកម្រិត២ ចំនួន ២៥២ ៩២៦ នាក់ ឬស្មើនឹង ១៥,៤៧% នៅមន្ទីរពេទ្យបង្អែកកម្រិត៣ ចំនួន ៣៦៩ ៥២១ នាក់ ឬស្មើនឹង ២២,៦១% និងនៅមន្ទីរពេទ្យជាតិចំនួន ៦៩១ ២២៩ នាក់ ឬស្មើនឹង ៤២,២៩% (ក្រាហ្វិក ២.៣.)។

ចំនួនករណីវះកាត់ធំ បានកើនឡើងពី បានកើនឡើងពី ១៩៥ ៤៧១ ករណី នៅឆ្នាំ២០២៤ ដល់ ២២០ ៩៤០ ករណី ឬកើន ១៣,០៣% នៅឆ្នាំ២០២៥ ក្នុងនោះការវះកាត់បន្ទាន់នៅមន្ទីរពេទ្យជាតិ ចំនួន ៨៩ ៤៤១ ករណី ឬស្មើ ៦៤,៥៣% នៅមន្ទីរពេទ្យបង្អែកកម្រិត៣ ចំនួន ២៦ ៨០០ ករណី ឬស្មើ ២៩,៩៦% និងនៅមន្ទីរពេទ្យស្រុកកម្រិត២ ចំនួន ៤ ៨៨១ ករណី ឬស្មើ ៥,៤៦%)។ រីឯការវះកាត់ដាក់កម្មវិធី ចំនួន ១៣១ ៤៩៨ ករណី។ ករណីវះកាត់តូចថយចុះ ពី ១២៥ ៨៨៣ ករណី នៅឆ្នាំ២០២៤ ដល់ ៨៣ ៤១៦ ករណី ឬថយចុះ ៣៣,៧៣% នៅឆ្នាំ២០២៥។

**ក្រាហ្វិក ២.៣.** ចំនួន និង ភាគរយនៃអ្នកជំងឺសម្រាកព្យាបាល នៅតាមមូលដ្ឋានសុខាភិបាល នៅឆ្នាំ២០២៥




ជារួម សមិទ្ធកម្មនៃការផ្តល់សេវាថែទាំព្យាបាលនៅមន្ទីរពេទ្យសាធារណៈគ្រប់កម្រិត ដោយរាប់បញ្ចូលទាំងមណ្ឌលសុខភាពមានគ្រែ បង្ហាញពីសមត្ថភាពកើនឡើងនៃមូលដ្ឋានសុខាភិបាល ក្នុងការឆ្លើយតបនឹងតម្រូវការប្រើប្រាស់សេវារបស់ប្រជាពលរដ្ឋ តាមរយៈវឌ្ឍនភាពនៃសូចនាករគន្លឹះ ចំនួន ៤ ខាងក្រោម៖

- **អត្រាសម្រាកពេទ្យ** បានកើនឡើងពី ៧៣,៦ ក្នុងប្រជាជន ១ ០០០ នាក់ នៅឆ្នាំ២០២៤ ទៅ៩២,៩៩ នៅឆ្នាំ២០២៥ (ក្រាហ្វិក ២.៤)។
- **អត្រាមធ្យមប្រើប្រាស់គ្រែ** បានកើនឡើងពី ៨៦,០១% នៃចំនួនគ្រែសរុប ១៦ ៦៤៥គ្រែ នៅឆ្នាំ២០២៤ ដល់ ៩៩,៤០% នៃចំនួនគ្រែសរុប ១៦ ៩២២ គ្រែ (ដោយមិនរាប់បញ្ចូលគ្រែសម្រាប់អ្នកជំងឺរបេង) នៅឆ្នាំ២០២៥ (ក្រាហ្វិក ២.៥.)។ គួរកត់សម្គាល់ថា អត្រាប្រើប្រាស់គ្រែជាមធ្យមនៅមន្ទីរពេទ្យជាតិ ចំនួន ១០ និងនៅមន្ទីរពេទ្យបង្អែកខេត្ត មានកម្រិតខ្ពស់ ជាង១០០% (ក្រាហ្វិក ២.៦.)។ តារាង ក្នុងឧបសម្ព័ន្ធ១ បង្ហាញពីអត្រាប្រើប្រាស់នៅមន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យរាជធានី ខេត្ត ក្នុងឆ្នាំ២០២៥។
- **អត្រាស្លាប់នៅមន្ទីរពេទ្យ** បានធ្លាក់ចុះពី ០,៥៦% នៅឆ្នាំ២០២៤ មកនៅ ០,៤៨% នៃចំនួនអ្នកជំងឺសម្រាកព្យាបាលសរុបនៅឆ្នាំ២០២៥។ គួរកត់សម្គាល់ថាអត្រាស្លាប់ជាមធ្យមនៅមន្ទីរពេទ្យបង្អែកខេត្ត ១,០៤% ធៀបនឹងចំណុចដៅ <១% ដែលបានកំណត់សម្រាប់ឆ្នាំ២០២៥។ រីឯអត្រាស្លាប់ក្នុងអំឡុងពេល ៤៨ម៉ោង ក្រោយការវះកាត់ នៅឆ្នាំ ២០២៥ ដូចគ្នានឹងឆ្នាំ២០២៤ ដែរ គឺក្នុងរង្វង់ ០,០១%។
- **រយៈពេលមធ្យមសម្រាកព្យាបាល៖** ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ចំនួនថ្ងៃជាមធ្យមដែលអ្នកជំងឺម្នាក់សម្រាកព្យាបាលនៅមន្ទីរពេទ្យសាធារណៈ ស្ថិតក្នុងរង្វង់ ៤ ថ្ងៃ។ រយៈពេលមធ្យមសម្រាកព្យាបាលនៅឆ្នាំ២០២៥ គឺ ៣,៧៦ ថ្ងៃ ហើយប្រែប្រួលទៅតាមកម្រិតមន្ទីរពេទ្យ ក្នុងនោះ មន្ទីរពេទ្យជាតិមានរយៈពេលមធ្យមសម្រាកព្យាបាល ៣,៧១ ថ្ងៃ និងមន្ទីរពេទ្យខេត្ត ៤,១៥ ថ្ងៃ។

## ក្រាហ្វិក ២.៤. និន្នាការនៃអត្រាសម្រាកពេទ្យលើប្រជាជន ១ ០០០នាក់ ពីឆ្នាំ២០២៣-២០២៥




## ក្រាហ្វិក ២.៥. និន្នាការនៃអត្រាប្រើប្រាស់គ្រែ (%) ឆ្នាំ២០២១-២០២៥




## ក្រាហ្វិក ២.៦. អត្រាប្រើប្រាស់គ្រែជាមធ្យម (%) តាមប្រភេទមូលដ្ឋានសុខាភិបាលសាធារណៈ នៅឆ្នាំ២០២៥



## ២.២. ការលើកកម្ពស់ឥរិយាបថល្អដើម្បីសុខភាព

ក្នុងឆ្នាំ២០២៥ ក្រសួងសុខាភិបាល បានបន្តយកចិត្តទុកដាក់ខ្ពស់លើការអប់រំលើកម្ពស់សុខភាព ការបង្ការ និងការគ្រប់គ្រងជំងឺ និងការប្រាស្រ័យទាក់ទង ដើម្បីផ្លាស់ប្តូរឥរិយាបថប្រកបដោយសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព បានសហការយ៉ាងជិតស្និទ្ធជាមួយអង្គភាពសុខាភិបាលគ្រប់លំដាប់ថ្នាក់ នៅក្នុងការពង្រឹងការថែទាំសុខភាពបឋម និងការចូលរួមរបស់សហគមន៍ដើម្បីសម្រេចគោលដៅនៃកម្មវិធីសុខភាព ជាអាទិភាពចំនួន បី៖ (១).លើកកម្ពស់សុខភាពបន្តពូជ មាតា ទារកនិងកុមារ និងអាហារូបត្ថម្ភ (២).ការបង្ការនិង ការគ្រប់គ្រងជំងឺឆ្លង (៣).ការបង្ការនិងការគ្រប់គ្រងជំងឺមិនឆ្លង និងការពង្រឹងសន្តិសុខសុខភាព។

- **យុទ្ធនាការអប់រំលើកកម្ពស់សុខភាព៖** បានធ្វើយុទ្ធនាការជាតិ ចំនួន ៤ លើកដើម្បីជំរុញការផ្លាស់ប្តូរឥរិយាបថប្រជាពលរដ្ឋ ទាក់ទងនឹងហានិភ័យនៃការប្រើប្រាស់ផលិតផលគ្រឿងស្រវឹង ផលិតផលថ្នាំជក់ បារីអេឡិចត្រូនិក ហានិភ័យនៃជំងឺមិនឆ្លង និងអត្ថប្រយោជន៍នៃការប្រើប្រាស់មូលនិធិសមធម៌សុខាភិបាល។
- **ការរៀបចំសម្ភារៈអប់រំសុខភាព៖** បង្កើតសារអប់រំសុខភាពជា ស្ប៉តវីដេអូ វិទ្យុ ចម្រៀង រូបភាពផ្ទាំងធំ បដា ប៉ាន់ណូ សន្លឹកបត់ សន្លឹកផ្ទាត់ ចំនួន ៩៤ ប្រភេទ និងមាតិកាសម្រាប់បង្ហោះក្នុងបណ្តាញសង្គម ចំនួន ៨៦ ដែលទាក់ទងនឹងជំងឺមិនឆ្លង សុខភាពផ្លូវចិត្ត វិធានបង្ការជំងឺឆ្លង កត្តាហានិភ័យសុខភាព និងសុខភាពសាធារណៈដទៃទៀត ដូចជាវិធានការពស់ចឹក ទឹកជំនន់ លើកទឹកចិត្តជនមានពិការភាពក្នុងការប្រើប្រាស់សេវានៅមណ្ឌលស្តារលទ្ធភាពកាយសម្បទា និងនៅមណ្ឌលសុខភាព និងអំពីអត្ថប្រយោជន៍នៃមូលនិធិសមធម៌។
- **ការផ្សព្វផ្សាយសម្ភារៈអប់រំសុខភាព៖** សម្ភារៈអប់រំសុខភាពខាងលើ ត្រូវបានផលិត ក្នុងនោះរួមមាន៖ ផ្ទាំងប៉ាណូចំនួន ៥៨៣ បដាចំនួន ២ ២៦៨ រូបភាពផ្ទាំងធំចំនួន ១៤ ៩០០ សន្លឹកបកបិទចំនួន ៥០០ សន្លឹកបត់ចំនួន ១៥០ ៤០០ អាវយឺតចំនួន ៤ ៦៧០ អាវភ្លៀង ចំនួន ៤០០ កូនសៀវភៅ ចំនួន៩ ១៣០ក្បាល សៀវភៅសន្លឹកផ្ទាត់ចំនួន ៣ ៨៧៧ ក្បាល និងបានផ្សព្វផ្សាយតាមស្ថានីយ៍ទូរទស្សន៍ចំនួន ៤ រួមមាន បាយ័ន CNC ហង្សមាស និងទូរទស្សន៍ជាតិកម្ពុជា សរុប ២១២ ដង និងបានចាក់ផ្សាយស្ប៉តវិទ្យុជាស៊េរី ចំនួន ៣ ៤០៨ដង នៅក្នុងខេត្ត ចំនួន ៩ ដែលជាគោលដៅនៃគម្រោងអាហារូបត្ថម្ភបានចំនួន ៣ ៤០៨ ដង និងបណ្តាញសង្គមចំនួន ២៨៧ ដង។
- **ការឆ្លើយតបទៅនឹងស្ថានភាពតានតឹងនៃបញ្ហាព្រំដែន៖** បានផលិតសារអប់រំទាក់ទងវិធានការអនាម័យ ការថែទាំសុខភាពផ្លូវចិត្ត សារជាតុគីមីពុល និងស្មារតីសាមគ្គីភាព ចំនួន ៩ ប្រភេទ ក្នុងទម្រង់ជារូបភាពផ្ទាំងធំ និងសារសម្លេង ហើយបានបិទតាំង និងចាក់ផ្សាយនៅតាមមណ្ឌលសុវត្ថិភាព និងផ្សព្វផ្សាយតាមបណ្តាញសង្គម។
- **ការគាំទ្រការប្រើប្រាស់ និងការផ្សព្វផ្សាយសម្ភារៈអប់រំសុខភាពឱ្យបានត្រឹមត្រូវ៖** ការអភិបាលគាំទ្របច្ចេកទេសដល់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត ស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព ត្រូវបានធ្វើឡើង នៅក្នុងខេត្តចំនួន ១២ (ខេត្តសៀមរាប រតនគិរី មណ្ឌលគិរី ប៉ៃលិន បន្ទាយមានជ័យ បាត់ដំបង ក្រចេះ

ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ធំ ព្រះវិហារ និងស្ទឹងត្រែង) ស្តីពីការប្រើប្រាស់សម្ភារៈអប់រំសុខភាព ព្រមទាំងបានធ្វើការសាកល្បងសម្ភារៈអប់រំសុខភាពមុនពេល បោះពុម្ពផ្សព្វផ្សាយ ៤ លើក ជាមួយ ប្រជាជនគោលដៅចំនួន ១០៧ នាក់ (ស្រី ៧៧ នាក់)។

## ២.៣. ការពង្រីកការគ្របដណ្តប់នៃសេវាថែទាំសុខភាព

ក្នុងឆ្នាំ២០២៥ ក្រសួងសុខាភិបាលបានពិនិត្យលើសំណើរបស់រដ្ឋបាលខេត្ត ក្នុងការដំឡើង និងការបង្កើត អង្គភាពសុខាភិបាលថ្មី ២៣កន្លែង និងការប្តូរឈ្មោះមណ្ឌលសុខភាព ៤ កន្លែង ហើយបានលើកសំណើសុំការឯកភាព ជាគោលការណ៍ពីក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ៖

- អង្គភាពបង្កើតថ្មី ២០ កន្លែង៖ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិថ្មី ១ កន្លែង មណ្ឌលសុខភាពថ្មី ១៤កន្លែង និងប៉ុស្តិ៍សុខភាពថ្មី ៥ កន្លែង។
- តម្លើងមុខងារ៖ មណ្ឌលសុខភាពគូលែន ក្នុងខេត្តព្រះវិហារ ទៅជាមន្ទីរពេទ្យបង្អែក «សម្តេចធិបតី និង លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី គូលែន» កម្រិត១ និងតម្លើងមុខងារប៉ុស្តិ៍សុខភាព ២ កន្លែង ទៅជា មណ្ឌលសុខភាព។
- ប្តូរឈ្មោះមណ្ឌលសុខភាព ៤កន្លែង៖ (១).មណ្ឌលសុខភាពលង្វែក ប្តូរឈ្មោះជាមណ្ឌលសុខភាពសេដ្ឋី ដែលស្ថិតក្នុងឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង (២).មណ្ឌលសុខភាពស្វាយ ប្តូរឈ្មោះ ជាមណ្ឌលសុខភាពលង្វែក ដែលស្ថិតក្នុងឃុំលង្វែក ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង (៣). មណ្ឌលសុខភាពកំពង់ត្រឡាចលើ ប្តូរឈ្មោះជាមណ្ឌលសុខភាពកំពង់ត្រឡាច ដែលស្ថិតក្នុងកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង និង (៤).មណ្ឌលសុខភាពសាលាលេខប្រាំ ប្តូរឈ្មោះជា មណ្ឌលសុខភាពពានី ដែល ស្ថិតក្នុងឃុំពានី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។

គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលសាធារណៈមានចំនួនសរុប ១ ៥៧៨ កន្លែង ក្នុងនោះ មន្ទីរពេទ្យជាតិចំនួន ១២ មន្ទីរពេទ្យបង្អែករាជធានី ខេត្ត ២៥ មន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ ៩៩ មណ្ឌលសុខភាព ១ ៣១១ និងប៉ុស្តិ៍សុខភាព ១៣១ (ប៉ុស្តិ៍ពន្ធនាគារ ១៦) (តារាង ៩.១ ក្នុងឧបសម្ព័ន្ធ ៩)។

## ២.៤. ការចូលរួមរបស់សហគមន៍ដើម្បីសុខភាព

ក. ការគាំទ្រគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព (គ.គ.ម.)៖ មណ្ឌលសុខភាពដែលមានរចនាសម្ព័ន្ធ គ.គ.ម. បានកើនឡើងពី ១ ២៧៧ កន្លែង ក្នុងឆ្នាំ២០២៤ ទៅ ១ ២៩៣ ឬស្មើនឹង ៩៨,៥៥% នៃចំនួន មណ្ឌលសុខភាពសរុប ១ ៣១១ កន្លែង នៅក្នុងឆ្នាំ២០២៥ ហើយ ៩១,៣៣% នៃមណ្ឌលសុខភាពដែលមាន គ.គ.ម. កំពុងដំណើរការពេញលេញ។ គ.គ.ម. ដែលដំណើរការភាគច្រើន ត្រូវការគាំទ្រដោយថវិកាមណ្ឌលសុខភាព ៧២,៩៨% ថវិកាឃុំនិងមណ្ឌលសុខភាព ១២,៧០% ថវិកាឃុំសុទ្ធ ១៣,៤៤% និងថវិកាដៃគូអភិវឌ្ឍន៍ ៨,៤៥%។ គួរកត់សម្គាល់ថា ពីឆ្នាំ២០២៣ ដល់ ឆ្នាំ២០២៥ ការគាំទ្រដោយថវិកាឃុំ/សង្កាត់ ដល់កិច្ចដំណើរការ គ.គ.ម. មាននិន្នាការកើនឡើងជិត ៨% ខណៈដែលថវិការបស់ដៃគូអភិវឌ្ឍន៍បានថយចុះជាង ៣% (តារាង ២.៣.)។

**តារាង ២.៣**. ភាគរយនៃ គ.គ.ម. ដំណើរការពេញលេញ នៅឆ្នាំ២០២៥

| | 2023 | 2024 | 2025 |
|---|---|---|---|
| ១. % នៃ គ.គ.ម. ដែលដំណើរការពេញលេញ | **89.60** | **91.42** | **91.33** |
| ២. ប្រភពថវិកាគាំទ្រដំណើរការ គ.គ.ម៖ | | | |
| ▪ ថវិកាឃុំ/សង្កាត់ | 5.74% | 10.47% | 13.45% |
| ▪ ថវិកាមណ្ឌលសុខភាព | 79.60% | 75.20% | 73.00% |
| ▪ ថវិការួមឃុំ និងមណ្ឌលសុខភាព | 10.47% | 12.18% | 12.70% |
| ▪ ថវិកាដៃគូអភិវឌ្ឍន៍ | 4.19% | 2.15% | 0.85% |

ខ. ការគាំទ្រក្រុមទ្រទ្រង់សុខភាពភូមិ (ក.ទ.ស.ភ.)៖ មជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព បានបណ្តុះបណ្តាលស្តីពីសុខភាពមាតា ទារក កុមារនិងអាហារូបត្ថម្ភ ដល់ ក.ទ.ស.ភ. ចំនួន ២៨ នាក់ (ស្រី២៤) សិក្ខាសាលាបណ្តុះបណ្តាលស្តីពីសុខភាពមាតា ទារក កុមារ និងអាហារូបត្ថម្ភ ដល់មន្ត្រីមណ្ឌលសុខភាព អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ (អ.ក.ន.ក) និង ក.ទ.ស.ភ. សរុបចំនួន ១ ២៦៣ នាក់ (ស្រី ៨១១ នាក់) នៅខេត្តគោលដៅចំនួន ៩ នៃគម្រោងអាហារូបត្ថម្ភនៅកម្ពុជា និងចុះអភិបាល តាមដាន បង្វឹក និងគាំទ្របច្ចេកទេសដល់ ក.ទ.ស.ភ. ចំនួន ១ ០៩៦ រូប មន្ត្រីមណ្ឌលសុខភាព ១៣៧រូប និង អ.ក.ន.ក ចំនួន ១៣៧ រូប និងគ្រួសារ ១ ០០០ ថ្ងៃដំបូងនៃជីវិត ចំនួន ៨២២ គ្រួសារ។ ទន្ទឹមនឹងនេះ មន្ត្រីមន្ទីរសុខាភិបាល មន្ត្រីការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ បានចុះអភិបាលតាមដាន និងជួបសម្ភាសក្រុមទ្រទ្រង់សុខភាពភូមិ ចំនួន ៤៤០រូប និងគ្រួសារ ១ ០០០ថ្ងៃដំបូងនៃជីវិត ចំនួន ៨៥គ្រួសារ ហើយមន្ត្រីមណ្ឌលសុខភាព និងមន្ត្រី អ.ក.ន.ក បានចុះអភិបាលតាមដាន បានចំនួន ៦៤ដង ជួបសម្ភាសក្រុមទ្រទ្រង់សុខភាពភូមិ ចំនួន ១២៨ រូប និងគ្រួសារ ១ ០០០ថ្ងៃដំបូងនៃជីវិត ២៥៦គ្រួសារ។

## ២.៥. លើកកម្ពស់សុខភាពបន្តពូជ មាតា ទារក កុមារ និងអាហារូបត្ថម្ភ

(% បំរែបំរួលលទ្ធផលធៀបចំណុចដៅ)

| | លទ្ធផល | | | ចំណុចដៅ | %បំរែបំរួល |
|---|---|---|---|---|---|
| សូចនាករស្នូល | 2023 | 2024 | 2025 | 2025 | |
| 1. អត្រាប្រើមធ្យោបាយពន្យារកំណើតទំនើប (%) | 14.14 | 13.25 | **12.24** | **25** | **-12.76** |
| 2. អត្រាពិនិត្យផ្ទៃពោះគភ៌មុនសម្រាល ២លើក ដោយបុគ្គលិកសុខាភិបាល (%) | 99.34 | 91.41 | **95.05** | **90** | **+5.05** |

| | | | | | | |
|---|---|---|---|---|---|---|
| 3. | អត្រាពិនិត្យផ្ទៃពោះមុនសម្រាល ៤លើក ដោយបុគ្គលិកសុខាភិបាល (%) | 74.90 | 72.02 | **73.04** | **75** | **-1.96** |
| 4. | អត្រាសម្រាលដោយបុគ្គលិកសុខាភិបាល (%) | 90.62 | 77.63 | **71.31** | **91** | **-19.69** |
| 5. | អត្រាសម្រាលនៅមូលដ្ឋានសុខាភិបាល (%) | 88.23 | 75.82 | **70.89** | **89** | **-18.11** |
| 6. | អត្រាពិនិត្យផ្ទៃពោះម្ដាយក្រោយសម្រាលលើកទី១ (ក្នុងសប្ដាហ៍ទី១ ក្រោយសម្រាល) ដោយបុគ្គលិកសុខាភិបាល (%) | 57.08 | 51.80 | **51.48** | **59** | **-7.52** |
| 7. | អត្រាពិនិត្យផ្ទៃពោះម្ដាយក្រោយសម្រាលលើកទី២ (ក្នុងសប្ដាហ៍ទី២ក្រោយសម្រាល) ដោយបុគ្គលិកសុខាភិបាល (%) | 41.73 | 40.12 | **38.42** | មិនកំណត់ចំណុចដៅ | |
| 8. | អត្រាសម្រាលដោយវិធីវះកាត់ (% នៃទារកកើតរស់) | 10.14 | 11.24 | **13.84** | **11.5** | **+2.34** |

## ២.៥.១. សុខភាពបន្តពូជ

**ក. ផែនការគ្រួសារ៖** អត្រាប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបណាមួយក្នុងចំណោមស្ត្រីក្នុងវ័យបន្តពូជ អាយុពី ១៥-៤៩ឆ្នាំ ដែលបានរៀបការ បានធ្លាក់ចុះ បីឆ្នាំជាប់គ្នា ពីឆ្នាំ២០២៣ មកដល់ឆ្នាំ២០២៥ (ក្រាហ្វិក ២.៧)។ ចំនួនស្ត្រីគោលដៅខាងលើ កំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបណាមួយ បានថយចុះពី ៥៥៦ ៤៥៧ នាក់ នៅឆ្នាំ២០២៤ មកត្រឹម ៥៣០ ៣២២នាក់ នៅឆ្នាំ២០២៥ ឬថយចុះ ១,០១% ធៀបនឹងឆ្នាំ២០២៤។ ការប្រើប្រាស់នៅសេវាសាធារណៈមានចំនួន ៥១២ ៤២៩នាក់ និងនៅសេវាឯកជនដែលបានរាយការណ៍ ចំនួន ១៧ ៨៩៣ នាក់។ អត្រានេះប្រែប្រួលពីខេត្តដែលមានអត្រាទាបជាងគេ ១,២៦% ទៅខេត្តដែលអត្រាខ្ពស់ជាងគេ ២១,៣២% (ក្រាហ្វិក ២.៨. និង តារាង ២.១. ក្នុងឧបសម្ព័ន្ធ ២)។

មធ្យោបាយពន្យារកំណើតទំនើបដែលកំពុងប្រើប្រាស់នៅមូលដ្ឋានសុខាភិបាលសាធារណៈ ភាគច្រើន គឺថ្នាំគ្រាប់ ៥០,១៥% នៃចំនួនស្ត្រីប្រើប្រាស់សរុប ថ្នាំចាក់ ៣០,៣៦% បន្ទាប់មកដាក់កងក្រោមស្បែក ៩,១០% កងដាក់ក្នុងស្បូន ៦,៩៤% និងស្រោមអនាម័យ ៣,៤៥%។ នៅឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលសាធារណៈកំពុងផ្ដល់សេវាសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ សម្រាប់យុវវ័យ តាមពិធីសារដែលបានធ្វើបច្ចុប្បន្នភាពមានចំនួន ១៥៥ កន្លែង។

### ក្រាហ្វិក ២.៧. និន្នាការនៃអត្រាប្រើមធ្យោបាយពន្យាកំណើតទំនើប (%) ឆ្នាំ២០២១-២០២៥




### ក្រាហ្វិក ២.៨. អត្រាប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប (%) នៅមូលដ្ឋានសុខាភិបាលសាធារណៈ នៅតាមរាជធានី ខេត្ត ឆ្នាំ២០២៥



**ខ. ការរំលូត/រលូត៖** រវាងឆ្នាំ២០២៤ និងឆ្នាំ២០២៥ ករណីរលូត និងរំលូត បានកើនឡើង ៤,៦២% ឬពី ១៧ ៤១៧ ករណី នៅឆ្នាំ២០២៤ ទៅ ១៨ ២២០ នៅឆ្នាំ២០២៥ ក្នុងនោះ ករណីរលូត ចំនួន ១១ ៩៣៦ ករណី ឬកើនឡើងប្រមាណ ៤,៦៤% (ឆ្នាំ២០២៤ មានចំនួន ១១ ៤០៧ ករណី) និងករណីរំលូត ៦ ២៨៤ ករណី ឬកើនឡើង ៩,៤៨% (ឆ្នាំ២០២៤ មានចំនួន ៥ ៧៤០ ករណី) (ក្រាហ្វិក ២.៩.)។ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលមានផ្តល់សេវារំលូត/រលូត ប្រកបដោយសុវត្ថិភាព និងសេវាថែទាំក្រោយរំលូត/រលូត មានចំនួន ៩៣០ កន្លែង។ ចំនួនករណីរំលូត និងករណីរលូតមានកម្រិតផ្សេងៗគ្នា ពីខេត្តមួយ ទៅខេត្តមួយទៀត (តារាង ២.២. ក្នុងឧបសម្ព័ន្ធ ២)។

**ក្រាហ្វិក ២.៩.** ករណីរំលូត និងរលូត នៅតាមរាជធានី ខេត្ត ឆ្នាំ២០២១-២០២៥




## ២.៥.២. សុខភាពមាតា និងទារក

**ក. ការថែទាំគភ៌មុនសម្រាល៖** នៅឆ្នាំ២០២៥ ករណីពិនិត្យថែទាំគភ៌មុនសម្រាលលើកទី២ បានកើនឡើង ៣,៦៤% ធៀបនឹងឆ្នាំ២០២៤ (ក្រាហ្វិក ២.១០.)។ ស្ត្រីមានគភ៌ ៣៣៧ ៤៨២ នាក់ បានមកពិនិត្យថែទាំគភ៌ លើកទី២ (ពិនិត្យនៅសេវាសាធារណៈចំនួន ៣០៥ ២៩១ នាក់ និងនៅសេវាឯកជនដែលបានរាយការណ៍ចំនួន ៣២ ១៩១ នាក់) ឬស្មើនឹង ៩៥,០៥% នៃស្ត្រីមានគភ៌រំពឹងទុក។ អត្រាពិនិត្យ លើកទី២ ប្រែប្រួលពីកម្រិតទាបបំផុត ៥៩,៦៥% ទៅកម្រិតខ្ពស់បំផុត ១០០,៥៥% (ក្រាហ្វិក ២.១១. និង តារាង ៣.១. ក្នុងឧបសម្ព័ន្ធ ៣)។ រីឯការពិនិត្យថែទាំគភ៌មុនសម្រាលលើកទី៤ បានកើនឡើង ១,០២% ធៀបនឹងឆ្នាំ២០២៤។ ការពិនិត្យថែទាំគភ៌មុនសម្រាលបានស្រាវជ្រាវរកឃើញស្ត្រីចំនួន ៣៧ ៤០៦ បម្រុងមានគ្រោះថ្នាក់ ក្នុងនោះមានបញ្ហាធ្លាក់ឈាម ៨៦៩ នាក់ ស្លេកស្លាំង ១២ ៩៤៨ នាក់ និងបញ្ហាផ្សេងៗទៀត ២៣ ៥៨៩ នាក់។ ស្ត្រីប្រឈមគ្រោះថ្នាក់ទាំងនោះបានទទួលការប្រឹក្សាយោបល់និងការណែនាំ ព្រមទាំងការពិនិត្យតាមដាន និងការថែទាំយ៉ាងយកចិត្តទុកដាក់នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ។

## **ក្រាហ្វិក ២.១០.** និន្នាការពិនិត្យថៃទាំគភ៌លើកទី២ និងទី៤ ឆ្នាំ២០២១-២០២៥ (%)




## **ក្រាហ្វិក ២.១១.** អត្រាពិនិត្យថៃទាំគភ៌មុនសម្រាលលើកទី២ និងទី៤ តាមរាជធានី ខេត្ត ឆ្នាំ២០២៥



**ខ. ការសម្រាលទូទៅ៖** នៅឆ្នាំ២០២៥ ស្ត្រីបានសម្រាលកូន មានចំនួនសរុប ២៥៣ ៣០៨ នាក់ ក្នុងនោះ សម្រាល៖

- នៅមណ្ឌលសុខភាព ៩៣ ០០២ នាក់ ឬស្មើនឹង ៣៦,៧១%
- នៅមន្ទីរពេទ្យបង្អែក ១៤៣ ៣០០ នាក់ ឬស្មើនឹង ៥៦,៥៧%
- នៅសេវាឯកជនដែលរាយការណ៍ ១៥ ៤១៦ នាក់ ឬស្មើនឹង ៦,០៩%
- នៅផ្ទះដោយបុគ្គលិកសុខាភិបាល ១ ៤៨៧ នាក់ ឬស្មើនឹង ០,៥៩%
- នៅផ្ទះដោយឆ្មបបុរាណ ១០៣ នាក់ ឬស្មើនឹង ០,០៤%

នៅឆ្នាំ២០២៥ ស្ត្រីមានគភ៌បានសម្រាលដោយបុគ្គលិកសុខាភិបាល មានចំនួន ២៥៣ ២០៥ នាក់ ទាបជាងឆ្នាំ២០២៤ ដែលមានចំនួន ២៨៣ ៩៥១ នាក់។ បើគិតជាភាគរយនៃស្ត្រីមានគភ៌រំពឹងទុក អត្រានេះបានធ្លាក់ចុះពី ៧៧,៦៣% នៅឆ្នាំ២០២៤ មកនៅ ៧១,៣១% នៅឆ្នាំ២០២៥។ រីឯចំនួនស្ត្រីសម្រាលនៅមូលដ្ឋានសុខាភិបាល មានចំនួនសរុប ២៥១ ៧១៨ នាក់ ក្នុងនោះ សម្រាលនៅមូលដ្ឋានសុខាភិបាលសាធារណៈចំនួន ២៣៦ ៣០១ នាក់ និងនៅសេវាសុខាភិបាលឯកជនដែលបានរាយការណ៍ ១៥ ៤១៦ នាក់។ បើគិតជាអត្រាសម្រាលនៅមូលដ្ឋានសុខាភិបាលបានធ្លាក់ចុះ ពី ៧៥,៨២% នៅឆ្នាំ ២០២៤ មកនៅ ៧០,៨៩% នៃស្ត្រីមានគភ៌រំពឹងទុក នៅឆ្នាំ២០២៥ (ក្រាហ្វិក ២.១២.)។ អត្រាសម្រាលនៅមូលដ្ឋានសុខាភិបាលសាធារណៈប្រែប្រួលពីខេត្តមួយទៅខេត្តមួយ ពីអត្រាទាបបំផុត ១២,១៥% ទៅខ្ពស់បំផុត ៨៨,២៤% ហើយអត្រាសម្រាលដោយបុគ្គលិកសុខាភិបាលក៏ប្រែប្រួលពីអត្រាទាបបំផុត ១២,១៥% ទៅខ្ពស់បំផុត ៨៨,២៤% (តារាង ៣.២. នៃឧបសម្ព័ន្ធ ២)។

**ក្រាហ្វិក ២.១២.** និន្នាការនៃអត្រា សម្រាលដោយបុគ្គលិកសុខាភិបាល និងនៅមូលដ្ឋានសុខាភិបាល ពីឆ្នាំ២០២១-២០២៥ (%)



**គ. ការសម្រាលត្រូវការអន្តរាគមន៍៖** នៅឆ្នាំ២០២៥ ស្ត្រីសម្រាលដែលត្រូវការជំនួយអន្តរាគមន៍ ក្នុងពេលសម្រាលដោយសារមូលហេតុចម្បងៗ នៅមូលដ្ឋានសុខាភិបាលសាធារណៈមានចំនួន ៤៩ ២៥៤ នាក់ ក្នុងនោះ សម្រាលមុនពេល ៥ ៨៧៥ នាក់ ធ្លាក់ឈាម ១ ៦៣២ នាក់ បម្រុងក្រឡាភ្លើងមិនធ្ងន់ធ្ងរ ៦៥០ នាក់ បម្រុងក្រឡាភ្លើងធ្ងន់ធ្ងរ ៨០០ នាក់ ក្រឡាភ្លើង ៧២នាក់ រហែកស្បូន ១៣ នាក់ ក្លាយរោគ ២៧២ នាក់ បូម ៤ ៧៦៦ នាក់ ជំនួយផ្សេងៗ ២ ២៦៩ នាក់ និងសម្រាលដោយវិធីវះកាត់ ៣២ ៩០៥ នាក់ (តារាង ៣.៣. នៃឧបសម្ព័ន្ធ ៣)។ ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ អត្រាសម្រាលដោយវិធីវះកាត់បានកើនឡើងពី ៦,៥៨% នៅឆ្នាំ២០២១ ដល់ ១៣,៨៤% នៅឆ្នាំ២០២៥ (ក្រាហ្វិក ២.១៣) និងប្រែប្រួលពីខេត្តមួយ ទៅខេត្តមួយផ្សេងទៀត (តារាង ៣.៤. នៃឧបសម្ព័ន្ធ ៣)។

នៅឆ្នាំ២០២៥ សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារក (Emergency Obstetric and Neonatal care ឬ EmONC) មានចំនួនសរុប ២១៩ កន្លែង ក្នុងនោះមានសេវា EmONC កម្រិតគ្រប់ជ្រុងជ្រោយ (Comprehensive EmONC) ដោយរាប់បញ្ចូលទាំងសេវាសម្រាលតាមវិធីវះកាត់ ៥០កន្លែង និង EmONC កម្រិតមូលដ្ឋាន (Basic EmONC) ចំនួន ១៦៩កន្លែង (តារាង ៣.៥. នៃឧបសម្ព័ន្ធ ៣)។

ក្នុងរយៈពេល ១៦ឆ្នាំចុងក្រោយនេះ (២០១០-២០២៥) ធនធានជាសារវន្តសម្រាប់ការផ្តល់សេវា EmONC គឺបានបណ្តុះបណ្តាល វេជ្ជបណ្ឌិត ២២៥ រូប ឆ្មប ១ ១៤៤ រូប និងគិលានុបដ្ឋាកដាក់ថ្នាំសណ្តំ ២០៥ រូប ព្រមទាំងបានកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបំពាក់ឧបករណ៍ បរិក្ខារពេទ្យ ដែលជាតម្រូវការចាំបាច់។ ដោយឡែកក្នុងឆ្នាំ២០២៥ វេជ្ជបណ្ឌិតចំនួន ៥៨ រូប និងគិលានុបដ្ឋាកដាក់ថ្នាំសណ្តំចំនួន ១៣៥ រូប ត្រូវបានទទួលការបណ្តុះបណ្តាលអំពី សេវា EmONC។

**ក្រាហ្វិក ២.១៣.** អត្រាសម្រាលដោយវិធីវះកាត់ ឆ្នាំ២០២១-២០២៥ (% នៃចំនួនទារកកើតរស់)



**ឃ. ការថែទាំមាតា និងទារកក្រោយសម្រាល៖** ស្ត្រីដែលបានទទួលការពិនិត្យថែទាំក្រោយសម្រាល លើកទី១ ចំនួន ១៨២ ៧៩៦ នាក់ ឬស្មើ ៥១,៤៨% ធៀបនឹងចំនួនស្ត្រីមានគភ៌រំពឹងទុក លើកទី២ ចំនួន ១៣៦ ៤១៩ នាក់ (៣៨,៤២%) លើកទី៣ ចំនួន ៩៤ ៨៤៥ នាក់ (២៦,៧១%) និងលើកទី៤ ចំនួន ២៣ ៦៦៧ នាក់ (៦,៦៧%)។ ក្រាហ្វិក ២.១៤. បង្ហាញពីនិន្នាការ និងកម្រិតនៃអត្រាពិនិត្យថែទាំម្តាយក្រោយសម្រាល លើកទី១ ទី២ ទី៣ និងទី៤ រវាងឆ្នាំ២០២១ និង ឆ្នាំ២០២៥។ ចំណែកទារកដែលបានទទួលការថែទាំក្រោយកំណើតលើកទី១ មានចំនួន ១៧៣ ២៦១ នាក់ លើកទី២ ចំនួន ១៣៣ ៣២១ នាក់ លើកទី៣ ចំនួន ៩៤ ២៤១ នាក់ និងលើកទី៤ ចំនួន ២៣ ៥៨៨ នាក់។ តារាង ៣.៤. ក្នុង ឧបសម្ព័ន្ធ ៣ បង្ហាញពីស្ថិតិ នៃការផ្តល់សេវាថែទាំមាតា និងទារកក្រោយសម្រាល តាមរាជធានី ខេត្ត។

**ក្រាហ្វិក ២.១៤.** និន្នាការអត្រាពិនិត្យថែទាំម្តាយក្រោយសម្រាល (គិតជា % នៃចំនួនស្ត្រីមានគភ៌រំពឹងទុក) ឆ្នាំ២០២១-២០២៥




**ង. មរណភាពមាតា និងទារក៖** យោងតាមរបាយការណ៍នៃប្រព័ន្ធតាមដានមរណភាពមាតា និងការសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបកើត នៅឆ្នាំ២០២៥ ករណីសង្ស័យមរណភាពមាតាដែលបានរាយការណ៍ពីមូលដ្ឋានសុខាភិបាលសាធារណៈមានចំនួនសរុប ៤៣ នាក់ ទាបជាងឆ្នាំ២០២៤ ដែលមានចំនួន ៧៩ នាក់។ រីឯ ទារកកើតរស់មានចំនួន ២៣៧ ៧៥៧ នាក់ ទារកកើតស្លាប់ ៤៩៦ នាក់ (កើតស្លាប់មុន២៤ម៉ោង ២០៩ នាក់) និងស្លាប់កើត ១ ៤០១ នាក់ (ស្លាប់កើតភ្លាមៗ និងស្លាប់កើតយូរ)។ ក្រៅពីស្ថានភាពទាំងនេះ ទារកកើតទម្ងន់តិចជាង ២,៥ គ.ក្រ មានចំនួន ១៥ ៦៥៥ នាក់ ទារកទម្ងន់លើសពី ២,៥ គ.ក្រ ចំនួន ២២១ ៩៤១ នាក់ ទារកកើតមិនបានថ្លឹងទម្ងន់ចំនួន ១៦១ នាក់ និងម្តាយផ្តល់កំណើតកូនភ្លោះពីរ ១ ៣៨២ នាក់ និងកូនភ្លោះបីចំនួន ១១ នាក់ (តារាង ២.៤.)។

**តារាង ២.៤.** ស្ថានភាពទារកកើតនៅមូលដ្ឋានសុខាភិបាលសាធារណៈ ឆ្នាំ២០២១-២០២៥

| ស្ថានភាពទារកកើត | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|
| ទារកកើតរស់ | 285,173 | 259,954 | 280,972 | 267,500 | 237,757 |
| ទារកកើតស្លាប់ ក្នុងនោះ៖ | 2,540 | 2,042 | 2,087 | 1,055 | 496 |
| ▪ ទារកកើតស្លាប់មុន២៤ម៉ោង | 280 | 240 | 492 | 198 | 209 |
| ទារកស្លាប់កើត (កើតភ្លាមៗ/កើតយូរ) | 1,157 | 1,100 | 2,025 | 1,716 | 1,406 |
| ទារកកើតមានទម្ងន់តិចជាង ២,៥ គ.ក្រ. | 17,942 | 17,902 | 17,472 | 17,415 | 15,655 |
| ទារកកើតមានទម្ងន់លើសពី ២,៥ គ.ក្រ. | 266,949 | 241,747 | 263,353 | 249,687 | 221,941 |
| ទារកកើតមិនបានថ្លឹងទម្ងន់ | 282 | 8,234 | 147 | 398 | 161 |
| ចំនួនម្តាយផ្តល់កំណើតកូនភ្លោះពីរ/បី | 1,673/22 | 1,442/15 | 1,769/18 | 1,597/18 | 1,382/11 |

**ច. ការបង្ការការចម្លងរោគអេដស៍/មេរោគស្វាយពីម្តាយទៅកូន៖** ស្ត្រីមានគភ៌ដែលមកទទួលការពិនិត្យផ្ទៃទាំមុនសម្រាល ហើយបានធ្វើតេស្តរិជ្ជមានមេរោគអេដស៍ មានចំនួន ១ ១៤៤ នាក់ ក្នុងនោះស្ត្រី ១ ១៣៧ នាក់ បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និង ស្ត្រីមានគភ៌ហើយបានធ្វើតេស្តវិជ្ជមានមេរោគស្វាយ មានចំនួន ៧ ៧៣៥ នាក់ ក្នុងនោះ ស្ត្រីចំនួន ៧ ៥១៦ នាក់ បានទទួលការព្យាបាលជំងឺស្វាយ។ រីឯ ស្ត្រីមានគភ៌ដែលបានមកសម្រាល ហើយបានរកឃើញមានផ្ទុកមេរោគអេដស៍ មានចំនួន ១ ១៩៤ នាក់ ក្នុងនោះស្ត្រី ១ ១៨៨ នាក់ បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍តាមលក្ខខណ្ឌបច្ចេកទេស (នៅពេលពិនិត្យផ្ទៃទាំគភ៌ ពេលឈឺពោះសម្រាល និងក្រោយសម្រាល) និងទារកប្រឈមហានិភ័យ ១ ១៧៧ នាក់ បានទទួលឱសថសម្រាប់ការបង្ការការចម្លងពីម្តាយ។ សេវាបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន មានចំនួនសរុប ១ ៤២៣ កន្លែង នៅឆ្នាំ២០២៥ ដោយបានកើនឡើង ៧ កន្លែង (នៅឆ្នាំ២០២៤ មានចំនួន ១ ៣៨៧ កន្លែង)។

## ២.៥.៣. សុខភាពកុមារ

| សូចនាករស្នូល | លទ្ធផល 2023 | 2024 | 2025 | ចំណុចដៅ 2025 | %បំរែបំរួល |
|---|---|---|---|---|---|
| 1. អត្រាគ្របដណ្តប់នៃបង្ការជំងឺខាន់ស្លាក់ ក្អកមាន់ តេតាណូស រលោកថ្លើមប្រភេទបេ រលាកសួត រលាកស្រោមខួរ (DPT-HepB-Hib3) ៣ដូស (%) | 107.77 | 95.35 | 93.14 | > 95 | -1.86 |
| 2. អត្រាគ្របដណ្តប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹល-ស្អូច នៅខែទី៩ (%) | 108.63 | 109.1 | 98.32 | > 95 | +3.32 |
| 3. ចំនួនលើកនៃការពិគ្រោះជំងឺក្រៅករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំ ម្នាក់ក្នុងមួយឆ្នាំ | 1.64 | 1.63 | 1.77 | 1.69 | +4.73 |

**ក. ការផ្តល់ថ្នាំបង្ការជំងឺ៖** នៅឆ្នាំ២០២៥ កម្មវិធីជាតិផ្តល់ថ្នាំបង្ការបានផ្តល់វ៉ាក់សាំងកញ្ជ្រឹល-ស្អូច ដល់កុមារអាយុ ៦ខែ ឡើងវិញ ដើម្បីទប់ស្កាត់ការផ្ទុះរីករាលដាលនៃជំងឺកញ្ជ្រឹល។ ក្នុងឆ្នាំ២០២៥ កុមារចំណុចអាយុក្រោមមួយឆ្នាំ ចំនួន ៣២៨ ៧០៤ នាក់ ដែលបានទទួលថ្នាំបង្ការតាមប្រភេទវ៉ាក់សាំង រួមមាន៖

- វ៉ាក់សាំងបង្ការរបេង (BCG) ៨៤,៧៨% (កុមារ ២៧៨ ៦៨៤ នាក់)
- វ៉ាក់សាំងបង្ការរលាកថ្លើមប្រភេទបេ< ២៤ម៉ោង (Hep B) ៧៣,៦៨% (កុមារ ២៤២ ១៧៨ នាក់)
- វ៉ាក់សាំងបង្ការគ្រុនស្វិតដៃជើង៣ ដូស ៩២,៧៧% (កុមារ ៣០៤ ៩៥០នាក់)
- វ៉ាក់សាំងបង្ការជំងឺខាន់ស្លាក់-ក្អកមាន់-តេតាណូស-រលាកថ្លើមប្រភេទបេ-រលាកសួត-រលាកស្រោមខួរ (DPT-HepB-Hib3) ៣ ដូស ៩៣,១៤% (កុមារ ៣០៦ ១៥៥ នាក់)
- វ៉ាក់សាំងបង្ការជំងឺកញ្ជ្រឹល-ស្អូច (MR9) ៩៨,៣២% (កុមារ ៣២៣ ១៨១ នាក់)
- វ៉ាក់សាំងបង្ការជំងឺរលាកខួរក្បាល (JE) ៩៨,៣២% (កុមារ ៣២៣ ១៨១ នាក់)
- វ៉ាក់សាំងបង្ការជំងឺរលាកសួត និងស្រោមខួរក្បាល (PCV3) ៣ ដូស ៩២,៨៥% (កុមារ ៣០៥ ២០២ នាក់)

ទន្ទឹមនឹងនេះ ក្រុមកុមារដែលមានអាយុលើសពី ១ឆ្នាំ ចំនួន ៣០០ ៣៣២ នាក់ បានទទួលថ្នាំបង្ការជំងឺកញ្ជ្រឹល-ស្អូច (MR18) ឬស្មើនឹង ៩១,៣៧%។

**ក្រាហ្វិក ២.១៥.** និន្នាការនៃការគ្របដណ្តប់ការផ្តល់វ៉ាក់សាំងបង្ការ DPT-HepB-Hib 3 (៣ដូស) លើកុមារអាយុក្រោមមួយឆ្នាំ ពីឆ្នាំ២០២១-២០២៥



ការតាមដានស្រាវជ្រាវជំងឺដែលពាក់ព័ន្ធថ្នាំបង្ការ នៅឆ្នាំ២០២៥ ករណីដែលបានរាយការណ៍ និងបានបញ្ជាក់ដោយមន្ទីរពិសោធន៍ រួមមាន៖

- ករណីសង្ស័យជំងឺខ្វិនទន់អវៈយវៈ ៤០ ករណី ត្រូវបានបញ្ជាក់ថាជាករណីអវិជ្ជមាន
- ករណីសង្ស័យជំងឺកញ្ជ្រឹល និងជំងឺស្អូច ១០ ១៣០ ករណី ក្នុងនោះ ៤ ៥៦៦ ករណី ត្រូវបានបញ្ជាក់ថាជាជំងឺកញ្ជ្រឹល និង ៥៦ ករណីទៀត ជាជំងឺស្អូច
- ករណីសង្ស័យជំងឺក្អកមាន់ ៣៥ ករណី ត្រូវបានបញ្ជាក់ថាជាជំងឺក្អកមាន់ ៧ករណី
- ករណីសង្ស័យជំងឺរលាកស្រោមខួរ-ខួរក្បាលស្រួចស្រាល់ ១៧៨ ករណី ត្រូវបានបញ្ជាក់ថាជាជំងឺរលាកខួរក្បាលជេអ៊ី (Japanese Encephalitis) ៦ ករណី។
- ក្នុងចំណោមទារកស្លាប់ក្រោម២៨ថ្ងៃ (Neonatal Death) ចំនួន ១៨១ ករណី ដែលបានរាយការណ៍នៅក្នុងឆ្នាំ២០២៥ មាន ១ ករណី ដែលត្រូវគ្នានឹងលក្ខខ័ណ្ឌវិនិច្ឆ័យជាជំងឺតេតាណូសទារក (Neonatal Tetanus)។

ចំពោះមុខករណីសង្ស័យជំងឺដែលពាក់ព័ន្ធនឹងថ្នាំបង្ការ កម្មវិធីជាតិផ្ដល់ថ្នាំបង្ការបានសហការជាមួយអង្គភាពសុខាភិបាលថ្នាក់ក្រោមជាតិ រដ្ឋអំណាចមូលដ្ឋាន និងសហគមន៍ ធ្វើការស្រាវជ្រាវបន្ថែម និងផ្ដល់វ៉ាក់សាំងបន្ថែមដែលជាបទអន្តរាគមន៍ឆ្លើយតបបន្ទាន់ នៅតាមសហគមន៍ដែលបានរាយការណ៍ពីករណីសង្ស័យទាំងនោះ។ គួរកត់សម្គាល់ថា នៅក្នុងឆ្នាំ២០២៥ ទូវ៉ាក់សាំង ២៣៤ គ្រឿង នៅគ្រប់ថ្នាក់ (ថ្នាក់មន្ទីរសុខាភិបាលរាជធានី ខេត្ត ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមណ្ឌលសុខភាព) ត្រូវបានជួសជុលនិងថែទាំ។

**ខ. ការពិគ្រោះជំងឺក្រៅលើកុមារ៖** ការពិនិត្យជំងឺក្រៅករណីថ្មី លើកុមារអាយុក្រោមប្រាំឆ្នាំ បានកើនពី ២ ៥៩៤ ៣៨៩ ករណី នៅឆ្នាំ២០២៤ ទៅ ២ ៧៨៥ ៦៧៤ ករណី នៅឆ្នាំ២០២៥ ក្នុងនោះ ពិនិត្យនៅមូលដ្ឋានសុខាភិបាលសាធារណៈ ចំនួន ២ ៤៨៥ ០០៦ ករណី និងនៅសេវាឯកជនដែលបានរាយការណ៍ចំនួន ៣០០ ៦៦៨ ករណី។ រីឯ ចំនួនលើកនៃការពិនិត្យពិគ្រោះជំងឺក្រៅករណីថ្មី នៃកុមារអាយុក្រោមប្រាំឆ្នាំម្នាក់ ក្នុងមួយឆ្នាំ មាននិន្នាការកើនពី ១,២៦ នៅឆ្នាំ២០២១ មកដល់ ១,៧៧ នៅឆ្នាំ២០២៥ (ក្រាហ្វិក ២.១៦.)។ កម្រិតប្រើប្រាស់សេវាពិនិត្យជំងឺក្រៅករណីថ្មី និងចំនួនលើកពិនិត្យជំងឺករណីថ្មី ក្នុងកុមារអាយុក្រោម៥ឆ្នាំម្នាក់ ក្នុងមួយឆ្នាំ ប្រែប្រួលតាមរាជធានី-ខេត្ត ពីអត្រាទាបបំផុត ០,៥៨ លើក ទៅអត្រាខ្ពស់បំផុត ២,៧៥ លើក (ក្រាហ្វិក ២.១៧. និង តារាង ៣.៦. ក្នុងឧបសម្ព័ន្ធ ៣)។

**ក្រាហ្វិក ២.១៦.** និន្នាការពិគ្រោះជំងឺក្រៅករណីថ្មីនៃកុមារអាយុក្រោម៥ឆ្នាំ ម្នាក់ ក្នុងមួយឆ្នាំ (ចំនួនលើក) រវាងឆ្នាំ២០២១-២០២៥




**ក្រាហ្វិក ២.១៧.** និន្នាការពិគ្រោះជំងឺក្រៅករណីថ្មី លើកុមារអាយុ៥ឆ្នាំម្នាក់ក្នុងមួយឆ្នាំ នៅសេវាសាធារណៈ (ចំនួនលើក) តាមរាជធានី ខេត្ត ឆ្នាំ២០២៥



ជំងឺនាំមុខ ឬបញ្ហាសុខភាព ១០ ដែលជាមូលហេតុចម្បងនៃការពិគ្រោះជំងឺក្រៅករណីថ្មី ឆ្នាំ២០២៥ សរុប ៨៤៣ ២៨៥ ករណី ក្នុងនោះរួមមាន ជំងឺរលាកផ្លូវដង្ហើមលើស្រួចស្រាល់ ចំនួន ៥៨២ ៨៨៣ ករណី ឬស្មើនឹង ៦៩,១២% ជំងឺរាកគ្មានខ្សោះជាតិទឹក ចំនួន ៦២ ០០៧ ករណី ឬស្មើនឹង ៧,៣៥% ជំងឺរលាកសួត ចំនួន ៤៣ ៦៤៨ ករណី ឬស្មើនឹង ៥,១៨% ជំងឺរលាកបំពង់កស្រួចស្រាល់ ចំនួន ៣៣ ០៥០ ករណី ឬស្មើនឹង ៣,៩២% ជំងឺរលាកផ្លូវដង្ហើមផ្នែកខាងក្រោមផ្សេងៗទៀត ចំនួន ២៧ ៣៩៦ ករណី ឬស្មើនឹង ៣,២៥% ជំងឺរលាកទងសួតស្រួចស្រាល់ ចំនួន ២៥ ២៣៦ ករណី ឬស្មើនឹង ២,៩៩% ជំងឺរាកមួល ចំនួន ២៣ ៤៩១ ករណី ឬស្មើនឹង ២,៧៩% ជំងឺមាស់ស្បែក ចំនួន ១៨ ១៣៥ ករណី ឬស្មើនឹង ២,១៥% ជំងឺរាកមានខ្សោះជាតិទឹកមធ្យម ចំនួន ១៥ ០៣៧ ករណី ឬស្មើនឹង ១,៨៩% និងជំងឺក្រហមភ្នែក ចំនួន ១១ ៥០២ ករណី ឬស្មើនឹង ១,៣៦% (តារាង ២.៥.)។

**តារាង ២.៥.** បញ្ហាសុខភាពចម្បង១០ នៃការពិគ្រោះជំងឺក្រៅករណ៍ថ្មីលើកុមារអាយុក្រោម៥ឆ្នាំ នៅឆ្នាំ២០២៥

| បញ្ហាសុខភាព | 0-28 ថ្ងៃ | | 29 ថ្ងៃ-11 ខែ | | 1-4 ឆ្នាំ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| 1. រលាកផ្លូវដង្ហើមលើស្រួចស្រាល់ | 3,769 | 4,902 | 102,707 | 111,723 | 175,014 | 184,768 | 281,490 | 301,393 |
| 2. រាកគ្មានខ្សោះជាតិទឹក | 483 | 553 | 11,144 | 12,122 | 18,380 | 19,325 | 30,007 | 32,000 |
| 3. រលាកសួត | 138 | 203 | 7,295 | 7,633 | 14,128 | 14,251 | 21,561 | 22,087 |
| 4. ជំងឺរលាកបំពង់កស្រួចស្រាល់ | 108 | 156 | 3,766 | 3,932 | 12,669 | 12,419 | 16,543 | 16,507 |
| 5. រលាកផ្លូវដង្ហើមផ្នែកខាងក្រោមផ្សេងៗទៀត | 349 | 476 | 4,171 | 5,411 | 7,733 | 9,256 | 12,253 | 15,143 |
| 6. រលាកទងសួតស្រួចស្រាល់ | 400 | 398 | 4,603 | 4,225 | 7,945 | 7,665 | 12,948 | 12,288 |
| 7. រាកមួល | 194 | 294 | 3,926 | 4,217 | 7,079 | 7,781 | 11,199 | 12,292 |
| 8. រមាស់ស្បែក | 73 | 124 | 2,011 | 2,125 | 6,562 | 7,240 | 8,646 | 9,489 |
| 9. រាកមានខ្សោះជាតិទឹកមធ្យម | 109 | 132 | 3,163 | 2,955 | 4,975 | 4,603 | 8,247 | 7,690 |
| 10. ជំងឺក្រហមភ្នែក | 847 | 885 | 1,993 | 2,022 | 2,903 | 2,852 | 5,743 | 5,759 |
| **សរុបទូទាំងប្រទេស** | **6,470** | **8,123** | **144,779** | **156,365** | **257,388** | **270,160** | **408,637** | **434,648** |

គួរកត់សម្គាល់ថា ជំងឺហឺតដែលបានលេចឡើងនៅឆ្នាំ២០២៤ នៅលេខរៀងទី១០ នៃបញ្ហាសុខភាពចម្បងទាំង១០ មិនមានលេខរៀងនៅក្នុងបញ្ហាសុខភាពចម្បងទាំង១០ នៅឆ្នាំ២០២៥ និងជំនួសវិញដោយជំងឺភ្នែកក្រហមនៅលេខរៀងទី១០ ក្នុងឆ្នាំ២០២៥។ ដោយឡែកជំងឺរលាកបំពង់កស្រួចស្រាល់ ដែលមានលេខរៀងទី៧ ក្នុងឆ្នាំ២០២៤ បានឡើងមកលេខរៀងទី៤ ក្នុងឆ្នាំ២០២៥ ហើយជំងឺរលាកផ្លូវដង្ហើមផ្នែកខាងក្រោមផ្សេងៗទៀត ជំងឺរលាកទងសួតស្រួចស្រាល់ និងជំងឺរាកមួល បានធ្លាក់ចុះមួយលេខ ម្នាក់ពីឆ្នាំ២០២៤ មកឆ្នាំ២០២៥ (ពីលេខរៀងទី៤ មកទី៥ ទី៥ មកទី៦ និងទី៦ មកទី៧ តាមលំដាប់លំដោយ)។ រលាកបំពង់កស្រួចស្រាល់ ក៏បានថយលេខរៀងពីទី៦ មកទី៧ រវាងឆ្នាំ២០២៤ និងឆ្នាំ២០២៥។ ចំណែកជំងឺរាកមានខ្សោះជាតិទឹកមធ្យម និងជំងឺរមាស់ស្បែកបានផ្លាស់ប្តូរលេខរៀងគ្នា (ពីលេខរៀងទី៨ មកលេខរៀងទី៩ និងពីលេខរៀងទី៩ ទៅលេខរៀងទី១០ តាមលំដាប់លំដោយ) (តារាង ២.៦.)។ ការពិនិត្យជំងឺក្រៅតាមពិធីសារសមាហរណកម្មគ្រប់គ្រងជំងឺកុមារអាយុក្រោមប្រាំឆ្នាំ មានចំនួនសរុប ១ ១១០ ២៦៣ ករណី ក្នុងនោះករណីថ្មីចំនួន ១ ០៧០ ៤០៧ ករណី។ គួរកត់សម្គាល់ថា ការពិនិត្យក្រៅករណីថ្មី តាមបែបសមាហរណកម្ម នៅឆ្នាំ២០២៥ បានថយចុះតិចតួច ប្រមាណ 0,៥% ទាបជាងឆ្នាំ២០២៤។ តារាង ៣.៧. ក្នុងឧបសម្ព័ន្ធ ៣ បង្ហាញពីករណីពិនិត្យជំងឺក្រៅតាមពិធីសារសមាហរណកម្ម គ្រប់គ្រងជំងឺកុមារនៅតាមរាជធានី ខេត្ត ក្នុងឆ្នាំ២០២៥។

**តារាង ២.៦.** បម្រែបម្រួលចំណាត់ថ្នាក់បញ្ហាសុខភាពចម្បង១០ នៃការពិគ្រោះជំងឺក្រៅករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំ រវាងឆ្នាំ២០២៤ និងឆ្នាំ២០២៥

| បញ្ហាសុខភាពចម្បង | 2024 | | 2025 | |
|---|---|---|---|---|
| | ចំណាត់ថ្នាក់ | ចំនួន | ចំណាត់ថ្នាក់ | ចំនួន |
| 1. រលាកផ្លូវដង្ហើមលើស្រួចស្រាល់ | 1 | 675,446 | 1 | 582,883 |
| 2. រាកគ្មានខ្សោះជាតិទឹក | 2 | 79,277 | 2 | 62,007 |
| 3. រលាកសួត | 3 | 52,459 | 3 | 43,648 |
| 4. រលាកផ្លូវដង្ហើមផ្នែកខាងក្រោមផ្សេងៗទៀត | 4 | 35,138 | 5 | 27,396 |
| 5. រលាកទងសួតស្រួចស្រាល់ | 5 | 35,040 | 6 | 25,236 |
| 6. រាកមួល | 6 | 30,128 | 7 | 23,491 |
| 7. ជំងឺរលាកបំពង់កស្រួចស្រាល់ | 7 | 23,733 | 4 | 33,050 |
| 8. រាកមានខ្សោះជាតិទឹកមធ្យម | 8 | 22,265 | 9 | 15,937 |
| 9. រមាស់ស្បែក | 9 | 18,932 | 8 | 18,135 |
| 10. ជំងឺហឺត | 10 | 12,598 | | 10,041 |
| 11. ជំងឺភ្នែកក្រហម | | 10,812 | 10 | 11,502 |

## គ. ការសម្រាកព្យាបាល

នៅឆ្នាំ២០២៥ កុមារអាយុក្រោមប្រាំឆ្នាំសម្រាកព្យាបាលបានកើនឡើងពី ២៥៩ ១២៥នាក់ (ស្រី ១១៤ ៩៤៥ នាក់) នៅឆ្នាំ២០២៤ ទៅ ២៧៦ ៤៩០ នាក់ (ស្រី ១២១ ៩៤៨ នាក់) នៅឆ្នាំ២០២៥ ឬកើនឡើង ៦,៧០% និងស្លាប់មានចំនួន ១ ២៥០ នាក់ ទាបជាងឆ្នាំ២០២៤ ដែលកុមារស្លាប់មានចំនួន ១ ៣០១ នាក់។ មូលហេតុនាំមុខនៃការចូលសម្រាកព្យាបាល របស់កុមារ ៨៦ ១៣៩ នាក់ គឺជំងឺរលាកបំពង់កស្រួចស្រាល់ ២៣ ៥០៥ករណី ឬស្មើនឹង ២៧,២៩% ជំងឺរលាកទងសួតស្រួចស្រាល់ ១៩ ៣១៩ ករណី ឬស្មើនឹង ២២,៤៣% ជំងឺរលាកផ្លូវដង្ហើមលើស្រួចស្រាល់ ១៦ ៤៥៥ ករណី ឬស្មើនឹង ១៩,១០% ជំងឺរលាកសួត ១៣ ៩៨១ករណី ឬស្មើនឹង ១៦,២៣% និងជំងឺរាកគ្មានខ្សោះជាតិទឹក ១២ ៨៧៩ ករណី ឬស្មើនឹង ១៤,៩៥% (តារាង ២.៧.)។ តារាង ៣.៨. ក្នុងឧបសម្ព័ន្ធ ៣ បង្ហាញពីចំនួនកុមារតាមក្រុមអាយុនិងភេទ ដែលបានសម្រាកព្យាបាលនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈទូទាំងប្រទេស នៅក្នុងឆ្នាំ២០២៥។

រីឯរោគវិនិច្ឆ័យចេញពីមន្ទីរពេទ្យនៃជំងឺនាំមុខ ៥ ដែលជាមូលហេតុនៃការចូលសម្រាកពេទ្យរបស់កុមារអាយុក្រោម៥ឆ្នាំ រវាងឆ្នាំ២០២៤ និង២០២៥ បានផ្លាស់ប្តូរ។ ជំងឺរាកគ្មានខ្សោះជាតិទឹក បានធ្លាក់ពីលេខរៀងទី៣ ទៅលេខរៀងទី៥ ហើយជំងឺរលាកផ្លូវដង្ហើមលើស្រួចស្រាល់ និងជំងឺរលាកសួត បានឡើងពីលេខរៀងទី៤ មកទី៣ និងទី៥ មកទី៤ តាមលំដាប់លំដោយ។ តារាង ២.៨ បង្ហាញពីការផ្លាស់ប្តូរនៃរោគវិនិច្ឆ័យជំងឺចម្បង ៥ លើកុមារអាយុក្រោម៥ឆ្នាំ រវាងឆ្នាំ២០២៤ និងឆ្នាំ២០២៥។

**តារាង ២.៧.** មូលហេតុចម្បង៥ នៃការសម្រាកពេទ្យរបស់កុមារអាយុក្រោម៥ឆ្នាំ នៅឆ្នាំ២០២៥

| មូលហេតុចម្បង | 0-28 ថ្ងៃ | | 29 ថ្ងៃ-11 ខែ | | 1-4 ឆ្នាំ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| 1. រលាកបំពង់កស្រួចស្រាល់ | 148 | 101 | 2,580 | 2,100 | 10,101 | 8,475 | 12,829 | 10,676 |
| 2. រលាកទងសួតស្រួចស្រាល់ | 371 | 286 | 5,141 | 3,463 | 5,741 | 4,317 | 11,253 | 8,066 |
| 3. រលាកផ្លូវដង្ហើមលើស្រួចស្រាល់ | 29 | 32 | 2,359 | 1,895 | 6,494 | 5,646 | 8,882 | 7,573 |
| 4. រលាកសួត | 312 | 215 | 3,342 | 2,146 | 4,594 | 3,372 | 8,248 | 5,733 |
| 5. រាកគ្មានខ្សោះជាតិទឹក | 179 | 124 | 3,060 | 2,134 | 4,167 | 3,215 | 7,406 | 5,473 |
| **សរុបទូទាំងប្រទេស** | **1,039** | **758** | **16,482** | **11,738** | **31,097** | **25,025** | **48,618** | **37,521** |

**តារាង ២.៨.** បម្រែបម្រួលចំណាត់ថ្នាក់រោគវិនិច្ឆ័យចេញចម្បង៥ នៃជំងឺសម្រាកពេទ្យលើកុមារអាយុក្រោម៥ឆ្នាំ រវាងឆ្នាំ២០២៤ នឹងឆ្នាំ២០២៥

| រោគវិនិច្ឆ័យចេញ | 2024 | | 2025 | |
|---|---|---|---|---|
| | លេខរៀង | ចំនួន | លេខរៀង | ចំនួន |
| 1. ជំងឺរលាកបំពង់កស្រួចស្រាវ | 1 | 19,580 | 1 | 23,505 |
| 2. រលាកទងសួតស្រួចស្រាវ | 2 | 17,012 | 2 | 19,319 |
| 3. រាកគ្មានខ្សោះជាតិទឹក | 3 | 14,814 | 5 | 12,879 |
| 4. រលាកផ្លូវដង្ហើមលើស្រួចស្រាវ | 4 | 13,807 | 3 | 16,455 |
| 5. រលាកសួត | 5 | 13,023 | 4 | 13,981 |

## ២.៥.៤. ការកែលម្អកង្វះអាហារូបត្ថម្ភ

(% បំរែបំរួលលទ្ធផលធៀបចំណុចដៅ)

| សូចនាករស្នូល | លទ្ធផល 2023 | 2024 | 2025 | ចំណុចដៅ 2025 | %បំរែបំរួល |
|---|---|---|---|---|---|
| 1. % នៃទារកបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងអំឡុងម៉ោងដំបូងនៃកំណើត | 71.02 | 72.73 | **76.28** | **74** | **+2.28** |
| 2. % នៃកុមារអាយុពី៦-៥៩ខែ បានទទួលគ្រាប់ថ្នាំជីវជាតិ-អាក្នុងអំឡុងពេល៦ខែចុងក្រោយនៃឆ្នាំ | 84.02 | 92.73 | **84.60** | **93** | **-8.40** |
| 3. % នៃកុមារអាយុពី១២-៥៩ខែ បានទទួលថ្នាំមេបង់ដាហ្សុលក្នុងអំឡុង ពេល៦ខែចុងក្រោយនៃឆ្នាំ | 73.73 | 92.73 | **83.87** | **93** | **-9.13** |
| 4. % នៃស្ត្រីមានគភ៌ទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលិក ៩០គ្រាប់ | 87.29 | 79.55 | **85.87** | **90** | **-4.13** |
| 5. % ស្ត្រីក្រោយសម្រាលបានទទួលគ្រាប់ថ្នាំជីវជាតិ ដែក/អាស៊ីតហ្វូលិក ៤២គ្រាប់ | 76.22 | 68.39 | **67.25** | **82** | **-14.75** |

**ក. ការបំបៅកូនដោយទឹកដោះម្តាយ៖** នៅឆ្នាំ២០២៥ ទារកកើតរស់ដែលបានទទួលការបំបៅដោយទឹកដោះម្តាយ នៅក្នុងម៉ោងដំបូងក្រោយកំណើតបានកើនឡើង ៣,៥៥% (ក្រាហ្វិក ២.១៨.)។ អត្រានេះប្រែប្រួលពីខេត្តមួយទៅខេត្តមួយ ពីអត្រាទាបបំផុត ៦៩,៥៦% ទៅអត្រាខ្ពស់បំផុត ៩៩,៣៤% (ក្រាហ្វិក ២.១៩. និងតារាង ៤.១. នៃឧបសម្ព័ន្ធ ៤)។

**ក្រាហ្វិក ២.១៨.** និន្នាការនៃអត្រាបំបៅទារកដោយទឹកដោះម្ដាយ នៅក្នុងមួយម៉ោងដំបូងក្រោយកំណើត រវាងឆ្នាំ២០២១-២០២៥




**ក្រាហ្វិក ២.១៩.** អត្រាបំបៅកូនដោយទឹកដោះម្ដាយ ក្នុងមួយម៉ោងដំបូងក្រោយកំណើតតាមរាជធានី ខេត្ត ឆ្នាំ២០២៥



**ខ. ការផ្តល់គ្រាប់ថ្នាំជីវជាតិ អា៖** តាមការប៉ាន់ស្មានដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ កុមារអាយុពី ៦-៥៩ខែ នៅឆ្នាំ២០២៥ មានចំនួន ១ ៤០០ ៩៥៨ នាក់ ក្នុងនោះ កុមារបានទទួលគ្រាប់ថ្នាំជីវជាតិ-អា ក្នុងអំឡុងពេល ៦ខែ ដើមឆ្នាំ២០២៥ (ជុំទីមួយ) មានចំនួន ១ ២៤១ ៧១៩ នាក់ ស្មើនឹង ៨៨,៦៣% និង ក្នុងអំឡុងពេល ៥ខែ ចុងឆ្នាំ (ជុំទីពីរ គិតត្រឹមខែវិច្ឆិកា) មានចំនួន ១ ១៨៥ ១៥៣ នាក់ ឬស្មើនឹង ៨៤,៦០%។ អត្រានេះមានការប្រែប្រួលពីខេត្ត មួយទៅខេត្តមួយទៀត ពីអត្រាទាបបំផុត ១៩,២១% ទៅកម្រិតខ្ពស់បំផុត ១៣២,៦០% (តារាង ៤.២. ក្នុង ឧបសម្ព័ន្ធ ៤)។ ដោយឡែក គិតត្រឹមខែវិច្ឆិកាឆ្នាំ២០២៥ ការផ្តល់គ្រាប់ថ្នាំជីវជាតិ-អា ក្នុងការព្យាបាលកុមារមានជំងឺស្ងួតភ្នែក និងជំងឺខ្វាក់មាន់ បានចំនួន ១១ ៣២២ នាក់ កុមារមានជំងឺកញ្ជ្រិល ១៣៩នាក់ និងកុមារមានជំងឺកង្វះអាហារូបត្ថម្ភ ឬរាកជាប់ ឬរាករ៉ុាំរ៉ៃ ចំនួន ៣៥០ នាក់។

**គ. ការផ្តល់ថ្នាំទំលាក់ព្រូន៖** នៅឆ្នាំ២០២៥ កុមារអាយុពី ១២-៥៩ខែ ដែលបានទទួលថ្នាំមេបង់ដាហ្សុល ជុំទីពីរ (៥ខែចុងឆ្នាំ គិតត្រឹមខែវិច្ឆិកា) មានចំនួន ១ ០៤០ ៨៤៤ នាក់។ គិតត្រឹមខែវិច្ឆិកាឆ្នាំ២០២៥ ស្ត្រីក្នុងវ័យបន្តពូជអាយុពី១៥-៤៩ឆ្នាំ ចំនួន ២៥១ ៣៦១ នាក់ និងស្ត្រីបំបៅដោះកូន ចំនួន ១៤៥ ៤៩៩ នាក់ (តារាង ៤.៣. ក្នុងឧបសម្ព័ន្ធ ៤)។

**ឃ. ការផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិក៖** នៅឆ្នាំ២០២៥ ស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិក៩០គ្រាប់ មានចំនួន ៣០៤ ៥៣២ នាក់ ឬស្មើនឹង ៨៥,៧៧% នៃស្ត្រីមានគភ៌រំពឹងទុក។ រីឯស្ត្រីក្រោយសម្រាលបានទទួលគ្រាប់ថ្នាំជាតិដែក/អាស៊ីតហ្វូលិក៤២គ្រាប់ មានចំនួន ២៣៨ ៧៧៨ នាក់ ឬស្មើនឹង ៦៧,២៥% (តារាង ៤.៤. ក្នុងឧបសម្ព័ន្ធ ៤)។

**ង. ការពិនិត្យពិគ្រោះ និងព្យាបាលជំងឺកង្វះអាហារូបត្ថម្ភស្រួចស្រាល់ មធ្យម និងធ្ងន់ធ្ងរ៖** នៅឆ្នាំ២០២៥ កុមារអាយុក្រោម ៥ឆ្នាំ ដែលបានមកពិនិត្យជំងឺក្រៅ និងបានរកឃើញមានបញ្ហា កង្វះអាហារូបត្ថម្ភស្រួចស្រាល់ មានចំនួនសរុប ៨ ២៩៤ ករណី ដោយថយចុះប្រមាណ ២៧% បើធៀបនឹងឆ្នាំ២០២៤ (១១ ៣១០ ករណី) (តារាង ២.៩.)។ ដោយឡែកកុមារអាយុក្រោម ៥ឆ្នាំ ដែលបានធ្វើរោគវិនិច្ឆ័យ ថាមានជំងឺកង្វះអាហារូបត្ថម្ភស្រួចស្រាល់ បានមកសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ នៅក្នុងឆ្នាំ២០២៥ មានចំនួនសរុប ៩៣០ នាក់ ច្រើនជាងឆ្នាំ២០២៤ ចំនួន ១៤ នាក់ (តារាង ២.១០.)។

**តារាង ២.៩.** ជំងឺកង្វះអាហារូបត្ថម្ភស្រួចស្រាល់ ដែលបានមកទទួលសេវាពិគ្រោះជំងឺក្រៅករណីថ្មី លើកុមារអាយុក្រោម៥ឆ្នាំ ក្នុងឆ្នាំ២០២៤-២០២៥

| បញ្ហាសុខភាព (ករណីថ្មី) | កុមារអាយុពី ០ ថ្ងៃ ទៅក្រោម៥ឆ្នាំ | | | | | |
|---|---|---|---|---|---|---|
| | 2024 | | | 2025 | | |
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភ ស្រួចស្រាល់ធ្ងន់ធ្ងរ (មានហើមប្រអប់ជើងទាំងសងខាង) | 66 | 86 | 152 | 65 | 65 | 130 |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាល់ធ្ងន់ធ្ងរ (ទម្ងន់ធៀបនឹងប្រវែង/កម្ពស់ < -3 SD) - គ្មានផលវិបាក | 845 | 1,094 | 1,939 | 600 | 740 | 1,340 |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាល់ធ្ងន់ធ្ងរ (រង្វាស់ជុំវិញពាក់កណ្ដាលដើមដៃ < ១១,៥ cm.) - គ្មានផលវិបាក | 162 | 258 | 420 | 114 | 192 | 306 |

| | | | | | | |
|---|---|---|---|---|---|---|
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាល់មធ្យម ( ទម្ងន់ធៀបនឹងប្រវែង/កម្ពស់ < - 2 SD និង - 3 SD ) | 2,715 | 3,422 | 6,137 | 1,844 | 2,077 | 3,922 |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាល់មធ្យម ( វង្វាស់ជុំវិញពាក់កណ្តាលដើមដៃចន្លោះពី ១១,៥ cm. ដល់ < ១២,៥ cm. ) | 364 | 480 | 844 | 197 | 286 | 482 |
| ចំនួនកុមារដែលមានទម្ងន់ទាបខ្លាំងធៀបនឹងអាយុ/ទម្ងន់ក្រោមស្តង់ដារ ( ទម្ងន់ធៀបនឹងអាយុ < - 3 SD ) | 666 | 1,152 | 1,818 | 815 | 1,300 | 2,114 |
| **សរុបទូទាំងប្រទេស** | **4,818** | **6,492** | **11,310** | **3,635** | **4,660** | **8,294** |

## **តារាង ២.១០.** ពេគវិនិច្ឆ័យចេញពីមន្ទីរពេទ្យនៃកុមារអាយុក្រោម៥ឆ្នាំ មានជំងឺកង្វះអាហារូបត្ថម្ភស្រួចស្រាល់ ក្នុងឆ្នាំ២០២៤-២០២៥

| ពេគវិនិច្ឆ័យចេញ | កុមារអាយុពី ០ ថ្ងៃ ទៅក្រោម៥ឆ្នាំ | | | | | |
|---|---|---|---|---|---|---|
| | **2024** | | | **2025** | | |
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភ ស្រួចស្រាល់ធ្ងន់ធ្ងរ (មានហើមប្រអប់ជើងទាំងសងខាង ) | 63 | 41 | 104 | 84 | 50 | 134 |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាល់ធ្ងន់ធ្ងរ ( ទម្ងន់ធៀបនឹងប្រវែង/កម្ពស់ < 3- SD ) - គ្មានផលវិបាក | 2 | 1 | 3 | 1 | 0 | 1 |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាល់ធ្ងន់ធ្ងរ ( ទម្ងន់ធៀបនឹងប្រវែង/កម្ពស់ < 3- SD ) - មានផលវិបាក | 367 | 331 | 698 | 386 | 325 | 711 |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាល់ធ្ងន់ធ្ងរ ( វង្វាស់ជុំវិញពាក់កណ្តាលដើមដៃ < ១១,៥ cm. ) - មានផលវិបាក | 37 | 39 | 76 | 40 | 43 | 83 |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាល់ធ្ងន់ធ្ងរ ( វង្វាស់ជុំវិញពាក់កណ្តាលដើមដៃ < ១១,៥ cm. ) - គ្មានផលវិបាក | 0 | 0 | 0 | 0 | 0 | 0 |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាល់មធ្យម ( ទម្ងន់ធៀបនឹងប្រវែង/កម្ពស់ < - 2 SD និង - 3 SD ) | 1 | 2 | 3 | 1 | 0 | 1 |
| ចំនួនកុមារកង្វះអាហារូបត្ថម្ភស្រួចស្រាល់មធ្យម ( វង្វាស់ជុំវិញពាក់កណ្តាលដើមដៃចន្លោះពី ១១,៥ cm. ដល់ < ១២,៥ cm. ) | 19 | 12 | 31 | 0 | 0 | 0 |
| ចំនួនកុមារដែលមានទម្ងន់ទាបខ្លាំងធៀបនឹងអាយុ/ទម្ងន់ក្រោមស្តង់ដារ ( ទម្ងន់ធៀបនឹងអាយុ < - 3 SD ) | 0 | 1 | 1 | 0 | 0 | 0 |
| **សរុបទូទាំងប្រទេស** | **489** | **427** | **916** | **513** | **417** | **930** |

## ២.៦. ការបង្ការ និងការគ្រប់គ្រងជំងឺឆ្លង

### ២.៦.១. ការបង្ការ និងគ្រប់គ្រងមេរោគអេដស៍/ជំងឺអេដស៍

(% បំរែបំរួលលទ្ធផលធៀបចំណុចដៅ)

| សូចនាករគន្លឹះ | លទ្ធផល | | | | ចំណុចដៅ | % បំរែបំរួល |
|---|---|---|---|---|---|---|
| | 2022 | 2023 | 2024 | 2025 | 2025 | |
| 1. ករណីឆ្លងថ្មីនៃមេរោគអេដស៍ក្នុងចំណោមប្រជាជនគ្មានផ្ទុកមេរោគអេដស៍ ក្នុង ១ ០០០នាក់ | 320 | 0.07 | 0.07 | **0.07** | **0.07** | បានសម្រេច |
| 2. ចំនួននិងភាគរយនៃអ្នកផ្ទុកមេរោគអេដស៍ (មនុស្សពេញវ័យនិងកុមារ) បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | 23 | 99.98 | 99.98 | **99.98** | **99** | **+0.98** |
| 3. ភាគរយនៃអ្នករស់នៅជាមួយមេរោគអេដស៍ (មនុស្សពេញវ័យនិងកុមារ) កំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍បានធ្វើតេស្ត viral load ហើយមានលទ្ធផល viral load suppressed ក្នុងរយៈពេល១២ខែកន្លងមក | 96 | 98.02 | 98.46 | **98.43** | **98** | **+0.43** |

នៅឆ្នាំ២០២៥ កម្ពុជាបន្តនៅលើមាគ៌ាវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅសកល ៩៥-៩៥-៩៥ ដែលជាមូលដ្ឋានឆ្ពោះទៅបញ្ចប់មេរោគអេដស៍ក្នុងចំណោមប្រជាជនជាគោលដៅ នៅឆ្នាំ២០៣០៖

- ៩៥ ទីមួយ សម្រេចបាន ៩២% (គោលដៅទី១៖ ៩៥% នៃអ្នកកំពុងរស់នៅជាមួយមេរោគអេដស៍ (អ.ម.អ.) បានដឹងពីស្ថានភាពនៃមេរោគអេដស៍របស់ខ្លួន)
- ៩៥ ទីពីរ សម្រេចបាន ៩៨,៤៣% (គោលដៅទី២៖ ៩៥% នៃ អ.ម.អ. បានដឹងពីស្ថានភាពមេរោគអេដស៍របស់ខ្លួនកំពុងទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍
- ៩៥ ទីបី សម្រេចបាន ៩៨,៤៣% (១០០%) (គោលដៅទីបី៖ ៩៥% នៃ អ.ម.អ. កំពុងទទួលការព្យាបាលបានធ្វើតេស្ត viral load ហើយមានលទ្ធផល viral load suppressed ក្នុងរយៈពេល១២ខែកន្លង។

### ក. ករណីថ្មី និងករណីស្លាប់

នៅឆ្នាំ២០២៥ តាមការប៉ាន់ប្រមាណ អ្នកឆ្លងថ្មីមេរោគអេដស៍មានចំនួន ១ ២០០ នាក់ បើគិតជាអត្រាករណីឆ្លងថ្មី គឺ ០,០៧ ក្នុងប្រជាជនគ្មានផ្ទុកមេរោគអេដស៍ ១ ០០០ នាក់ ។ ៨៨% នៃករណីឆ្លងថ្មី គឺក្រុមគោលដៅហានិភ័យខ្ពស់ និងដៃគូរបស់ខ្លួន ក្នុងនោះ ៤៤% ជាក្រុមយុវវ័យដែលមានអាយុពី ១៥-២៤ ឆ្នាំ។ រីឯ អ្នករស់នៅជាមួយមេរោគអេដស៍មានចំនួន ៧៦ ០០០ នាក់។ អ្នកជំងឺ ៦៩៧ នាក់ (មនុស្សពេញវ័យ ចំនួន ៦៨៨ នាក់ និងកុមារចំនួន ០៩ នាក់) ត្រូវបានរាយការណ៍ថាស្លាប់។

**ខ. ការថែទាំ-ព្យាបាល៖** សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសម្ងាត់ មាន ៧៤ កន្លែង គ្រប់មន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែកមួយចំនួន និងសេវាពិនិត្យជំងឺកាមរោគដោយផ្អែកលើចង្កោមរោគសញ្ញាមាននៅមណ្ឌលសុខភាពចំនួន ២៣៤ កន្លែង ក្នុងស្រុកប្រតិបត្តិ ៧៧ និងគ្លីនិកសុខភាពគ្រួសារ ៦៣ កន្លែង ក្នុងនោះ ៣៨ កន្លែង គ្រប់គ្រងដោយមន្ទីរពេទ្យបង្អែក ក្នុងរាជធានី-ខេត្ត ទាំង ២៥។ រីឯ មន្ទីរពិសោធន៍ការពិនិត្យនិងរាប់ចំនួនបន្ទុកមេរោគអេដស៍មាន ០២ កន្លែង (មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ និងមន្ទីរពេទ្យខេត្តសៀមរាប)។ ក្នុងឆ្នាំ២០២៥ ការផ្តល់សេវាថែទាំព្យាបាល និងធ្វើតេស្តឈាមសម្រេចបានលទ្ធផល ដូចខាងក្រោម៖

- **ជំងឺអេដស៍៖** អ្នកជំងឺថ្មីដែលចាប់ផ្តើមទទួលការព្យាបាល មានចំនួន ៣ ៦០៤ នាក់ (មនុស្សពេញវ័យ ៣ ៥៦៦នាក់ និងកុមារ ៣៨នាក់)។ អ្នកជំងឺ ១ ១៤២ នាក់ (កុមារ ១១៨ នាក់) ក្នុងចំណោមអ្នកជំងឺព្យាបាលសរុបត្រូវបានបញ្ជូនឱ្យទៅទទួលសេវាព្យាបាលដែលនៅជិតទីកន្លែងដែលពួកគេរស់នៅ។ អ្នកជំងឺដែលបានបោះបង់ចោលការព្យាបាលមានចំនួន ១ ៩៥៤ នាក់ (មនុស្សពេញវ័យ ១ ៩២៩ នាក់ និងកុមារ ២៥ នាក់)។ រីឯ អ្នកជំងឺសកម្មដែលបានទទួលការព្យាបាលបានកើនឡើងពី ៦៩ ៩៩៤ នាក់ នៅឆ្នាំ២០២៤ ដល់ ៧១ ៦៩៧ នៅឆ្នាំ២០២៥ ឬកើនឡើង ២,៤៣% (ក្រាហ្វិក ២.២០)។
- **ជំងឺកាមរោគ៖** អ្នកជំងឺបានមកពិនិត្យនិងព្យាបាលជំងឺកាមរោគមានចំនួនសរុប ១៨ ៦០៦ ករណី (បុរស ១ ២៥៤ ករណី និងស្ត្រី ១១ ៥៧២ ករណី ដៃគូជាបុរស ៦៦៤ ករណី ដៃគូជាស្ត្រី ៥ ១១៦ ករណី) និងគ្លីនិកសុខភាពគ្រួសារ បានទទួលពិគ្រោះជំងឺសរុប ១៨០ ២១៧ ករណី ក្នុងនោះ បុរស ៣០ ០៦៦ ករណី ក្រុមបុរសស្រឡាញ់បុរស ៣ ៦៥៦ ករណី ស្ត្រីប្រឈមហានិភ័យទាប ១៣៣ ១១៦ ករណី ស្ត្រីបម្រើសេវាកម្សាន្ត ៤ ៧៣១ ករណី ស្ត្រីមានផ្ទៃពោះ ២ ៤៩៤ ករណី អ្នកប្រើគ្រឿងញៀន ៤៧ ករណី និង ដៃគូរួមភេទ ៦ ១០៧ ករណី (ដៃគូរួមភេទជាបុរស ២ ៨៨៤ ករណី)។
- **ការប្រឹក្សាធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់សំងាត់ (Voluntary Counseling Confidential Testing-VCCT)៖** ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តរកមេរោគអេដស៍មានអតិថិជនចំនួន ៣០ ២០១ នាក់ បានមកទទួលសេវាន ក្នុងនោះអ្នកមានតេស្តវិជ្ជមានចំនួន ៣ ៧១៧ នាក់ ការផ្តល់សេវាក្រោយធ្វើតេស្តរកមេរោគអេដស៍មានអតិថិជនបានធ្វើតេស្ត ចំនួន ៣០ ២០០ នាក់ ក្នុងនោះមានអតិថិជនដែលទទួលការផ្តល់ប្រឹក្សាក្រោយធ្វើតេស្តមានចំនួន ២៨ ៤៨០ នាក់ ឬស្មើនឹង ៩៤,៣០% នៃអតិថិជនដែលបានធ្វើតេស្ត។

**ក្រាហ្វិក ២.២០.** ចំនួនអ្នកជំងឺសកម្មកំពុងព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍




## ២.៦.២. ការបង្ការ និងការគ្រប់គ្រងជំងឺរបេង

(% បំរែបំរួលលទ្ធផលធៀបចំណុចដៅ)

| សូចនាករគន្លឹះ | លទ្ធផល | | | | ចំណុចដៅ | % បំរែបំរួល |
|---|---|---|---|---|---|---|
| | 2022 | 2023 | 2024 | 2025 | 2025 | |
| 1. អាំងស៊ីដង់ជំងឺរបេងគ្រប់សណ្ឋាន ក្នុងចំណោមប្រជាជន 100 000នាក់ | 320 | 335 | 272 | (-) | **268** | |
| 2. អត្រាស្លាប់ជំងឺរបេងក្នុងចំណោម ប្រជាជន 100 000នាក់ | 20 | 19 | 18 | (-) | **18** | |
| 3. អត្រាព្យាបាលជោគជ័យនៃជំងឺរបេង (%) | 96 | 96 | 96 | **96** | **> 90** | **+6** |
| 4. ចំនួនករណីស្រាវជ្រាវជំងឺរបេង | 32,865 | 32,286 | 33,769 | **30,000** | **39,000** | **-3%** |

(-) លទ្ធផលអាចដឹងបាននៅចុងឆ្នាំ២០២៦ យោងតាម Global Tuberculosis Report 2026 របស់អង្គការសុខភាពពិភពលោក

កម្ពុជាបានចាកចេញពីបញ្ជីសកលលោក នៃក្រុមប្រទេស ៣០ ដែលមានបន្ទុកជំងឺរបេងខ្ពស់ មកនៅក្នុងក្រុមប្រទេសដែលត្រូវឃ្លាំមើលជំងឺរបេង សម្រាប់ឆ្នាំ២០២១-២០២៥ ដោយសារការធ្លាក់ចុះយ៉ាងលឿននៃករណីជំងឺរបេងថ្មីក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយនេះ។

**ក. ករណីថ្មី និងករណីស្លាប់៖** ក្នុងឆ្នាំ២០២៥ ករណីស្រាវជ្រាវជំងឺរបេងថ្មីមានចំនួនសរុប ៣០ ០០០ ករណី ក្នុងនោះ ១៣ ០០០ ករណី ជារបេងវិជ្ជមានបេកា (ក្រាហ្វិក ២.២១)។ អត្រាព្យាបាលជោគជ័យនៃជំងឺរបេងរក្សាបាន ខ្ពស់ ៩៦% សម្រេចបានចំណុចដៅឆ្នាំ២០២៥ដែលបានកំណត់លើសពី ៩០% ហើយអត្រាស្លាប់បានធ្លាក់ចុះពី ២០ ក្នុងប្រជាជន ១០០ ០០០ នាក់ នៅឆ្នាំ២០២២ មកត្រឹម ១៨ ក្នុងប្រជាជន ១០០ ០០០ នាក់ នៅឆ្នាំ២០២៤។ សេវាជំងឺរបេងនៅរក្សាបានការគ្របដណ្តប់ ១០០% នៅគ្រប់មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ទាំងអស់ ទូទាំងប្រទេស ហើយបណ្តាញមន្ទីរពិសោធន៍វិភាគរកមេរោគរបេងដោយប្រើមីក្រូទស្សន៍មាន ចំនួន ២២០ កន្លែង និង ប្រើម៉ាស៊ីនជិនអិចស្ព៊ីតនៅក្នុងស្រុកប្រតិបត្តិចំនួន ៩៩ ក្នុងចំណោមស្រុកប្រតិបត្តិ ១០៣។ ការងាររបេងសហគមន៍ និងការងារអនុវត្តន៍សកម្មភាពរបេង-អេដស៍ មាននៅក្នុងស្រុកប្រតិបត្តិទាំងអស់។ កិច្ចសហការគ្នារវាងសេវាសាធារណៈ និងសេវាឯកជន ពាក់ពន្ធ័ការស្រាវជ្រាវជំងឺរបេង មាននៅក្នុងស្រុកប្រតិបត្តិ ៦៤ ។

**ក្រាហ្វិក ២.២១.** និន្នាការនៃចំនួនករណីជំងឺរបេងដែលបានស្រាវជ្រាវនិងរាយការណ៍ ឆ្នាំ២០២០-២០២៥




**ខ. ការព្យាបាលបង្ការជំងឺរបេង៖** អង្គការសុខភាពពិភពលោកបានគូសបញ្ជាក់ថាការព្យាបាលបង្ការជំងឺរបេង គឺជាអន្តរាគមន៍ដ៏សំខាន់មួយ ឆ្ពោះទៅបញ្ចប់គោលដៅសកលបញ្ចប់ជំងឺរបេងនៅឆ្នាំ២០៣០។ រវាងឆ្នាំ២០២៤-២០២៥ ការព្យាបាលបង្ការនៅកម្ពុជាត្រូវបានពង្រីកការគ្របដណ្តប់ដោយមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់។ តាមការប៉ាន់ប្រមាណ នៅក្នុងឆ្នាំ២០២៥ ការព្យាបាលបង្ការបានគ្របដណ្តប់លើប្រជាជនពី ៥៥ ០០០-៦០ ០០០ នាក់ ដោយកើនលើស ឆ្នាំ២០២៤ ដែលមានប្រមាណ ៤០ ០០០-៥០ ០០០ នាក់។ ក្រុមប្រជាជនជាគោលដៅនៃការព្យាបាលបង្ការ នេះរួមមាន អ្នកផ្ទុកមេរោគអេដស៍ កុមាររស់នៅក្នុងគ្រួសារដែលមានអ្នកជំងឺរបេង ឬប៉ះពាល់ជាមួយអ្នកជំងឺរបេង និងបុគ្គលិកសុខាភិបាលដែលបំរើការងារប្រឈមហានិភ័យនៃជំងឺរបេង។

## ២.៦.៣. ការបង្ការ និងការគ្រប់គ្រងជំងឺគ្រុនចាញ់

(% បំរែបំរួលលទ្ធផលធៀបចំណុចដៅ)

| សូចនាករគន្លឹះ | លទ្ធផល | | | | ចំណុចដៅ | % បំរែបំរួល |
|---|---|---|---|---|---|---|
| | 2022 | 2023 | 2024 | 2025 | 2025 | |
| 1. ករណីថ្មីជំងឺគ្រុនចាញ់ក្នុងចំណោមប្រជាជន 1 000នាក់ | 0.24 | 0.08 | 0.02 | **0.00** | **0.00** | សម្រេច |
| 2. អត្រាស្លាប់នៃជំងឺគ្រុនចាញ់ដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈក្នុងប្រជាជន 100 000នាក់ | 0.00 | 0.00 | 0.00 | **0.00** | **0.00** | សម្រេច |
| 3. អត្រាស្លាប់ដោយជំងឺគ្រុនឈាមដែលបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ (%) | 0.15 | 0.28 | 0.26 | **0.12** | **0.10** | **-0.02** |
| 4. ករណីថ្មីនៃជំងឺគ្រុនឈាមក្នុងប្រជាជន 100 000នាក់ | 74.6 | 214.3 | 108.4 | **303.9** | **169.8** | ខ្ពស់ជាង (អវិជ្ជមាន) |

កម្ពុជាសម្រេចបានគោលដៅជាតិលុបបំបាត់ជំងឺគ្រុនចាញ់ឆ្នាំ២០២៥។ ក្រសួងសុខាភិបាលបាន និងកំពុងរៀបចំឧបករណ៍បច្ចេកទេសចាំបាច់នានា ដែលជាតម្រូវការចាំបាច់ សម្រាប់គាំទ្រការស្នើទៅ អង្គការសុខភាពពិភពលោកធ្វើការវាយតម្លៃ និងផ្តល់វិញ្ញាបនបត្រលុបបំបាត់ជំងឺគ្រុនចាញ់ជាផ្លូវការនៅកម្ពុជា។ ទន្ទឹមនឹងនេះ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ បាននិងកំពុងរៀបចំយុទ្ធសាស្ត្រជាតិរក្សាការលុបបំបាត់ជំងឺគ្រុនចាញ់ ឆ្នាំ២០២៦-២០៣៥។

ចាប់ពីខែវិច្ឆិកាឆ្នាំ២០២៥ គ្មានករណីឆ្លងថ្មីនៃជំងឺគ្រុនចាញ់ទេ នៅកម្ពុជា។ ទោះជាដូច្នេះក្តី ករណីជំងឺនាំចូលពីក្រៅប្រទេស នៅមាន ដែលតម្រូវអោយពង្រឹងវិធានការបង្ការ និងជំរុញកិច្ចសហការប្រតិបត្តិការទប់ស្កាត់ជំងឺគ្រុនចាញ់ឆ្លងព្រំដែនជាមួយប្រទេសជិតខាង និងបណ្តាប្រទេសដទៃទៀតដែលមានការចម្លងជំងឺគ្រុនចាញ់។

**ក. ករណីឈឺ និងករណីស្លាប់៖** ក្នុងឆ្នាំ២០២៥ ចាប់ពីខែមករា ដល់ខែវិច្ឆិកា ករណីជំងឺគ្រុនចាញ់មានចំនួនសរុប ៩២ ករណី និងករណីជំងឺគ្រុនចាញ់នាំចូលពីក្រៅប្រទេស មានចំនួន ៩៨ ករណី។ អត្រាអាំងស៊ីដង់នៃករណីគ្រុនចាញ់គ្រប់ប្រភេទក្នុងចំណោមមនុស្ស ១ ០០០ នាក់ បានថយចុះពី ០,២៤% នៅឆ្នាំ២០២២ មកនៅ ០% ក្នុងឆ្នាំ២០២៥ និងករណីស្លាប់ដោយជំងឺគ្រុនចាញ់ដែលបានធ្លាក់ចុះដល់សូន្យករណី នៅឆ្នាំ២០១៨ បានបន្ត ដោយគ្មានករណីស្លាប់ រហូតមកដល់ឆ្នាំ២០២៥ (ក្រាហ្វិក ២.២២.)។

**ក្រាហ្វិក ២.២.** ចំនួនករណីឈឺ និងករណីស្លាប់នៃជំងឺគ្រុនចាញ់ ឆ្នាំ២០១១-២០២៥




ប្រភព៖ របាយការណ៍មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ ប៉ារ៉ាស៊ីតសាស្ត្រ និងបាណកសាស្ត្រ

**ខ. ការបង្ការ និងការគ្រប់គ្រងជំងឺគ្រុនចាញ់៖** អន្តរាគមន៍លុបបំបាត់ជំងឺគ្រុនចាញ់បានផ្តោតលើសកម្មភាពសំខាន់ៗ ដូចខាងក្រោម៖

- **ការអប់រំសុខភាព៖** ផ្សព្វផ្សាយសារអបអរសាទរទិវាជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងបានសហការជាមួយអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននៃក្រសួងបរិស្ថាន ចុះផ្សព្វផ្សាយអំពី «ការការពារ បង្ការទប់ស្កាត់ និងលុបបំបាត់ជំងឺគ្រុនចាញ់» នៅខេត្តកំពង់ស្ពឺ (វត្តតាំងបំពង់) និងខេត្តកោះកុង (សាលាបឋមសិក្សាជីត្រេះ) ព្រមទាំងបានផ្តល់ការអប់រំសុខភាពដល់ប្រជាពលរដ្ឋក្នុងសហគមន៍ចំនួន ៥២៤ នាក់ (ស្ត្រី ៣៤២ នាក់) និងផ្សព្វផ្សាយសារអប់រំសុខភាពស្តីពីជំងឺគ្រុនចាញ់ តាមរយៈទូរទស្សន៍ ចំនួន ៧២ លើក។
- **ការពង្រឹងសកម្មភាពអង្កេតស្រាវជ្រាវ** ធ្វើរោគវិនិច្ឆ័យ និងអន្តរាគមន៍ទប់ស្កាត់ការរាតត្បាតទាន់ពេលវេលា ដោយមានការចូលរួមពីក្រុមការងារពិសេសលុបបំបាត់ជំងឺគ្រុនចាញ់ អជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ សហគមន៍ និងដៃគូអភិវឌ្ឍន៍។
- **ការអនុវត្តយុទ្ធនាការលុបបំបាត់ជំងឺគ្រុនចាញ់ ៦០ថ្ងៃ** តាមរយៈការផ្តល់ថ្នាំលេបជាសមូហភាពដើម្បីកាត់ផ្តាច់ការចម្លង ដល់ប្រជាជន និងកងទ័ពនៅគ្រប់គោលដៅ នៅស្រុកសៀមប៉ាង ក្នុងខេត្តស្ទឹងត្រែង។
- **ការគ្រប់គ្រង និងតាមដានករណីជំងឺ** តាមរយៈយុទ្ធសាស្ត្រ **១-៣-៧** ដែលជាគោលការណ៍សម្រាប់ការអង្កេតតាមដាននិងការលុបបំបាត់ជំងឺគ្រុនចាញ់៖ **ក្នុងថ្ងៃទី១.** គ្រប់អ្នកសង្ស័យមានជំងឺគ្រុនចាញ់ត្រូវបានធ្វើរោគវិនិច្ឆ័យនិងព្យាបាលជាបន្ទាន់ក្នុងអំឡុង២៤ម៉ោង ក្នុងរយៈពេល **៣ថ្ងៃ** ត្រូវចុះដល់ទីតាំង

អ្នកជំងឺរស់នៅដើម្បីធ្វើរោគវិនិច្ឆ័យបញ្ជាក់ជំងឺ និងរកប្រភពចម្លង ហើយបើសិនរកឃើញថាជាករណីឆ្លងនៅនឹងកន្លែង ត្រូវចាប់មូសមកវិភាគនិងបន្តធ្វើការអង្កេតរកសំបុកចម្លងមិនអោយលើសពី **៧ថ្ងៃ** គិតចាប់ពីថ្ងៃទី១។

- **ការទប់ស្កាត់ និងគ្រប់គ្រងភ្នាក់ងារចម្លងជំងឺគ្រុនចាញ់៖** មុងជ្រលក់ថ្នាំដែលមានប្រសិទ្ធភាពរយៈពេលយូរ ចំនួន ១០៥ ៩៦៨មុង ត្រូវបានចែកជូនប្រជាជនគោលដៅ និងបន្តតាមដានលទ្ធផលនៃការប្រើប្រាស់មុង។
- **ការបណ្តុះបណ្តាលរំលឹក** ដល់ក្រុមឆ្លើយតបបន្ទាន់ថ្នាក់ក្រោមជាតិ ចំនួន ១៩៧ នាក់ (ស្រី ៤៥ នាក់) នៅមន្ទីរសុខាភិបាលខេត្ត និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ដែលទទួលបន្ទុកមន្ទីរពិសោធន៍ អេពីដេមីសាស្ត្រ និងបាណកសាស្ត្រ នៃខេត្តចំនួន ១៥ ដែលមានហានិភ័យគ្រុនចាញ់ និងខេត្ត រាជធានី ៤ ដែលមិនមានហានិភ័យគ្រុនចាញ់។

### ២.៧.៤. ការបង្ការ និងការគ្រប់គ្រងជំងឺឆ្លងដទៃទៀត

**ក. ជំងឺគ្រុនឈាម៖** ក្នុងឆ្នាំ២០២៥ (គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៥) ជំងឺគ្រុនឈាមដែលបានរាយការណ៍មានចំនួនសរុប ៥៣ ៣៩៧ ករណី ឬបើគិតជាអត្រាអាំងស៊ីដង់ គឺ៣០៣,៨ នាក់ ក្នុងចំណោមប្រជាជន ១០០ ០០០ នាក់។ យោងតាមការព្យាករណ៍របស់កម្មវិធីជាតិ ជំងឺគ្រុនឈាមអាចកើនឡើងរហូតដល់ ១១១ ៣៧៩ ករណី រហូតដល់ដំណាច់ឆ្នាំ២០២៥ ដោយកើនឡើងប្រមាណជាង ៣ដង បើធៀបនឹងរយៈពេលដូចគ្នា នៃឆ្នាំ២០២៤។ រីឯ ករណីស្លាប់ដែលបានរាយការណ៍មានចំនួនសរុប ៦៤ ករណី បើគិតជាអត្រាស្លាប់ស្មើនឹង ០,១២%។ អន្តរាគមន៍សំខាន់ៗ ក្នុងការបង្ការ និងការគ្រប់គ្រងជំងឺគ្រុនឈាម បានផ្តោតលើរួមមានការអប់រំសុខភាព ការគ្រប់គ្រងភ្នាក់ងារចម្លងជំងឺ ការគ្រប់គ្រងករណីឈឺ ការពង្រឹងសមត្ថភាពធ្វើរោគវិនិច្ឆ័យគ្លីនិក និងការអង្កេតស្រាវជ្រាវ។

- **ការអប់រំសុខភាព៖** ចលនាប្រជាជនតាមសហគមន៍ អនុវត្តវិធានការបង្ការជំងឺគ្រុនឈាម និងគ្រុនឈីក នៅ ២ ៧៥០ភូមិ មានប្រជាជនចូលរួមសរុបចំនួន ៩៥៥ ៥២៣ នាក់ (ស្រី ៥២៩ ៤៦២ នាក់) និងបានចែកសម្ភារៈអប់រំសុខភាព ដូចជាសន្លឹកបត់ ៧ ៧០០ សន្លឹក និង ផ្ទាំងសារអប់រំសុខភាព ១០ ០០០ ផ្ទាំង ដល់ខេត្តដែលប្រឈមហានិភ័យខ្ពស់នៃជំងឺ។
- **ការគ្រប់គ្រងភ្នាក់ងារចម្លង៖** បានបែងចែកថ្នាំបាណកឃាដ (អាបែត) ពីឃ្លាំងឱសថកណ្តាល ចំនួន ១៦០ តោន និងថ្នាំបាញ់មូស ចំនួន ៦ ០០០ លីត្រ ដល់មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- **ការអង្កេតតាមដានជំងឺ៖** សំណាកចំនួន ២១៣ ត្រូវបានប្រមូល ពីមន្ទីរពេទ្យខេត្តចំនួន ១៥ ដើម្បីពិនិត្យមើលប្រភេទសេរ៉ូទីប ក្នុងការអង្កេតតាមដានសេរ៉ូឡូជីនៃជំងឺគ្រុនឈាម និងបានចុះធ្វើការអង្កេតករណីស្លាប់ ៥៩ ករណី។
- **ការបណ្តុះបណ្តាល** ស្តីពីការអង្កេតតាមដានអេពីដេមីសាស្ត្រជំងឺគ្រុនឈាម ដល់បុគ្គលិកសុខាភិបាល ១០៩ នាក់ (ស្រី ២៩ នាក់) បណ្តុះបណ្តាលគ្រូបង្គោលស្តីពីការធ្វើរោគវិនិច្ឆ័យ ព្យាបាលថែទាំជំងឺគ្រុនឈាម ដល់គ្រូពេទ្យ បុគ្គលិកចំនួន ១១៦ នាក់ (ស្រី ៣៥ នាក់) បណ្តុះបណ្តាលស្តីការឆ្លើយតបការផ្ទុះរាតត្បាត និងការគ្រប់គ្រងភ្នាក់ងារចម្លងនៃជំងឺគ្រុនឈាម ដល់បុគ្គលិកសុខាភិបាល ៤៦ នាក់ (ស្រី ១៣ នាក់)។

**ខ. ជំងឺគ្រុនឈិក៖** ក្នុងឆ្នាំ២០២៥ (គិតត្រឹមថ្ងៃទី០២ ខែវិច្ឆិកា) អ្នកជំងឺគ្រុនឈីកមានចំនួន ៥ករណី (ស្រី ១ករណី) ស្មើនឹងអត្រាអាំងស៊ីដង់ ០,០៣ នាក់ ក្នុងចំណោមប្រជាជន ១០០ ០០០ នាក់។ ជំងឺគ្រុនឈីកកើតលើមនុស្សគ្រប់វ័យចាប់ពីអាយុ ៤ខែ រហូតដល់អាយុ ៧៤ឆ្នាំ ដែលក្នុងនោះ សមាមាត្រអ្នកជំងឺអាយុលើសពី ១៥ឆ្នាំ មានចំនួនជាង ៥៦% កុមារអាយុចន្លោះ ៥ ទៅ ១៥ឆ្នាំ មាន ៣៣% និងកុមារអាយុក្រោម៥ឆ្នាំមាន ១១%។ ក្នុងចំណោមមនុស្សធំ អ្នកជំងឺភេទស្រីមាន ៦១,៦០% និង អ្នកជំងឺភេទប្រុស ៣៨,៤០%។

**គ. ជំងឺរលាកថ្លើម៖** ក្នុងឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលផ្តល់សេវាជំងឺរលាកថ្លើមមានចំនួនសរុប ២៧៦ កន្លែង ក្នុងនោះ មន្ទីរពេទ្យបង្អែក ២១ និងមណ្ឌលសុខភាព ២៥៥ នៅក្នុងរាជធានី ខេត្តចំនួន ៨ (ខេត្តកំពង់ចាម សៀមរាប បាត់ដំបង កំពង់ឆ្នាំង តាកែវ ពោធិ៍សាត់ កំពត និងរាជធានីភ្នំពេញ)។ ការពិគ្រោះជំងឺក្រៅនៃជំងឺរលាកថ្លើមប្រភេទបេ និងប្រភេទ សេ ហើយបានធ្វើតេស្ត មានចំនួន ១៧៤ ៩៧៤ ករណី និងអ្នកជំងឺរលាកថ្លើមប្រភេទ បេ និងប្រភេទ សេ ដែលបានសម្រាកព្យាបាលមានចំនួន ៤ ០៩៣ ករណី (តារាង ២.១១.)។ ក្រសួងសុខាភិបាលកំពុងធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រស្តីពីការលុបបំបាត់ជំងឺរលាកថ្លើម និងគោលការណ៍ណែនាំស្តីពីការព្យាបាលជំងឺរលាកថ្លើម បេ និងសេ។

**តារាង ២.១១.** ករណីពិនិត្យពិគ្រោះ និងព្យាបាលជំងឺរលាកថ្លើម ពីឆ្នាំ២០២១-២០២៥

| សូចនាករ | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|
| **ជំងឺរលាកថ្លើមប្រភេទ សេ** | | | | | |
| ករណីពិនិត្យពិគ្រោះជំងឺបានធ្វើតេស្ត | 36,386 | 11,826 | 17,943 | 88,665 | 81,079 |
| អ្នកជំងឺមានលទ្ធផលតេស្តរហ័សវិជ្ជមាន | | | 1,053 | 3,573 | 2,541 |
| អ្នកជំងឺមានលទ្ធផលមេរោគវិជ្ជមាន | 2,067 | 420 | 397 | 1,669 | 1,051 |
| អ្នកជំងឺរលាកថ្លើមប្រភេទ សេ បានព្យាបាល | 1,982 | 278 | 472 | 1,590 | 1,002 |
| **ជំងឺរលាកថ្លើមប្រភេទ បេ** | | | | | |
| ករណីពិនិត្យពិគ្រោះជំងឺបានធ្វើតេស្ត | 284 | 257 | 1,165 | 94,378 | 93,895 |
| អ្នកជំងឺមានលទ្ធផលតេស្តរហ័សវិជ្ជមាន | | | 225 | 8,128 | 7,340 |
| អ្នកជំងឺមានលទ្ធផលមេរោគវិជ្ជមាន | 272 | 255 | 136 | 4,174 | 4,308 |
| អ្នកជំងឺរលាកថ្លើមប្រភេទ បេ បានព្យាបាល | 43 | 63 | 8 | 3,247 | 3,091 |

**ឃ. ជំងឺព្រូនឆ្លងតាមដី** (Soil-Transmitted Helminth) ដូចជា ព្រូនចង្កឺះ (Ascaris lumbricoides) ព្រូនរំពាត់សេះ (Trichuris trichiura) និងព្រូនទម្ពក់ (Hookworms) ឆ្លងមកមនុស្សតាមរយៈកង្វះអនាម័យ ដូចជាការបរិភោគចំណីអាហារ ទឹក បន្លែផ្លែឈើ ដែលមិនបានលាងស្អាតល្អ និងការដើរលើដីដោយជើងទទេ ជាដើម។ សព្វថ្ងៃនេះមានប្រជាជនប្រឈមជំងឺព្រូនឆ្លងតាមដី ប្រមាណជា ៧,៥លាននាក់។ ក្រុមងាយរងគ្រោះ ហើយ

មានផលវិបាកដល់សុខភាពជាងគេ គឺកុមារត្រៀមចូលសាលារៀន (អាយុ១២ខែ-៥៩ខែ) កុមារស្ថិតក្នុងវ័យសិក្សា (អាយុ៦ឆ្នាំ-១៤ឆ្នាំ) និងស្ត្រីស្ថិតក្នុងវ័យបន្តពូជ(អាយុ ១៥ឆ្នាំ-៤៩ឆ្នាំ)។ យោងតាមការសិក្សាស្រាវជ្រាវរកព្រូនឆ្លងតាមដី នៅឆ្នាំ២០២៥ លើប្រជាជនចំនួន ១៧១២ នាក់ នៅក្នុង ២០ភូមិ (៩ភូមិ នៅក្នុងខេត្តក្រចេះ និង១១ភូមិ នៅក្នុងខេត្តស្ទឹងត្រែង) បានបង្ហាញថា ប្រេវ៉ាឡង់នៃជំងឺព្រូនឆ្លងតាមដី មាន៥,៨% (វិជ្ជមាន ៩៩ នាក់ ក្នុងចំនួនប្រជាជនដែលបានអង្កេត)។

**ង. ជំងឺព្រូនស៊ីស្តូសូមីញ៉ាស៊ីស ឬជំងឺព្រូនធំពោះ** (Schistosomiasis mekongi) បាននិងកំពុងចម្លងដល់ប្រជាជនសរុបប្រមាណ១០ម៉ឺននាក់ ដែលរស់នៅក្នុងភូមិចំនួន ១១៤ តាមដង និងដៃទន្លេមេគង្គ ក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។ ជំងឺព្រូននេះ ឆ្លងតាមរយៈការប៉ះពាល់ផ្ទាល់នឹងទឹកទន្លេមេគង្គ ដូចជា ហែលទឹក បោកគក់ និងនេសាទត្រីជាដើម ដោយការជ្រៀតចូលតាមស្បែក នៃកូនដង្កូវព្រូន ដែលចេញពីសត្វខ្ចៅខ្លា (Neotricula aperta)។ ការផ្តល់ថ្នាំជាសមូហភាព ការអប់រំសុខភាព និងការលើកកម្ពស់អនាម័យ ក្នុងរយៈពេល៣០ឆ្នាំកន្លងមកនេះ បានធ្វើឱ្យប្រេវ៉ាឡង់នៃជំងឺព្រូនធំពោះ នៅក្នុង៤ភូមិ ដែលត្រូវបានតាមដានជាប្រចាំនៅក្នុងខេត្តក្រចេះ បានធ្លាក់ចុះពី ៧២% នៅឆ្នាំ១៩៩៥ មកនៅក្រោម១% នៅឆ្នាំ២០២៥ ក្នុង ២០ភូមិដែលប្រឈមហានិភ័យ ប្រេវ៉ាឡង់ព្រូនធំពោះ មាន០,៣% ។

**ច. ជំងឺហង់សិន(ជំងឺឃ្លង់)៖** កម្មវិធីជាតិកំចាត់រោគហង់សិននៅរក្សាការគ្របដណ្តប់នៃសេវាការស្រាវជ្រាវ និងព្យាបាលជំងឺហង់សិន នៅមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដោយសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ការពិនិត្យសុខភាពរកជំងឺហង់សិនលើប្រជាជន ៣៩ ១៦៨ នាក់ នៅក្នុងស្រុកប្រតិបត្តិ មង្គលបូរី បាទី ព្រៃកប្បាស អង្គរការ កោះអណ្តែត ស៊ីសន្ធរកណ្តាល ពារាំង បារាំ្ន ពាមរក៍ ពាមជរ ក្រុងព្រៃវែង រមាសហែក ស្វាយរៀង ស្វាយទាប កំពង់ស្ពឺ គងពិសី ឧត្តុង ភ្នំស្រួច បាត់ដំបង សំពៅលូន មោងឬស្សី បរិបូរណ៍ កំពង់ឆ្នាំង កំពង់ត្រឡាច សំពៅមាស ក្រវាញ ក្រគរ កំពង់ចាម-កំពង់សៀម ព្រៃឈរ កោះសូទិន ស្រីសន្ធរ ចំការលើ ស្ទឹងត្រង់ កងមាស អូរាំងឪ កំពង់ធំ និងស្ទោង។
- ការស្រាវជ្រាវករណីហង់សិនថ្មីបានរកឃើញលើប្រជាពលរដ្ឋ ៣១ នាក់ ក្នុងទូទាំងប្រទេស
- អត្រាព្យាបាលជាសះស្បើយនៃជំងឺហង់សិនរក្សាបានខ្ពស់រហូតដល់ ៩៨%
- ការព្យាបាលបង្ការការចម្លងជំងឺហង់សិនលើប្រជាជនចំនួន ៣ ៧៤៨ នាក់ នៅក្នុងស្រុកប្រតិបត្តិចំនួន ១៦ (មង្គលបូរី គងពិសី កំពង់ស្ពឺ ព្រៃកប្បាស អង្គរការ កោះអណ្តែត ស្រីសន្ធរ ពារាំង បារាំ្ន ពាមរក៍ ពាមជរ ក្រុងព្រៃវែង រមាសហែក ស្វាយទាប ឧត្តុង ភ្នំស្រួច និងអូរាំងឪ)។
- ការផ្សព្វផ្សាយអប់រំដល់ប្រជាជនបានចំនួន ១០៨ភូមិ និង ១០៨ មណ្ឌលសុខភាពចំនួន ១០៨ ក្នុងស្រុកប្រតិបត្តិ ៥៨ នៃរាជធានី ខេត្ត ២៥។
- ការបណ្តុះបណ្តាលអំពីការថែទាំដំបៅបាតជើងស្ពឹក ដោយសារជំងឺហង់សិនដល់ថ្នាក់មន្ទីរសុខាភិបាល និងមណ្ឌលសុខភាព នៅខេត្តបន្ទាយមានជ័យ ចំនួន ៦៦ នាក់។

## ២.៧. ការបង្ការ និងការគ្រប់គ្រងជំងឺមិនឆ្លង និងបញ្ហាសុខភាពចម្បងដទៃទៀត

(% បំរែបំរួលលទ្ធផលធៀបចំណុចដៅ)

| | លទ្ធផល | | | ចំណុចដៅ | %បំរែបំរួល |
|---|---|---|---|---|---|
| សូចនាករស្នូល | 2023 | 2024 | 2025 | 2025 | |
| 1. ភាគរយនៃអ្នកជំងឺអាយុ៤០ឆ្នាំឡើង មានជំងឺឡើងសម្ពាធឈាម បានទទួលការព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ ស្របតាមពិធីសារព្យាបាល | 24 | 29 | **30** | **31** | **-1** |
| 2. ភាគរយនៃអ្នកជំងឺអាយុ៤០ឆ្នាំឡើង មានជំងឺទឹកនោមផ្អែម ដែលបានទទួលការព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ ស្របតាមពិធីសារព្យាបាល | 25 | 40 | **35** | **45** | **-10** |
| 3. ភាគរយស្ត្រីអាយុ ៣០-៤៩ឆ្នាំ បានទទួលការពិនិត្យមាត់ស្បូនរកជំងឺមហារីកយ៉ាងតិចមួយដង (VIA) | 20.3* | 20.3 | **20.3** | **20** | **+0.3** |
| 4. អត្រាអ្នកជំងឺធ្លាក់ទឹកចិត្តបានទទួលការព្យាបាល (%) | 1.71<br>(9 947) | 5.0<br>(29 432) | **5.6 ****<br>**(34,303)** | **25** | **-19.4** |

* STEP Survey ** ទិន្នន័យគិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៥

### ២.៧.១. ការកាត់បន្ថយកត្តាហានិភ័យនៃជំងឺមិនឆ្លង

**ក. ការត្រួតពិនិត្យផលិតផលថ្នាំជក់៖** ក្នុងឆ្នាំ២០២៥ ការត្រួតពិនិត្យផលិតផលថ្នាំជក់ សម្រេចលទ្ធផលចម្បងៗ រួមមាន៖

- បោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់សម្រេចបាន ៩០,១% នៃគោលដៅផែនការ
- ពង្រឹងអនុវត្តអនុក្រឹត្យស្តីពីវិធានការហាមជក់ ឬបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ ឬទីសាធារណៈ៖ (១) ការដាក់សារព្រមាន ៥៥% លើកញ្ចប់ផលិតផលថ្នាំជក់ សម្រេចបាន ៩០,១% (២) វិធានការលើករណីល្មើសការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីដោយឧស្សាហករថ្នាំជក់នៅកន្លែងលក់រាយសម្រេចបាន ៥០% និង (៣) វិធានការហាមការជក់ ឬបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ ឬកន្លែងសាធារណៈសម្រេចបាន ៨៧%
- រៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីការអប់រំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ ២០២៧-២០៣១

- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្នុងការរៀបចំបទបញ្ញារាជរដ្ឋាភិបាល ស្តីពី វិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិក និងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា ដែលបានដាក់ចេញនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥
- សហការជាមួយក្រសួងមហាផ្ទៃ គណៈកម្មការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការរៀបចំពន្ធលើផលិតផលថ្នាំជក់ និងការគ្រប់គ្រងពាណិជ្ជកម្មលើផលិតផលថ្នាំជក់ខុសច្បាប់

**ខ. ការត្រួតពិនិត្យគ្រឿងស្រវឹង៖** បែបបទនីតិវិធី និងវិធានក្នុងការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង បានកំណត់ទីតាំងដែលមិនអនុញ្ញាតឱ្យផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង នៅចម្ងាយតិចជាង ២០០ម៉ែត្រ ជុំវិញបរិវេណគ្រឹះស្ថានសិក្សា គ្រឹះស្ថានសុខាភិបាល គ្រឹះស្ថានសាសនា រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ អាកាសយានដ្ឋានអន្តរជាតិ និងការដាក់សារអប់រំលើរាល់ការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង និងគ្រប់គ្រងលើខ្លឹមសារ សកម្មភាព និងមធ្យោបាយនៃការផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង។ ក្នុងឆ្នាំ២០២៥ ក្រសួងសុខាភិបាលបានពិនិត្យលិខិតអនុញ្ញាតផ្សាយពាណិជ្ជកម្មផលិតផលគ្រឿងស្រវឹង ដែលទទួលបានពី ក.គ.ផ.ស បានចំនួន ៦៤ លិខិត និងបានរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពីផលប៉ះពាល់នៃការប្រើប្រាស់ផលិផលគ្រឿងស្រវឹងលើសុខភាព សេដ្ឋកិច្ច និងសង្គម មានសិក្ខាកាមចូលរួមសរុប ២៥រូប។

### ២.៧.២. ជំងឺទឹកនោមផ្អែម

**ក. ករណីឈឺ និងករណីស្លាប់៖** ក្នុងឆ្នាំ២០២៥ ករណីថ្មីជំងឺទឹកនោមផ្អែមដែលបានមកពិនិត្យព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ មានចំនួន ២៩២ ១៩៧ ករណី (ក្នុងនោះ អ្នកជំងឺទឹកនោមផ្អែមប្រភេទ១ មានចំនួន ១៧ ៤៩៤ ករណី និង ប្រភេទ២ មានចំនួន ២៧៤ ៦៥៣ ករណី និងលើស្ត្រីមានគភ៌ ៥០ ករណី) ដោយកើនឡើង ២៦,៨% ធៀបនឹងឆ្នាំ២០២៤។ រីឯ អ្នកជំងឺសម្រាកពេទ្យមានចំនួន ១៨ ៤២៩ នាក់ (ក្នុងនោះអ្នកជំងឺទឹកនោមផ្អែមប្រភេទ១ មានចំនួន ១ ៣៥៤ នាក់ ស្រី ៧៩០ នាក់) និងប្រភេទ២ មានចំនួន ១៧ ០៧១ នាក់ ស្រី ១០ ៧៤៤ នាក់) និងស្ត្រីមានគភ៌ ៥ នាក់)។

### ២.៧.៣. ជំងឺឡើងសម្ពាធឈាម និងជំងឺបេះដូងសរសៃឈាម

**ក. ករណីឈឺ និងករណីស្លាប់៖** ករណីថ្មីជំងឺឡើងសម្ពាធឈាមដែលបានមកពិនិត្យព្យាបាល នៅមូលដ្ឋានសុខាភិបាលសាធារណៈ មានចំនួន ៤៥១ ០០៩ ករណី (ក្នុងនោះ ជំងឺឡើងសម្ពាធឈាមដំបូងចំនួន ៣២៧ ០៣៤ ករណី និងជំងឺឡើងសម្ពាធឈាមមានផលវិបាកផ្សេងៗចំនួន ១២៣ ៩៧៥ ករណី) ដោយកើនឡើង ១២,២០% ធៀបនឹងឆ្នាំ២០២៤។ រីឯ អ្នកជំងឺសម្រាកព្យាបាលមានចំនួន ៤១ ៤៦៣ ករណី (ក្នុងនោះ អ្នកជំងឺឡើងសម្ពាធឈាមដំបូងចំនួន ២០ ៥៨៩ ករណី និងជំងឺឡើងសម្ពាធឈាមមានផលវិបាកផ្សេងៗចំនួន ២០ ៨៧៥ ករណី) ដោយកើនឡើង ១៩,១៧% ធៀបនឹងឆ្នាំ២០២៤។ ដោយឡែក អ្នកជំងឺបេះដូងសរសៃឈាមដែលបានមកពិនិត្យជំងឺមានចំនួន ១៥ ៣៥៧ ករណី និងសម្រាកព្យាបាលចំនួន ២៥ ៤៨១ នាក់ ក្នុងនោះអ្នកជំងឺ ១ ០៩១ នាក់ បានទទួលមរណភាព (តារាង ២.១២.)។

**តារាង ២.១២.** ករណីពិនិត្យជំងឺបេះដូងសរសៃឈាម និងសម្រាកពេទ្យ ឆ្នាំ២០២៤-២០២៥

| ប្រភេទជំងឺ | 2024 | | | 2025 | | |
|---|---|---|---|---|---|---|
| | ពិគ្រោះជំងឺ (ចំនួនករណី) | សម្រាកពេទ្យ (នាក់) | ស្លាប់ (នាក់) | ពិគ្រោះជំងឺ (ចំនួនករណី) | សម្រាកពេទ្យ (នាក់) | ស្លាប់ (នាក់) |
| 1. ជំងឺខ្សោយបេះដូង | 8,087 | 5,214 | 347 | 8,162 | 7,670 | 372 |
| 2. ចុកទ្រូង | 1,898 | 4,129 | 197 | 2,371 | 3,922 | 216 |
| 3. ស្លាប់សាច់បេះដូងស្រួចស្រាល់ | 388 | 1,978 | 147 | 460 | 1,475 | 120 |
| 4. ស្ទះសរសៃឈាមខួរក្បាល | 1,025 | 8,174 | 271 | 1,133 | 9,418 | 240 |
| 5. សរសៃឈាមខួរក្បាលមានផលវិបាក | 2,318 | 2,723 | 112 | 3,231 | 2,996 | 143 |

### ២.៧.៤. ជំងឺមហារីក

ផែនការជាតិប្រយុទ្ធនឹងជំងឺមហារីក ២០២៥-២០៣០ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ នីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការពិនិត្យព្យាបាល និងគ្រប់គ្រងជំងឺមហារីកមាត់ស្បូន ត្រូវបានដាក់ឱ្យអនុវត្ត នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ ហើយប្រព័ន្ធកត់ត្រាអេឡិចត្រូនិកបាននិងនិងកំពុងអភិវឌ្ឍ។ ក្នុងឆ្នាំ២០២៥ ចំនួនអ្នកជំងឺមហារីកទាំងពីរភេទមកទទួលសេវាព្យាបាលនៅមន្ទីរពេទ្យ មានចំនួន ៣៥ ៩២១ នាក់ ឬកើនឡើង ១៣,៩% បើធៀបនឹងឆ្នាំ២០២៤ ដែលមានចំនួន ៣១ ៥១៨ នាក់ (ស្ត្រី ១៩ ៣៨២ នាក់)។ អ្នកជំងឺ ១៥៥ នាក់ បានទទួលមរណភាព នៅក្នុងឆ្នាំ២០២៥។ ជំងឺមហារីក ១០ ប្រភេទនាំមុខគេ ក្នុងចំណោមអ្នកជំងឺមហារីកសម្រាកព្យាបាលខាងលើគឺ៖ (១).មហារីកដោះ ២២,៩៥% (២).មហារីកមាត់ស្បូន ៨,៩៨% (៣).មហារីកពោះវៀនធំ ៨,៤៤% (៤).មហារីកថ្លើម ៥,៩% (៥).មហារីកសួតនិងទងសួត ៥,៩១% (៦).មហារីកអូវែ ៣,៥៩% (៧).មហារីកចុងពោះវៀនធំ ៣,០៨% (៨).មហារីករន្ធគូថ ២.៣៧% (៩).មហារីកក្រពះ ២.០១% និង(១០). មហារីកថង់ប្រម៉ាត់ ១,៧៣% និងមហារីកផ្សេងៗទៀត ៣៥,០៦%។

**មហារីកសុដន/មហារីកមាត់ស្បូន៖** ក្នុងឆ្នាំ២០២៥ ស្ត្រីចំនួន ៣៨០ ១៤៨ នាក់ បានទទួលការអប់រំពីជំងឺមហារីកដោះ និងរៀនស្ទាបរកដុំដោះដោយខ្លួនឯង ក្នុងនោះស្ត្រីចំនួន ៥ ២៣៨ នាក់ ត្រូវបានរកឃើញមានដុំដោះ (តារាង ២.១៣)។ រីឯស្ត្រីដែលបានធ្វើតេស្តរកភាពមិនប្រក្រតីនៃកោសិកាមាត់ស្បូន (Visual Inspection with Acetic Acid) មានចំនួន ៣០ ៤៥៦ នាក់ ក្នុងនោះមានស្ត្រីអាយុក្រោម៣០ឆ្នាំ ចំនួន ៤ ៦៨៧ នាក់ និងស្ត្រីអាយុ ៣០ ដល់ ៤៩ឆ្នាំ ចំនួន ២៥ ៧៦៩ នាក់។ ក្នុងចំណោមស្ត្រីដែលបានធ្វើតេស្តទាំងនោះ ស្ត្រីចំនួន ៤៧៤ នាក់មានលទ្ធផលតេស្តវិជ្ជមាន (ស្ត្រីអាយុក្រោម៣០ឆ្នាំ ៦៤ នាក់ និងស្ត្រីអាយុ ៣០ ដល់ ៤៩ឆ្នាំ ៤១០ នាក់) និងស្ត្រីចំនួន ១៩៥ នាក់ ត្រូវបានសង្ស័យមានមហារីកមាត់ស្បូន(ស្ត្រីអាយុក្រោម៣០ឆ្នាំ ចំនួន ២៩ នាក់ និងស្ត្រីអាយុពី ៣០ ដល់ ៤៩ឆ្នាំ ចំនួន ១៥៧ នាក់) ត្រូវបានបញ្ជូនទៅមន្ទីរពេទ្យថ្នាក់ជាតិដើម្បីធ្វើរោគវិនិច្ឆ័យបញ្ជាក់ និងទទួលការព្យាបាល (តារាង ២.១៤.)។

**តារាង ២.១៣.** ការអប់រំពីសុខភាពដោះស្ត្រី និងការពិនិត្យ/ស្ទាបដោះដោយខ្លួនឯង ឆ្នាំ២០២១-២០២៥

| ឆ្នាំ | ចំនួនស្ត្រីបានទទួលការអប់រំអំពីសុខភាពដោះ (នាក់) | ចំនួនស្ត្រីដែលបានរកឃើញបញ្ហា | | បញ្ជូនទៅ |
|---|---|---|---|---|
| | | ដុំដោះ | ផ្សេងៗទៀត | |
| **2021** | 378,296 | 2,260 | 1,162 | 130 |
| **2022** | 405,406 | 3,200 | 1,075 | 111 |
| **2023** | 462,278 | 3,728 | 966 | 122 |
| **2024** | 455,440 | 7,135 | 1,158 | 105 |
| **2025** | **380,148** | **5,238** | **988** | **228** |

**តារាង ២.១៤.** ចំនួនស្ត្រីដែលបានពិនិត្យស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូនឆ្នាំ២០២៤-២០២៥

| ឆ្នាំ | ចំនួនស្ត្រីអាយុក្រោម 30ឆ្នាំ ដែលបានពិនិត្យស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូន | | | | ចំនួនស្ត្រីអាយុ 30-49ឆ្នាំ ដែលបានពិនិត្យស្រាវជ្រាវរកជំងឺមហារីកមាត់ស្បូន | | | |
|---|---|---|---|---|---|---|---|---|
| | ស្ត្រីបានធ្វើតេស្ត VIA | ចំនួនស្ត្រីរកឃើញ | | | ចំនួនស្ត្រីបានធ្វើតេស្ត VIA | ចំនួនស្ត្រីរកឃើញ | | |
| | | VIA (+) | សង្ស័យមហារីក | បញ្ជូន | | VIA (+) | សង្ស័យមហារីក | បញ្ជូន |
| **2024** | 6,112 | 66 | 23 | 30 | 35,960 | 566 | 150 | 251 |
| **2025** | 4,687 | 64 | 29 | 29 | 25,769 | 410 | 166 | 157 |

## ២.៧.៦. ជំងឺផ្លូវចិត្ត និងការញៀនគ្រឿងញៀន

**ក. ករណីឈឺ និងករណីស្លាប់៖** ក្នុងឆ្នាំ២០២៥ ករណីពិនិត្យពិគ្រោះនិងព្យាបាលជំងឺផ្លូវចិត្តមានចំនួនសរុប ៣៨៩ ៥៥៣ ករណី (ស្រី ២០៩ ៥៣៤ ករណី) ដោយកើនឡើង ៣៧,៨៣% ធៀបនឹងឆ្នាំ២០២៤ ដែលមានចំនួន ២៨២ ៦១៥ ករណី (ស្រី ១៦៣ ៣៨២ ករណី) និងអ្នកញៀនគ្រឿងញៀនបានទទួលសេវាពិនិត្យពិគ្រោះនិងព្យាបាលចំនួន ៧ ៤២៨ ករណី ក្នុងនោះ ៥៦៥ ករណី លើស្ត្រី (តារាង ២.១៥ និងក្រាហ្វិក ២.២៣.)។ គួរកត់សម្គាល់ថា មិនមានការរាយការណ៍ពីករណីស្លាប់ នៃអ្នកជំងឺផ្លូវចិត្ត និងការញៀនគ្រឿងញៀនទេ។ អ្នកជំងឺធ្លាក់ទឹកចិត្តបានទទួលការពិនិត្យព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ ៥៥៦ កន្លែង មានចំនួន ៣៤ ៣០៣ ករណី។

**តារាង ២.១៥.** ចំនួនអ្នកជំងឺផ្លូវចិត្តទទួលសេវាពិនិត្យ និងព្យាបាល ឆ្នាំ២០២៥ (គិតត្រឹមខែវិច្ឆិកា)

| មូលដ្ឋានសុខាភិបាល | សុខភាពផ្លូវចិត្ត | | គ្រឿងញៀន | |
|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី |
| **ពិគ្រោះជំងឺ** | **378,355** | **209,534** | **7,428** | **565** |
| ▪ មណ្ឌលសុខភាព | 38,996 | 25,798 | 2,265 | 198 |
| ▪ មន្ទីរពេទ្យ | 339,359 | 183,736 | 5,163 | 367 |
| **សម្រាកពេទ្យ** | **11,198** | **7,434** | **-** | **-** |
| ▪ មន្ទីរពេទ្យ | 11,198 | 7,434 | - | - |
| **សរុបរួម** | **389,553** | **216,968** | **7,428** | **565** |

**ក្រាហ្វិក ២.២៣.** ចំនួនអ្នកជំងឺផ្លូវចិត្តទទួលសេវាពិនិត្យពិគ្រោះ និងព្យាបាលឆ្នាំ២០២៣-២០២៥




**ខ. ការគ្រប់ដណ្តប់ និងការកែលម្អគុណភាពសេវា៖** ក្នុងឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលសាធារណៈចំនួន ៥៥៦ កន្លែង មានផ្តល់សេវាព្យាបាលជំងឺផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន ដោយកើនឡើងពី ៤៥៨ កន្លែង ក្នុងឆ្នាំ២០២៤។ នាយកដ្ឋានសុខភាពផ្លូវចិត្តនិងបំពានគ្រឿងញៀន បានផ្តល់ការបណ្តុះបណ្តាលបង្កើនចំណេះដឹង និងសមត្ថភាពបច្ចេក ទេសទាក់ទងការផ្តល់សេវាសុខភាពផ្លូវចិត្ត និងភាពញៀនគ្រឿងញៀន ដល់គ្រូពេទ្យ និងគិលានុបដ្ឋាក នៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ដោយផ្តោតលើប្រធានបទសំខាន់ៗ ស្តីពី៖

- សុខភាពផ្លូវចិត្តនិងភាពញៀនគ្រឿងញៀន ចំនួន ១៧៤ នាក់ និងការគ្រប់គ្រងវិបត្តិបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀនលើសកម្រិត ចំនួន ៤៩ នាក់

- ការកំណត់និងការឆ្លើយតបលើជនរងគ្រោះដែលមានបញ្ហាផ្លូវចិត្ត និងបញ្ហាផ្លូវចិត្តសង្គមចំនួន ១៦០ នាក់ (ស្រី ៩២ នាក់) និងការគាំទ្រចិត្តសង្គម ចំនួន ១០៥ នាក់ (ស្រី ២៣ នាក់)
- ការព្យាបាលផ្លូវចិត្តតាមបែប អ៊ី. អឹម. ឌី. អា កម្រិត១ និងការថែទាំបឋមសម្រាប់ជនរងគ្រោះដោយការប៉ះទង្គិចផ្លូវចិត្ត ចំនួន ១០២ នាក់ (ស្រី ៤៨ នាក់)។
- អភិវឌ្ឍគោលការណ៍ណែនាំប្រតិបត្តិស្តីពីការអន្តរាគមន៍រួមបញ្ចូលសុខភាពផ្លូវចិត្តគ្រឿងញៀន និងមេរោគអេដស៍/ជំងឺអេដស៍ សម្រាប់ក្រុមប្រជាជនងាយរងគ្រោះ

**គ. ការអប់រំលើកកម្ពស់សុខភាពផ្លូវចិត្ត ដែលបានអនុវត្តក្នុងឆ្នាំ២០២៥ រួមមាន៖** ការកែសម្រួល និងការផលិតសារអប់រំស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការថែទាំផ្លូវចិត្តសង្គម ចំនួន ២០មុខ ការផ្សព្វផ្សាយពីសុខភាពផ្លូវចិត្ត និងគ្រឿងញៀនជាប្រចាំតាមបណ្តាញទំនាក់ទំនងសង្គម ការបណ្តុះបណ្តាលស្តីពីការពង្រឹងគុណភាពនៃការចុះអប់រំផ្ទាល់ដល់សហគមន៍ ក្នុងកម្មវិធីកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន។

**ឃ. កិច្ចសហការពហុវិស័យ៖** សកម្មភាពសំខាន់ៗ ដែលបានអនុវត្តក្នុងឆ្នាំ២០២៥ រួមមាន៖ ការពិគ្រោះយោបល់លើសេចក្តីព្រាងផែនការសកម្មភាពពហុវិស័យសម្រាប់ការបង្ការការធ្វើអត្តឃាតនៅកម្ពុជាដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការដៃគូ និងរដ្ឋបាលរាជធានី ខេត្តទាំង២៥ ការរៀបចំសិក្ខាសាលាស្តីពីសុខភាពក្នុងពន្ធនាគារ ដោយមានការចូលរួមពីអគ្គនាយកដ្ឋានពន្ធនាគារ និងអង្គការដៃគូ ការរៀបចំផែនការអន្តរាគមន៍សុខភាពផ្លូវចិត្តដើម្បីឆ្លើយតបនឹងគ្រោះអាសន្ននៅតាមព្រំដែន និងការបណ្តុះបណ្តាលស្តីពីការរាយការណ៍ព័ត៌មានអត្តឃាត ដោយមានការទទួលខុសត្រូវ សម្រាប់អ្នកប្រកបវិជ្ជាជីវៈសារព័ត៌មាន ដែលមានអ្នកចូលរួមចំនួន ១៧០ នាក់។

### ២.៧.៧. បញ្ហាសុខភាពចម្បងដទៃទៀត

**ក. ជំងឺចក្ខុរោគ៖** អត្រាវះកាត់បាយភ្នែកបានកើនឡើង ៤,២៤% គឺពី ២ ៥៦៨ ករណី ក្នុងចំណោមប្រជាជន ១លាន នាក់ នៅឆ្នាំ២០២៤ មក ២ ៦៧៧ ករណី នៅឆ្នាំ២០២៥។ ករណីពិនិត្យជំងឺភ្នែកទូទៅគ្រប់អាយុ បានកើនឡើង ៧,៩២% គឺពី ៥៩៤ ៣២២ ករណី នៅឆ្នាំ២០២៤ ទៅ ៦៤១ ៣៧១ ករណី នៅឆ្នាំ២០២៥។ ចំណែកការវះកាត់ភ្នែកសរុបបានកើនឡើង ៣,១៥% គឺពី ៦៥ ២៩៤ ករណី នៅឆ្នាំ២០២៤ ទៅ ៦៧ ៣៥២ ករណី នៅឆ្នាំ២០២៥ (តារាង ២.១៦.)។

ក្នុងឆ្នាំ២០២៥ កម្មវិធីជាតិសុខភាពភ្នែកចុះពិនិត្យ ភ្នែកនៅតាមសហគមន៍ សិស្សសាលា និងរោងចក្របានចំនួន ៣០០ ៨៩៨ នាក់ និងចែកវ៉ែនតាចំនួន ៣៣ ១០៧ វ៉ែនតា ព្រមទាំងបានបណ្តុះបណ្តាលចក្ខុសាស្ត្រមូលដ្ឋាន រយៈពេល ៣ខែ ដល់វេជ្ជបណ្ឌិតទូទៅចំនួន ៦រូប និងបណ្តុះបណ្តាលចក្ខុមាត្រការី រយៈពេល៦ខែបានចំនួន ២៤រូប និងបណ្តុះបណ្តាលគ្រូស្តីពីការវាស់ គំហើញចំនួន ៦៦៤ នាក់។ កម្មវិធីជាតិសុខភាពភ្នែក និងអង្គការដៃគូអភិវឌ្ឍន៍សុខភាពភ្នែក បានបង្កើតមណ្ឌលថែទាំភ្នែកថ្មីចំនួន៧ និងពង្រឹងមណ្ឌលថែទាំភ្នែកដែលមានស្រាប់ចំនួន ៤ ដោយបានបំពាក់សម្ភារបរិក្ខារ និងវ៉ែនតា សម្រាប់ដំណើរការ។ មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី ខេត្តបាននិងកំពុងរៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការគ្រប់គ្រង និងបង្ការភាពពិការភ្នែក ក្នុងនោះផែនទីបង្ហាញផ្លូវរបស់ខេត្តចំនួន ៩ ត្រូវបានដាក់ឱ្យអនុវត្ត និងខេត្ត៥ផ្សេងទៀតនឹងត្រូវបានបញ្ចប់នៅឆ្នាំ២០២៦។

**តារាង ២.១៦.** ទិន្នន័យពិនិត្យព្យាបាលជំងឺភ្នែក ឆ្នាំ២០២២-២០២៥

| សូចនាករ | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|
| ករណីពិគ្រោះពិនិត្យជំងឺភ្នែកទូទៅ | 736,429 | 609,764 | 595,322 | 641,371 |
| ករណីវះកាត់ភ្នែកសរុប | 63,420 | 63,920 | 65 294 | 67 352 |
| អ្នកជំងឺវះកាត់បាយភ្នែក | 34,344 | 39,172 | 41,631 | 45,512 |
| ករណីវះកាត់បាយភ្នែកក្នុងប្រជាជន១លាននាក់ | 2,147 | 2,304 | 2,568 | 2,677 |

**ខ. សុខភាពមាត់-ធ្មេញ៖** ក្នុងឆ្នាំ២០២៥ អន្តរាគមន៍សុខភាពមាត់-ធ្មេញ សម្រេចបានលទ្ធផលដូចខាងក្រោម៖

- បានអប់រំផ្សព្វផ្សាយ លើកកម្ពស់សុខភាពមាត់ធ្មេញ ដល់កុមារ និងគ្រូអនាម័យបង្គោល តាមសាលាបឋមសិក្សា និងសហគមន៍ សាលាចំនួន ១៣០ សរុបសិស្សចំនួន ៤៣ ២៦៣ នាក់ (សិស្សស្រី ២១ ១៥០ នាក់) និងលោកគ្រូអ្នកគ្រូចំនួន ១ ១៤៧ នាក់ (អ្នកគ្រូ ៤៦១ នាក់) ដោយបានសហការជាមួយអង្គការដៃគូ។
- មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកទូទាំងប្រទេស បានពិនិត្យ និងព្យាបាលជំងឺមាត់-ធ្មេញ បានចំនួន ១៤៣ ៥៧០ ករណី។

### គ. របួស និងគ្រោះថ្នាក់

ក្នុងឆ្នាំ២០២៥ ជនរងគ្រោះដោយរបួស ឬគ្រោះថ្នាក់ផ្សេងៗ បានសម្រាកព្យាបាលមានចំនួន ៧៤ ៦៥៤ ករណី (ស្លាប់ ៣៦១ នាក់) ក្នុងនោះរបួសដោយគ្រោះថ្នាក់មានប៉ះទង្គិចក្បាល ២០ ៦៩៦ ករណី របួសដោយគ្មានប៉ះទង្គិចក្បាល ចំនួន ២៩ ៤៤២ ករណី របួសបើកមុខផ្ទៃកពោះ ចំនួន ៦០២ ករណី និងរបួសផ្សេងៗក្រៅពីគ្រោះថ្នាក់ចរាចរណ៍ និងគ្រាប់មីន ចំនួន ១៨ ៤៨៦ ករណី ពស់ចឹកចំនួន ៥ ៤២៨ ករណី (តារាង ២.១៧)។

**តារាង ២.១៧.** ស្ថិតិរបួសនិងគ្រោះថ្នាក់ដែលបានសម្រាកព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ

| ប្រភេទគ្រោះថ្នាក់ | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|
| របួសដោយគ្រោះថ្នាក់មានប៉ះទង្គិចក្បាល | 12,166 | 14,079 | 16,639 | 16,974 | 20,696 |
| របួសដោយគ្រោះថ្នាក់ចរាចរណ៍ (គ្មានប៉ះទង្គិចក្បាល) | 19,183 | 22,455 | 27,227 | 25,535 | 29,442 |
| របួសផ្សេងៗ (ក្រៅពីគ្រោះថ្នាក់ចរាចរណ៍និងគ្រាប់មីន) | 13,826 | 14,366 | 16,559 | 15,828 | 18,486 |
| របួសបើកមុខផ្ទៃកពោះ | - | - | - | 438 | 602 |
| ពស់ចឹក | - | - | - | 5,422 | 5,428 |

# ៣ គុណភាព និងសុវត្ថិភាព នៃសេវាថែទាំសុខភាព





៣.១. ការគ្រប់គ្រងរំហូរអ្នកជំងឺ

៣.២. សុវត្ថិភាពអ្នកជំងឺ និងការកាត់បន្ថយហានិភ័យ

៣.៣. ការថែទាំព្យាបាលអ្នកជំងឺ

៣.៤. ការកែលម្អគុណភាពសេវា

# ៣. គុណភាព និងសុវត្ថិភាពនៃសេវាថែទាំសុខភាព

## គោលដៅ

« ជានាសេវាថែទាំសុខភាពដែលបានផ្តល់ដោយមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន មានអនុលោមភាពស្របតាមស្តង់ដាគ្លីនិក ព្រមទាំងបង្កើនភាពពេញចិត្តរបស់អ្នកជំងឺ និងអតិថិជន » សំដៅឆ្លើយតបនឹងការរំពឹងទុកនាពេលបច្ចុប្បន្ន និងរក្សាចីរភាពឧត្តមានុវត្តន៍គុណភាពសម្រាប់ពេលអនាគត តាមរយៈការផ្លាស់ប្តូរជាយុទ្ធសាស្ត្រពីការថែទាំសុខភាពផ្តោតលើបរិមាណ ទៅការថែទាំសុខភាពផ្តោតលើតម្លៃប្រាក់ចំណាយ *(ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០២៥-២០៣៤)*។

| សូចនាករគន្លឹះ | លទ្ធផល 2023 | លទ្ធផល 2024 | លទ្ធផល 2025 | ចំណុចដៅ 2025 |
|---|---|---|---|---|
| **1.** មូលដ្ឋានសុខាភិបាលទទួលពិន្ទុគុណភាពលើស ៦០% (ចំនួន/ភាគរយ) | | | | |
| ▪ មណ្ឌលសុខភាព | 0.00/00 | 24/1.86 | **580/44.55** | **23** |
| ▪ មន្ទីរពេទ្យបង្អែកកម្រិត១ | 0.00/00 | 9/15.25 | **49/80.33** | **50** |
| ▪ មន្ទីរពេទ្យបង្អែកកម្រិត២ | 0.00/00 | 6/15.79 | **29/76.32** | **65** |
| ▪ មន្ទីរពេទ្យបង្អែកកម្រិត៣ | 0.00/00 | 12/54.55 | **21/95.45** | **85** |
| **2.** ពិន្ទុនៃការពេញចិត្តរបស់អ្នកជំងឺ/គ្រួសារ/អតិថិជន (%) | 75 | 80 | | **81** |
| ▪ មណ្ឌលសុខភាព | | | **86** | |
| ▪ មន្ទីរពេទ្យបង្អែកគ្រប់កម្រិត | | | **83** | |
| **3.** អត្រាស្លាប់នៅមន្ទីរពេទ្យ (%) | 0.70 | 0.56 | **0.48** | **<1** |
| **4.** អត្រាស្លាប់ក្នុងអំឡុង៤៨ម៉ោងក្រោយការវះកាត់ (%) | 0.01 | 0.01 | **0.01** | |
| **5.** រយៈពេលមធ្យមនៃការសម្រាកព្យាបាល (ចំនួនថ្ងៃ) | 4.37 | 4.11 | **3.84** | **5** |

## ៣.១. ការគ្រប់គ្រងហានិភ័យអ្នកជំងឺ

ក្នុងឆ្នាំ២០២៥ ក្រសួងសុខាភិបាលបានសហការជាមួយក្រសួងមុខងារសាធារណៈ រៀបចំវគ្គបណ្តុះបណ្តាលស្តីពី បរិវត្តកម្មនៃការគ្រប់គ្រង និងការផ្តល់សេវានៃផ្នែកជួរមុខរបស់មន្ទីរពេទ្យបង្អែក ដល់មន្ត្រីគ្រប់គ្រង និងមន្ត្រីផ្តល់សេវាជួរមុខនៃមន្ទីរពេទ្យបង្អែករាជធានី ខេត្តចំនួន ៥០រូប រយៈពេល៤ថ្ងៃ។ ក្នុងវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមទាំង ៥០រូប បានទៅទស្សនកិច្ចសិក្សាស្តីពី ការរៀបចំ និងដំណើរការនៃការគ្រប់គ្រង និងការផ្តល់សេវានៃផ្នែកជួរមុខរបស់មន្ទីរពេទ្យបង្អែក នៅមន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យអរៀនជា និងមន្ទីរពេទ្យជប៉ុនសាន់រ៉ាយស៍ភ្នំពេញ។

## ៣.២. សុវត្ថិភាពអ្នកជំងឺ និងការកាត់បន្ថយហានិភ័យ

លើកកម្ពស់សុវត្ថិភាពអ្នកជំងឺ និងអ្នកផ្តល់សេវា តាមរយៈការបង្ការ និងកាត់បន្ថយគ្រោះថ្នាក់ដែលអាចជៀសវាងបាន នៅក្នុងបែបបទនៃការផ្តល់សេវាថែទាំសុខភាព នឹងរួមចំណែកដល់ការកែលម្អគុណភាពសេវា និងលទ្ធផលសុខភាពអ្នកជំងឺ។

**ក. ការបង្ការការចម្លងរោគ និងការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ ក្នុងមូលដ្ឋានសុខាភិបាល៖** ក្នុងឆ្នាំ២០២៥ សកម្មភាពសំខាន់ៗ ដែលបានអនុវត្តដើម្បីពង្រឹងការបង្ការ និងការឆ្លងរោគនៅក្នុងមូលដ្ឋានសុខាភិបាល រួមមាន៖

- វាយតម្លៃការគ្រប់គ្រងសំណល់ពីការផ្តល់សេវាថែទាំសុខភាពនៅមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យឯកជន និងមណ្ឌលសុខភាព សរុបចំនួន ៣០ កន្លែង និងការពិភាក្សារៀបចំផែនទីបង្ហាញផ្លូវស្តីពីការគ្រប់គ្រងសំណល់ពីការផ្តល់សេវាថែទាំសុខភាព ។
- ផ្តត់ផ្គង់ឧបករណ៍បច្ចេកវិទ្យាចម្រុះសម្រាប់បំផ្លាញសំណល់ (incinerator, autoclave) ដល់មន្ទីរពេទ្យបង្អែកខេត្ត និងស្រុក ក្នុងនោះមាន ឡដុតសំណល់ឆ្លងរោគ ចំនួន ២៩ គ្រឿង(ជំនួយប្រទេសជប៉ុន) មីក្រូវេវប្រព្រឹត្តកម្មសំណល់ឆ្លងរោគ(Sterilware) ៤ គ្រឿង (ជំនួយអង្គការយូនីសេហ្វ) ដល់មន្ទីរពេទ្យគន្ធបុប្ផា មន្ទីរពេទ្យខេត្តសៀមរាប មន្ទីរពេទ្យបាត់ដំបង និង មន្ទីរពេទ្យខេត្តកោះកុង។
- បណ្តុះបណ្តាលបុគ្គលិកសុខាភិបាល ១៥០ នាក់ ស្តីអំពីការគ្រប់គ្រងសំណល់គ្រប់ប្រភេទ។

**ខ. ទឹកស្អាត និងអនាម័យ (WASH/Water, Sanitation and Hygiene)៖** សកម្មភាពសំខាន់ៗ ដែលបានអនុវត្ត រួមមាន៖

- បង្កើតស្តង់ដាបច្ចេកទេស WASH សម្រាប់មន្ទីរពេទ្យ ស្របតាមគោលការណ៍ណែនាំស្តីពីទឹកស្អាត និងអនាម័យ ក្នុងមូលដ្ឋានសុខាភិបាល។
- បណ្តុះបណ្តាលគ្រូបង្គោល WASH ចំនួន ៣០ នាក់ និងបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ឧបករណ៍វាយតម្លៃទឹកស្អាត និងអនាម័យ នៅមន្ទីរពេទ្យបង្អែកបរកែវ គីរីវង្ស ស្នួល និងព្រះវិហារ។
- សាងសង់ប្រព័ន្ធចម្រោះ (អាងសុិបទីច) នៅក្នុងមន្ទីរពេទ្យស្នួល មន្ទីរពេទ្យបរកែវ និងមន្ទីរពេទ្យគិរីវង់។

- រៀបចំស្តង់ដាបង្គន់អនាម័យនៅមណ្ឌលសុខភាព រួមជាមួយ វីដេអូ 3D ស្តីពីគំនូសប្លង់បង្គន់ អនាម័យសម្រាប់មណ្ឌលសុខភាព។

## ៣.៣. ការបញ្ជូនអ្នកជំងឺ

ការបញ្ជូនករណីថ្មីនៃពិគ្រោះជំងឺក្រៅ ពីមូលដ្ឋានសុខាភិបាលសាធារណៈថ្នាក់ទាប ទៅមូលដ្ឋានសុខាភិបាលសាធារណៈថ្នាក់ខ្ពស់ បានកើនឡើងពី ២ ៩០៤ ៨៨៩ ករណី នៅឆ្នាំ២០២៤ ទៅ ៣ ៥០៤ ០៣៦ ករណី នៅឆ្នាំ២០២៥ ឬកើន ២០,១៣% ក្នុងនោះ ២,៨៨% ប៉ុណ្ណោះមានលិខិតបញ្ជូន ខណៈដែល ៩៧,១២% ទៀតអ្នកជំងឺ ឬប្រជាជនដែលមានបញ្ហាសុខភាពទៅយកសេវា នៅមន្ទីរពេទ្យ ដោយមិនបានមកមណ្ឌលសុខភាព ឬមន្ទីរពេទ្យថ្នាក់ទាប នៅពេលដំបូង (តារាង ៣.១.)។ រីឯអ្នកជំងឺសម្រាកពេទ្យដែលត្រូវបានបញ្ជូនតាមប្រព័ន្ធមានចំនួន ៩២ ៦៨៧ នាក់ (ឆ្នាំ២០២៤ មានចំនួន ៥១ ៤១២ នាក់) ក្នុងនោះបញ្ជូនពីមណ្ឌលសុខភាពមានគ្រែទៅមន្ទីរពេទ្យបង្អែក ចំនួន ៣ ៨២២ នាក់ និងពីមន្ទីរពេទ្យបង្អែកកម្រិតទាប ទៅមន្ទីរពេទ្យបង្អែកកម្រិតខ្ពស់ មានចំនួន ៨៨ ៨៦៥ នាក់។

**តារាង ៣.១.** ចំនួនពិគ្រោះជំងឺករណីថ្មីបញ្ជូនពីមូលដ្ឋានសុខាភិបាលកម្រិតទាបទៅមូលដ្ឋានសុខាភិបាលកម្រិតខ្ពស់ ២០២៣-២០២៥

| ទិសដៅបញ្ជូន | 2023 | 2024 | 2025 |
|---|---|---|---|
| ពីមណ្ឌលសុខភាពទៅមន្ទីរពេទ្យបង្អែក | 70,174 | 86,464 | 86,691 |
| ពីមន្ទីរពេទ្យបង្អែកកម្រិតទាបទៅមន្ទីរពេទ្យបង្អែកកម្រិតខ្ពស់ | 24,752 | 12,182 | 14,486 |
| អ្នកជំងឺទៅមន្ទីរពេទ្យដោយខ្លួនឯង | 2,263,415 | 2,806,243 | 3,402,859 |
| **សរុបរួម** | **2,358,341** | **2,904,889** | **3,504,036** |

ក្រុមរថយន្តគិលានសង្គ្រោះថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចូលរួមប្រចាំការក្នុងព្រឹត្តិការណ៍សំខាន់នានា ដូចជា៖ កិច្ចប្រជុំនីតិកាលរដ្ឋសភា កិច្ចប្រជុំជាតិ-អន្តរជាតិ ព្រះរាជពិធីបុណ្យជាតិ-បុណ្យអន្តរជាតិ សន្និបាតក្រសួង-ស្ថាប័ន កម្មវិធីសំណេះសំណាលកម្មករនិយោជិត តាមរោងចក្រ សហគ្រាស ព្រឹត្តិការណ៍ជាតិ-អន្តរជាតិ ដំណើរទស្សនកិច្ចគណៈប្រតិភូអន្តរជាតិ ទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូជាន់ខ្ពស់នៃបណ្តាប្រទេសនានា ពិធីបុណ្យផ្សេងៗ សរុបចំនួន ១២១ លើក និងបានពិនិត្យព្យាបាល និងសង្គ្រោះបឋម ជូនថ្នាក់ដឹកនាំ សមាជិក សមាជិការដ្ឋសភា ភ្ញៀវជាតិ ភ្ញៀវអន្តរជាតិ ព្រះសង្ឃ កងកំលាំងប្រដាប់អាវុធ កីឡាករ កីឡាការិនី និងមហាជន សរុបចំនួន ១៩ ៣១៨ នាក់ ក្នុងនោះ ប្រុស ១២ ៨៦៤ នាក់ ស្រី ៦ ៤៥៤ នាក់ ព្រមទាំងបានបញ្ជូនទៅព្យាបាលបន្តនៅមន្ទីរពេទ្យចំនួន ៧៩ នាក់ (ស្រី ៣០ នាក់)។

## ៣.៤. ការកែលម្អគុណភាពសេវា

ក្រសួងសុខាភិបាលបានអនុវត្តកម្មវិធីវាយតម្លៃនិងលើកកម្ពស់គុណភាពសេវាដែលមានលក្ខណៈជាប្រព័ន្ធនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត ក្នុងទូទាំងប្រទេស ដោយប្រើប្រាស់ឧបករណ៍វាយតម្លៃកម្រិត១ ចាប់ពីឆ្នាំ២០១៧ និងឧបករណ៍វាយតម្លៃពីកម្រិត២ ចាប់ពីឆ្នាំ២០២៣ តាមយន្តការនៃការវាយតម្លៃ ដូចបង្ហាញក្នុង តារាង ៣.២។ ជាគោលការណ៍ ឧបករណ៍វាយតម្លៃផ្តោតលើវិមាត្រ ៣ នៃគុណភាព៖ ទី១. រចនាសម្ព័ន្ធ (ជាតុចូល) ទី២. បច្ចេកទេស (បែបបទនៃការផ្តល់សេវាថៃទាំព្យាបាល) និងទី៣. លទ្ធផលសុខភាពអ្នកជំងឺ/អតិថិជន (លទ្ធផលសុខភាព)។

**តារាង ៣.២.** បែបបទនៃការវាយតម្លៃ និងលើកកម្ពស់គុណភាពសេវាសុខាភិបាល

| ជំហាននៃការវាយតម្លៃ | អ្នកទទួលខុសត្រូវ | ចំនួនលើក | ពេលវេលា |
|---|---|---|---|
| **ទី1.** ការវាយតម្លៃផ្ទៃក្នុង (Self-Assessment) | ▪ មន្រ្តីមណ្ឌលសុខភាព<br>▪ មន្រ្តីមន្ទីរពេទ្យបង្អែក | 2ដង/ឆ្នាំ | ▪ ខែកុម្ភៈ<br>▪ ខែសីហា |
| **ទី2.** ការវាយតម្លៃពីខាងក្រៅ (External Assessment) | ▪ អ្នកវាយតម្លៃថ្នាក់ការិយាល័យស្រុកប្រតិបត្តិធ្វើការវាយតម្លៃមណ្ឌលសុខភាព<br>▪ អ្នកវាយតម្លៃថ្នាក់មន្ទីរសុខាភិបាលធ្វើការវាយតម្លៃមន្ទីរពេទ្យបង្អែក | 2ដង/ឆ្នាំ | ▪ ខែមីនា-មេសា<br>▪ ខែកញ្ញា-តុលា |
| **ទី3.** ការវាយតម្លៃផ្ទៀងផ្ទាត់ (Quality Verification) | ▪ ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ | 2ដង/ឆ្នាំ | ▪ ខែមេសា-មិថុនា<br>▪ ខែតុលា-ធ្នូ |

### ៣.៤.១. ការកែលម្អគុណភាពសេវាមណ្ឌលសុខភាព

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៥ មណ្ឌលសុខភាពសរុបមានចំនួន ១ ៣១១ ក្នុងនោះ មណ្ឌលសុខភាព ១ ៣០២ ត្រូវបានវាយតម្លៃ។ ការវាយតម្លៃរវាងឆមាសទី១ និងឆមាសទី២ នៃឆ្នាំ២០២៥ ទទួលបានលទ្ធផល ដូចខាងក្រោម៖

- ពិន្ទុមធ្យមរបស់មណ្ឌលសុខភាពបានកើនពី ៥០,៩៦% ទៅ ៥៧,៧៣% ហើយចំនួនមណ្ឌលសុខភាពដែលពិន្ទុគុណភាព លើសពី ៦០% បានកើនពី ២៧៩ កន្លែង ទៅ ៥៨០ កន្លែង ឬ កើនពី ២១,៥៤% ទៅ ៤៤,៥៥% នៃចំនួនមណ្ឌលសុខភាពសរុប (ក្រាហ្វិក ៣.១.)។
- ពិន្ទុមធ្យមនៃការពេញចិត្តចំពោះសេវា នៅឆ្នាំ២០២៥ គឺ ៨៦% (ក្រាហ្វិក ៣. ២.)។ អ្នកជំងឺឬគ្រួសារអ្នកជំងឺនិងប្រជាជនដែលបានប្រើប្រាស់សេវាមណ្ឌលសុខភាព ចំនួន ២៤០ ៣៧៨ នាក់ បានចូលរួមផ្តល់មតិ តាមរយៈការស្កេន QR កូដ ដែលបានចាប់ផ្តើមប្រើប្រាស់កាលពីខែកុម្ភៈ ឆ្នាំ២០២៥ ដើម្បីដាក់ពិន្ទុសំណួរ ចំនួន ៧ (តារាង ៣.៣.) ។

## ក្រាហ្វិក ៣.១. និន្នាការនៃចំនួនមណ្ឌលសុខភាពដែលទទួលបានពិន្ទុលើសពី ៦០%




## ក្រាហ្វិក ៣.២. ពិន្ទុមធ្យមនៃការពេញចិត្តរបស់អ្នកជំងឺ/គ្រួសារ អ្នកប្រើប្រាស់សេវានៅមណ្ឌលសុខភាព



**តារាង ៣.៣.** កម្រងសំណួរទាក់ទងនឹងការពេញចិត្តចំពោះសេវា

| | សំណួរអំពីការពេញចិត្ត | ពិន្ទុពី 1-5 |
|---|---|---|
| 1 | តើអ្នកពេញចិត្តនឹងភាពរួសរាយរាក់ទាក់របស់គ្រូពេទ្យ កម្រិតណា? | ពេញចិត្តខ្លាំង (5ពិន្ទុ)<br>ពេញចិត្ត (4ពិន្ទុ)<br>ទទួលយកបាន (3ពិន្ទុ)<br>មិនពេញចិត្ត (2ពិន្ទុ)<br>មិនពេញចិត្តខ្លាំង (1ពិន្ទុ) |
| 2 | តើអ្នកពេញចិត្តនឹងពេលវេលាដែលអ្នករង់ចាំមុនពេលបានជួបគ្រូពេទ្យ កម្រិតណា? | |
| 3 | តើអ្នកពេញចិត្តនឹងការព្យាបាល និងថៃទាំដែលអ្នកទទួលបាន កម្រិតណា? | |
| 4 | តើអ្នកពេញចិត្តនឹងការពន្យល់ ការផ្តល់ប្រឹក្សា របស់គ្រូពេទ្យ អំពីស្ថានភាពជំងឺរបស់អ្នក កម្រិតណា? | |
| 5 | តើអ្នកពេញចិត្តនឹងភាពស្អាត សោភ័ណភាព ក្នុងបរិវេណមណ្ឌលសុខភាព ឬមន្ទីរពេទ្យ កម្រិតណា? | |
| 6 | តើអ្នកពេញចិត្តនឹងភាពស្អាត នៃបន្ទប់ផ្តល់សេវា កម្រិតណា? | |
| 7 | តើអ្នកពេញចិត្តនឹងអនាម័យនៃបង្គន់ និងបន្ទប់ទឹក កម្រិតណា? | |

**ការវាយតម្លៃមណ្ឌលសុខភាពគំរូ៖** គណៈកម្មការបច្ចេកទេសអន្តរក្រសួងនៃគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ (គ.វ.ជ.) បានធ្វើបច្ចុប្បន្នភាពឯកសារណែនាំវិធីសាស្ត្រនៃការវាយតម្លៃមណ្ឌលសុខភាព និងបានផ្សព្វផ្សាយទូទាំងប្រទេស។ មណ្ឌលសុខភាពចំនួន ៥០ បានដាក់ពាក្យចូលរួមប្រឡងប្រណាំងថ្នាក់ជាតិ បន្ទាប់ពីត្រូវបានជ្រើសរើសចុងក្រោយ ចំនួន ២ មណ្ឌលសុខភាពក្នុងរាជធានី ខេត្តនីមួយៗ ដោយគណៈកម្មការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់រាជធានី ខេត្ត។

## ៣.៤.២. ការកែលម្អគុណភាពសេវាមន្ទីរពេទ្យបង្អែក

ការវាយតម្លៃគុណភាពមន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ៦១ កម្រិត២ ចំនួន ៣៨ និងកម្រិត៣ ចំនួន ៣៨ រវាងឆមាសទី១ និងឆមាសទី២ នៃឆ្នាំ២០២៥ ទទួលបានលទ្ធផលដូចខាងក្រោម៖

- ពិន្ទុជាមធ្យមរបស់មន្ទីរពេទ្យបង្អែកកម្រិត១ បានកើនឡើង ៤,១៦% ឬពី ៦៥,១៩% ទៅ ៦៩,៣៥% មន្ទីរពេទ្យបង្អែកកម្រិត២ បានកើនឡើង ៤,៣៥% ឬពី ៦៣,៨១% ទៅ ៦៨,១៦% និង មន្ទីរពេទ្យបង្អែកកម្រិត៣ បានកើនឡើង ៣,៦៥% ឬពី ៧០,០១% ទៅ ៧៣,៦៦%។
- ចំនួនមន្ទីរពេទ្យបង្អែកកម្រិត១ ដែលទទួលបានពិន្ទុលើសពី៦០% បានកើនឡើងពី ៣៨ កន្លែង ទៅ ៤៩ កន្លែង ឬពី ៦៣,៣៣% ទៅ ៨០,៣៣% (ក្រាហ្វិក ៣.៣.)
- ចំនួនមន្ទីរពេទ្យបង្អែកកម្រិត២ ដែលទទួលបានពិន្ទុគុណភាពលើសពី៦០% បានកើនឡើងពី ២៥ កន្លែង ទៅ ២៩ កន្លែង ឬពី ៦៥,៧៩% ទៅ ៧៦,៣២% (ក្រាហ្វិក ៣. ៤.)
- ចំនួនមន្ទីរពេទ្យបង្អែកកម្រិត៣ ដែលទទួលបានពិន្ទុគុណភាពលើសពី៦០% បានកើនឡើងពី ១៨ កន្លែង ទៅ ២១ កន្លែង ឬពី ៨១,៨២% ទៅ ៩៥,៤៥% (ក្រាហ្វិក ៣.៥.)

- ការវាយតម្លៃអំពីចំណេះដឹង និងសមត្ថភាពដោយផ្អែកលើការធ្វើតេស្តករណីសិក្សាគ្លីនិកៈ មន្ទីរពេទ្យបង្អែក កម្រិត១ ទទួលបានពិន្ទុ ពី ២៥,៩៩% ទៅ ២៦,២៣% មន្ទីរពេទ្យបង្អែក កម្រិត២ ទទួលបានពិន្ទុគុណភាព ពី ២៦,៣៤% ទៅ ២៦,៣១% និងមន្ទីរពេទ្យបង្អែក កម្រិត៣ ទទួលបានពិន្ទុគុណភាព ពី ២៥,៥៣% ទៅ ២៦,៦៩% (ពិន្ទុដែលកំណត់ឱ្យសម្រាប់ផ្នែកនេះគឺ ៣០% នៃពិន្ទុសរុប)។
- ពិន្ទុមធ្យមនៃការពេញចិត្តចំពោះសេវាមន្ទីរពេទ្យបង្អែកគ្រប់កម្រិតនៅឆ្នាំ២០២៥ គឺ ៨៣% (ក្រាហ្វិក ៣.៦)។ អ្នកជំងឺឬគ្រួសារអ្នកជំងឺ និងប្រជាជនដែលបានមកប្រើប្រាស់សេវាមន្ទីរពេទ្យបង្អែកគ្រប់កម្រិត ចំនួន ៤៩ ៦៥៧ នាក់ បានចូលរួមផ្តល់មតិ តាមរយៈការស្កេន QR កូដ និងដាក់ពិន្ទុសំណួរចំនួន ៧ ដូចមណ្ឌលសុខភាពដែរ។

### ក្រាហ្វិក ៣.៣. និន្នាការនៃចំនួនមន្ទីរពេទ្យកម្រិត១ ដែលពិន្ទុមធ្យមលើសពី ៦០% ពីឆ្នាំ២០២៣-២០២៥




### ក្រាហ្វិក ៣.៤. និន្នាការនៃចំនួនមន្ទីរពេទ្យកម្រិត២ ដែលពិន្ទុមធ្យមលើសពី ៦០% ពីឆ្នាំ២០២៣-២០២៥



## ក្រាហ្វិក ៣.៥. និន្នាការនៃចំនួនមន្ទីរពេទ្យកម្រិត៣ ដែលពិន្ទុមធ្យមលើសពី ៦០% ពីឆ្នាំ២០២៣-២០២៥




## ក្រាហ្វិក ៣.៦. ពិន្ទុមធ្យមនៃការពេញចិត្តរបស់អ្នកជំងឺ នៅមន្ទីរពេទ្យបង្អែកគ្រប់កម្រិត ឆ្នាំ២០២៥



គួរកត់សម្គាល់ថា រវាងឆមាសទី២ ឆ្នាំ២០២៤ និងឆមាសទី២ ឆ្នាំ២០២៥ មន្ទីរពេទ្យបង្អែកភាគច្រើនបានរក្សាពិន្ទុគុណភាពលើសពី ៦០% មន្ទីរពេទ្យបង្អែកមួយចំនួនដែលបានទទួលពិន្ទុក្រោម ៦០% បានខិតខំប្រឹងប្រែងកែលម្អគុណភាព ដោយបង្កើនពិន្ទុលើសពី ៦០% និងពិន្ទុកើនឡើងដែរ ប៉ុន្តែនៅតែក្រោម ៦០% ដដែលខណៈដែលមន្ទីរពេទ្យបង្អែកខ្លះ ពិន្ទុគុណភាពបានធ្លាក់ចុះមកវិញ (ក្រាហ្វិក ៣.៧. ៣.៨. និង ៣.៩.)។ ព័ត៌មានលម្អិតរបស់មន្ទីរពេទ្យបង្អែកគ្រប់កម្រិតមាននៅក្នុងតារាង៥.១ តារាង៥.២ និង តារាង៥.៣ នៃឧបសម្ព័ន្ធ ៥។

**ក្រាហ្វិក ៣.៧.** មន្ទីរពេទ្យកម្រិត១ ដែលពិន្ទុមធ្យមលើសពី ៦០% និងធ្លាក់ចុះក្រោម ៦០% វិញ រវាងឆមាសទី២ ឆ្នាំ២០២៤ និងឆមាសទី២ ឆ្នាំ២០២៥




**ក្រាហ្វិក ៣.៨.** មន្ទីរពេទ្យកម្រិត៣ ដែលពិន្ទុមធ្យមលើសពី ៦០% និងធ្លាក់ចុះក្រោម ៦០% វិញ រវាងឆមាសទី២ ឆ្នាំ២០២៤ និងឆមាសទី២ ឆ្នាំ២០២៥



**ក្រាហ្វិក ៣.៩.** មន្ទីរពេទ្យកម្រិត២ ដែលពិន្ទុមធ្យមលើសពី ៦០% និងធ្លាក់ចុះក្រោម ៦០% វិញ រវាងឆមាសទី២ ឆ្នាំ២០២៤ និងឆមាសទី២ ឆ្នាំ២០២៥




**ការវាយតម្លៃមន្ទីរពេទ្យបង្អែកគំរូ៖** មន្ទីរពេទ្យបង្អែកកម្រិត១ ចំនួន ១០ កម្រិត២ ចំនួន ១០ និងកម្រិត៣ ចំនួន ១០ ត្រូវបានជ្រើសរើសជាមន្ទីរពេទ្យជ័យលាភីក្នុងការប្រឡងប្រជែងអង្គភាពផ្តល់សេវាសាធារណៈគំរូ ក្នុងនោះ មន្ទីរពេទ្យជ័យលាភីលេខ ១ សម្រាប់មន្ទីរពេទ្យកម្រិត១ គឺ មន្ទីរពេទ្យបង្អែកបាកាន ខេត្តពោធិ៍សាត់ កម្រិត២ គឺ មន្ទីរពេទ្យបង្អែកខេត្តកោះកុង និងកម្រិត៣ គឺ មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម (តារាង ៥.៤ នៃឧបសម្ព័ន្ធ ៥)។

# ៤ សមធម៌ក្នុងការទទួលបានសេវាថែទាំសុខភាព




៤.១. ការគ្របដណ្តប់ប្រជាជន

៤.២. ការគ្របដណ្តប់នៃសេវាសុខភាព

៤.៣. ការកាត់បន្ថយបន្ទុកហិរញ្ញវត្ថុ

# ៤. សមធម៌ក្នុងការទទួលបានសេវាថែទាំសុខភាព

**គោលដៅ**

« ប្រជាជនគ្រប់រូបទទួលបានសេវាថែទាំសុខភាពមានគុណភាព និងទាន់ពេល នៅពេលត្រូវការដោយមិនប្រឈមការលំបាកផ្នែកហិរញ្ញវត្ថុ » តាមរយៈប្រព័ន្ធសុខាភិបាលដែលលើកស្ទួយសមធម៌ និងសាមគ្គីភាពសង្គម ជានាការរួមភាគទានហិរញ្ញវត្ថុប្រកបដោយយុត្តិធម៌ និងកាត់បន្ថយចំណាយប្រាក់ហោប៉ៅលើការថែទាំសុខភាព ទូទាំងប្រជាជន ខណៈបង្កើនចំណាយថវិកាជាតិលើសុខភាព ដោយការផ្លាស់ប្តូរជាយុទ្ធសាស្ត្រពីការគាំពារហិរញ្ញវត្ថុសម្រាប់ប្រជាជនគោលដៅ ទៅការគាំពារហិរញ្ញវត្ថុជាសកលសម្រាប់ទាំងអស់គ្នា (*ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០២៥-២០៣៤*) ។

| | លទ្ធផល | | | ចំណុចដៅ |
|---|---|---|---|---|
| សូចនាករ | 2023 | 2024 | 2025 | 2025 |
| **1. ប្រជាជនគ្របដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គម (%)** [1] | **41** | **43.71** | **43.39** | **50** |
| ▪ មូលនិធិសមធម៌ (ម.ស.ស.) | 18.83 | 27.44 | 26.54 | |
| ▪ របបសន្តិសុខសង្គម (ប.ស.ស.) | - | 16.26 | 16.84 | |
| **2. សន្ទស្សន៍គ្របដណ្តប់សេវាសុខភាពនៃការគ្របដណ្តប់សុខភាពជាសកល(រង្វាស់ពី ០-១០០)** [2] | **58** | **60.10** | **63.6** | **64** |
| **3. កម្រិតចំណាយប្រាក់ពីហោប៉ៅលើការថែទាំសុខភាព (%)** [3] | **61** | **60** | **61** | **57** |

**ប្រភពទិន្នន័យ៖** [1] របាយការណ៍ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ និង ប.ស.ស. [2] របាយការណ៍វិភាគ ស.គ.ស. វិទ្យាស្ថានជាតិសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល [3] របាយការណ៍គណនេយ្យសុខាភិបាលជាតិ ឆ្នាំ២០២៥ ក្រសួងសុខាភិបាល។

## ៤.១. ការគ្របដណ្តប់ប្រជាជន

ចំនួនប្រជាជនគ្របដណ្តប់ដោយ ម.ស.ស. និង ប.ស.ស.ផ្នែកថែទាំសុខភាព (ប.ស.ស-ថ) បានកើនឡើងពី ៧ ៥៧៧ ៥៧៨ នាក់ ឬស្មើ ៤៣,៧១% នៃប្រជាជនសរុបចំនួន ១៧ ៣៣៦ ៣០៦ នាក់ នៅឆ្នាំ២០២៤ ដល់ ៧ ៦២៦ ៤១៦ នាក់ ឬស្មើ ៤៣,៣៩% នៃប្រជាជនសរុបចំនួន ១៧ ៥៧៧ ៧៥៩ នាក់ នៅឆ្នាំ២០២៥។ រវាងឆ្នាំ២០២៤ និងឆ្នាំ២០២៥ ចំនួនប្រជាជនដែលត្រូវបានគ្របដណ្តប់ដោយ ម.ស.ស. បានថយចុះ ១,៩៣% និងសមាជិក ប.ស.ស-ថ ដែលបានចុះបញ្ជី និងបានបង់ភាគទាន បានកើនឡើង ៤,៩៩% ។ តារាង ៤.១ បង្ហាញស្ថិតិក្រុមប្រជាជនផ្សេងៗគ្នា ដែលបានគ្របដណ្តប់ដោយ ម.ស.ស. និងប.ស.ស-ថ រវាងឆ្នាំ២០២៤ និងឆ្នាំ២០២៥។

**តារាង ៤.១. ស្ថិតិប្រជាជនគ្របដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គមពី ឆ្នាំ២០២៤-២០២៥**

| បរិយាយ | 2024 | | 2025 | | 2024-2025 |
|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | %បំរែបំរួល |
| **១. មូលនិធិសមធម៌** | **4,757,915** | **27.44** | **4,665,888** | **26.54** | **-0.90** |
| គ្រួសារក្រីក្រអត្តសញ្ញាណ: | 2,902,483 | 16.74 | 3,043,780 | 17.32 | +0.58 |
| គ្រួសារងាយរងហានិភ័យ | 1,750,201 | 10.09 | 1,533,398 | 8.72 | -1.37 |
| កម្មករក្រៅប្រព័ន្ធ/ក្រុមផ្សេងទៀត | 105,231 | 0.60 | 88,710 | 0.50 | -0.10 |
| **២. ប.ស.ស.** | **2,819,663 *** | **16.26** | **2,960,528** | **16.84** | **+0.58** |
| **សរុប(១+២)** | **7,577,578** | **43.71** | **7,626,416** | **43.39** | **-0.32** |

* ចំនួនសមាជិក ប.ស.ស. ដែលបានចុះបញ្ជី និងបានបង់វិភាគទាន។

## ៤.២. ការគ្របដណ្តប់នៃសេវាសុខភាព

### ៤.២.១. សន្ទស្សន៍នៃការគ្របដណ្តប់សេវាសុខភាពសម្រាប់ការគ្របដណ្តប់សុខភាពជាសកល (ស.គ.ស.)

**ស.គ.ស. កម្ពុជាបានកើនឡើងពី ៦០,១ នៅឆ្នាំ២០២៤ ដល់ ៦៣,៦ នៅឆ្នាំ២០២៥។** សន្ទស្សន៍នេះ មានសូចនាករសរុបចំនួន ១៧ ហើយចែកចេញជា ៤ ផ្នែក។ បើធៀបនឹងលទ្ធផលឆ្នាំ២០២៤ ផ្នែកសេវាសុខភាពបន្តពូជ មាតា ទារក និងកុមារ នៅទ្រឹង (៦៦,៦ ដដែល) ផ្នែកសេវាជំងឺមិនឆ្លងបានកើនឡើងគួរឱ្យកត់សម្គាល់ ពី ៥១,៤ ទៅ ៥៩ ផ្នែកសេវាជំងឺឆ្លងបានកើនឡើងពី ៨៧,១ ទៅ ៩១,៩% និងផ្នែកសមត្ថភាពផ្តល់សេវា និងការទទួលបានសេវាបានកើនឡើងពី ៤៣,៨ ទៅ ៤៥,២ (ក្រាហ្វិក ៤.១.)។

ការពិនិត្យមើលនិន្នាការ និងកម្រិត ស.គ.ស.កម្ពុជា បង្ហាញពីវឌ្ឍនភាពប្រកបដោយសង្គតិភាពនៅក្នុងសេវាសុខភាពបន្តពូជ មាតា ទារក និងកុមារ និងសេវាជំងឺឆ្លង (ក្រាហ្វិក ៤.២.) ដោយសន្ទស្សន៍បានកើនឡើងទ្វេដងពី ៣០ នៅឆ្នាំ២០០០ ដល់ ៦២ នៅឆ្នាំ២០២៤ ខណៈដែលក្នុងរយៈពេលដូចគ្នានេះ សន្ទស្សន៍មធ្យមសកលបានកើនឡើងពី ៤៥ ទៅ ៧០ ឬកើនឡើង ២៥ ពិន្ទុ។ ទោះជាសន្ទស្សន៍កម្ពុជា នៅតែស្ថិតក្រោមសន្ទស្សន៍សកលក្តី ក៏គម្លាតត្រូវបានបង្រួញពី ១៥ នៅឆ្នាំ២០០០ មកនៅ ៨ នៅឆ្នាំ២០២៤ ក្រាហ្វិក ៤.៣.)។

**ក្រាហ្វិក ៤.១.** និន្នាការ ស.គ.ស. កម្ពុជា តាមផ្នែកទាំង ៤ (ឆ្នាំ២០២៤-២០២៥)




**ក្រាហ្វិក ៤.២.** ស.គ.ស. ផ្នែកទាំង៤ ឆ្នាំ២០០០-២០២៥



**ក្រាហ្វិក ៤.៣..** និន្នាការ ស.គ.ស. កម្ពុជាធៀបនឹង ស.គ.ស.សកល (ឆ្នាំ២០០០-២០២៤)




**ប្រភព:** (1). WHO Global Health Observatory; WHO UHC Service Coverage Index updates, report published 1 June 2023. (2). Tracking Universal Health Coverage: 2021 Global monitoring report, Global report published 21 May 2024. (3). World health statistics 2024: monitoring health for the SDGs, sustainable development goals, Statistical release 21 May 2024.

## ៤.២.២. ការប្រើប្រាស់សេវាសុខាភិបាល

រវាងឆ្នាំ២០២៤ និងឆ្នាំ២០២៥ ករណីប្រើប្រាស់សេវាសុខភាពក្រោមប្រព័ន្ធគាំពារសុខភាពសង្គម បានកើនឡើង ៣,៥៨% ក្នុងនោះ ករណីប្រើប្រាស់សេវាក្រោមកម្មវិធីមូលនិធិសមធម៌បានកើនឡើងពី ៤ ៨៦១ ៨២៩ ករណី ដល់ ៥ ០៧៩ ៧៥០ ករណី ឬ ៤,៤៨% និងក្រោមគម្រោង ប.ស.ស-ថ បាន កើនឡើងពី ៧ ៨៦៧ ៤៧៩ ករណី ទៅ ៨ ១០៣ ៥៨៥ ឬកើន ៣,០% (តារាង ៤.២)។

**តារាង ៤.២.** ករណីប្រើប្រាស់សេវាសុខភាពក្រោមកម្មវិធីមូលនិធិសមធម៌ និង ប.ស.ស-ថ

| ការប្រើប្រាស់សេវា | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|
| មូលនិធិសមធម៌ | 3,091,962 | 3,086,148 | 3,347,344 | 4,861,829 | 5,079,750 |
| ប.ស.ស. ផ្នែកថែទាំសុខភាព | 1,896,858 | 2,530,983 | 5,054,639 | 7,867,479 | 8,103,585 |
| **សរុប** | **4,988,820** | **5,617,131** | **8,401,983** | **12,729,308** | **13,183,335** |

**ប្រភព៖** ទីភ្នាក់ងារជាតិបញ្ញាក់ចំណាយ និងបេឡាជាតិសន្តិសុខសង្គម

### ៤.២.៣. មូលដ្ឋានសុខាភិបាលអនុវត្តគម្រោងគាំពារសុខភាពសង្គម

ក្នុងឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលសាធារណៈ ដែលបានអនុវត្ត ម.ស.ស. មានចំនួនសរុប ១ ៤១៦ កន្លែង និងទាំងមូលដ្ឋានសុខាភិបាលសាធារណៈ ទាំងឯកជនដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.សស. ផ្នែកថែទាំសុខភាព (ប.ស.ស-ថ) និងផ្នែកហានិភ័យការងារ (ប.ស.ស-ហ) មានចំនួនសរុប ១ ៦១៦ កន្លែង (តារាង ៤.៣.) ។

**តារាង ៤.៣.** ចំនួនមូលដ្ឋានសុខាភិបាលអនុវត្តគម្រោងគាំពារសុខភាពសង្គម ឆ្នាំ២០២៤-២០២៥

| បរិយាយ | ឆ្នាំ2024 | | | ឆ្នាំ2025 | | |
|---|---|---|---|---|---|---|
| | ម.ស.ស. | ប.ស.ស-ហ | ប.ស.ស-ថ | ម.ស.ស. | ប.ស.ស-ហ | ប.ស.ស-ថ |
| **មូលដ្ឋានសុខាភិបាលសរុប** | **1,401** | **433** | **1,594** | **1,416** | **451** | **1,616** |
| ▪ មន្ទីរពេទ្យគ្រប់កម្រិត * | 131 | 136 | 140 | 131 | 136 | 140 |
| ▪ មណ្ឌលសុខភាព | 1,270 | 214 | 1,291 | 1,285 | 233 | 1,302 |
| ▪ ឯកជន | | 83 | 163 | - | 82 | 174 |

**ប្រភពទិន្នន័យៈ** ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ និងបេឡាជាតិសន្តិសុខសង្គម

* មន្ទីរពេទ្យបង្អែកគ្រប់កម្រិតនៃក្រសួងសុខាភិបាល រួមទាំងមន្ទីរពេទ្យនៃក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ

## ៤.៣. ការកាត់បន្ថយបន្ទុកហិរញ្ញវត្ថុ

### ៤.៣.១. ការចំណាយលើតារាកាលិក

រវាងឆ្នាំ២០២៣ និងឆ្នាំ២០២៥ និន្នាការ និងកម្រិតចំណាយលើមូលនិធិសមធម៌បានកើនឡើង ក្នុងរង្វង់ ១០ ក្នុងមួយឆ្នាំ។ ដោយឡែកកម្រិតចំណាយលើ ម.ស.ស. នៅឆ្នាំ២០២៥ បានកើនឡើង ៥៨,៦៦% ធៀបនឹងចំណាយក្នុងឆ្នាំ២០២៤ និងកម្រិតចំណាយលើ ប.ស.ស-ថ បានកើនឡើង ២៦, ៦៨% ធៀបនឹងឆ្នាំ២០២៤ (តារាង ៤.៤.)។ ជារួម កំណើនកម្រិតចំណាយលើ ម.ស.ស. និង ប.ស.ស-ថ មានសង្គតិភាពជាមួយកំណើននៃការប្រើប្រាស់សេវាសុខភាព និងការពង្រីកវិសាលភាពគ្របដណ្តប់ប្រជាជននៃកម្មវិធីទាំងពីរនេះ។

**តារាង ៤.៤.** ចំណាយដោយប្រព័ន្ធគាំពារសុខភាពសង្គម ឆ្នាំ២០២២-២០២៥ (គិតជារៀល)

| ប្រភេទចំណាយ | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|
| 1. ម.ស.ស. | 77,667,145,000 | 86,518,736,000 | 95,616,281,000 | 151,703,294,000 |
| ▪ វេជ្ជសាស្ត្រ | 71,716,308,000 | 80,855,844,000 | 89,240,326,000 | - |
| ▪ មិនមែនវេជ្ជសាស្ត្រ | 5,950,837,000 | 5,662,892,000 | 6,375,955,000 | - |
| 2. ប.ស.ស-ថ | 135,407,844,600 | 307,771,190,184 | 507,305,026,746 | 642,682,940,000 |
| សរុប (1+2) | **213,074,989,600** | **394,289,926,184** | **602,921,307,746** | **794,386,234,000** |

### ៤.៣.២. កម្រិតចំណាយប្រាក់ហោប៉ៅលើការថែទាំសុខភាព

ទោះបីជាមានវឌ្ឍនភាពក្នុងការកែលម្អសមធម៌ និងនិរន្តរភាពនៃហិរញ្ញប្បទានសុខាភិបាលក្តី ចំណាយប្រាក់ហោប៉ៅលើការថែទាំសុខភាព (ច.ហ.ស.) របស់គ្រួសារនៅតែមានកម្រិតខ្ពស់ ក្នុងរង្វង់ ៦០% នៅក្នុងទសវត្សរ៍ចុងក្រោយនេះ។ គួរកត់សម្គាល់ថា លើសពីពាក់កណ្តាលនៃ ច.ហ.ស. ត្រូវបានចំណាយនៅមន្ទីរពេទ្យឯកជន និងគ្លីនិកឯកជន ខណៈដែលគ្រួសារបន្តប្រឈមនឹងបន្ទុកហិរញ្ញវត្ថុក្នុងការព្យាបាលជំងឺ។ ការណ៍នេះរំលេចពីភាពចាំបាច់ត្រូវអភិវឌ្ឍគោលនយោបាយហិរញ្ញប្បទាន ដើម្បីពង្រឹងកញ្ចប់តារកាលិកនិងធ្វើសមាហរកម្មផ្នែកឯកជនទៅក្នុងគម្រោងនានាដែលផ្តល់ដោយមូលនិធិសាធារណៈ យោងតាមរបាយការណ៍គណនីសុខាភិបាលជាតិ ឆ្នាំ២០២៥ របស់ក្រសួងសុខាភិបាល នៅក្នុងឆ្នាំ២០២៣ កម្រិត ច.ហ.ស. ស្មើនឹង ៦១% នៃការចំណាយចរន្តសរុបលើសុខភាព។ តាមការធ្វើចំណោលប៉ាន់ស្មាននៅឆ្នាំ២០៣០ ច.ហ.ស. អាចនៅចន្លោះពី ៥០% ទៅ ៥៥% នៅក្នុងបរិកាណ៍ដែលការចំណាយមូលនិធិសាធារណៈក្នុងប្រទេសបន្តកើនឡើង (ថវិកាជាតិ) និងការបន្តពង្រីកវិសាលភាពគ្របដណ្តប់ប្រជាជន ដោយប្រព័ន្ធគាំពារសង្គម (មូលនិធិ ប.ស.ស. និងមូលនិធិជំនួយសង្គម)។

**ក្រាហ្វិក ៤.៤.** និន្នាការនៃកម្រិតចំណាយលើការថែទាំសុខភាព គិតជា % នៃចំណាយចរន្តសរុបលើការថែទាំសុខភាព រវាងឆ្នាំ២០១០-២០៣០




**ប្រភព៖** WHO Global Health Expenditure Database.

* របាយការណ៍គណនីសុខាភិបាលជាតិ ឆ្នាំ ២០២៥ ក្រសួងសុខាភិបាល

# ៥ ភាពធន់ប្រព័ន្ធសន្តិសុខសុខភាព



៥.១. ការបង្ការ និងគ្រប់គ្រងជំងឺឆ្លងដែលលេចឡើង និងលេចឡើងសាជាថ្មី
៥.២. ការបង្ការ និងការគ្រប់គ្រងហានិភ័យសុខភាពតែមួយ
៥.៣. សេវាមន្ទីរពិសោធន៍សុខាភិបាល
៥.៤. សេវាផ្តល់ឈាម

# ៥. ភាពធន់ប្រព័ន្ធសន្តិសុខ សុខភាព

**គោលដៅយុទ្ធសាស្ត្រ**

« ជានាប្រព័ន្ធសុខាភិបាលមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការត្រៀម ការសម្រប ការឆ្លើយតបនិងការស្តារស្ថានភាពឡើងវិញ ប្រកបដោយប្រសិទ្ធភាព ពីគ្រប់ទម្រង់នៃគ្រោះអាសន្នសុខភាព និងគ្រោះថ្នាក់សុខភាព » សំដៅរក្សាការផ្តល់សេវាសុខភាពសារវន្ត កាត់បន្ថយការស្លាប់ និងការឈឺ ព្រមទាំងរក្សាសកម្មភាពសង្គម-សេដ្ឋកិច្ច នៅក្នុងពេលមានវិបត្តិ តាមរយៈការផ្លាស់ប្តូរជាយុទ្ធសាស្ត្រ ពីប្រព័ន្ធសន្តិសុខសុខភាពប្រតិកម្មទៅប្រព័ន្ធមានភាពធន់ *(ផែនការយុទ្ធសាស្ត្រសុខាភិបាល ២០២៥-២០៣៤)* ។

## ៥.១. ការបង្ការ និងគ្រប់គ្រងជំងឺឆ្លងដែលលេចឡើង និងលេចឡើងសាជាថ្មី

### ៥.១.១. ការពង្រឹងសមត្ថភាពស្នូលនៃនិយតកម្មសុខភាពអន្តរជាតិ (International Health Regulation, IHR, 2005)

ពិន្ទុសមត្ថភាពស្នូលកម្ពុជា មាននិន្នាការកើនឡើងពី ៦០% នៅឆ្នាំ២០២២ ដល់ ៦៤% នៅឆ្នាំ២០២៤ (ក្រាហ្វិក ៥.១) ដែលឆ្លុះបញ្ចាំងពីលទ្ធផលនៃការបន្តវិនិយោគធនធានរបស់រាជរដ្ឋាភិបាល ជាពិសេស នៅក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ការខិតខំប្រឹងប្រែងរួមនៃក្រសួង ស្ថាប័នពាក់ព័ន្ធ ការចូលរួមពីសហគមន៍ និងការគាំទ្របច្ចេកទេស និងថវិកាពីដៃគូអភិវឌ្ឍនានា។

**ក្រាហ្វិក ៥.១.** និន្នាការនៃសមត្ថភាពស្នូលរវាងឆ្នាំ២០១៨-២០២៤ (មធ្យមភាគជា %)




ដើម្បីបន្តពង្រឹងភាពធន់នៃប្រព័ន្ធសន្តិសុខសុខភាពជាតិ ជាពិសេស ដើម្បីសម្រេចបានសមត្ថភាពស្នូលនិយ័តកម្មសុខភាពអន្តរជាតិ នៅក្នុងរយៈពេលមធ្យម ទៅរយៈពេលវែង នាយកដ្ឋានប្រយុទ្ធជំងឺឆ្លង សហការជាមួយអង្គភាពសុខាភិបាល ក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ បានបញ្ចប់សេចក្តីផែនការសកម្មភាពជាតិសម្រាប់

សន្តិសុខសុខភាព ផែនការឆ្លើយតបជំងឺរាតត្បាតផ្លូវដង្ហើម និយាមប្រតិបត្តិការស្តង់ដាសម្រាប់ការគ្រប់គ្រង និងការឆ្លើយតបនឹងព័ត៌មានទាក់ទងនឹងសុខភាព និយាមប្រតិបត្តិស្តង់ដាសម្រាប់ការសហការអន្តរក្រសួង និងអន្តរវិស័យលើការប្រាស្រ័យទាក់ទងហានិភ័យសម្រាប់គ្រោះអាសន្នសុខភាពសាធារណៈ។

## ៥.១.២. ការពង្រឹងប្រព័ន្ធអង្កេតតាមដាន និងឆ្លើយតបនឹងជំងឺឆ្លងឬបញ្ហាសុខភាពសាធារណៈ

ក. ប្រព័ន្ធទូរស័ព្ទទាន់ហេតុការណ៍លេខ ១១៥៖ ប្រព័ន្ធនេះត្រូវបានធ្វើបច្ចុប្បន្នភាព និងតម្លើង មុខងារថ្មី និងឆ្លាតវៃ ដោយសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ សារសំខាន់នៃប្រព័ន្ធនេះ រួមមាន៖ (១).ផ្តល់ភាពងាយស្រួលដល់សាធារណៈជនក្នុងការប្រាស្រ័យទាក់ទងជាមួយមន្ត្រីនាយកដ្ឋានប្រយុទ្ធជំងឺឆ្លងដែលប្រចាំការ ២៤ ម៉ោងក្នុងថ្ងៃ និង ៧ ថ្ងៃក្នុងមួយសប្តាហ៍ តាមរយៈការបញ្ជូនការហៅចូលទៅលេខទូរស័ព្ទអ៊ិនធឺណិតរបស់មន្ត្រីទទួលបន្ទុក (២).សំរួលការងារតាមដានព្រឹត្តិការណ៍សុខភាពសាធារណៈដែលកើតឡើង និង (៣).សម្រួលការបញ្ចូលទិន្នន័យដោយស្វ័យប្រវត្តិទៅក្នុងប្រព័ន្ធប្រព័ន្ធរបាយការណ៍សូន្យ របស់ក្រុមឆ្លើយតបបន្ទាន់នៅមន្ទីរពេទ្យ និងមណ្ឌលសុខភាព។ ក្នុងឆ្នាំ២០២៥ ការហៅទូរស័ព្ទចូល និងទូរស័ព្ទត្រឡប់ទៅវិញ តាមប្រព័ន្ធលេខ ១១៥ មានចំនួនសរុប ៧៨៤ លើក ក្នុងនោះ៖ ហៅចូលយកជាការបាន ចំនួន ១១៨ លើក (ទាក់ទងសុខភាពមនុស្ស/សុខភាពសត្វ វិធានការបង្ការជំងឺ ការចាក់វ៉ាក់សាំង បញ្ហាជំងឺ និងការរាយការណ៍អំពីករណីជំងឺគ្រុនឈាម សង្ស័យជំងឺផ្តាសាយបក្សី នៅក្នុងភូមិ ជាដើម) ហៅត្រឡប់ទៅវិញ ១២៨ លើក ហៅចូលរំខាន ២២៤ លើក និងហៅចូលមិនបានការ ៣១៤ លើក។

ខ. ប្រព័ន្ធរបាយការណ៍សូន្យ **(Cambodia Early warning system)**៖ ប្រព័ន្ធជាប្រព័ន្ធ web-based application តាមដានជំងឺឆ្លង ដែលមានភាពងាយស្រួល និងបត់បែន ដើម្បីធានានូវការរាយការណ៍ទាន់ពេល និងពេញលេញ ហើយត្រូវរាយការណ៍រៀងរាល់សប្តាហ៍ ពីអង្គភាពសុខាភិបាលរាជធានី ខេត្ត ទាំង ២៥ ដោយផ្តោតលើករណីជំងឺអាទិភាពដែលបានកំណត់ចំនួន ០៧៖ (១).ជំងឺរាកស្រួចស្រាវ (២).ជំងឺគ្រុនក្តៅស្រួចស្រាវ និងមានចេញកន្ទួលក្រហម (៣).ជំងឺទន់អវៈយវៈ ឬសង្ស័យជំងឺគ្រុនស្វិតដៃជើង (៤).ជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ (៥).ជំងឺគ្រុនក្តៅស្រួចស្រាវ និងមានសញ្ញាចេញឈាម (៦).ជំងឺរលាកខួរក្បាលឬស្រោមខួរ និង (៧).ជំងឺលឿងស្រួចស្រាវ។

គ. ប្រព័ន្ធតាមដានព្រឹត្តិការណ៍ **(Cambodia Event Monitoring System)**៖ ប្រពន្ធ័នេះសម្រាប់ការគ្រប់គ្រងការវាស់វែងរយៈពេលជាមធ្យមនៃការឆ្លើយតបទៅនឹងព្រឹត្តិការណ៍ហានិភ័យសុខភាពនីមួយៗដែលបានកើតឡើង និងការរក្សាទិន្នន័យដែលបានរាយការណ៍ ជាពិសេស អំឡុងពេលចុះអង្កេតករណីផ្ទុះជំងឺ ឬហានិភ័យសុខភាពសាធារណៈដទៃទៀត និងការចែករំលែកព័ត៌មានជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើចុះអនុស្សរណៈរវាងក្រសួងទាំងពីរ។ ក្នុងឆ្នាំ២០២៥ ព្រឹត្តិការណ៍សុខភាពសាធារណៈដែលបានកើតឡើង មានសរុបចំនួន ៣១ ព្រឹត្តិការណ៍ នៅក្នុង រាជធានី ខេត្ត ទាក់ទងនឹងជំងឺផ្តាសាយបក្សី H5N1 ជំងឺផ្តាសាយ (Influenza) ជំងឺឆ្កែឆ្កួតខាំ (Rabies) ពុលត្រីកំពត ចំណីអាហារ ពុលស្រាមានសារជាតិ Methanol ខ្ពស់ រាករូសស្រួចស្រាវ។ ការអង្កេតស្រាវជ្រាវបានរកឃើញ ជំងឺផ្តាសាយបក្សីវិជ្ជមាន ១៨ ករណី លើមនុស្ស (ស្រី ៧ ករណី)។ រីឯ ជំងឺអុតស្វាត្រូវបានគ្រប់គ្រងដោយមិនមានរកឃើញករណីណាមួយ នៅក្នុងឆ្នាំ២០២៥ ។

**ឃ. ប្រព័ន្ធអង្កេតតាមដានជំងឺស្រដៀងនឹងជំងឺផ្តាសាយ៖** ប្រព័ន្ធនេះជាប្រព័ន្ធឃ្លាំមើលជំងឺដែលស្រដៀងនឹងជំងឺផ្តាសាយ (Influenza-like Illness/ILI) និងជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ (Severe Acute Respiratory Infections/SARI)។ របាយការណ៍ការឃ្លាំមើលជំងឺផ្តាសាយនៅកម្ពុជាត្រូវបានផ្សាយនៅលើគេហទំព័រ www.cdcmoh.gov.kh នៃនាយកដ្ឋានប្រយុទ្ធជំងឺឆ្លង រៀងរាល់សប្តាហ៍។ ក្នុងឆ្នាំ២០២៥ ជំងឺដែលស្រដៀងនឹងជំងឺផ្តាសាយ H5N1ចំនួន ១៩ករណី ត្រូវបានរាយការណ៍ ក្នុងនោះអ្នកជំងឺ ៩ នាក់ បានស្លាប់។ ការចុះអង្កេតស្រាវជ្រាវ និងឆ្លើយតបជំងឺផ្តាសាយបក្សីលើមនុស្សបានចំនួន ១៨ លើក នៅក្នុងខេត្តចំនួន ៩ (ខេត្តកំពង់ចាម កំពង់ស្ពឺ កំពត ក្រចេះ ព្រៃវែង ស្វាយរៀង តាកែវ និង ត្បូងឃ្មុំ) និងការចុះអង្កេតស្រាវជ្រាវ និងឆ្លើយតបជំងឺផ្តាសាយបក្សីលើសត្វ ចំនួន ២ លើក នៅខេត្តតាកែវ និងកំពង់ស្ពឺ។ ក្រុមគ្រូពេទ្យនៃរាជធានី ខេត្ត ទាំង ២៥ បានចូលរួមក្នុងការបណ្តុះបណ្តាល online ស្តីពីការគ្រប់គ្រងវេជ្ជសាស្រ្តជំងឺផ្តាសាយបក្សី A/H5N1 និងត្រូវបានធ្វើតេស្តវាស់ស្ទង់ចំណេះដឹងជាលើកទីពីរ ក្រោយបញ្ចប់ការបណ្តុះបណ្តាល ៤ខែ។

**ង. ការអប់រំសុខភាពដើម្បីទប់ស្កាត់និងគ្រប់គ្រងការឆ្លងរាតត្បាត៖** អន្តរាគមន៍ដែលបានអនុវត្ត រួមមាន៖ ការផលិត ការចែកចាយ និងការផ្សាយសម្ភារៈអប់រំសុខភាព និងសារអប់រំ ទាក់ទងនឹងវិធានការបង្ការហានិភ័យនៃជំងឺឆ្លងនានា ទាំងមុនពេលជំងឺផ្ទុះឡើង ទាំងក្នុងអំឡុងជំងឺផ្ទុះឡើង ដល់សាធារណៈជនជាពិសេស សហគមន៍ជាគោលដៅនៃហានិភ័យ ព្រមទាំងចេញសេចក្តីប្រកាសព័ត៌មាន និងសេចក្តីជូនដំណឹងចំនួន ២៨លើក រួមទាំងការឆ្លើយតបនឹងព័ត៌មានក្លែងក្លាយ តាមរយៈបណ្តាញសង្គមដូចជាទូរទស្សន៍ វិទ្យុ និងការចុះអប់រំផ្ទាល់។

### ៥.១.៣. ការងារចត្តាឡីស័កនៅតាមច្រកទ្វារព្រំដែន

ក្នុងឆ្នាំ២០២៥ វិធានចត្តាឡីស័កនៅតាមច្រកទ្វារព្រំដែនប្រទេស ត្រូវបានអនុវត្តជាប្រចាំ ដោយសម្រេចបានលទ្ធផលដូចខាងក្រោម៖

- **អាកាសយានដ្ឋានអន្តរជាតិតេជោ** ត្រូវបានរៀបចំទីតាំងចត្តាឡីស័កថ្មី ដោយបំពាក់នូវគ្រឿងសង្ហារឹម ឧបករណ៍ បរិក្ខាពេទ្យ និងរថយន្តគិលានសង្គ្រោះ។
- **ការពិនិត្យអ្នកដំណើរចេញ-ចូល៖** អ្នកដំណើរ នាវិក និងនិយោជិត ដែលបានចេញចូល តាមអាកាសយានដ្ឋាន កំពង់ផែ និងច្រកព្រំដែន ចំនួន ៩ ១៥៧ ០៩៦ នាក់ ត្រូវបានត្រួតពិនិត្យ ក្នុងនោះជនជាតិបរទេសចំនួន ៥ ៨៥៣ ៥០៦នាក់ និងជនជាតិខ្មែរចំនួន ៣ ៣០៣ ៥៩០ នាក់។
- **ការពិនិត្យយានដឹកជញ្ជូន៖** យន្តហោះដែលបានចុះចតចំនួនសរុប ២៤ ២៨៧ គ្រឿង នាវាចូល ១០ ៩៨៣ គ្រឿង និងចេញ ៧ ៥៩៦ គ្រឿង រថយន្តចូល ៣២៧ ២៧០ គ្រឿង និងចេញ ១៨៣ ១២៨ គ្រឿង ត្រូវបានត្រួតពិនិត្យ។
- **ស្ថានភាពអ្នកដំណើរ នាវិក និយោជិក ដែលមានរោគសញ្ញា៖** ការត្រួតពិនិត្យអ្នកដំណើរ នាវិកនិងនិយោជិក បានរកឃើញអ្នកមានសញ្ញាក្តៅខ្លួនលើសពី ៣៧,៥ អង្សាសេ ចំនួន ៤ ៨៤០ នាក់ ក្តៅខ្លួន ហើយមានរោគសញ្ញាផ្លូវដង្ហើម ១៣ នាក់ មានរោគសញ្ញាសើស្បែក ២ នាក់ និងមានរោគសញ្ញាផ្សេងៗ ៩ នាក់។

- **ការអប់រំ៖** បានចែកប័ណ្ណ/សេចក្តីជូនដំណឹងសុខភាព ចំនួន ១២៥ ៦៦៣ សន្លឹក អប់រំអំពីវិធានការសុខភាពដល់ការីយានដឹកជញ្ជូន ១០១ ៥៩៧ លើក ធ្វើប្រព្រឹត្តកម្មវេជ្ជសាស្ត្រលើយានដឹកជញ្ជូន ៥៤ ៨៨៣ គ្រឿង និងបានរកឃើញអ្នកមានសញ្ញាក្តៅខ្លួន ៥ ៧៩១ នាក់ មានរោគសញ្ញាផ្លូវដង្ហើម ៥៣ នាក់ មានរោគសញ្ញាសើស្បែក ១ នាក់ និងមានរោគសញ្ញាផ្សេងៗ ៦៥២ នាក់។
- **ត្រួតពិនិត្យសាកសព និងអដ្ឋិធាតុ៖** បានត្រួតពិនិត្យ និងអនុញ្ញាតិឲ្យនាំសាកសព ឬអដ្ឋិធាតុ ចូលមកក្នុងប្រទេស ១៤៨ករណី និងនាំចេញសាកសពឬអដ្ឋិធាតុទៅក្រៅប្រទេស ២៩ករណី។

## ៥.២. ការបង្ការ និងការគ្រប់គ្រងហានិភ័យសុខភាពតែមួយ

ក. ការបង្ការ និងគ្រប់គ្រងជំងឺឆ្លងពីសត្វមកមនុស្ស៖ សកម្មភាពដែលបានអនុវត្តនៅក្នុងឆ្នាំ២០២៥ រួមមាន៖

- **ការអភិវឌ្ឍនឧបករណ៍ផែនការ និងនិយាមប្រតិបត្តិស្តង់ដា៖** រៀបចំផែនការយុទ្ធសាស្ត្រស្តីពីការលុបបំបាត់ជំងឺឆ្កែឆ្កួតឆ្នាំ២០៣០ សេចក្តីព្រាងនិយាមប្រតិបត្តិស្តង់ដាស្តីពីក្រុមឆ្លើយតបបន្ទាន់សុខភាពតែមួយ សេចក្តីព្រាងនិតិប្រតិបត្តិស្តង់ដាស្តីពីការរួមបញ្ចូលគ្នាគ្រប់គ្រងករណីសត្វខាំសម្រាប់ជំងឺឆ្កែឆ្កួត មគ្គុទេសក៏ស្តីពីក្របខ័ណ្ឌ ៧-១-៧ សម្រាប់វាស់ប្រសិទ្ធភាពនៃការរកឃើញ និងឆ្លើយតបមានប្រសិទ្ធភាពទៅនឹងព្រឹត្តិការណ៍សុខភាពសាធារណៈ។
- បណ្តុះបណ្តាលបុគ្គលិកសុខាភិបាលចំនួន ៣៩៩នាក់ ស្តីពីសុខភាពតែមួយក្នុងការឆ្លើយតបបន្ទាន់នឹងជំងឺផ្តាសាយបក្សី ការគ្រប់គ្រងរួមបញ្ចូលគ្នាករណីសត្វខាំសម្រាប់ជំងឺឆ្កែឆ្កួត និង ជំងឺឆ្លងពីសត្វមកមនុស្ស និងសិក្ខាសាលាស្តីពីដាក់ឱ្យការអនុវត្តវិធីសាស្ត្រ ៧-១-៧ សម្រាប់គ្រោះអាសន្នសុខភាពសាធារណៈដល់បុគ្គលិកសុខាភិបាល ចំនួន ៩៨ នាក់ (ស្រី ១៩ រូប)។
- រៀបចំវេទិការជំងឺផ្តាសាយបក្សីនៅតាមសាលារៀន ១៣៦ កន្លែង ដោយមានអ្នកចូលរួម ៣៦ ០០០ នាក់ (ស្រី ១៨ ០០០ នាក់)។
- **ចុះអង្កេតស្រាវជ្រាវ និងឆ្លើយតបនឹង៖** ជំងឺផ្តាសាយបក្សីលើមនុស្សវិជ្ជមាន ចំនួន ១០ ករណី (ស្រី ៤ ករណី) ក្នុងនោះស្លាប់មាន ២ ករណី (ស្រី ១ ករណី) ជំងឺផ្តាសាយបក្សីលើសត្វបក្សីវិជ្ជមានដើម្បីស្វែងរកករណីលើមនុស្ស ៨ លើក ករណីសង្ស័យជំងឺផ្តាសាយបក្សីលើមនុស្សនិងផ្តាសាយកន្លែងឡើងជាបណ្តុំ ២៥ លើក និងជំងឺឆ្កែឆ្កួត ចំនួន ៧ ករណី (ស្រី ២ ករណី) ក្នុងនោះស្លាប់ទាំង ៧ ករណី។

ខ. ភាពស៊ាំនៃមេរោគនឹងឱសថប្រឆាំងមេរោគ៖ ក្នុងឆ្នាំ២០២៥ ក្នុងការទប់ស្កាត់ភាពស៊ាំរបស់មេរោគទៅនឹងឱសថប្រឆាំងមេរោគ ក្រសួងសុខាភិបាលបានអនុវត្តសកម្មភាពមួយចំនួន ដូចខាងក្រោម៖

- ប្រជុំក្រុមការងារបច្ចេកទេសដើម្បីពង្រឹងគុណភាពថែទាំ ព្យាបាលសុខមាលភាពមាតា ទារក កុមារ និងរោគស្ត្រី និងទប់ស្កាត់ភាពស៊ាំរបស់មេរោគទៅនឹងថ្នាំអង់ទីប៊ីយ៉ូទិក
- បញ្ចប់ផែនការសកម្មភាពពហុវិស័យស្តីពី ភាពស៊ាំ និងឱសថប្រឆាំងមេរោគ ឆ្នាំ២០២៥-២០២៩ និងយុទ្ធសាស្ត្រជាតិសុខភាពតែមួយ ២០២៥-២០២៩

- បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីសុខាភិបាលសរុបចំនួន ២៣៧ រូប (ស្រី ៦៣ រូប) ស្តីពីនិតិវិធីប្រតិស្តង់ដា លំហាត់សមយុទ្ធ សម្រាប់ប្រព័ន្ធតាមដាន និងអង្កេតស្រាវជ្រាវភាពស៊ាំនឹងឱសថប្រឆាំងមេរោគ
- រៀបចំសិក្ខាសាលា និងកិច្ចប្រជុំពិនិត្យតាមដានលើការអនុវត្ត និងការអង្កេតស្រាវជ្រាវ និងឆ្លើយតបភ្នាក់ងារបង្ករជំងឺភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ចំនួន ៥លើក ដោយមានអ្នកចូលរួមចំនួន ១៧៧រូប (ស្រី ៤៤ រូប)
- អភិបាល តាមដាន និងបង្កើនការយល់ដឹងដល់បុគ្គលិកសុខាភិបាលអំពីភាពស៊ាំរបស់មេរោគទៅនឹងឱសថប្រឆាំងមេរោគ បានចំនួន ៦៨ លើក ក្នុងនោះ ទៅមន្ទីរពេទ្យខេត្តចំនួន ៦៨ លើក និងមន្ទីរពេទ្យបង្អែកស្រុកចំនួន ៦៨ លើក។

គ. ការបង្ការ និងគ្រប់គ្រងហានិភ័យសុខភាពទាក់ទងបរិស្ថាន/គ្រោះមហន្តរាយ៖ សកម្មភាពចម្បងបានផ្តោតជាចម្បងលើការពង្រឹងសមត្ថភាពស្ថាប័ន និងលើកកម្ពស់ការយល់ដឹងរបស់ប្រជាជន តាមរយៈ៖

- ចេញសេចក្តីប្រកាសព័ត៌មានអំពីជំងឺឆ្លងនានា ២៤ លើក រួមមាន៖ ព័ត៌មានស្តីពីជំងឺផ្តាសាយបក្សី ការប្រុងប្រយ័ត្ន និងការបង្ការការចម្លងជំងឺគ្រុនឈាម ការការពារសុខភាព បណ្តាលមកពីការប្រែប្រួលគុណភាពខ្យល់ក្នុងបរិយាកាស ការរកឃើញការកើនឡើងនៃជំងឺពងបែកដៃ ជើង និងមាត់ ពង្រឹងការឆ្លើយតប ទៅនឹងការកើនឡើងជំងឺគ្រុនឈាម នៅក្នុងរដូវវស្សា និងការបង្កើនការការពារខ្លួនពីការឆ្លងវីរុសកូវីដ-១៩។
- រៀបចំសេចក្តីព្រាង៖ (១).ផែនការសកម្មភាពជាតិសម្រាប់សន្តិសុខសុខភាពនៅកម្ពុជា ២០២៦-២០២៩ (២).ផែនការឆ្លើយតបជំងឺរាតត្បាតផ្លូវដង្ហើមនៅកម្ពុជា (៣).និយាមប្រតិបត្តិការស្តង់ដារសម្រាប់ការគ្រប់គ្រង និងឆ្លើយតបទៅនឹងព័ត៌មានទាក់ទងសុខភាព និង (៤).និយាមប្រតិបត្តិស្តង់ដា សម្រាប់ការសហប្រតិបត្តការអន្តរក្រសួង និងអន្តរវិស័យលើការប្រាស្រ័យទាក់ទងហានិភ័យ សម្រាប់ស្ថានភាពមានគ្រោះអាសន្នសុខភាពសាធារណៈនៅកម្ពុជា។
- ផលិតវីដេអូឃ្លីបស្តីពី វិធានការការពារសុខភាពពីការឆ្លងជំងឺគ្រុនផ្តាសាយបក្សីក្នុងអំឡុងពេលពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីខ្មែរ និងពិធីបុណ្យភ្ជុំបិណ្ឌ និងបានអប់រំផ្សព្វផ្សាយតាមបណ្តាញសង្គមសរុបចំនួន ៣៨២ លើក។

## ៥.៣. សេវាមន្ទីរពិសោធន៍សុខាភិបាល

ក. ការលើកកម្ពស់គុណភាព និងសុវត្ថិភាពមន្ទីរពិសោធន៍វេជ្ជសាស្ត្រ៖ ក្រសួងសុខាភិបាលបាននិងកំពុងពង្រឹងគុណភាពសេវាមន្ទីរពិសោធន៍ តាមរយៈកម្មវិធីចម្បង ៤៖ (១).កម្មវិធីពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាពសេវាមន្ទីរពិសោធន៍ (Quality Management System/QMS) (២).កម្មវិធីវាយតម្លៃគុណភាពពីខាងក្រៅ (External Quality Assessment/EQA) (៣).ការរៀបចំដំណើរឆ្ពោះទៅរកការទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាព (International Organization for Standardization/ISO) និង (៤).ការចូលរួមត្រួតពិនិត្យគុណភាពក្រិតខ្នាត (Calibration)នៃឧបករណ៍វាស់វែងក្នុងមន្ទីរពិសោធន៍

- មន្ទីរពិសោធន៍នៃ ម.ជ.ព.ស. ទទួលបានវិញ្ញាបនបត្រ ISO Accreditation (ISO/IEC 17025) នៅឆ្នាំ២០២៣ និង WHO-Prequalification (WHO-PQ) ពីអង្គការសុខភាពពិភពលោក នៅសម្រាប់មន្ទីរពិសោធន៍រូបគីមីសាស្ត្រ និងវិញ្ញាបនបត្រ ISO Accreditation (ISO/IEC 17025) នៅឆ្នាំ២០២៥ សម្រាប់មន្ទីរពិសោធន៍អតិសុខុមសាស្ត្រ។
- មន្ទីរពិសោធន៍វេជ្ជសាស្ត្របង្អែកជាតិនៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ (វ.ជ.ស.ស) បានទទួលវិញ្ញាបនបត្រទទួលស្គាល់គុណភាពជាអន្តរជាតិ (ISO15189 ពីប្រទេសកាណាដា) សម្រាប់សេវាមន្ទីរពិសោធន៍ជាមូលដ្ឋានផ្នែកជំងឺក្រៅ នៅឆ្នាំ២០១៨ និង ISO15189 Plus (ដោយបន្ថែមផ្នែកមីក្រូសាស្ត្រ) រហូតដល់ឆ្នាំ២០២៧។
- មន្ទីរពិសោធន៍នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែកនិងកាមរោគ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យបង្អែកខេត្តសៀមរាប បានទទួលវិញ្ញាបនបត្រទទួលស្គាល់គុណភាព ISO15189 Plus នៅឆ្នាំ២០២៥ ដោយមានជំនួយបច្ចេកទេសពីមន្ទីរពិសោធន៍វេជ្ជសាស្ត្របង្អែកជាតិ ដែលបាននឹងកំពុងបន្តជួយពង្រឹងគុណភាពមន្ទីរពិសោធន៍នៅមន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យខេត្ត ៦ ទៀត ឈានឆ្ពោះទៅទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណភាព ISO ក្នុងពេលខាងមុខ។

## ៥.៤. សេវាផ្តល់ឈាម

| សូចនាករគន្លឹះ | លទ្ធផល | | | | ចំណុចដៅ | បម្រែបម្រួលលទ្ធផលធៀបចំណុចដៅ |
|---|---|---|---|---|---|---|
| | 2022 | 2023 | 2024 | 2025 | 2025 | |
| 1. ការផ្តល់ឈាមដោយអ្នកស្ម័គ្រចិត្ត (%)* | 15.4 | 19.4 | 22.1 | **28.5** | **25** | +3.5% |
| 2. ប្រេវ៉ាឡង់នៃមេរោគឆ្លងបួនប្រភេទ ដែលធ្វើតេស្តវិភាគឃើញក្នុងឈាមអំណោយ(%)៖ | | | | | | |
| ▪ មេរោគហ៊ីវ | | 0.5 | 0.6 | 0.5 | - | -01 |
| ▪ មេរោគជំងឺរលាកថ្លើមប្រភេទបេ | | 1.3 | 1.3 | 1.2 | - | -0.1 |
| ▪ មេរោគជំងឺរលាកថ្លើមប្រភេទសេ | | 0.3 | 0.4 | 0.3 | - | -0.1 |
| ▪ មេរោគជំងឺស្វាយ | | 2.2. | 3.0 | 2.5 | - | -0.5 |

* សូចនាករទី១ ជាសូចនាករនៅក្នុង ផ.យ.ស.៤ ចំណែកសូចនាករទី២ សម្រាប់តាមដានការរក្សាសុវត្ថិភាពឈាមអំណោយ និងមិនកំណត់ចំណុចដៅទេ ការបម្រែបម្រួលគឺការប្រៀបធៀបលទ្ធផលរវាងឆ្នាំ២០២៤ និងឆ្នាំ២០២៥។

ក. ការផ្តល់អំណោយឈាម៖ ឆ្នាំ២០២៥ មជ្ឈមណ្ឌលជាតិផ្តល់ឈាម និងមណ្ឌលផ្តល់ឈាមខេត្ត ២៣ បានចុះអប់រំផ្សព្វផ្សាយ និងទទួលអំណោយឈាមពីអ្នកស្ម័គ្រចិត្តផ្តល់ឈាមមិនទទួលកម្រៃ តាមរយៈក្រុមចល័តចុះប្រមូលឈាម ២១៧ លើក (២២៣ លើក ក្នុងឆ្នាំ២០២៤) និងតាមរយៈក្រុមគ្រួសារអ្នកជំងឺ (បរិច្ចាគជំនួស) ទទួលបានអំណោយឈាមសរុបចំនួន ១៨៣ ១៤១ ប្លោក ដោយកើន ៩,៩៧% ធៀបនឹងឆ្នាំ២០២៤ (អំណោយឈាមសរុបចំនួន ១៦៦ ៥២៤ ប្លោក) ក្នុងនោះ៖

- អំណោយឈាមស្ម័គ្រចិត្តមិនទទួលកម្រៃ មានចំនួន ៥២ ១៣២ប្លោក ឬស្មើ ២៨,៤៦% នៃអំណោយឈាមសរុបខាងលើ។ បើធៀបនឹងឆ្នាំ២០២៤ (៣៦ ៨៨៥ប្លោក) អំណោយឈាមស្ម័គ្របានចិត្តកើនឡើង ៤១,៣%។
- ការបរិច្ចាគឈាមដោយគ្រួសារអ្នកជំងឺ (បរិច្ចាគឈាមជំនួស) មានចំនួន ១៣១ ០០៩ប្លោក ឬស្មើ ៧១,៥៣% នៃអំណោយឈាមសរុប។ បើធៀបនឹងឆ្នាំ២០២៤ (១២៩ ៦៣៩ប្លោក) ការបរិច្ចាគឈាមដោយគ្រួសារអ្នកជំងឺបានកើនឡើង ១,០៥%។

**ក្រាហ្វិក ៥.៣.** និន្នាការនៃអំណោយឈាម (ចំនួនប្លោក) ឆ្នាំ២០២២-២០២៥




**ខ. ការផ្គត់ផ្គង់ឈាម៖** ឈាម និងផលិតផលឈាម ដែលបានផ្គត់ផ្គង់ដល់មន្ទីរពេទ្យរដ្ឋ និងឯកជនក្នុងឆ្នាំ២០២៥ មានចំនួនសរុប ២១០ ១៣៦ ប្លោក ដោយកើនលើសឆ្នាំ២០២៤ (១៧៨ ២៦៣ ប្លោក នៅឆ្នាំ២០២៤) ឬស្មើនឹង ១៧,៨៧%។ ក្នុងចំណោមឈាមផ្គត់ផ្គង់ទាំងអស់មានប្រភេទសមាសភាគឈាមផ្សេងៗ បើគិតជាភាគរយនៃឈាមផ្គត់ផ្គង់ទាំងអស់គឺ៖ ឈាមទាំងស្រុង ៩,៥% គោលិកាក្រហម មាន ៧៤,៥% ប្លាស្មាបង្កកមាន ៨% និងប្លាកែត ៨% (តារាង ៥.២ បង្ហាញចំនួនប្លោកឈាម និងសមាសភាគឈាមដែលបានផ្គត់ផ្គង់ក្នុងឆ្នាំ២០២៥)។

**តារាង ៥.២.** ចំនួនប្លោកឈាមនិងសមាសភាគឈាមដែលបានការផ្គត់ផ្គង់ក្នុងឆ្នាំ២០២៥

| ការផ្គត់ផ្គង់ឈាម | ឈាមទាំងស្រុង | គោលិកាក្រហម | ប្លាស្មាបង្កក | ប្លាកែត | សរុប |
|---|---|---|---|---|---|
| មជ្ឈមណ្ឌលផ្តល់ឈាម | 3,887 | 121,139 | 14,380 | 16,112 | **155,518** |
| មណ្ឌលផ្តល់ឈាមខេត្ត | 16,154 | 35,479 | 2,364 | 621 | **54,618** |
| **សរុបឆ្នាំ២០២៥** | **20,041** | **156,618** | **16,744** | **16,733** | **210,136** |
| **សរុបឆ្នាំ២០២៤** | **19,121** | **134,036** | **12,455** | **12,651** | **178,263** |

**គ. សុវត្ថិភាពឈាម៖** មជ្ឈមណ្ឌលជាតិផ្តល់ឈាម និងមណ្ឌលផ្តល់ឈាមខេត្ត បានបន្តអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសុវត្ថិភាពឈាម ដោយធ្វើការវិភាគឈាមអំណោយរកមេរោគនៃជំងឺឆ្លងបួនប្រភេទ គឺមេរោគអេដស៍ រលាកថ្លើមប្រភេទបេ ប្រភេទសេ និងជំងឺស្វាយ។ នៅឆ្នាំ២០២៥ ការវិភាគឈាមអំណោយទាំងអស់បានរកឃើញឈាមមានផ្ទុកមេរោគអេដស៍ ០,៥% មេរោគរលាកថ្លើមប្រភេទ បេ ១,២% ប្រភេទសេ ០,៣% និងមេរោគស្វាយ ២,៥%។ អត្រានេះចុះទាបជាងអត្រាឆ្នាំ២០២៤ បន្តិច។

**ឃ. ការពង្រឹងសេវាផ្តល់ឈាម៖** មជ្ឈមណ្ឌលជាតិផ្តល់ឈាមបានផ្គត់ផ្គង់សម្ភារៈបរិក្ខារសម្រាប់ដំណើរការមណ្ឌលផ្តល់ឈាមនៅខេត្ត ២៤ និងដេប៉ូឈាម ចំនួន ១៣ បានទាន់ពេលវេលាតាមផែនការផ្គត់ផ្គង់ប្រចាំត្រីមាស។ គណៈកម្មការជំរុញលើកកម្ពស់ការបរិច្ចាគឈាមថ្នាក់ខេត្តត្រូវបានបង្កើតឡើងនៅខេត្តចំនួន ២៣ ដែលមានមជ្ឈមណ្ឌលផ្តល់ឈាម ដើម្បីលើកកម្ពស់ការអប់រំផ្សព្វផ្សាយអំពីអំណោយឈាមតាមរយៈទំនាក់ទំនងសាធារណៈ និងការធ្វើយុទ្ធនាការបរិច្ចាគឈាមដោយស្ម័គ្រចិត្ត ព្រមទាំងការចុះទទួលអំណោយឈាម នៅតាមសាកលវិទ្យាល័យ ក្រសួង ស្ថាប័ន អង្គភាពនានា និងក្នុងវិស័យឯកជន ទាំងនៅរាជធានីភ្នំពេញ និងខេត្ត។ យុទ្ធនាការលើកកម្ពស់ការបរិច្ចាគឈាមបានធ្វើឡើងក្នុងទិវា សំខាន់ៗ ដូចជានៅថ្ងៃទី១៤ ខែកុម្ភៈ ២០២៥ ជាទិវាបរិច្ចាគឈាមនៃក្តីស្រឡាញ់ និងថ្ងៃទី១៤ ខែមិថុនា ជាទិវាពិភពលោកនៃអ្នកបរិច្ចាគឈាម បានសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា ក្រសួង ស្ថាប័ន និងក្រុមហ៊ុនឯកជន រៀបចំយុទ្ធនាការលើកកម្ពស់ការបរិច្ចាគឈាមជាបន្តបន្ទាប់ នៅរាជធានីភ្នំពេញ និងតាមខេត្តនានា។

ប្រព័ន្ធគ្រប់គ្រងគុណភាពសេវាផ្តល់ឈាមនៅមជ្ឈមណ្ឌលជាតិផ្តល់ឈាម ត្រូវបានទទួលស្គាល់គុណភាពកម្រិត១ ទាំងនៅកម្រិតជាតិ ទាំងកម្រិតអន្តរជាតិ ហើយមជ្ឈមណ្ឌលជាតិបាននិងកំពុងអនុវត្តប្រព័ន្ធគ្រប់គ្រងគុណភាព នៅក្នុងមន្ទីរពិសោធន៍ និងក្នុងសេវាកម្មផ្តល់ឈាមទាំងមូល ដើម្បីឆ្ពោះទៅការទទួលគុណភាពកម្រិត២ ទាំងនៅកម្រិតជាតិ និងកម្រិតអន្តរជាតិ។

# ៦ ការពង្រឹងភាពធន់ និងការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល



៦.១. ការអភិវឌ្ឍស្ថាប័ន និងអភិបាលកិច្ចសុខាភិបាល
៦.២. ការអភិវឌ្ឍធនធានមនុស្ស
៦.៣. ការគ្រប់គ្រងហិរញ្ញវត្ថុ
៦.៤. ការផ្គត់ផ្គង់ឱសថ ឧបករណ៍ពេទ្យនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
៦.៥. ការអភិវឌ្ឍទិន្នន័យ ប្រព័ន្ធព័ត៌មានសុខាភិបាល និងសុខាភិបាលឌីជីថល

# ៦. ការពង្រឹងភាពធន់ និងការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល

**វិនិយោគវៃឆ្លាតលើហេដ្ឋារចនាសម្ព័ន្ធគ្រឹះក្នុងប្រព័ន្ធសុខាភិបាល សំដៅពង្រឹងសមត្ថភាព និងភាពធន់ និង ធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល ក្នុងពេលបច្ចុប្បន្ន និងសម្រាប់ពេលអនាគត** ដើម្បីសម្រេច និងរក្សានិរន្តរភាព គោលបំណងសុខភាពដែលប៉ងប្រាថ្នា ដោយផ្តោតលើបរិស្ថានគាំទ្រជាយុទ្ធសាស្ត្រចំនួន ៥៖ (១).ការអភិវឌ្ឍ សមត្ថភាពស្ថាប័ននិងអភិបាលកិច្ចសុខាភិបាល (២).ការអភិវឌ្ឍធនធានមនុស្សសុខាភិបាល (៣).ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ (៤).ការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ឱសថ បរិក្ខារ ឧបករណ៍ពេទ្យ និងបច្ចេកវិទ្យាវេជ្ជសាស្ត្រ និង ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង (៥).ការអភិវឌ្ឍន៍ទិន្នន័យ ការគ្រប់គ្រងព័ត៌មានសុខាភិបាល និងការធ្វើ ឌីជីថលូបនីយកម្មក្នុងប្រព័ន្ធសុខាភិបាល។

## ៦.១. ការអភិវឌ្ឍស្ថាប័ន និងអភិបាលកិច្ចសុខាភិបាល

ស្ថាប័នសុខាភិបាលមានទេពកោសល្យសម្រេបខ្លួន ដឹកនាំ និងគ្រប់គ្រងវិស័យសុខាភិបាលទាំងមូល (សាធារណៈ និងឯកជន) និងអនុវត្តកំណែទម្រង់វិស័យសុខាភិបាល ដើម្បីធានាឱ្យប្រជាជនគ្រប់រូបទទួលបាន ជាសកលសេវាថែទាំសុខភាពប្រកបដោយប្រសិទ្ធភាព។

### ៦.១.១. ការរៀបចំ និងការពង្រឹងសមត្ថភាពស្ថាប័ន

ក. ការរៀបចំលិខិតបទដ្ឋានគតិយុត្ត៖ ក្រសួងសុខាភិបាល ដោយមាននាយកដ្ឋានបុគ្គលិក ជាសេនាធិការ បានរៀបចំលិខិតបទដ្ឋានគតិយុត្ត និងអនុវត្តសកម្មភាពសំខាន់ៗ ដែលទាក់ទងនឹងគោលនយោបាយកំណែទម្រង់ សាធារណៈរបស់រាជរដ្ឋាភិបាល ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ហើយសម្រេចបានលទ្ធផល ដូច ខាងក្រោម៖

- អនុក្រឹត្យលេខ ២៣៩ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល ដែលមាន ១៥ជំពូក និង ៣៦មាត្រា ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ៣ ខែធ្នូ ឆ្នាំ២០២៥ ដោយ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (ឧបសម្ព័ន្ធ ៦៖ អង្គការលេខថ្មី នៃ ក្រសួងសុខាភិបាល)។
- សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈនៃអង្គសុខាភិបាល ដែលមាន ៩ជំពូក និង ៥៤ មាត្រា
- អនុក្រឹត្យ លេខ ៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ ស្តីពីការជ្រើសរើស និងការគ្រប់គ្រង មន្ត្រីផ្នែកលើកិច្ចព្រមព្រៀងការងារ ដែលមាន ៧ជំពូក និង ៤៧ មាត្រា
- សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់ និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈសុខាភិបាល ដោយមានភ្ជាប់ ឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២
- សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការគ្រប់គ្រងការចាត់ចែងប្រើប្រាស់មន្ត្រីសុខាភិបាល នៃអង្គភាពសុខាភិបាលមូលដ្ឋាន។

- សារាចរលេខ១១ សរ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ ស្ដីពីការធ្វើបច្ចុប្បន្នភាព រចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័នចំណុះអង្គការនីតិប្រតិបត្តិនៃអង្គភាពសុខាភិបាលមូលដ្ឋាន
- សារាចរលេខ១០ សរ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៥ ស្ដីពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធនៃអង្គភាពសុខាភិបាលមូលដ្ឋាន
- ធ្វើការត្រួតពិនិត្យឡើងវិញ វិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួងសុខាភិបាល
- ការត្រួតពិនិត្យ និងបញ្ចូលទិន្នន័យមន្ត្រីរាជការសុខាភិបាលនៅក្នុងប្រព័ន្ធរបស់ក្រសួងមុខងារសាធារណៈ។
- ផ្ដល់ធាតុចូលលើសេចក្ដីព្រាងៈ ព្រះរាជក្រឹត្យ ស្តីពីគោលការណ៍រួមនៃការជ្រើសរើសនិងការគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ វិស័យអប់រំ វិស័យសុខាភិបាល អនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តនិយាមនិងនីតិវិធីប្រតិបត្តិសម្រាប់ការជ្រើសរើស មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ និយាមនិងនីតិវិធីប្រតិបត្តិសម្រាប់ការជ្រើសរើសមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ និងការកំណត់ចំនួនមុខតំណែង និងការពិពណ៌នាមុខតំណែងវិជ្ជាជីវៈសុខាភិបាល។

**ខ. ការពង្រឹងភាពជាអ្នកដឹកនាំៈ** ចាប់តាំងពីសប្តាហ៍ទីមួយនៃខែតុលា ឆ្នាំ២០២៣ រហូតមកដល់បច្ចុប្បន្ននេះ កម្មវិធីបណ្ដុះបណ្ដាលតាមប្រព័ន្ធអេឡិចត្រូនិចនៅរៀងរាល់ល្ងាចថ្ងៃអង្គារ ស្តីពីការចែករំលែកបទពិសោធន៍នៃភាពជាអ្នកដឹកនាំ និងនវានុវត្តន៍ ដែលដឹកនាំផ្ទាល់ដោយ **ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រី**ក្រសួងសុខាភិបាល ត្រូវបានរៀបចំឡើងចំនួន ៩៧ វគ្គ។ ក្នុងមួយលើកសិក្សាមានមន្ត្រីចាប់ពីថ្នាក់ប្រធានមណ្ឌលសុខភាព រហូតដល់ប្រធានមន្ទីរសុខាភិបាលរាជធានី ខេត្ត និងពីអនុប្រធានការិយាល័យថ្នាក់កណ្ដាល រហូត ដល់ថ្នាក់ដឹកនាំជាទីប្រឹក្សា អគ្គនាយក អនុរដ្ឋលេខាធិការ និងរដ្ឋលេខាធិការ បានចូលរួម ជាមធ្យមជិត ៤ ០០០ នាក់។ តារាង ៦.១ សង្ខេប ពីចំនួនវគ្គ ចំនួនមធ្យមនៃសិក្ខាកាមដែលបានចូលរួមក្នុងវគ្គនីមួយៗ ចំនួនប្រធានបទករណី សិក្សា ចែករំលែកបទពិសោធន៍ និងការវិភាគ Problem-Driven Iterative Adaptation (PDIA) ក្នុងឆ្នាំ២០២៥។

**តារាង ៦.១.** លក្ខណៈសំខាន់ៗ នៃកម្មវិធីបណ្ដុះបណ្ដាលស្តីពីការចែករំលែកបទពិសោធន៍នៃភាពជាអ្នកដឹកនាំ និងនវានុវត្តន៍

| ល.រ | បរិយាយ | ចំនួនសរុប |
|---|---|---|
| 1. | ចំនួនវគ្គដែលបានរៀបចំ | 44 |
| 2. | ចំនួនមធ្យមនៃសិក្ខាកាមដែលបានចូលរួមក្នុងវគ្គនីមួយ | 3 600 |
| 3. | ប្រធានបទទាក់ទងនឹង ភាពជាអ្នកដឹកនាំ និងទស្សនវិជ្ជា | 22 |
| 4. | គោលការណ៍ណែនាំ ឬជាករណីសិក្សា | 30 |
| 5. | បទបង្ហាញបទពិសោធន៍នៃការដឹកនាំរបស់មន្ទីរសុខាភិបាល | 9 |
| 6. | PDIA របស់មន្ទីរពេទ្យបង្អែកស្រុក CPA1 និងមន្ទីរពេទ្យជាតិ | 28 |

គ. ការពង្រឹងការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំមូលដ្ឋានសុខាភិបាលៈ វ.ជ.ស.ស. បានចូលរួមក្នុងការពង្រឹងសមត្ថភាពស្ថាប័ន តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់មន្ត្រីគ្រប់គ្រងមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក ការិយាល័យស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាល ចំនួន ៣៨៩ ចាប់ពីឆ្នាំ២០១៨ រហូតដល់ឆ្នាំ២០២៥ ដោយប្រើប្រាស់ថវិកាជំនួយនៅពេលដំបូង បច្ចុប្បន្នវគ្គវគ្គបណ្តុះបណ្តាលទាំងនោះ ត្រូវបានដំណើរការដោយប្រើប្រាស់ថវិកាជាតិទាំងស្រុង។

- **វគ្គបណ្តុះបណ្តាលសម្រាប់មណ្ឌលសុខភាព** មាន ៦ ម៉ូឌុល បានចាប់ផ្តើមនៅឆ្នាំ២០១៨ និង បណ្តុះបណ្តាលមន្ត្រីថ្នាក់ដឹកនាំមណ្ឌលសុខភាព បាន ៨ ជំនាន់ សរុប ២០១ នាក់។
- **វគ្គបណ្តុះបណ្តាលសម្រាប់មន្ទីរពេទ្យ** មាន៥ម៉ូឌុល បានចាប់ផ្តើមនៅឆ្នាំ២០២០ និងបណ្តុះបណ្តាលមន្ត្រីថ្នាក់ដឹកនាំមន្ទីរពេទ្យ បាន ៦ ជំនាន់ សរុប ១៦៦ នាក់។
- **វគ្គសម្រាប់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាល** ទើបចាប់ផ្តើមនៅឆ្នាំ២០២៥ បណ្តុះបណ្តាលមន្ត្រីថ្នាក់ដឹកនាំការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងមន្ទីរសុខាភិបាលបាន ២២ នាក់ (ជំនាន់ទី១)។

### ៦.១.២. ការងារនីតិកម្ម អធិការកិច្ច និងសវនកម្ម

ក. ការងារនីតិកម្មៈ ក្នុងឆ្នាំ២០២៥ នាយកដ្ឋាននីតិកម្ម បានសហការជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួងសុខាភិបាល ក្រសួង ស្ថាប័ន ក្នុងការរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្តវិស័យសុខាភិបាល និងការទទួលបណ្តឹង ដោយសម្រេចបានលទ្ធផល ដូចខាងក្រោមៈ

- **សេចក្តីសម្រេចចំនួន ១០ ស្តីពីៈ** (១).ការកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេសបរិស្ថាន និងសុខភាព (២).ការរៀបចំចងសម្ព័ន្ធ មេត្រីភាព រវាងមន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យរាជធានីខេត្ត (៣).ការតែងតាំងសមាសភាពគណៈកម្មការត្រួតពិនិត្យផលិតផលថ្នាំជក់ (៤).ស្តីពីការបង្កើតក្រុមការងារបណ្ណសារនៃក្រសួងសុខាភិបាល (៥).ការបង្កើតក្រុមការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនក្រសួងសុខាភិបាល (៦).ការបង្កើតគណៈកម្មការគ្រប់គ្រងប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ក្រសួងសុខាភិបាល (៧).ការបង្កើតគណៈកម្មការទទួលបន្ទុកសម្របសម្រួលក្រុមវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ថ្នាក់ជាតិ និងរៀបចំសមយុទ្ធអាស៊ានឆ្នាំ២០២៥ (៨).ការបង្កើតក្រុមការងារកែទម្រង់ច្បាប់របស់ក្រសួងសុខាភិបាល (៩).ការបង្កើតក្រុមការងារបច្ចេកទេសរៀបចំសេចក្តីណែនាំអនុវត្តគោលនយោបាយស្តីពីការចូលរួមរបស់សហគមន៍ដើម្បីសុខភាព និង (១០).ការបង្កើតក្រុមការងារសរសេររបាយការណ៍ស្តីពីសិទ្ធិមនុស្សនិងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃក្រសួងសុខាភិបាល។
- **ប្រកាសអន្តរក្រសួងចំនួន ២ ស្តីពីៈ** (១).ការដំឡើងកម្រិតនិងការបង្កើតអង្គភាពសុខាភិបាល និង (២).ការពង្រីកវិសាលភាពនៃការអនុវត្តកម្មវិធីផ្តល់សាច់ប្រាក់ឧបត្ថម្ភ របស់រាជរដ្ឋាភិបាល សម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម(ពីរ)ឆ្នាំ ដល់មន្ត្រីនគរបាលជាតិ និងមន្ត្រីពន្ធនាគារ
- **ប្រកាសចំនួនមួយ** ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៃក្រសួងសុខាភិបាល។

- **ការទទួលបណ្ដឹង**ពីអ្នកទទួលសេវាចំនួន ៣ ករណី ទទួលបណ្ដឹងផ្ទៃក្នុង ១ករណី។

**ខ. ការងារអធិការកិច្ច៖** ក្នុងឆ្នាំ២០២៥ អគ្គាធិការដ្ឋានបានចុះត្រួតពិនិត្យជាប្រក្រតី នៅតាមបណ្ដាអង្គភាពសុខាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានចំនួន ១១០ អង្គភាព ក្នុងនោះមានអង្គភាពសុខាភិបាលសាធារណៈ ៨៩ (មន្ទីរសុខាភិបាលខេត្ត ៨ មន្ទីរពេទ្យខេត្ត ៨ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ២៨ មន្ទីរពេទ្យបង្អែកស្រុក ២៧ និងមណ្ឌលសុខភាព ១៨) សេវាសុខាភិបាលឯកជនចំនួន ២១។ រីឯ អធិការកិច្ចលើបាតុភាពដែលបានកើតឡើងទាក់ទងនឹងការងារគ្រប់គ្រង កិច្ចការរដ្ឋបាល បុគ្គលិក បច្ចេកទេស និងឱសថ មានចំនួនសរុប ២២ករណី ក្នុងនោះមាន៖

- ផ្នែកសុខាភិបាលសាធារណៈ ៨ ករណី(មណ្ឌលសុខភាព ១ មន្ទីរពេទ្យខេត្ត ៤ មន្ទីរពេទ្យបង្អែកស្រុក ២ និងមជ្ឈមណ្ឌលជាតិ ១)។
- ផ្នែកសុខាភិបាលឯកជន១៤ ករណី៖ នៅរាជធានីភ្នំពេញ ៦ ករណី (មន្ទីរពេទ្យ ២ មន្ទីរសម្រាកព្យាបាល ៤) ខេត្តកណ្ដាល ៤ ករណី(មន្ទីរសម្រាកព្យាបាល និងសម្ភព ១ មន្ទីរសម្រាកព្យាបាល ២ និង មន្ទីរសម្ភព ១) ខេត្តកំពង់ស្ពឺ ១ ករណី (មន្ទីរពេទ្យ) ខេត្តស្វាយរៀង ១ ករណី (មន្ទីរសម្រាកព្យាបាល) ខេត្តបន្ទាយមានជ័យ ១ ករណី (បន្ទប់ពិនិត្យផ្ទៃពោះ) ខេត្តសៀមរាប ១ ករណី(បន្ទប់ពិគ្រោះព្យាបាលធ្មេញ)

របាយការណ៍ត្រួតពិនិត្យ និងរបាយការណ៍អធិការកិច្ច ត្រូវបានដាក់ជូនថ្នាក់ដឹកនាំក្រសួងសុខាភិបាលពិនិត្យ និងសម្រេច ព្រមទាំងបានធ្វើលិខិតជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ពាក់ព័ន្ធ ដើម្បីពង្រឹងការគ្រប់គ្រងសេវាសុខាភិបាល នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ជាមួយគ្នានោះ របាយការណ៍ក៏ត្រូវបានជូនថ្នាក់ដឹកនាំគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ ដើម្បីពិនិត្យ និងចាត់វិធានការវិន័យដល់សមាជិករបស់ខ្លួនដែលបានប្រព្រឹត្តកំហុសធ្ងន់។ មន្ត្រីអគ្គាធិការដ្ឋានចំនួន ៦ រូប បានចូលរួមវគ្គបណ្ដុះបណ្ដាលនៅវិទ្យាស្ថានអធិការកិច្ច ៣ រូប ទៀតបានចូលរួមវគ្គបណ្ដុះបណ្ដាលជំនាញឌីជីថលនៅវិទ្យាស្ថានអភិបាលកិច្ចឌីជីថលនៃបណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា។

**គ. ការងារសវនកម្ម៖** ក្នុងឆ្នាំ២០២៥ នាយកដ្ឋានសវនកម្មផ្ទៃក្នុងបានចុះធ្វើសវនកម្មថវិកាជាតិ និងថវិកាគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ដែលគ្រប់គ្រងដោយក្រសួងសុខាភិបាល ដោយសម្រេចបានលទ្ធផលដូចខាងក្រោម៖

- សវនកម្មថវិកាជាតិនៅមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត ចំនួន ២០ សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ ចំនួន ៤ និង ច្រកចេញ-ចូលតែមួយ នៃអង្គភាពថ្នាក់កណ្ដាលមួយ។
- សវនកម្មថវិកាគម្រោងផ្ដល់ថ្នាំបង្ការ (Global Alliance for Vaccines & Immunization) នៅមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តចំនួន១៤ និងនៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក គម្រោងលើកកម្ពស់គុណភាពនិងសមធម៌សុខាភិបាល(ធនាគារពិភពលោក រដ្ឋាភិបាលអូស្ត្រាលី អាល្លឺម៉ង់ និងសាធារណរដ្ឋកូរ៉េ Global Health Facility) នៅមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តចំនួន ៦ គម្រោងសន្តិសុខសុខភាពក្នុងអនុមហាតំបន់មេគង្គ (ធនាគារអភិវឌ្ឍអាស៊ី) នៅមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តចំនួន ១៦ គម្រោងអាហារូបត្ថ នៅមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តចំនួន ៨ និងគម្រោងមូលនិធិ

សកលនៅមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តចំនួន៥ នៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

- ថ្នាក់ដឹកនាំ និងមន្ត្រី នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុងបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិចំនួន ០៦ វគ្គ និងវគ្គបណ្តុះបណ្តាលផ្ទៃក្នុងដែលរៀបចំឡើងដោយនាយកដ្ឋានផ្ទាល់ចំនួន ០៦ វគ្គ។

### ៦.១.៣. កិច្ចការរដ្ឋបាល

ក្នុងឆ្នាំ២០២៥ ក្រសួងសុខាភិបាលបានបន្តពង្រឹងរំហូរការងាររដ្ឋបាលជាប្រចាំ ដើម្បីគាំទ្រដល់កិច្ចដំណើរការមុខងាររបស់អង្គភាពនៅទីស្តីក្រសួង និងអង្គភាពសុខាភិបាលក្រោមឱវាទ ដោយសម្រេចបានលទ្ធផល ដូចខាងក្រោម៖

- ក្រសួងសុខាភិបាលបានបូកសរុបរបាយការណ៍សកម្មភាពការងារ និងសមិទ្ធផលសុខាភិបាលប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំចំនួន ១២ លើក ជូនទីស្តីការគណៈរដ្ឋមន្ត្រី ជាទៀងទាត់។
- ចរាចរលិខិត៖ លិខិតចូលចំនួន ១០ ៨៩២ ច្បាប់ លិខិតចេញចំនួន ១២ ៧២៤ ច្បាប់ លិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារដល់មន្ត្រី ៤៨៦ នាក់ (ព្យាបាលជំងឺ ៤០ នាក់ ឈប់ប្រចាំឆ្នាំ ១៧២នាក់ លំហែមាតុភាព ១២៨នាក់ និងឈប់សម្រាកផ្សេងៗ ១៤៦នាក់។
- លិខិតបញ្ជាបេសកកម្ម៖ ចេញលិខិតបញ្ជាបេសកកម្មថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា អង្គភាពចំណុះទីស្តីការ និងអង្គភាពថ្នាក់កណ្តាលបានចំនួន ៤ ៣១០ បេសកកម្ម និងបញ្ជាក់ទិដ្ឋាការលិខិតធ្វើដំណើរត្រឡប់ពីខេត្តរបស់ថ្នាក់ដឹកនាំ និងមន្ត្រីទីស្តីការ និងអង្គភាពថ្នាក់កណ្តាលបានចំនួន ៣ ៤៩១ ព្រមទាំងបញ្ជាក់ទិដ្ឋាការលិខិតធ្វើដំណើររបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានី-ខេត្ត បានចំនួន ២៨១៧។
- រៀបចំទីកន្លែងប្រជុំផ្សេងៗ ក្នុងទីស្តីការចំនួន ៧៤៤ លើក និងរៀបចំសម្របសម្រួលក្នុងកម្មវិធីជំនួបពិភាក្សាការងាររបស់ **ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រី** ឬតំណាង ជាមួយដៃគូអភិវឌ្ឍន៍ ទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ អង្គការដៃគូ។ល។ ចំនួន ៥៧ លើក ។
- លិខិតចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួងទៅចូលរួមក្នុងគណៈកម្មាធិការនៅក្រសួងផ្សេងៗ ចំនួន ៦៤ និងបានចាត់តាំងថ្នាក់ដឹកនាំ មន្ត្រីសុខាភិបាលចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ពិធីបុណ្យបុណ្យជាតិ-អន្តរជាតិ និងពិធីបុណ្យសាសនា ការចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ ការដាក់កម្រងផ្កា និងប្រទានភ្លើងជ័យនិងពន្លត់ភ្លើងជ័យ នៃទិវាឯករាជ្យជាតិ ទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ និងទិវាប្រកាសរដ្ឋធម្មនុញ្ញ។

### ៦.១.៤. ការសិក្សាស្រាវជ្រាវសុខាភិបាល

អភិបាលកិច្ចការងារស្រាវជ្រាវសុខាភិបាលកំពុងត្រូវបានពង្រឹង តាមរយៈគណៈកម្មាធិការជាតិក្រមសីលធម៌សម្រាប់ការស្រាវជ្រាវសុខភាពដែលទាក់ទងនឹងមនុស្ស។ ក្នុងឆ្នាំ២០២៥ គណៈកម្មាធិការបានពិនិត្យ និងផ្តល់ការអនុញ្ញាតដល់គម្រោងស្រាវជ្រាវចំនួន ៥៦៥ ក្នុងនោះ គម្រោងរបស់និស្សិតចំនួន ៤២១ និងគម្រោងរបស់អ្នកស្រាវស្រាវជំនាញចំនួន ១៤៤។ ចំនួននេះបានកើនឡើង បើធៀបនឹងឆ្នាំ២០២៤ (ក្រាហ្វិក ៦.១.)។

**ក្រាហ្វិក ៦.១.** គម្រោងស្រាវជ្រាវដែលបានពិនិត្យដោយគណៈកម្មាធិការជាតិក្រមសីលធម៌




**វ.ជ.ស.ស** បាននឹងកំពុងអនុវត្តគម្រោងសិក្សាស្រាវជ្រាវសុខាភិបាលលើបញ្ហាអាទិភាពនៃប្រព័ន្ធសុខាភិបាល និងបញ្ហាសុខភាពសាធារណៈជាអាទិភាពមួយចំនួន រួមមាន៖ ជំងឺឆ្លង ជំងឺមិនឆ្លង អនាម័យទឹកស្អាត សុខភាពតែមួយ ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ធនធានមនុស្ស និងហិរញ្ញប្បទានសុខាភិបាល និងការវាយតម្លៃគម្រោងនានា។ នៅឆ្នាំ២០២៥ វ.ជ.ស.ស កំពុងបន្តអនុវត្តគម្រោងសិក្សាស្រាវជ្រាវឆ្នាំមុន និងគម្រោងថ្មីសំខាន់ៗ ចំនួន១៥ ក្នុងនោះគម្រោងសិក្សាស្រាវជ្រាវ ៥ គាំទ្រដោយថវិកាជាតិ៖ (១).ការវាយតំលៃប្រព័ន្ធបញ្ជូនបន្ត នៅក្នុងប្រព័ន្ធសុខាភិបាលកម្ពុជា (២).ការសិក្សាស្រាវជ្រាវស្តីពីការវាស់សន្ទស្សន៍គ្របដណ្តប់សុខភាពជាសកលកម្ពុជាឆ្នាំ២០២៥ (៣).ពិធីសារនៃគម្រោងសិក្សាពិសោធន៍៖ ការកំណត់និយាមអប្បបរមារសម្រាប់រៀបចំមន្ទីរពិសោធន៍វេជ្ជសាស្ត្រនៅកម្ពុជា (៤).កាលវិភាគសម្រាប់ធ្វើសិក្សាពិសោធន៍ស្តីពីការកំណត់តម្លៃយោងនៃប៉ារ៉ាម៉ែត្រគ្រាប់ឈាមដោយប្រើម៉ាស៊ីន វិភាគស្វ័យប្រវត្តិលើក្រុមមនុស្សមានសុខភាពល្អនៅកម្ពុជា និង (៥).ការរៀបចំផែនទីនៃមូលដ្ឋានសុខាភិបាលនិងសមត្ថភាពផ្តល់សេវាជូនពលរដ្ឋដែលគ្របដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គមនៅកម្ពុជា។

លទ្ធផលនៃគម្រោងសិក្សាស្រាវជ្រាវដែលបានបញ្ចប់ត្រូវបានផ្សព្វផ្សាយតាមរយៈសិក្ខាសាលា និងការចងក្រងជារបាយការណ៍ ឯកសារសង្ខេបសម្រាប់គោលនយោបាយ និងអត្ថបទបោះពុម្ពផ្សាយក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រជាតិ (តំណភ្ជាប់ទៅទស្សនាវដ្តី៖ https://cjph.niph.org.kh/index.php/cjph) និងអន្តរជាតិ។

### ៦.១.៥. និយ័តកម្មផលិតផលឱសថ ឧបករណ៍ បរិក្ខារពេទ្យ និងផលិតផលគ្រឿងសម្អាង

**ក. ការរៀបចំលិខិតបទដ្ឋានគតិយុត្តៈ** ក្រសួងសុខាភិបាលកំពុងសហការជាមួយអង្គការសុខភាពពិភពលោក ក្នុងការបន្តរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងផលិតផលឱសថ ច្បាប់ស្តីពីការគ្រប់គ្រងឧបករណ៍បរិក្ខារពេទ្យ និងច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងសម្អាង ទន្ទឹមគ្នាការបន្តកែសម្រួលកម្រងសេវាសាធារណៈ និងការពិន័យអន្តរការណ៍ថ្នាក់ជាតិ ដើម្បីបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ខ. ការត្រួតពិនិត្យគុណភាពៈ** មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល (ម.ជ.ព.ស.) កំពុងបន្តជំរុញការអភិវឌ្ឍបច្ចេកទេសមន្ទីរពិសោធន៍ ឱ្យមានអនុលោមស្របតាមស្តង់ដាជាតិ និងអន្តរជាតិ ដើម្បីភាពសុក្រិត ត្រឹមត្រូវ និងអាចទុកចិត្តបាននៃលទ្ធផលវិភាគឱសថ ផលិតផលសុខាភិបាលដែលសង្ស័យក្លែងបន្លំ ឬគ្មានគុណភាព ឬបន្ថែមសារធាតុហាមឃាត់ ឬចរាចរលក់ដោយគ្មានការអនុញ្ញាតនិងផលិតផលចំណីអាហារ។ ក្នុងឆ្នាំ២០២៥ ម.ជ.ព.ស. បានពិនិត្យវិភាគគុណភាពឱសថ និងផលិតផលផ្សេងៗ សរុបចំនួន ៣ ៥៧៤ សំណាក (តារាង ៦.២.)។ នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាងបានទិញឱសថសម័យ ឱសថបុរាណ ផលិតផលបំប៉នសុខភាព និងផលិតផលគ្រឿងសម្អាងមកពិនិត្យវិភាគគុណភាព (Post Marketing Surveillance) ចំនួន ៨៣ សំណាក ក្នុងនោះបានរកឃើញឱសថ ១៥ មុខ ជាឱសថក្លែងក្លាយ និងអន់គុណភាព និងគ្រឿងសម្អាង ០២ មុខ ដែលផ្ទុកសារធាតុគីមីលើសកម្រិតបទដ្ឋានស្តង់ដា។

**តារាង ៦.២.** ប្រភេទ និងចំនួនសំណាកដែលបានវិភាគពីឆ្នាំ២០២៣-២០២៥ (គិតត្រឹមខែតុលា)

| ប្រភេទសំណាក | 2023 | 2024 | 2025 |
|---|---|---|---|
| ▪ ឱសថ និងផលិតផលសុខាភិបាលចុះបញ្ជិកា | 3,309 | 3,627 | 3,122 |
| ▪ ឱសថផ្សេងៗ ក្រៅពីការចុះបញ្ជិកា | 202 | 147 | 154 |
| ▪ ផលិតផលគ្រឿងសម្អាង | 11 | 13 | 21 |
| ▪ ផលិតផលចំណីអាហារ ចំណីអាហារ និងស្រាសង្ស័យពុល សូលុយស្យុងសម្លាប់មេរោគ | 143 | 135 | 277 |
| ▪ **សរុប** | **3,665** | **3,922** | **3,574** |

**គ. ការចុះទិដ្ឋាការ-បញ្ជិកាៈ** នៅក្នុងឆ្នាំ២០២៥ ការចេញសេចក្តីសម្រេច និងវិញ្ញាបនបត្រទាក់ទងពាណិជ្ជនាមស្លាកសញ្ញា/រចនាបថឱសថ ការចុះបញ្ជីគ្រឹះស្ថាន/សាខាផលិតផលឱសថ បញ្ជិកាឱសថ ឧបករណ៍ បរិក្ខារពេទ្យ ប្រតិករ ផលិតផលបំប៉នសុខភាព/ជំនួយសុខភាព ឱសថបុរាណ ផលិតផលគ្រឿងសម្អាង មានចំនួនសរុប ៨ ៤៥៥ ឯកសារ (តារាង ៦.៣)។ រីឯ ចំនួនគ្រឹះស្ថានផលិតឱសថ ផលិតឧបករណ៍បរិក្ខារពេទ្យ ផលិតគ្រឿងសម្អាង ផលិតផលជំនួយសុខភាព គ្រឹះស្ថាន/សាខាអាហរ័ណនីហរ័ណឱសថ គ្រឹះស្ថានអាហរ័ណនីហរ័ណគ្រឿងសម្អាង មជ្ឈមណ្ឌល/សាខាថែរក្សាសម្ផស្ស ឱសថស្ថាន និងឱសថស្ថានរង មានចំនួនសរុប ៥ ៨០៧ ដោយកើនឡើង ២,៩៤ ធៀបនឹងឆ្នាំ២០២៤ (តារាង ៧.២. ក្នុងឧបសម្ព័ន្ធ ៧)។

**តារាង ៦.៣.** ស្ថិតិនៃការចុះបញ្ជីគ្រឹះស្ថាន និងបញ្ជីកាឱសថ ឧបករណ៍បរិក្ខារពេទ្យ គ្រឿងសម្អាង និងផលិតផលបំប៉នសុខភាព ២០២១-២០២៥ (១១ ខែ)

| ល.រ | ប្រភេទលិខិត | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|
| 1 | **សេចក្តីសម្រេចលើពាណិជ្ជនាម-ស្លាកសញ្ញានិងរចនាបថឱសថ** | 1,704 | 1,369 | 1,583 | 1,721 | 1,840 |
| 2 | **វិញ្ញាបនបត្រចុះបញ្ជី៖** | | | | | |
| | ▪ គ្រឹះស្ថានផលិតផលឱសថមកពីបរទេសថ្មី | 133 | 89 | 150 | 163 | 138 |
| 3 | **វិញ្ញាបនបត្របន្តសុពលភាព៖** | | | | | |
| | ▪ ចុះបញ្ជីគ្រឹះស្ថានផលិតផលឱសថមកពីបរទេស | 115 | 88 | 122 | 154 | 150 |
| | ▪ បញ្ជិកាឱសថ | 888 | 1,166 | 1,133 | 1,662 | 1,269 |
| | ▪ បញ្ជិកាឧបករណ៍បរិក្ខារពេទ្យ | 129 | 83 | 214 | 365 | 414 |
| | ▪ ទិដ្ឋាការឱសថ | 112 | 146 | 166 | 137 | 184 |
| | ▪ បញ្ជិកាផលិតផលបំប៉នសុខភាព | 138 | 158 | 146 | 192 | 157 |
| | ▪ បញ្ជិកាប្រតិករ | 168 | 86 | 281 | 399 | 294 |
| | ▪ បញ្ជិកាផលិតផលជំនួយសុខភាព | 50 | 79 | 82 | 75 | 73 |
| | ▪ ឱសថបូរាណ | 42 | 58 | 54 | 42 | 20 |
| 4 | **វិញ្ញាបនបត្របញ្ជិកា៖** | | | | | |
| | ▪ ឱសថថ្មី | 781 | 1,048 | 778 | 1,128 | 1,186 |
| | ▪ ឧបករណ៍បរិក្ខារពេទ្យថ្មី | 231 | 335 | 544 | 499 | 777 |
| | ▪ ប្រតិករថ្មី | 264 | 190 | 256 | 245 | 351 |
| | ▪ ផលិតផលបំប៉នសុខភាពថ្មី | 170 | 240 | 177 | 152 | 143 |
| | ▪ ផលិតផលជំនួយសុខភាពថ្មី | 121 | 75 | 124 | 49 | 74 |
| | ▪ ឱសថបុរាណថ្មី | 43 | 31 | 35 | 32 | 2 |
| 5 | **វិញ្ញាបនបត្រទិដ្ឋាការ៖** | | | | | |
| | ▪ ឱសថថ្មី | 32 | 90 | 94 | 69 | 141 |
| 6 | **វិញ្ញាបនបត្រប្រវេទន៍ផលិតផលគ្រឿងសម្អាងថ្មី** | | | | 3,903 | 3,803 |
| | **សរុប** | **5,122** | **5,331** | **5,939** | **10,987** | **11,016** |

**ឃ. អនុលោមភាពនិយ័តកម្ម៖** ការពង្រឹងអនុលោមភាពស្របតាមលិខិតបទដ្ឋាន គតិយុត្តជាធរមាន លើអាជីវកម្មផលិតផលឱសថ ឧបករណ៍បរិក្ខារពេទ្យ ផលិតផលបំប៉នសុខភាព និងគ្រឿងសម្អាង នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅក្នុងឆ្នាំ២០២៥ សម្រេចបានលទ្ធផលដូចខាងក្រោម៖

- ត្រួតពិនិត្យគ្រឹះស្ថានផលិតឱសថ ផលិតឧបករណ៍បរិក្ខារពេទ្យ និងផលិតគ្រឿងសម្អាង ចំនួន ២៦ លើក និងគ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថ គ្រឹះស្ថានអាហរ័ណ-នីហរ័ណផលិតផលគ្រឿងសម្អាង និងមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ចំនួន ៥១២កន្លែង។
- ត្រួតពិនិត្យឱសថស្ថាន និងឱសថស្ថានរង ១៣២ កន្លែង នៅក្នុងរាជធានីភ្នំពេញ ខេត្ត ។
- ពិន័យអន្តរការណ៍គ្រឹះស្ថានអាហរ័ណ-នីហរ័ណឱសថ គ្រឹះស្ថានអាហរ័ណ-នីហរ័ណផលិតផលគ្រឿងសម្អាង ឱសថស្ថាន មជ្ឈមណ្ឌលថែរក្សាសម្ផស្ស និងទីតាំងលក់ឱសថនិងគ្រឿងសម្អាង ដែលមិនបានគោរពតាមច្បាប់ ចំនួន ១០៨ករណី គិតជាទឹកប្រាក់ ២២៨ ១០០ ០០០៛។
- ចេញសេចក្ដីជូនដំណឹងស្ដីពីការរកឃើញឱសថក្លែងក្លាយ និងគ្រឿងសម្អាងមានសារធាតុគីមីលើសកម្រិតបទដ្ឋានស្តង់ដា ២ លិខិត។
- លុបបញ្ជិកាឱសថបុរាណ ១ មុខ ។
- បិទមជ្ឈមណ្ឌលថែរក្សាសម្ផស្ស ២ កន្លែង និងគ្រឹះស្ថានអាហរ័ណ-នីហរ័ណផលិតផល គ្រឿងសម្អាង ១ កន្លែង ដែលបានអនុវត្តមិនត្រឹមត្រូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។
- ធ្វើនិយ័តកម្ម (ដឹកនាំពីតំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ) លើទីតាំងចែកចាយ ឬលក់ឱសថគ្មានលេខបញ្ជិកា ឬក្លែងក្លាយ ៦ ទីតាំង និងបានបញ្ជូនសំណុំរឿង ចំនួន ៥ និងជនសង្ស័យ ១១ រូប ទៅតុលាការ។
- ចេញលិខិតស្នើនិយ័តករទូរគមនាគមន៍កម្ពុជា នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជួយទប់ស្កាត់ការការផ្សព្វផ្សាយ ឱសថ និងគ្រឿងសម្អាង តាមបណ្ដាញទំនាក់ទំនងសង្គម ចំនួន ០៤លើក ។
- កម្ទេចឱសថគ្មានលេខបញ្ជិកា និងគ្រឿងសម្អាងគ្មានលេខប្រវេទន៍ ១លើក ដែលមានទម្ងន់ផលិតផលសរុប ប្រមាណ ៥ តោន។

## ៦.១.៦. ការលើកកម្ពស់សុវត្ថិភាពចំណីអាហារ

**គិតចាប់ពីខែមករា ដល់ខែវិច្ឆិកា ឆ្នាំ២០២៥ មានការពុលចំណីអាហារចំនួន ១៩ ករណី នៅខេត្តកណ្ដាល កោះកុង កំពង់ចាម កំពង់ធំ តាកែវ ត្បូងឃ្មុំ រតនគិរី សៀមរាប និងឧត្តរមានជ័យ ហើយមានអ្នកឈឺចូលសម្រាកពេទ្យចំនួន ២៧៧ នាក់ ក្នុងនោះ ១១ នាក់ បានស្លាប់។** សកម្មភាពសំខាន់ៗ ទាក់ទងនឹងការលើកកម្ពស់សុវត្ថិភាពចំណីអាហារ ដែលបានអនុវត្តក្នុងឆ្នាំ២០២៥ រួមមាន៖

- ត្រួតពិនិត្យ និងវាយតម្លៃអនាម័យ និងសុវត្ថិភាពចំណីអាហារតាមភោជនីយដ្ឋាន អាហារដ្ឋាន ៧៥កន្លែង នៅខេត្តសៀមរាប បន្ទាយមានជ័យ កំពង់ចាម កំពត និងខេត្តព្រះសីហនុ។

- ចេញវិញ្ញាបនបត្របញ្ជាក់ (១).គោលការណ៍អនុវត្តអនាម័យល្អ ដល់ភោជនីយដ្ឋាន ២៤១ កន្លែង (២).គោលការណ៍អនុវត្តអនាម័យល្អសម្រាប់រោងចក្រ សិប្បកម្មផលិតចំណីអាហារ ១៥ កន្លែង និង (៣).អនាម័យផលិតផលចំណីអាហារ សម្រាប់ផលិតផលចំណីអាហារនាំចេញ និងលក់ក្នុងស្រុក ១៤៥ មុខ។
- ចេញលិខិតអនុញ្ញាតផ្សព្វផ្សាយផលិតផលទឹកដោះគោម្សៅ ៥២៤ ឯកសារ ក្នុងនោះមានស្លាកសញ្ញាផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ ១០០ ឯកសារ អនុញ្ញាតផ្សព្វផ្សាយផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ ៤០១ ឯកសារ និងសិក្ខាសាលាផ្សព្វផ្សាយផលិតផលសម្រាប់ទារកនិងកុមារ ផ្សព្វផ្សាយផលិតផលចំណីអាហារ ១៩ ឯកសារ។
- ចុះយកសំណាកចំណីអាហារនៅតាមភោជនីយដ្ឋាន អាហារដ្ឋាន ចំណីអាហារលក់តាមផ្លូវ និងតាមផ្សារនៅរាជធានីភ្នំពេញ ខេត្តសៀមរាប កំពត បាត់ដំបង និងកំពង់ឆ្នាំង ចំនួន ៥០០សំណាកមកវិភាគដោយប្រើតេស្តរហ័សដើម្បីរកសារធាតុគីមីដាក់ក្នុងចំណីអាហារ និងមេរោគនៅក្នុងចំណីអាហារ សម្ភារផ្ទះបាយ។ លទ្ធផលវិជ្ជមានបានរកឃើញលើសំណាក ១៥០៖ មាន Borax ៤២ សំណាក Formalin ២៨ សំណាក Sodium Hydrosulfite ២ សំណាក Synthetic Color ៥ សំណាក ភាពស្អាត (Cleanliness) ១៣ សំណាក Coliform នៅក្នុងចំណីអាហារ ទឹក និងទឹកកក ៦១ សំណាក និង Staphylococcus Aureus) ៤ សំណាក។
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងការបណ្តុះបណ្តាលស្តីពីអនាម័យ និងសុវត្ថិភាពចំណីអាហារដល់ម្ចាស់ឬអ្នកតំណាង អ្នករៀបចំចំណីអាហារ ចុងភៅ អ្នកប៉ះពាល់ចំណីអាហារ នៅតាមភោជនីយដ្ឋាន អាហារដ្ឋាន និងអ្នកគ្រប់គ្រង បុគ្គលិក តាមសាខារបស់ក្រុមហ៊ុនកាហ្វេ។
- បណ្តុះបណ្តាលអំពីកូនសោគន្លឹះទាំង៥ ដើម្បីធ្វើឱ្យផ្សារម្ហូបអាហារបែបប្រពៃណីមានអនាម័យ និងសុវត្ថិភាពដល់អាជីវករតាមផ្សារ សណ្ឋាគារ និងគ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ៦.១.៧. និយ័តកម្មសេវាសុខាភិបាលឯកជន

**ក. ស្ថិតិសេវាសុខាភិបាលឯកជន៖** ក្នុងឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលឯកជនគ្រប់ប្រភេទ ក្នុងទូទាំងប្រទេសត្រូវបានផ្តល់អាជ្ញាបណ្ណប្រកបអាជីវកម្មមាន ចំនួន ២ ៧៩៦ កន្លែង ក្នុងនោះ មានបន្ទប់ព្យាបាល ២ ៦៧៦ កន្លែង និងមន្ទីរព្យាបាល ១២០ កន្លែង និងផ្តល់អាជ្ញាបណ្ណបន្តសុពលភាពចំនួន ៣ ៦០៩ កន្លែង ក្នុងនោះ មានបន្ទប់ព្យាបាល ៣ ៤២០ កន្លែង និងមន្ទីរព្យាបាល ១៨៩ កន្លែង (តារាង ៧.១. ក្នុងឧបសម្ព័ន្ធ ៧)។

**ខ. ការពង្រឹងអនុលោមភាពនិយ័តកម្ម៖** ក្នុងឆ្នាំ២០២៥ សេវាសុខាភិបាលឯកជនប្រភេទបន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះ បន្ទប់ថែទាំ បន្ទប់ពិគ្រោះព្យាបាលចំនួន ១ ០១៤ កន្លែង និងមន្ទីរពហុព្យាបាល មន្ទីរសម្រាកព្យាបាល និងមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ចំនួន ៦៨ ត្រូវបានបិទ ដោយមូលហេតុផ្សេងៗ (តារាង ៦.៤.)។ បើធៀបនឹងឆ្នាំ២០២៤ (៥៩៤ កន្លែងបានបិទ) សេវាសុខាភិបាលឯកជនដែលត្រូវបានបិទក្នុងឆ្នាំ២០២៥ មានចំនួនច្រើនគួរឱ្យកត់សម្គាល់។ ការណ៍នេះអាចបញ្ជាក់ពីប្រសិទ្ធភាពនៃការពង្រឹងអនុលោមភាពនិយ័តកម្ម និងការភ្ញាក់រលឹករបស់អ្នកផ្តល់សេវាសុខាភិបាលឯកជន(បិទដោយខ្លួនឯង)។ ដោយឡែក ទីតាំងផ្តល់សេវាសុខាភិបាលឯកជនចំនួន ៣៨ កន្លែង ត្រូវបានទទួលការណែនាំ និងការព្រមានផាកពិន័យ ដោយសារគ្មានលិខិតអនុញ្ញាតឬលិខិតអនុញ្ញាតហួសសុពលភាព និងការផ្សព្វផ្សាយពាណិជ្ជកម្មដោយគ្មានការអនុញ្ញាត (តារាង ៦.៥.)។

## តារាង ៦.៤. ស្ថិតិសេវាសុខាភិបាលឯកជនតាមប្រភេទ ដែលត្រូវបានបិទ ក្នុងឆ្នាំ២០២៥

| ប្រភេទសេវា | ចំនួនបិទ | មូលហេតុនៃការបិទ | | | |
|---|---|---|---|---|---|
| 1. បន្ទប់ | | កំហុស | ស្នើសុំ | បិទខ្លួនឯង | បិទបណ្ដោះអាសន្ន * |
| បន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះមុន/ក្រោយសម្រាល | 207 | 5 | 111 | 11 | 80 |
| បន្ទប់ថែទាំជំងឺ | 457 | 29 | 244 | 27 | 157 |
| បន្ទប់ថែទាំជំងឺមាត់-ធ្មេញ | 87 | 19 | 25 | 8 | 35 |
| បន្ទប់ព្យាបាលដោយចលនា | 5 | 1 | 2 | 0 | 2 |
| បន្ទប់ពិគ្រោះព្យាបាលជំងឺទូទៅ | 198 | 17 | 116 | 29 | 36 |
| បន្ទប់ពិគ្រោះជំងឺមាត់-ធ្មេញ | 57 | 21 | 18 | 5 | 13 |
| បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែក | 1 | 0 | 1 | 0 | 0 |
| បន្ទប់ពិគ្រោះជំងឺត្រចៀក ច្រមុះ បំពង់ក | 2 | 0 | 1 | 1 | 0 |
| **សរុប** | **1,014** | **92** | **518** | **81** | **323** |
| 2. មន្ទីរ | ចំនួនបិទ | កំហុសធ្ងន់ | ស្នើសុំបិទ | បិទខ្លួនឯង | បិទបណ្ដោះអាសន្ន* |
| មន្ទីរពហុព្យាបាល | 6 | 1 | 2 | 0 | 3 |
| មន្ទីរសម្រាកព្យាបាល | 52 | 2 | 39 | 6 | 5 |
| មន្ទីរព្យាបាលជំងឺផ្លូវចិត្ត | 1 | 0 | 1 | 0 | 0 |
| មន្ទីរពិសោធន៍វេជ្ជសាស្ត្រ | 2 | 0 | 2 | 0 | 0 |
| មជ្ឈមណ្ឌលកែសម្ផស្ស | 7 | 0 | 7 | 0 | 0 |
| **សរុប** | **68** | **3** | **51** | **6** | **8** |

* ការបិទក្នុងរយៈពេលមួយដើម្បីទុកពេលឱ្យម្ចាស់សេវាសុខាភិបាលឯកជនធ្វើការកែលម្អចំណុចខ្វះខាត ដែលក្រុម ការងារត្រួតពិនិត្យ ក្រសួងសុខាភិបាលបានពិនិត្យរកឃើញ។

**តារាង ៦.៥.** ស្ថិតិសេវាសុខាភិបាលឯកជនតាមប្រភេទ ដែលត្រូវបានណែនាំ និងព្រមានផាកពិន័យ ក្នុងឆ្នាំ២០២៥

| ល.រ | ប្រភេទសេវា | គ្មាន ឬហួសសុពលភាពនៃលិខិតអនុញ្ញាត | ផ្សាយពាណិជ្ជកម្មគ្មានការអនុញ្ញាត | សរុប |
|---|---|---|---|---|
| 1 | មន្ទីរព្យាបាលមាត់-ធ្មេញ | 1 | | 1 |
| 2 | មន្ទីរពិសោធន៍ | 3 | | 3 |
| 3 | មន្ទីរសម្ភព | | | 0 |
| 4 | មន្ទីរសម្រាកព្យាបាល | 16 | | 16 |
| 5 | មន្ទីរពហុព្យាបាល | 4 | | 4 |
| 6 | មន្ទីរពេទ្យឯកជន | 1 | | 1 |
| 7 | មជ្ឈមណ្ឌលកែសម្ផស្ស | 9 | 2 | 11 |
| 8 | មជ្ឈមណ្ឌលថែរក្សាសម្ផស្ស | | 1 | 1 |
| 9 | បន្ទប់ពិគ្រោះជំងឺ | | 1 | 1 |
| | **សរុប** | **34** | **4** | **38** |

## ៦.១.៨. ការកសាងភាពជាដៃគូសាធារណៈ-ផ្នែកឯកជន

ក្នុងឆ្នាំ២០២៥ ក្នុងនាមជាសហប្រធាននៃក្រុមការងារផ្នែកសុខាភិបាល ឬក្រុម «ឋ» នៃវេទិការាជរដ្ឋាភិបាល-ឯកជន ក្រសួងសុខាភិបាលបានប្រជុំក្រុមការងារ ១ លើក និងបានដោះស្រាយបញ្ហាចំនួន ៨ ក្នុងចំណោមបញ្ហាចំនួន ១២ ដែលផ្នែកឯកជនបានលើកឡើង។ រីឯបញ្ហាដែលនៅសេសសល់កំពុងបន្តដោះស្រាយ។

## ៦.១.៩. កិច្ចសហការ និងសហប្រតិបត្តិការ

ក. កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន៖ ក្នុងឆ្នាំ២០២៥ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិបានសម្របសម្រួលការអនុវត្តសកម្មភាពសុខាភិបាល នៅក្នុងក្របខ័ណ្ឌកម្មវិធីអភិវឌ្ឍន៍សុខភាពអាស៊ាន (APHDA) ២០២១–២០២៥ ដែលមានសកម្មភាពសរុបចំនួន ១៧០ ក្នុងនោះ ១៤១ សកម្មភាពត្រូវបានសម្រេច។ ក្រុមការងារសុខាភិបាលអាស៊ានទាំងបួន បានបង្ហាញពីភាពរួបរួមគ្នា និងសមត្ថភាពតំបន់ក្នុងការឆ្លើយតបនឹងអាទិភាពសុខាភិបាលសហគមន៍អាស៊ាន។ ទោះជាដូច្នេះក្តី កម្រិតសមត្ថភាព និងកម្រិតធនធានផ្សេងៗគ្នា នៃប្រទេសជាសមាជិក ភាពស្មុគស្មាញនៃការសម្របសម្រួលនិងយន្តការអនុវត្តគឺជាបញ្ហាប្រឈមចម្បង។ ក្របខ័ណ្ឌ APHDA ២០២៦–២០៣០ ផ្តោតលើភាពធន់ សមធម៌ និរន្តរភាព និងនវានុវត្តន៍ ដើម្បីគាំទ្រចក្ខុវិស័យសហគមន៍អាស៊ាន ឆ្នាំ២០៤៥។ ក្រសួងសុខាភិបាល បានចូលរួមយ៉ាងសកម្មក្នុងការពិនិត្យ ពិភាក្សា និងផ្តល់យោបល់លើឯកសារទស្សនាទាន សេចក្តី

ថ្លែងការណ៍រួម និងឯកសារពាក់ព័ន្ធផ្សេងទៀត នៅក្នុងក្របខ័ណ្ឌអាស៊ាន និងអាស៊ានបូក។ នៅ ឆ្នាំ២០២៦ ប្រទេសម៉ាឡេស៊ី នឹងជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំឧត្តមមន្ត្រីសុខាភិបាលអាស៊ានលើកទី២០ និងកិច្ចប្រជុំពាក់ព័ន្ធ ព្រមទាំងកិច្ចប្រជុំរដ្ឋមន្ត្រីសុខាភិបាលអាស៊ានលើកទី១៧ និងកិច្ចប្រជុំពាក់ព័ន្ធ។

**ខ. កិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌពហុភាគី និងទ្វេភាគី៖** ក្នុងឆ្នាំ២០២៥ ដោយបានទទួលសិទ្ធិប្រទានពីប្រមុខដឹកនាំរដ្ឋាភិបាល ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាលបានដឹកនាំគណប្រតិភូកម្ពុជា ចូលរួម និងថ្លែងការណ៍ នៅក្នុងមហាសន្និបាតសុខភាពពិភពលោក លើកទី៧៨ នៅទីក្រុងហ្សឺណែវ សហព័ន្ធស្វីស និងសម័យប្រជុំប្រចាំឆ្នាំលើកទី៧៦ របស់គណកម្មការតំបន់នៃអង្គការសុខភាពពិភពលោកតំបន់ប៉ាស៊ីហ្វិកខាងលិច នៅទីក្រុងណាឌី ប្រទេសហ្វីជី (ប្រទេសកោះស្ថិតនៅក្នុងភាគកើតនៃមហាសមុទ្រប៉ាស៊ីហ្វិក។ បន្ថែមលើនេះ ឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រី អមដោយថ្នាក់ដឹកនាំនិងមន្ត្រីជំនាញ បានជួបពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងវិស័យសុខាភិបាលជាមួយទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ អង្គទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនលើក។

**គ. កិច្ចសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល៖** នៅឆ្នាំ២០២៥ អង្គការជាតិមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាលចំនួន ១២៣ អង្គការ កំពុងអនុវត្តគម្រោងនានានៅក្នុងវិស័យសុខាសភិបាល ក្នុងនោះអង្គការមិនមែនរដ្ឋាភិបាល ដែលកិច្ចព្រមព្រៀងនៅមានសុពលភាពមានចំនួន ៩៤ អង្គការ និងដែលបានចុះកិច្ចព្រៀមព្រៀងថ្មីមានចំនួន ២៩អង្គការ (អង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល ១៩ និង អង្គការជាតិមិនមែនរដ្ឋាភិបាល ១០អង្គការ)។ ក្រសួងសុខាភិបាល/នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ បានសម្របសម្រួលជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លើលិខិតគាំទ្រជូនអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល ចំនួន ២២ លិខិត ដើម្បីបន្តសុពលភាពនៃអនុស្សរណៈនៃការយោគយល់គ្នា និងបានជួយសម្របសម្រួលការនាំចូលជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាលចំនួន ៥៤ អង្គការ។

**ឃ. ក្រុមការងារបច្ចេកទេសសុខាភិបាល៖** លេខាធិការដ្ឋាន និងក្រុមការងារបច្ចេកទេសសុខាភិបាលដែលជាយន្តការលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងវិស័យសុខាភិបាល រវាងក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល បានប្រជុំប្រចាំខែយ៉ាងទៀងទាត់។ កិច្ចប្រជុំបានចែករំលែកព័ត៌មានបច្ចុប្បន្នភាពចាំបាច់នានា និងបទពិសោធន៍ដែលពាក់ព័ន្ធនឹងអាទិភាពសុខភាពជាក់លាក់ តាមរយៈការផ្ដល់ទស្សនៈទានលើបទបង្ហាញ (៣-៤បទបង្ហាញក្នុងកិច្ចប្រជុំប្រចាំខែនីមួយៗ) ដែលឧទ្ទេសដោយនាយកដ្ឋាន អង្គភាពសុខាភិបាលថ្នាក់ មន្ទីរសុខាភិបាលរាជធានី ខេត្ត និងដៃគូអភិវឌ្ឍ។

- **នៅក្នុងឆមាសទីមួយ៖** កិច្ចប្រជុំបានផ្ដោតលើមូលបទសំខាន់ៗ ដូចជា៖ ការលុបបំបាត់ជំងឺគ្រុនចាញ់ និងការគ្រប់គ្រងជំងឺដែលឆ្លងតាមភ្នាក់ងារចម្លង(វ៉ិចទ័រ) ការស្វែងយល់ពីបរិវត្តកម្ម សុខាភិបាលឌីជីថល និងបញ្ញាសិប្បនិម្មិតក្នុងការថែទាំសុខភាព ការអភិវឌ្ឍនិងការរក្សាកម្លាំងពលកម្មសុខាភិបាល ការគ្រប់គ្រងជំងឺមិនឆ្លងនិងការគាំទ្រសុខភាពផ្លូវចិត្ត-ចិត្តសង្គម ការពិនិត្យមើលអន្តរាគមន៍ដើម្បីកែលម្អការថែទាំសុខភាពបឋម ប្រព័ន្ធមន្ទីរពេទ្យ និងការធ្វើសមាហរណកម្មសេវាដើម្បីធានាបាននូវការចូលទៅប្រើប្រាស់គុណភាព និងការគ្របដណ្ដប់កាន់តែប្រសើរ។

- **នៅក្នុងឆមាសទីពីរ៖** កិច្ចប្រជុំបានផ្តោតលើមូលបទសំខាន់ៗ ផ្សេងទៀត ដូចជា៖ សន្តិសុខសុខភាពជាពិសេសផលប៉ះពាល់លើប្រជាជនដែលងាយរងគ្រោះ សមធម៌សុខភាពនិងហិរញ្ញប្បទានសុខាភិបាល ការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងជំងឺដែលឆ្លងតាមអាហារដែលផ្តោតលើការកិច្ចសហការពហុវិស័យ ប្រព័ន្ធគ្រប់គ្រងការផ្គត់ផ្គង់និងហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល សុខភាពបន្តពូជ មាតា ទារក និងកុមារ និងអាហារូបត្ថម្ភ ការចូលរួមរបស់ វិស័យឯកជនក្នុងការថែទាំសុខភាពដោយសង្កត់ធ្ងន់លើការនវានុវត្តន៍ និងភាពជាដៃគូរវាងរដ្ឋ និងឯកជន និងការអភិវឌ្ឍវិស័យសុខភាពប្រកបដោយចីរភាព។

## ៦.២. ការអភិវឌ្ឍធនធានមនុស្ស

ធានាប្រព័ន្ធសុខាភិបាលដំណើរការប្រកបដោយប្រសិទ្ធភាព ដោយមានធនធានមនុស្សគ្រប់គ្រាន់ ប្រកបដោយគុណភាពខ្ពស់ ដើម្បីផ្តល់សេវាថែទាំសុខភាពប្រកបដោយប្រសិទ្ធភាព និងឆ្លើយតបនឹងតម្រូវការសុខភាពវិវត្តរបស់ប្រជាជន នាពេលបច្ចុប្បន្ន និងពេលអនាគត។

### ៦.២.១. ការរៀបចំផែនការអភិវឌ្ឍធនធានមនុស្ស

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សសុខាភិបាលឆ្នាំ២០២៥-២០៣៤ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការកាលពីថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០២៥។ ផែនការនេះ គឺជាឧបករណ៍ផែនការនីយកម្មធនធានមនុស្សសុខាភិបាលរយៈពេលវែង។ ធនធានមនុស្សសុខាភិបាលសមស្របសម្រាប់អនាគត ដើម្បីធានាការរស់នៅប្រកបដោយសុវត្ថិភាព សុខភាពល្អ និងសុខុមាលភាព សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប» និងមានគោលបំណងឈានដល់ការសម្រេចឱ្យបាននូវ ប្រព័ន្ធសុខាភិបាលមានធនធានមនុស្សគ្រប់គ្រាន់ មានជំនាញចម្រុះ ទឹកចិត្តមុះមុត អនុវត្តតាមនិយ័តកម្មត្រឹមត្រូវ និងដោយសមធម៌ ដើម្បីផ្តល់ការថែទាំប្រកបដោយគុណភាព និងក្រមសីលធម៌ ដោយផ្តោតលើប្រជាជនជាស្នូល។ ផែនការនេះនឹងការបង្កើនវឌ្ឍនភាព និងពន្លឿនដំណើរការ ប្រព័ន្ធសុខាភិបាលកាន់តែរឹងមាំ ជាមួយបុគ្គលិកសុខាភិបាល ដែលមានការបណ្តុះបណ្តាលសមស្រប ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងការផ្តល់សិទ្ធិសម្រេចក្នុងការបម្រើសេវាសុខភាពគ្រប់ជ្រុងជ្រោយ ដែលប្រជាជនត្រូវការ។

### ៦.២.២. ការសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវៈសុខាភិបាល

ក្នុងឆ្នាំ២០២៥ គ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈសុខាភិបាលមានចំនួន ១៩ ដូចក្នុងឆ្នាំ២០២៤ ដែរ ក្នុងនោះ គ្រឹះស្ថានសាធារណៈមានចំនួន ៧ និងឯកជនចំនួន ១២។ **ប្រព័ន្ធបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលត្រូវបានធ្វើជា ៣ ផ្នែក៖ (១).ការបណ្តុះបណ្តាលមុនពេលបម្រើការងារ (២).ការបណ្តុះបណ្តាលក្រោយមូលដ្ឋាន និង (៣). ការបណ្តុះបណ្តាលកំពុងបម្រើការងារ។**

ក. ការបណ្តុះបណ្តាលមុនពេលបម្រើការងារ មាន២ កម្រិត គឺកម្រិតឧត្តម (បរិញ្ញាបត្រ) និងកម្រិតមធ្យម (បរិញ្ញាបត្ររង)។ លទ្ធផលដែលសម្រេចបានក្នុងឆ្នាំសិក្សា២០២៥ មានដូចខាងក្រោម៖

- **កម្រិតឧត្តម៖** បេក្ខជនដែលបានចូលរួមក្នុងការប្រឡងថ្នាក់ជាតិជ្រើសរើសចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន កម្រិតបរិញ្ញាបត្រក្នុងឆ្នាំសិក្សា ២០២៤-២០២៥ នៅគ្រឹះស្ថានបណ្តុះបណ្តាល ចំនួន ១២ មានចំនួនសរុប

១០ ៥២៧នាក់ ប្រឡងជាប់ ៣ ២៧៧ នាក់ ហើយចំនួនបេក្ខជនដែលប្រឡង ជាប់ត្រូវបានរាប់បញ្ចូលទៅក្នុងចំនួននិស្សិតកំពុងសិក្សា។ រីឯការប្រឡងជ្រើសរើសបេក្ខជនចូលរៀនថ្នាក់ ឆ្នាំសិក្សាមូលដ្ឋានសម្រាប់កម្រិតបរិញ្ញាបត្រ ឆ្នាំសិក្សា២០២៥-២០២៦ កំពុងដំណើរការរៀបចំ។ និស្សិតកំពុងសិក្សាកម្រិតបរិញ្ញាបត្រ មានចំនួន ១២ ៥៨៨ នាក់ (ស្រី ៧ ៩៨៨ នាក់) និងនិស្សិតបាន និងកំពុងត្រៀមប្រឡងបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្រ មានចំនួន ២ ៣០១ នាក់ (ស្រី ១ ៣៤៥ នាក់)។

- **កម្រិតមធ្យម៖** បេក្ខជនដែលបានចូលរួមក្នុងការប្រឡងថ្នាក់ជាតិជ្រើសរើសចូលរៀនថ្នាក់ឆ្នាំទី១ កម្រិតបរិញ្ញាបត្ររង សម្រាប់ឆ្នាំសិក្សា២០២៤-២០២៥ នៅគ្រឹះស្ថានបណ្ដុះបណ្ដាល ចំនួន ១៧ មានចំនួនសរុប ៥ ៨៩៩ នាក់ ប្រឡងជាប់សរុប ៣ ៦៩២ នាក់ ហើយ បេក្ខជនដែលប្រឡងជាប់ត្រូវបានរាប់បញ្ចូលទៅក្នុងចំនួននិស្សិតកំពុងសិក្សា។ ចំពោះការប្រឡងថ្នាក់ជាតិជ្រើសរើសចូលរៀនថ្នាក់ឆ្នាំទី១ សម្រាប់កម្រិតបរិញ្ញាបត្ររង ឆ្នាំសិក្សា២០២៥-២០២៦ កំពុងដំណើរការរៀបចំ។ និស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រមានចំនួន ៨ ៦៦៩ នាក់ (ស្រី ៦ ២៩០ នាក់) និងនិស្សិតបាន និងកំពុង ត្រៀមប្រឡងបញ្ចប់ការសិក្សាកម្រិតបរិញ្ញាបត្ររងមានចំនួនសរុប ២ ៣៩៩ នាក់ (ស្រី ១ ៦៩៩ នាក់)។

**តារាង ៦.៦.** និស្សិតប្រឡងថ្នាក់ជាតិជាប់ចូលរៀននិងបញ្ចប់ការសិក្សា ពីឆ្នាំ២០២១-២០២៥ (នាក់)

| កម្រិត | ឆ្នាំសិក្សា | | | | |
|---|---|---|---|---|---|
| **កម្រិតឧត្តម** | **2020-21** | **2021-22** | **2022-23** | **2023-24** | **2024-25** |
| ▪ ជាប់ចូលរៀន | 2645 | 2364 | 2961 | 3184 | 3,277 |
| ▪ បញ្ចប់ការសិក្សា | 1,525 | 2,217 | 1,703 | 2,042 | 2,301 |
| **កម្រិតមធ្យម** | | | | | |
| ▪ ជាប់ចូលរៀន | 2,591 | 3,435 | 3,871 | 3,565 | 3,692 |
| ▪ បញ្ចប់ការសិក្សា | 1,017 | 2,238 | 2,293 | 2,947 | 2,399 |

**ខ. ការបណ្ដុះបណ្ដាលក្រោយមូលដ្ឋាន** គឺជាកម្មវិធីបណ្ដុះបណ្ដាលឯកទេស និងសុខភាពសាធារណៈកម្រិតខ្ពស់ ដែលផ្ដល់ដោយសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល សាកលវិទ្យាល័យអន្តរជាតិ (គ្រឹះស្ថានឯកជន) និងសាលាសុខភាពសាធារណៈនៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ។ លទ្ធផលដែលសម្រេចបាននៅក្នុងឆ្នាំ សិក្សា ២០២៤-២០២៥ មានដូចខាងក្រោម៖

- **សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល** បានធ្វើការប្រឡងជ្រើសរើសនិស្សិតចូលរៀន៖ (១).ថ្នាក់វេជ្ជបណ្ឌិតឯកទេស ចំនួន ២៣៧ នាក់ សម្រាប់មុខវិជ្ជាឯកទេសចំនួន ២១ (២).បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវះកាត់មុខមាត់-ឆ្អឹងថ្គាម និងផ្នែកពត់ធ្មេញ ចំនួន ២៤ នាក់ និង (៣).ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សុខភាពសាធារណៈ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អេពីដេមីសាស្ត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំងឺឆ្លង សរុប

ចំនួន ៦២ នាក់ (តារាង ៩.១ ឧបសម្ព័ន្ធ ៩)។ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំងឺឆ្លង មាននិស្សិតបរទេសចូលរួមសិក្សា ៥ នាក់ មកពីប្រទេសបារាំង ប៉ាគីស្ថាន បង់ក្លាដេស និង Guinea។ និស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំងឺឆ្លងនេះនឹងទទួលបានសញ្ញាបត្រចំនួនពីរមួយចេញដោយសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល និងមួយទៀតដោយសាកលវិទ្យាល័យប៉ារីសសាក់ក្លេ ។

- **សាកលវិទ្យាល័យអន្តរជាតិ** បានធ្វើការប្រឡងជ្រើសរើសនិស្សិតចូលរៀនថ្នាក់វេជ្ជបណ្ឌិតឯកទេស ចំនួន ៧៣នាក់ សម្រាប់មុខវិជ្ជាឯកទេសចំនួន ១០ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២១ នាក់ សម្រាប់មុខវិជ្ជា ៥។
- **វិទ្យាស្ថានជាតិសុខភាពសាធារណៈ** បានធ្វើការជ្រើសរើសបេក្ខជនចូលរៀន៖ (១).ថ្នាក់បណ្ឌិតសុខភាពសាធារណៈ ០៦ នាក់ (២). ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សុខភាពសាធារណៈផ្នែកអភិវឌ្ឍន៍ប្រព័ន្ធសុខាភិបាល ២២ នាក់ (៣).ផ្នែកសេដ្ឋកិច្ច និងហិរញ្ញប្បទានសុខាភិបាល ៩ នាក់ (៤).ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រផ្នែកអេពីដេមីសាស្ត្រចំនួន ១១ នាក់ (៥).ផ្នែកអាហារូបត្ថម្ភ ១៤ នាក់ (៦).ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងមន្ទីរពេទ្យចំនួន ៣១ នាក់ និង (៧).ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសុខភាព និងអភិវឌ្ឍន៍សហគមន៍ ១២ នាក់។

គ. **ការបណ្តុះបណ្តាលក្នុងពេលបំរើការងារ** គឺជាការបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការសុខាភិបាល រួមទាំង គ្រូពេទ្យ បុគ្គលិកព្យាបាល និងថែទាំ ដែលមានរយៈពេលតិចជាង ៦ខែ និង លើសពី ៦ខែ នៅក្នុងប្រទេស និងក្រៅប្រទេស។ លទ្ធផលដែលសម្រេចបាននៅក្នុងឆ្នាំ២០២៥ មានដូចខាងក្រោម៖

- **នៅក្នុងប្រទេស៖** រយៈពេលខ្លីតិចជាង៦ខែ មានមន្ត្រីចូលរួមចំនួន ១៣៣ នាក់ (ស្រី ៤៨ នាក់) និងរយៈពេលលើសពី៦ខែឡើង មានមន្ត្រីចូលរួម ៤នាក់ (ស្រី ០នាក់)។
- **នៅក្រៅប្រទេស៖** រយៈពេលតិចជាង៦ខែ មានមន្ត្រីចូលរួម ចំនួន ៤១៣ នាក់ (ស្រី ១៣៤ នាក់) និងតាម Online ០១ នាក់ (ស្រី ០ នាក់) និងរយៈពេលវែងចាប់ពី៦ខែឡើង ចំនួន ១៨ នាក់ (ស្រី ៨ នាក់) ក្នុងនោះ ថ្នាក់បណ្ឌិតវិទ្យាសាស្ត្រចំណីអាហារ និងបច្ចេកវិទ្យា ០១ នាក់ (ស្រី ០១ នាក់) សិក្សានៅសហរដ្ឋអាមេរិក។ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសុខភាពសាធារណៈចំនួន ០៣ នាក់ (ស្រី ០៣ នាក់) សិក្សានៅប្រទេសអូស្ត្រាលីណូវែលសេឡង់ និងជប៉ុន។ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវះកាត់ ចំនួន ០១ នាក់ (ស្រី ០ នាក់) សិក្សានៅសាធារណរដ្ឋប្រជាមានិតចិន។ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកថែទាំ និង បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងសុខាភិបាល ចំនួន ០៣ នាក់ (ស្រី ០ នាក់) សិក្សានៅប្រទេសជប៉ុន។ បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកប្រព័ន្ធថែទាំសុខភាព និងរបបសន្តិសុខសង្គម ចំនួន ០១ នាក់ (ស្រី ០១ នាក់) សិក្សានៅប្រទេសជប៉ុន។ និងបានធ្វើកម្មសិក្សាថ្នាក់វេជ្ជបណ្ឌិតឯកទេសផ្នែកផ្នែកសង្គ្រោះបន្ទាន់កម្រិតធ្ងន់លើកុមារ និងទារក ការវះកាត់ផ្នែកឆ្អឹង និងបាក់បែក ផ្នែកជំងឺសួត ផ្នែកប្រពោធនកម្ម សញ្ញាប័ត្របណ្តុះបណ្តាលផ្នែកឯកទេសវេជ្ជសាស្ត្រជាន់ខ្ពស់ កម្មវិធីវិទ្យាសាស្ត្រផ្នែកមន្ទីរពិសោធន៍វេជ្ជសាស្ត្រ និង ផ្នែកការវះកាត់បេះដូង ចំនួន ០៩ នាក់ (ស្រី ០៣ នាក់) សិក្សានៅប្រទេសបារាំង កាណាដា និងឥណ្ឌូនេស៊ី។

ឃ. ការចុះបញ្ជិកា វិញ្ញាបនបត្រ ក្នុងឆ្នាំ២០២៥ នាយកដ្ឋានអភិវឌ្ឍធនធានមនុស្សបាន៖

- ពិនិត្យកែសម្រួល និងបញ្ចូលព័ត៌មានមន្ត្រី និងវគ្គបណ្តុះបណ្តាលមុន-/ក្នុងពេលបម្រើការងារ ចំនួន ៦៥៥នាក់។
- ពិនិត្យភាពត្រឹមត្រូវលើការធ្វើវិញ្ញាបនបត្របញ្ជាក់ការសិក្សា វគ្គបណ្តុះបណ្តាលគ្រូបង្គោចំនួន ១៥ នាក់ លើម៉ូឌុលចំនួន ៨។
- ពិនិត្យភាពត្រឹមត្រូវលើការធ្វើវិញ្ញាបនបត្របញ្ជាក់ការសិក្សាវគ្គវិក្រឹតការវេជ្ជបណ្ឌិតថ្នាក់មន្ទីរពេទ្យបង្អែក ស្តីពីការសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបកើត ១១ នាក់។
- ថ្នាល e-Learning platform មានអ្នកចុះឈ្មោះចូលរៀនចំនួន ២២៤ នាក់ និងបានពិភាក្សាជាមួយ អង្គការ JICA អំពីការកែសម្រួលលើការប្រើប្រាស់ platform នេះ។
- ទទួលព័ត៌មានស្តីពីការបណ្តុះបណ្តាល និងប្រវត្តិរូបមន្ត្រីដែលបានចូលរួមក្នុងការបណ្តុះបណ្តាលពីមន្ទីរ ពេទ្យជាតិ ១០ មជ្ឈមណ្ឌលជាតិ ៤ វិទ្យាស្ថានជាតិ១ នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងសាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល។

## ៦.២.៣. ការពង្រឹងគុណភាពការសិក្សានិងការបណ្តុះបណ្តាល

សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលបានកែលម្អឧបករណ៍បង្រៀន និងវិធីសាស្ត្របង្រៀន សម្រាប់ ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្ររង និងថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ក្នុងនោះរួមមាន៖

- គម្រោងលម្អិតនៃមុខវិជ្ជា (Course Syllabus) ដោយផ្អែកលើសមត្ថភាពស្នូលសម្រាប់ថ្នាក់បរិញ្ញាបត្រ ទន្តវេទនសាស្ត្រ ចំនួន ៣០ គម្រោង និងត្រួតពិនិត្យគុណភាពកម្រងសំណួរ MCQs ឱ្យស្របតាម គោលបំណងនៃមេរៀន និងស្របតាមសមត្ថភាពស្នូល ចំនួន ៩ ១៤២ សំណួរ
- កិច្ចតែងការបង្រៀន ដោយផ្តោតលើសមត្ថភាពស្នូល ចំនួន ៧១៣ កិច្ចតែងការបង្រៀន
- សេណារីយ៉ូ/បញ្ជីផ្ទៀងផ្ទាត់ ចំនួន ១៤៣ និងបញ្ចូលមេរៀន និងបង្រៀនតាមប្រព័ន្ធគ្រប់គ្រងការសិក្សា ចំនួន ៨៦ មុខវិជ្ជា
- ក្របខ័ណ្ឌសមត្ថភាពស្នូល ចំនួន ២៥ ឯកទេស
- បណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូ ចំនួន ១៥វគ្គ ដែលទាក់ទងនឹងគរុកោសល្យសុខាភិបាល របៀប ស្រាវជ្រាវឯកសារវិទ្យាសាស្ត្រ ការកំណត់ Blueprint និងការរៀបចំសំណួរ ផ្អែកលើ MCQs កិច្ចដំណើរ ការអនុវត្តកម្មវិធីសិក្សាជាតិថ្មីដោយផ្អែកលើសមត្ថភាពស្នូល ការប្រើប្រាស់ម៉ាស៊ីន Anatomage សម្រាប់ បណ្តុះបណ្តាល ការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមប្រព័ន្ធអនឡាញ ប្រព័ន្ធគ្រប់គ្រងការរៀន និង បង្រៀន។ល។
- ប្រើឧបករណ៍តាមដានវាយតម្លៃកម្មសិក្សាគ្លីនិក E-Portfolio & Electronic logbook សម្រាប់កម្មវិធី សិក្សាថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក ថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក និងកម្មវិធីអន្តរជាតិថ្នាក់បរិញ្ញាបត្រ គិលានុបដ្ឋាក។

### ៦.២.៤. ការគ្រប់គ្រងមន្ត្រីរាជការសុខាភិបាល

ក. ស្ថិតិមន្ត្រីរាជការសុខាភិបាល៖ រវាងឆ្នាំ២០២៤និង២០២៥ចំនួនមន្ត្រីរាជការសុខាភិបាលទូទាំងប្រទេស បានថយចុះ ១,៣៤% (ក្រាហ្វិក ៦.២) ពី ៣០ ៨៦៩ នាក់ (ស្រី ១៧ ០៨០ នាក់) មក ៣០ ៤៦១ នាក់ (ស្រី ១៦ ៧៣១ នាក់)។ នៅឆ្នាំ២០២៥ ក្រសួងមុខងារសាធារណៈបានរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រី ផ្អែកលើកិច្ចព្រមព្រៀងការងារចំនួន ៣២៩ នាក់ តាមមណ្ឌលសុខភាព ដើម្បីបំពេញបានចំនួន ៧ នាក់ សម្រាប់មណ្ឌលសុខភាពដែលមានបុគ្គលិកតិចជាង៧នាក់ក្នុងមួយមណ្ឌលសុខភាព យោងសេចក្តីសម្រេចលេខ ៤៦៣៨/២៥ មស.សសរ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៥។ គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ មន្ត្រីរាជការចំនួនសរុប ៣០ ៤៦១ នាក់ ក្នុងនោះមាន៖ វេជ្ជបណ្ឌិតឯកទេស ១ ១២៤ នាក់ វេជ្ជបណ្ឌិត ៣ ២៧០នាក់ គ្រូពេទ្យមធ្យម ៣៨៩ នាក់ ឱសថការីបណ្ឌិត ៣៥ នាក់ ឱសថការី ៧៤៤ នាក់ ឱសថការីមធ្យម ៦៧នាក់ ឱសថការីបឋម ២៦ នាក់ ទន្តបណ្ឌិត ៣២០ នាក់ ទន្តពេទ្យ ១៩នាក់ ទន្តគិលានុបដ្ឋាក ២៣៤ នាក់ បរិញ្ញាបត្រគិលានុបដ្ឋាក ៧៤៤ នាក់ គិលានុបដ្ឋាកមធ្យម ៩ ៧១២ នាក់ គិលានុបដ្ឋាកបឋម ២ ១៤៥ នាក់ បរិញ្ញាបត្រឆ្មប ៦៣២ នាក់ ឆ្មបមធ្យម ៥ ៨៧០ នាក់ ឆ្មបបឋម ១ ៩២៤ នាក់ បរិញ្ញាបត្រគិលានុបដ្ឋាក-ឆ្មប ១៥ នាក់ បរិញ្ញាបត្រមន្ទីរពិសោធន៍ ៣០នាក់ អ្នកបច្ចេកទេសមន្ទីរពិសោធន៍មធ្យម ១ ១៥៤ នាក់ អ្នកបច្ចេកទេសមន្ទីរពិសោធន៍បឋម ៤៥ នាក់ អ្នកបច្ចេកទេសព្យាបាលដោយចលនា ២៣២ នាក់ អ្នកបច្ចេកទេសវិទ្យុសាស្ត្រ ១៤៥ នាក់ និងជំនាញក្រៅសុខាភិបាល ១ ៥៨៥ នាក់ (តារាង ៦.៧.)។

**ក្រាហ្វិក ៦.២.** និន្នាការចំនួនសរុបមន្ត្រីរាជការសុខាភិបាល រវាងឆ្នាំ២០២០-២០២៥




**តារាង ៦.៧.** ស្ថិតិមន្ត្រីសុខាភិបាលសាធារណៈតាមប្រភេទបច្ចេកទេស ពីឆ្នាំ២០២០-២០២៥

| ប្រភេទបុគ្គលិក | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|
| វេជ្ជបណ្ឌិត/ឯកទេស | 3,923 | 4,547 | 4,591 | 4,469 | 4,394 | 4,394 |
| គ្រូពេទ្យមធ្យម | 599 | 561 | 424 | 400 | 389 | 389 |
| ឱសថការី/បណ្ឌិត/មធ្យម/បឋម | 859 | 958 | 938 | 893 | 872 | 872 |
| ទន្តបណ្ឌិត/ទន្តពេទ្យ/ទន្តគិលានុបដ្ឋាក | 546 | 605 | 612 | 589 | 573 | 573 |
| បរិញ្ញាបត្រឆ្មប | 458 | 551 | 632 | 623 | 632 | 744 |
| ឆ្មបមធ្យម | 5,426 | 6,144 | 5,820 | 5,911 | 5,870 | 9,712 |

| | | | | | | |
|---|---|---|---|---|---|---|
| ឆ្មបបឋម | 2,127 | 2,097 | 2,166 | 1,955 | 1,924 | 2,145 |
| បរិញ្ញាបត្រគិលានុបដ្ឋាក-ឆ្មប | 0 | 0 | 0 | 16 | 15 | 632 |
| បរិញ្ញាបត្រគិលានុបដ្ឋាក | 444 | 667 | 685 | 746 | 744 | 5,870 |
| គិលានុបដ្ឋាកមធ្យម | 9,194 | 10,315 | 9,812 | 9,717 | 9,712 | 1,924 |
| គិលានុបដ្ឋាកបឋម | 2,671 | 2,568 | 2,569 | 2,320 | 2,145 | 15 |
| អ្នកបច្ចេកទេសមន្ទីរពិសោធន៍បរិញ្ញាបត្រ/មធ្យម/បឋម | 1163 | 1296 | 1259 | 1,256 | 1,229 | 1,229 |
| អ្នកបច្ចេកទេសព្យាបាលដោយចលនា | 213 | 240 | 244 | 232 | 232 | 232 |
| វិទ្យុសាស្ត្រ | 124 | 145 | 145 | 142 | 145 | 145 |
| ជំនាញក្រៅសុខាភិបាល | 1,383 | 1,546 | 1,555 | 1,600 | 1,585 | 1,585 |
| **សរុប** | **29,130** | **32,240** | **31,452** | **30,869** | **30,461** | **30,461** |

**ខ. ការពង្រាយបុគ្គលិកសុខាភិបាល៖** មន្ត្រីរាជការសុខាភិបាលឆ្នាំ២០២៥ មានចំនួនសរុប ៣០ ៤៦១ នាក់ (ស្ត្រីចំនួន ១៦ ៧៣១ នាក់) ក្នុងនោះ មានមន្ត្រីរាជការបម្រើការងារនៅថ្នាក់ជាតិ ចំនួន ៧ ១៦៣ នាក់ (ស្ត្រីចំនួន ៣ ៦៧២ នាក់) ស្មើនឹង ២៣.៥២% និងមន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ ចំនួន ២៣ ២៩៨ នាក់ (ស្ត្រីចំនួន ១៣ ០៥៩ នាក់) ស្មើនឹង ៧៦.៤៨%។ ក្រាហ្វិក ៦.៣ និងតារាង ៦.៨. បង្ហាញពី និន្នាការនៃការពង្រាយមន្ត្រីរាជការសុខាភិបាលរវាង ឆ្នាំ២០២០ និងឆ្នាំ២០២៥។ នៅក្នុងឆ្នាំ២០២៥ ចំនួនមន្ត្រីរាជការនៅថ្នាក់ជាតិបានធ្លាក់ចុះ ០.១៦% (ពី ២៣.៦៨% ឆ្នាំ២០២៤ មក ២៣.៥២% ឆ្នាំ២០២៥) និងនៅថ្នាក់ក្រោមជាតិបានកើន ០.១៦% (ពី ៧៦.៣២% ឆ្នាំ២០២៤ ទៅ ៧៦.៤៨% នៅ ឆ្នាំ២០២៥) នៃចំនួនមន្ត្រីរាជការសរុបទូទាំងប្រទេស។ គួរកត់សម្គាល់ថា បុគ្គលិកមណ្ឌលសុខភាព បានថយចុះ ០.២៥% ពី ៣៥.៧៤% នៅឆ្នាំ២០២៤ កន្លែង (មណ្ឌលសុខភាពសរុប ១ ៣១៣) មក ៣៥.៤៩% នៅឆ្នាំ២០២៥ (មណ្ឌសុខភាពសរុប ១ ៣១៤)។

**ក្រាហ្វិក ៦.៣.** និន្នាការនៃការពង្រាយមន្ត្រីរាជការសុខាភិបាល រវាងឆ្នាំ ២០២១ និង ឆ្នាំ២០២៥ (% នៃចំនួនមន្ត្រីរាជការសរុប)



**តារាង៦.៨.** ស្ថិតិមន្ត្រីរាជការសុខាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រវាងឆ្នាំ២០២១-២០២៥ (គិតជា % នៃមន្ត្រីរាជការសុខាភិបាលសរុបទូទាំងប្រទេស)

| ថ្នាក់និងអង្គភាព | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|
| **1. ថ្នាក់កណ្តាល** | **21.04** | **21.92** | **23.75** | **23.68** | **22.98** |
| ទីស្តីការក្រសួង | 1.97 | 1.9 | 1.82 | 1.82 | 1.78 |
| មន្ទីរពេទ្យជាតិ | 14.85 | 15.96 | 17.35 | 17.38 | 17.33 |
| គ្រឹះស្ថានបណ្តុះបណ្តាល | 0.66 | 0.60 | 0.60 | 0.56 | 0.54 |
| អង្គភាពថ្នាក់កណ្តាល | 3.56 | 3.46 | 3.45 | 3.39 | 3.33 |
| **2. ថ្នាក់រាជធានី ខេត្ត** | **78.96** | **78.08** | **76.25** | **76.32** | **77.02** |
| មន្ទីរសុខាភិបាលរាជធានី ខេត្ត | 5.27 | 4.94 | 5.09 | 5.15 | 5.19 |
| មន្ទីរពេទ្យបង្អែកខេត្ត | 13.79 | 13.39 | 14.01 | 14.12 | 14.12 |
| ការិយាល័យស្រុកប្រតិបត្តិសុខាភិបាល | 5.72 | 5.41 | 5.82 | 5.81 | 5.94 |
| មន្ទីរពេទ្យបង្អែក | 16.04 | 16.17 | 15.41 | 15.49 | 15.75 |
| មណ្ឌលសុខភាព | 37.57 | 37.58 | 35.92 | 35.74 | 35.49 |
| សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | 0.56 | 0.58 | 0.53 | 0.53 | 0.54 |
| **សរុប** | **100%** | **100%** | **100%** | **100%** | **100%** |

**គ. ការគ្រប់គ្រងមន្ត្រីរាជការសុខាភិបាល៖** រវាងឆ្នាំ២០២០ និងឆ្នាំ២០២៥ ស្ថានភាពមន្ត្រីរាជការសុខាភិបាលមានការប្រែប្រួលគួរឱ្យកត់សម្គាល់ ដូចបង្ហាញនៅក្នុងតារាង ៦.៩។

**តារាង ៦.៩.** ស្ថានភាពនៃមន្ត្រីរាជការសុខាភិបាលឆ្នាំ២០២០-២០២៥

| | 2020 | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|---|
| មន្ត្រីរាជការសរុប | 25,449 | 29,130 | 32,240 | 31,452 | 30,869 | 30,461 |
| បញ្ចូលក្របខ័ណ្ឌ | 0 | 4,130 | 3,316 | 206 | 16 | 81 |
| តាំងស៊ុបក្នុងក្របខ័ណ្ឌ | 73 | 0 | 412 | 0 | 1,237 | 2 |
| ចូលនិវត្តន៍ | 399 | 83 | 81 | 83 | 91 | 104 |
| លុបចេញពីក្របខ័ណ្ឌ | 85 | 63 | 78 | 72 | 79 | 45 |
| ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | 65 | 66 | 59 | 144 | 136 | 70 |

**ការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលៈ** ក្នុងឆ្នាំ២០២៥ មន្ត្រីរាជការនៅថ្នាក់ជាតិ បានប្រកាសលុបឈ្មោះចេញពីក្របខ័ណ្ឌ ក្រសួងសុខាភិបាលរួមមានៈ មន្ត្រីរាជការទទួលមរណៈភាព បោះបង់កម្មសិក្សា លាឈប់ពីការងារ បោះបង់ការងារ និងឈប់ហួសកាលកំណត់ មានចំនួន ៤៥ នាក់ (១៧១ នាក់ នៅឆ្នាំ២០២៤) ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៧០នាក់ (១៣៦ នាក់ នៅឆ្នាំ២០២៤) និងមន្ត្រីរាជការដែលបានចូលមកបម្រើការងារវិញ បន្ទាប់ពីស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៤២ នាក់ (៤១ នាក់ នៅឆ្នាំ២០២៤)។

**ការផ្លាស់ប្តូរទីកន្លែងធ្វើការៈ** ក្នុងឆ្នាំ២០២៥ មន្ត្រីរាជការសុខាភិបាលក្នុងក្របខ័ណ្ឌមុខងារសាធារណៈត្រូវបានតែងតាំងតំឡើងឋានៈ មានចំនួន ២៤ នាក់ ក្នុងនោះ មានអនុប្រធានមជ្ឈមណ្ឌល ចំនួន ៧ នាក់ នាយករងមន្ទីរពេទ្យ ចំនួន ១ នាក់ ប្រធានការិយាល័យ ចំនួន ៩ នាក់ និងអនុប្រធានការិយាល័យ ចំនួន ៧ នាក់។ រីឯមន្ត្រីសុខាភិបាលដែលបានផ្លាស់ប្តូរទីកន្លែងធ្វើការងារមានចំនួនសរុប ១៩ នាក់ ក្នុងនោះផ្ទេរពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិចំនួន ១០ នាក់ ផ្ទេរពីថ្នាក់ជាតិទៅថ្នាក់ជាតិចំនួន ៦ នាក់ ផ្ទេរពីក្រសួងផ្សេងមកក្រសួងសុខាភិបាល ចំនួន ១ នាក់ និង ផ្ទេរពីក្រសួង សុខាភិបាលទៅក្រសួងផ្សេង ចំនួន ២នាក់។

**ការងារប្រាក់បៀវត្សពលកម្មៈ** ការបើកផ្តល់បៀវត្សសម្រាប់មន្ត្រីរាជការប្រចាំខែបានទាន់ពេលវេលា បានរៀបចំការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិល មានចំនួន ២៦៦៤ ករណី និងបានរៀបចំបញ្ចូលប្រាក់បៀវត្សមន្ត្រីជាប់កិច្ចសន្យា ១ ០០១ នាក់ នៅថ្នាក់ជាតិសម្រាប់ឆ្នាំ២០២៦។

**ការផ្តល់គ្រឿងឥស្សរិយយសៈ** ក្នុងឆ្នាំ២០២៥ ក្រសួងសុខាភិបាលបានទទួលព្រះរាជក្រឹត្យ អនុក្រឹត្យផ្តល់គ្រឿងឥស្សរិយយស ជូនមន្ត្រីរាជការចំនួនសរុប ២ ៥៥៥ គ្រឿង (ឥស្សរិយយសជាព្រះរាជក្រឹត្យ ៣៩ គ្រឿង និងគ្រឿងឥស្សរិយយសជាអនុក្រឹត្យ ២ ៥១៦ គ្រឿង)។

**ការស្នើសុំបណ្ណសមាជិក ប.ស.សៈ** ក្រសួងសុខាភិបាលបានស្នើសុំបណ្ណសមាជិក ប.ស.ស. ជូនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ៥៧៦ នាក់ ក្នុងនោះមានមន្ត្រីជាប់កិច្ចសន្យានៅទីស្តីការក្រសួងសុខាភិបាល ៥៥០ នាក់ និងមន្ត្រីរាជការ ២៦ នាក់ ព្រមទាំងបានសហការជាមួយមន្ត្រី ប.ស.ស. ធ្វើបច្ចុប្បន្នភាពបណ្ណសមាជិក ប.ស.ស ជូនមន្ត្រីរាជការ ៤៥៥ នាក់ ។

### ៦.២.៤. អភិបាលកិច្ចអ្នកវិជ្ជាជីវៈសុខាភិបាល

គិតត្រឹមខែ វិច្ឆិកា ឆ្នាំ២០២៥ អ្នកវិជ្ជាជីវៈសុខាភិបាលដែលបានចុះបញ្ជិកាជាមួយគណៈវិជ្ជាជីវៈទាំងប្រាំ មានចំនួនសរុប ៦៦ ១៩២ នាក់ និងមានអាជ្ញាបណ្ណវិជ្ជាជីវៈ ចំនួន ៦៥ ២០៤ នាក់ (តារាង ៦.១០.)។ ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ ក្រុមប្រឹក្សាគណៈគ្រូពេទ្យរាជធានី និងក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តព្រៃវែងបានរៀបចំមហាសន្និបាត និងបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគណៈគ្រូពេទ្យសម្រាប់អាណត្តិថ្មី៦ឆ្នាំ។ ប្រឹក្សាគណៈគ្រូពេទ្យជាតិក៏បានជួយរៀបចំការបោះឆ្នោះជ្រើសរើសការិយាល័យក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្តកំពត-កែប បន្ទាយមានជ័យ កំពង់ឆ្នាំង និងមហាសន្និបាត និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគណៈគ្រូពេទ្យភូមិភាគ១។

**តារាង ៦.១០.៖** ចំនួនអ្នកវិជ្ជាជីវៈសុខាភិបាលបានចុះបញ្ជិកា និងមានអាជ្ញាបណ្ណ ក្នុងឆ្នាំ២០២៥

| ប្រភេទ | បានចុះបញ្ជិកា(នាក់) | មានអាជ្ញាបណ្ណ(នាក់) |
|---|---|---|
| 1. គ្រូពេទ្យ | 14,257 | 12,141 |
| 2. ឱសថការី | 6,567 | 6,180 |
| 3. ទន្តពេទ្យ | 2,218 | 1,712 |
| 4. ឆ្មប | 13,404 | 13,404 |
| 5. គិលានុបដ្ឋាក | 31,767 | 31,767 |

## ៦.៣. ការគ្រប់គ្រងហិរញ្ញវត្ថុ

**ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសមិទ្ធកម្មខ្ពស់៖** ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងប្រព័ន្ធសុខាភិបាល ត្រូវបានពង្រឹង ដើម្បីធានាថាមូលនិធិពីគ្រប់ប្រភពដែលមាន ត្រូវបានតម្រៀបតាម អាទិភាពសុខភាព និងប្រើប្រាស់មូលនិធិទាំងនោះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ៦.៣.១. ថវិកាជាតិ

ក. ការវិភាជន៍ថវិកា៖ **ក្នុងឆ្នាំ២០២៥ ទំហំថវិកាជាតិសរុបដែលបានវិភាជន៍សម្រាប់វិស័យសុខាភិបាល មានចំនួន ២ ២២១ ៩១៦លានរៀល ដោយថយចុះ ៣,៣% ធៀបនឹងថវិកាវិភាជន៍សម្រាប់ឆ្នាំ២០២៤** ហើយត្រូវបានបែងចែកសម្រាប់រដ្ឋបាលកណ្តាល ចំនួន ១ ២៩៥ ៣៥៨លានរៀល (ថយចុះ ៨,២%) និងមន្ទីរសុខាភិបាលរាជធានី-ខេត្ត ចំនួន ៩២៦ ៥៥៨លានរៀល (កើនឡើង ៤,៤%)។ តារាង ៦.១១ បង្ហាញពីនិន្នាការនៃថវិកាវិស័យសុខាភិបាល ឆ្នាំ២០២១-២០២៥។

**តារាង ៦.១១.** និន្នាការនៃថវិកាវិភាជន៍វិស័យសុខាភិបាល ឆ្នាំ២០២១-២០២៥

ឯកតា៖ លានរៀល

| បរិយាយ | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|
| **វិស័យសុខាភិបាល** | | | | | |
| ▪ ផែនការថវិកាអនុម័ត | 1,720,684.0 | 2,127,196.0 | 2,292,909.0 | 2,298,362.0 | **2,221,916.0** |
| ▪ % កំណើនថវិកាវិភាជន៍ប្រចាំឆ្នាំ | 5.10% | 23.6% | 7.8% | 0.2% | **(-3.3%)** |
| **ថ្នាក់កណ្តាល** | | | | | |
| ▪ ផែនការថវិកាអនុម័ត | 1,030,290.0 | 1,381,377.0 | 1,446,887.0 | 1,411,352.0 | **1,295,358.0** |
| ▪ % កំណើនថវិកាវិភាជន៍ប្រចាំឆ្នាំ | 7.20% | 34.1% | 4.7% | -2.5% | **(-8.2%)** |
| **ថ្នាក់រាជធានី-ខេត្ត** | | | | | |
| ▪ ផែនការថវិកាអនុម័ត | 690,394.0 | 745,819.0 | 846,022.0 | 887,010.0 | **926,558.0** |
| ▪ % កំណើនថវិកាវិភាជន៍ប្រចាំឆ្នាំ | 2.30% | 8.0% | 13.4% | 4.8% | **4.4%** |

ខ. **ការចំណាយថវិកា៖** ការចំណាយថវិកាជាតិ ទាំងនៅថ្នាក់កណ្តាល និងថ្នាក់រាជធានី-ខេត្ត នៅតែបន្តតម្រង់ឆ្ពោះទៅការគាំទ្រដល់ដំណើរការមុខងារផ្តល់សេវាសុខភាពនៅតាមមូលដ្ឋាន ដោយផ្តោតលើការកែលម្អ និងលើកកម្ពស់គុណភាពសេវាសុខាភិបាលនៅមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។ តារាង ៦.១២. បង្ហាញនិន្នាការនៃការចំណាយថវិកាជាតិ រវាងឆ្នាំ២០២០-២០២៥។

**តារាង ៦.១២.** និន្នាការនៃការចំណាយថវិកាជាតិរវាង ឆ្នាំ២០២១-២០២៥

ឯកតា៖ លានរៀល

| បរិយាយ | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|
| **វិស័យសុខាភិបាល** | | | | | |
| ▪ ចំណាយចរន្ត | 4,329,871.9 | 1,764,154.3 | 1,950,846.9 | 2,054,340.5 | **2,175,435.6** |
| ▪ % ចំណាយធៀបនឹងផែនការថវិកាអនុម័ត | 251.6% | 82.9% | 85.1% | 89.4% | **97.9%** |
| **ថ្នាក់កណ្តាល** | | | | | |
| ▪ ចំណាយចរន្ត | 3,701,056.8 | 1,044,224.8 | 1,151,621.2 | 1,218,178.1 | **1,272,041.5** |
| ▪ %ចំណាយធៀបនឹងផែនការថវិកាអនុម័ត | 359.2% | 75.6% | 79.6% | 86.3% | **98.2%** |
| **ថ្នាក់រាជធានី-ខេត្ត** | | | | | |
| ▪ ចំណាយចរន្ត | 628,815.1 | 719,929.5 | 799,225.7 | 836,162.4 | **903,394.1** |
| ▪ %ចំណាយធៀបនឹងផែនការថវិកាអនុម័ត | 91.1% | 96.5% | 94.5% | 94.3% | **97.5%** |

គ. **ការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល៖** រាជរដ្ឋាភិបាលបានផ្តល់ថវិកាដល់ក្រសួងសុខាភិបាលក្នុងឆ្នាំ២០២៤ ចំនួន ៣៨ ១៣០លានរៀល (ប្រមាណ ៩ ៤១៤ ៨១៥ដុល្លារ) ដើម្បីទិញឱសថព្យាបាលជំងឺលើសសម្ពាធឈាមនិងជំងឺទឹកនោមផ្អែម និងក្នុងឆ្នាំ២០២៥ ចំនួន ៧៥ ៥៣៦លានរៀល (ប្រមាណ ១៨ ៦៥០ ៨៦៤ដុល្លារ) សម្រាប់ទិញឱសថព្យាបាលជំងឺលើសសម្ពាធឈាម និង ជំងឺទឹកនោមផ្អែម និងចំនួន ១៨ ៣០០ ០០០ដុល្លារ សម្រាប់ការជួសជុលហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់សម្ភារឧបករណ៍ពេទ្យ នៅផ្នែកសេវាសង្គ្រោះបន្ទាន់ និងសេវាវះកាត់នៅមន្ទីរពេទ្យបង្អែកចំនួន ៦១កន្លែង ក្នុងទូទាំងប្រទេស។

ឃ. **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** គឺជាកម្មវិធីកែទម្រង់អាទិភាពមួយនៅក្នុងរបៀបវារៈនៃការអនុវត្តការងារកែទម្រង់របស់រាជរដ្ឋាភិបាល។ កម្មវិធីកែនេះ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅក្នុងខែធ្នូ ឆ្នាំ២០០៤ ដោយត្រូវអនុវត្តតាមអភិក្រម ជាជំហានៗ តាមដំណាក់កាលទាំង ៤ គឺ (១).ភាពជឿទុកចិត្តនៃថវិកា (២០០៥-២០០៨) (២).គណនេយ្យភាពហិរញ្ញវត្ថុ (២០០៩-២០១៥) (៣).ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ (២០១៦-២០២២) និង (៤).គណនេយ្យភាពសមិទ្ធកម្ម (២០២៣-២០២៧)។ គោលដៅចម្បងនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការផ្លាស់ប្តូរជាបណ្តើរៗនៃប្រព័ន្ធថវិកា និងប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ ពីប្រព័ន្ធថវិកាដែលផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅប្រព័ន្ធថវិកាដែលផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ

ស្របតាមបទដ្ឋាន និងឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា។ ក្រសួងសុខាភិបាលបានចូលរួមអនុវត្តកម្មវិធីកែទម្រង់នេះយ៉ាងសកម្ម ចាប់ពីដំណាក់កាលទី១ រហូតដល់បច្ចុប្បន្នហើយសម្រេចបានសមិទ្ធផលសំខាន់ៗ រួមមាន៖

- អង្គភាពថវិកា ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ មានរចនាសម្ព័ន្ធច្បាស់លាស់ ការកំណត់សមិទ្ធកម្មនិងលទ្ធផលចុងក្រោយអាចវាស់វែងបាន ប្រកបដោយគណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាព ក្រសួងសុខាភិបាលបានបង្កើតអង្គភាពថវិកាសរុបចំនួន៨៩ ដែលក្នុងនោះថ្នាក់កណ្តាលចំនួន ២៤អង្គភាព ថ្នាក់រាជធានីខេត្តចំនួន ២៩អង្គភាព និងទីភ្នាក់ងារប្រតិបត្តិការពិសេសចំនួន ៣៦អង្គភាព។
- ផែនការថវិកា និងការអនុវត្តថវិកា ផែនការយុទ្ធសាស្ត្រថវិកា និងផែនការថវិកាប្រចាំឆ្នាំត្រូវបានរៀបចំដោយអង្គភាពថវិកានីមួយៗស្របតាមរចនាសម្ព័ន្ធថវិកាកម្មវិធីរបស់ក្រសួងសុខាភិបាល ដែលមានគោលនយោបាយ កម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាព ច្បាស់សាល់ និងមានគោលដៅសូចនាករអាចវាស់វែងបានពិតប្រាកដ។ ការផ្សារភ្ជាប់ថវិកាទៅនឹងសមិទ្ធកម្ម បានធ្វើឱ្យក្រសួងសុខាភិបាលអាចរៀបចំផែនការថវិកាបានកាន់តែមានភាពសុក្រិត ដែលធ្វើឱ្យការអនុវត្តចំណូល ចំណាយប្រចាំត្រីមាសធមាសនិងឆ្នាំ ស្ថិតក្នុងកម្រិតលម្អៀងតែរង្វង់ +/-៥%។
- អត្ថប្រយោជន៍របស់មន្ត្រីរាជការ ការបើកផ្តល់ប្រាក់បៀវត្ស ប្រាក់បេសកកម្ម ប្រាក់ម៉ោងយាម ប្រាក់ឧបត្ថម្ភឧបសម្រាលកូន និងអត្ថប្រយោជន៍របស់មន្ត្រីត្រូវបានអនុវត្តតាមប្រព័ន្ធធនាគារ ហើយប្រាក់បៀវត្សត្រូវបានបើកជូនដល់មន្ត្រីតាមប្រព័ន្ធធនាគារ ២ដងក្នុងមួយខែ។
- លទ្ធកម្មសាធារណៈ ត្រូវបានអនុវត្តដោយប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងលើសពី ៩៥%។
- ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋត្រូវបានអនុវត្តតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការកត់ត្រា និងរៀបចំបញ្ជីសារពើភ័ណ្ឌរបស់អង្គភាពថ្នាក់កណ្តាល និងរាជធានី ខេត្ត។ ការរៀបចំប័ណ្ណកម្មសិទ្ធិ ដីធ្លី ក៏ត្រូវបានពង្រឹង និងជំរុញ។
- ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅដំណាក់កាលទី២ ចាប់ពីដើមឆ្នាំ២០១៨ មកដល់បច្ចុប្បន្ននេះ ត្រូវបានអនុវត្តសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងស្រុង។

### ៦.៣.២. ហិរញ្ញប្បទានសហប្រតិបត្តិការ

ការចំណាយថវិកានៃគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ដែលគ្រប់គ្រងដោយក្រសួងសុខាភិបាលក្នុងឆ្នាំ២០២៥ រួមមាន៖

- **គម្រោងលើកកម្ពស់គុណភាពនិងសមធម៌សុខាភិបាល ទី២៖** ឆ្នាំ២០២៥ បានចំណាយ លើមូលនិធិសមធម៌សម្រាប់ប្រជាពលរដ្ឋក្រីក្រ ចំនួន ២៥ ៨៩៧ ៧៥៧,៣០ដុល្លារ ក្នុងនោះថវិកា បដិភាគរបស់រាជរដ្ឋាភិបាល ៧២,៩៧% នៃចំណាយសរុបនិងចំណាយសរុបកញ្ចប់ថវិកាផ្សារភ្ជាប់ស្នាដៃការងារចំនួន ៧ ០៥១ ១០២,៥៩ដុល្លារ ក្នុងនោះថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ៥០% នៃចំណាយសរុប។

- **គម្រោងអាហារូបត្ថម្ភនៅកម្ពុជា៖** ឆ្នាំ២០២៥ បានចំណាយលើមូលនិធិសមធម៌ចំនួន ២១,៩៣ដុល្លា ក្នុងនោះថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ៥០% នៃចំណាយសរុប និងចំណាយលើកញ្ចប់ថវិកាផ្សារភ្ជាប់ស្នាដៃការងារ ចំនួន ៥៧៦ ៣៦៣,៥៨ដុល្លារ ក្នុងនោះថវិកាបដិភាគរបស់រាជរដ្ឋាភិបាល ៥០% នៃចំណាយសរុប។
- **គម្រោងទប់ស្កាត់និងបង្ការជម្ងឺឆ្លងក្នុងមហាអនុតំបន់មេគង្គ និងហិរញ្ញប្បទានបន្ថែម** (ធនាគារអភិវឌ្ឍអាស៊ី)៖ បានចំណាយ ១០ ៦៨២ ០១៣ដុល្លារ ក្នុងនោះហិរញ្ញប្បទានឥណទានចំនួន ៩ ២៥២ ៤៨៩ដុល្លារ និងជំនួយឥតសំណង ១ ៤២២ ៥២៤ដុល្លារ លើការបំពាក់សម្ភារៈនិងឧបករណ៍ពេទ្យ ការកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្ភារៈមន្ទីរពិសោធន៍ និងការបណ្តុះបណ្តាលទាក់ទងប្រព័ន្ធតាមដានជំងឺឆ្លង ការពង្រឹងសេវាមន្ទីរពិសោធន៍ ជំងឺអេដស៍ ជំងឺរបេង ជំងឺគ្រុនឈាម/គ្រុនឈឹក និងសកម្មភាពចុះផ្តល់ថ្នាំទំលាក់ដង្កូវព្រូនតាមសហគមន៍។
- **គម្រោងមូលនិធិសកល**ចំណាយសរុប ២៥ ៣៧៧ ៣៨១,៥៣ដុល្លារ (ក្នុងនោះចំណាយលើគម្រោងជំងឺរបេង អេដស៍ចំណាយ ១៧ ៤០៩ ២៣៤,៨៧ដុល្លារ គម្រោងជំងឺគ្រុនចាញ់ ៤,៤៥៥,២០៨.៦៦ដុល្លារ និងយន្តការឆ្លើយតបជំងឺកូវីដ-១៩ ៣,៥១២,៩៣៨.០០ដុល្លារ) និងថវិកាជាតិចំណាយសរុប ៩ ០៦៨ ៥០១,៥៥ដុល្លារ (ក្នុងនោះចំណាយលើបុគ្គលិកកិច្ចសន្យានិងប្រាក់ឧបត្ថម្ភ ២ ២៤១ ០៨៣,៨៤ដុល្លារ ទិញឱសថរបេង ១ ៥០០ ០០០,០០ដុល្លារ ឱសថអេដស៍ ៥ ០០០ ០០០,០០ និងឱសថគ្រុនចាញ់ ៣២៧ ៤១៧,៧០ដុល្លារ។
- គម្រោងកម្មវិធីជាតិផ្តល់ថ្នាំបង្ការនិងពង្រឹងប្រព័ន្ធសុខាភិបាល ដែលគាំទ្រថវិកាដោយអង្គការ GAVI បានចំណាយសរុប ២ ៥៧៨ ៨៨៥ដុល្លារអាមេរិក។

## ៦.៤. ការផ្គត់ផ្គង់ឱសថ ឧបករណ៍ពេទ្យនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

**ពង្រឹងការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល ដើម្បីធានាថាប្រព័ន្ធសុខាភិបាលមានឱសថ បរិក្ខារ សម្ភារៈ ឧបករណ៍ពេទ្យ និងបច្ចេកវិទ្យា ដែលមានគុណភាព សុវត្ថិភាព និងតម្លៃសមស្រប ព្រមទាំងមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តបៃតង ហើយធន់នឹងអាកាសធាតុ។**

### ៦.៤.១. ការពង្រឹងប្រព័ន្ធផ្គត់ផ្គង់ និងការប្រើប្រាស់ឱសថ

ក្នុងឆ្នាំ២០២៥ ការផ្គត់ផ្គង់ឱសថសំភារៈបរិក្ខារពេទ្យ ដល់មូលដ្ឋានសុខាភិបាល និងអង្គភាពសុខាភិបាលរាជធានី-ខេត្តទូទាំងប្រទេស បានកើនឡើង បើប្រៀបធៀបទៅឆ្នាំ២០២៤ ដោយសារកំណើននៃការប្រើប្រាស់សេវាថែទាំសុខភាព និងការផ្គត់ផ្គង់ទាន់ពេលវេលាសមស្របតាមតម្រូវការ នៅក្នុងបរិការណ៍ នៃជម្លោះព្រំដែន។

ក. ការទទួលបញ្ចូលឃ្លាំង៖ ឱសថ សម្ភារៈ បរិក្ខារ វ៉ាក់សាំង និងប្រតិករ ឧបករណ៍ពេទ្យ ដែលបានទិញតាមរយៈថវិកាជាតិ ត្រូវបានក្រុមហ៊ុនផ្គត់ផ្គង់ជាអ្នកទទួលបន្ទុកក្នុងការដឹកជញ្ជូនមកប្រគល់ដល់ឃ្លាំងឱសថកណ្តាល។ រីឯរបស់ជំនួយ ក្រសួងសុខាភិបាលបានជួយសម្របសម្រួលបែបបទគយឱ្យបានឆាប់រហ័ស ដើម្បីនាំរបស់ពីមាត់ច្រកចូលឱ្យបានទាន់ពេលវេលា។ ក្នុងឆ្នាំ២០២៥ ឱសថ វ៉ាក់សាំង សំភារៈបរិក្ខារពេទ្យ ដែលបានទទួលបញ្ចូលឃ្លាំង មានទម្ងន់សរុប ៥ ២៤២ ០២៣ គ.ក្រ គិតជាទឹកប្រាក់ ១៧៥ ៧៣៦ ១៨០ដុល្លារអាមេរិក។

ខ. **ការផ្គត់ផ្គង់៖** ឃ្លាំងឱសថកណ្ដាលបានបង្កើនការយកចិត្តទុកដាក់គ្រប់គ្រងឱសថ សំភារៈបរិក្ខារពេទ្យ ប្រតិករ និងវ៉ាក់សាំង ដោយធានាបានការបែងចែកដល់ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែករាជធានី ខេត្ត មន្ទីរពេទ្យជាតិ សមស្របតាមលទ្ធភាពស្តុកជាក់ស្តែង ហើយពុំមានឱសថ ឬបរិក្ខារពេទ្យណាទុកឱ្យ កកស្ទះរហូតដល់ផុតកំណត់ប្រើ នៅក្នុងឃ្លាំងឱសថកណ្ដាលឡើយ។ ការផ្គត់ផ្គង់ឱសថ ប្រព្រឹត្តទៅរៀងរាល់បីខែម្តង ទាន់ពេល តាមផែនការបែងចែកដែលបានកំណត់។ ក្នុងឆ្នាំ២០២៥ បរិមាណឱសថបានចែកចាយមានទម្ងន់សរុប ៦ ៨៩១ ១៧៤គ.ក្រ គិតជាទឹកប្រាក់ប្រមាណ ១៦០ ៩៣៧ ២៧៦ដុល្លារអាមេរិក (តារាង ៦.១៣. បង្ហាញបរិមាណឱសថ បរិក្ខារ វ៉ាក់សាំង និងប្រតិករដែលបានទទួលចូល និងចែកចាយដល់មូលដ្ឋានសុខាភិបាលទូទាំងប្រទេស ពីឆ្នាំ២០២១-២០២៥ ។

**តារាង ៦.១៣.** បរិមាណទទួលចូល និងបែងចែក ពីឆ្នាំ២០២១-២០២៥ (គិតជា គ.ក្រ)

| | 2021 | 2022 | 2023 | 2024 | 2025 |
|---|---|---|---|---|---|
| បរិមាណទទួលចូល | 8,155,137 | 6,513,179 | 6,371,235 | 4,875,209 | 5,242,023 |
| បរិមាណបែងចែក | 25,399,638 | 13.498,178 | 8,161,982 | 5,334,085 | 6,891,174 |

**គ.ការលើកកម្ពស់ការប្រើប្រាស់ប្រកបដោយសនិទានកម្ម៖** ដើម្បីពង្រឹងការប្រើប្រាស់ឱសថសម្ភារៈ បរិក្ខារ ស្របតាមនិយាមបច្ចេកទេស ក្រុមការងារអភិបាលគ្រប់លំដាប់ថ្នាក់ បានធ្វើការត្រួតពិនិត្យ និងតាមដានការអនុវត្តន៍ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងឱសថ បរិក្ខារពេទ្យ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ដូចជានៅឃ្លាំងឱសថក្នុងស្រុកប្រតិបត្តិ ៥២ មន្ទីរពេទ្យបង្អែក ៥៤ និងមណ្ឌលសុខភាព ១៥៦ ដោយប្រើប្រាស់ថវិការដ្ឋជាតិ និងថវិកាដៃគូ ព្រមទាំងផ្តល់ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងឱសថ បរិក្ខារពេទ្យតាមប្រព័ន្ធ ZOOM សម្រាប់មន្ទីរពេទ្យ មណ្ឌលសុខភាពទូទាំងប្រទេស និងការបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការគ្រប់គ្រងឱសថ បរិក្ខារពេទ្យសម្រាប់ថ្នាក់ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យ។

## ៦.៤.២. ការបំពាក់សម្ភារៈ និងឧបករណ៍ពេទ្យជាសារវ័ន្ត

ក្នុងឆ្នាំ២០២៥ ក្រសួងសុខាភិបាលបានបន្តបំពាក់នូវសម្ភារៈ និងឧបករណ៍ពេទ្យជាសារវ័ន្ត ដោយប្រើប្រាស់ថវិកាជាតិ និងថវិកាគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ដល់មូលដ្ឋានសុខាភិបាល រួមមាន៖

- ឧបករណ៍ពេទ្យសម្រាប់ផ្នែកសង្គ្រោះបន្ទាន់ និងផ្នែកវះកាត់ នៅមន្ទីរពេទ្យបង្អែក ៦១ ដោយប្រើប្រាស់ថវិកាជាតិ។
- ម៉ាស៊ីនសម្លាប់មេរោគ (Autoclaves) នៅមន្ទីរពេទ្យ ១៧ កន្លែង ម៉ាស៊ីនបោកគក់នៅមន្ទីរពេទ្យ ៥ កន្លែង ម៉ាស៊ីនសម្ងួតនៅមន្ទីរពេទ្យ ១ កន្លែង ម៉ាស៊ីនចម្រោះទឹកនៅមន្ទីរពេទ្យ ៩៣ កន្លែង និងសម្ភារៈមន្ទីរពិសោធន៍ (Hematology Analyzer នៅមន្ទីរពេទ្យ ៨៧ កន្លែង Biochemistry នៅមន្ទីរពេទ្យ ៨៨ កន្លែង Electrolyte analyzer system នៅមន្ទីរពេទ្យ ៨៧ កន្លែង និង Coagulation analyzer នៅមន្ទីរពេទ្យ ៩៦ កន្លែង) ក្រោមគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការធនាគារអភិវឌ្ឍអាស៊ី។

### ៦.៤.៣. ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

- ក្រសួងសុខាភិបាលបានទទួលកញ្ចប់ថវិកាចំនួន ៦០ ០០០លានរៀល (ប្រមាណ ១៤ ៨០០ ០០០ដុល្លារ) សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល នៅទូទាំងប្រទេស រួមមាន៖ មណ្ឌលសុខភាព ចំនួន ២១ កន្លែង អគារសម្រាកនិងព្យាបាល (ដំណាក់កាលទី២) ០២ កន្លែង ហេដ្ឋារចនាសម្ព័ន្ធ គាំទ្រដំណាក់កាលទី២ (អគាររដ្ឋបាលទីស្តីការក្រសួង) ០១ កន្លែង អគាររដ្ឋបាលទូទៅ អគារឃ្លាំងឱសថ សាលប្រជុំ ចំណតរថយន្ត និងហេដ្ឋារចនា សម្ព័ន្ធគាំទ្រនានា (ដំណាក់កាលទី២) ០១ កន្លែង។
- ជួសជុលកែលម្អអគារផ្នែកសង្គ្រោះបន្ទាន់ និងផ្នែកវះកាត់ នៅមន្ទីរពេទ្យបង្អែក ៦១ ដោយប្រើប្រាស់ថវិកាជាតិ។
- ជួសជុលកែលម្អមន្ទីរពិសោធន៍ នៅមន្ទីរពេទ្យចំនួន ៥០ ក្នុងខេត្តចំនួន ១៦ (គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការធនាគារអភិវឌ្ឍអាស៊ី)។

## ៦.៥. ការអភិវឌ្ឍទិន្នន័យ ប្រព័ន្ធព័ត៌មានសុខាភិបាល និងសុខាភិបាលឌីជីថល

ពង្រឹងប្រព័ន្ធព័ត៌មានសុខាភិបាលរឹងមាំ រហ័សរហួន និងប្រព័ន្ធឌីជីថលអន្តរប្រតិបត្តិការ ដើម្បីលើកកម្ពស់ការសម្រេចចិត្តត្រឹមត្រូវ ការផ្តល់សេវាថែទាំសុខភាព និងអន្តរាគមន៍សុខភាពសាធារណៈ ប្រកបដោយប្រសិទ្ធភាព នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ៦.៥.១. ការគ្របដណ្តប់ គុណភាព និងភាពអាចប្រើបាននៃទិន្នន័យ

បច្ចុប្បន្នមានប្រព័ន្ធឌីជីថលជាច្រើន ដែលប្រមូលទិន្នន័យនៅក្នុងប្រព័ន្ធសុខាភិបាលសាធារណៈ។ ប្រព័ន្ធប្រមូលទិន្នន័យនៅកម្រិតមូលដ្ឋានសុខាភិបាល ដែលដំណើរការពេញលេញ និងមានវិសាលគ្របដណ្តប់មណ្ឌលសុខភាព និងមន្ទីរពេទ្យសាធារណៈគ្រប់កម្រិត **គឺប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល** (ប្រមូលទិន្នន័យនៃការប្រើប្រាស់សេវា) **ប្រព័ន្ធតាមដាន និងលើកកម្ពស់គុណភាពសេវាសុខាភិបាលនិងប្រព័ន្ធអង្កេតតាមដានជំងឺឆ្លង និងគ្រោះអាសន្នសុខភាពសាធារណៈ** ខណៈដែលប្រព័ន្ធប្រមូលទិន្នន័យនៅកម្រិតបុគ្គល ដូចជា ប្រព័ន្ធកត់ត្រាវេជ្ជសាស្ត្រអេឡិចត្រូនិក (ទិន្នន័យអ្នកជំងឺ និងអ្នកប្រើប្រាស់សេវា) ត្រូវបានប្រើប្រាស់នៅមន្ទីរពេទ្យជាតិទាំងអស់ និងមន្ទីរពេទ្យខេត្តមួយចំនួន និងប្រព័ន្ធគាំទ្រដទៃទៀត នៅមានកម្រិត។

**ក. ការអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថល៖** ក្នុងឆ្នាំ២០២៥ ការអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថល ត្រូវបានកត់សម្គាល់ ដោយវឌ្ឍនភាព ដូចខាងក្រោម៖

- **ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល** ក៏ប្រមូលទិន្នន័យនៃការប្រើប្រាស់សេវាថែទាំសុខភាពពីមូលដ្ឋានសុខាភិបាលឯកជន ផងដែរ។ គិតត្រឹមថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាលឯកជនដែលបានចុះបញ្ជីក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលមានចំនួន ៣ ៦៤៣ កន្លែង ក្នុងនោះ ១ ៤៣៩ កន្លែង ឬ ៣៩,៦៣% ប៉ុណ្ណោះ ដែលបានរាយការណ៍។ គួរគូសបញ្ជាក់ថា ចំនួនមូលដ្ឋានសុខាភិបាលឯកជនសរុបដែលបានទទួលអាជ្ញាបណ្ណប្រកបអាជីវកម្មពីក្រសួងសុខាភិបាលមានចំនួនសរុប។
- **ប្រព័ន្ធតាមដាន និងលើកកម្ពស់គុណភាពសេវាសុខាភិបាល** ត្រូវបានបង្កើនមុខងារសម្រាប់អ្នកជំងឺ ឬអ្នកប្រើប្រាស់សេវាផ្តល់យោបល់អំពីភាពពេញចិត្តចំពោះសេវាថែទាំសុខភាពដែលផ្តល់ដោយមណ្ឌលសុខភាព និងមន្ទីរពេទ្យ តាមរយៈការ QR កូដ ដែលផ្តល់ភាពងាយស្រួល គ្មានការភ័យខ្លាច និងរក្សាការសម្ងាត់ក្នុងការបញ្ចេញមតិ។
- **ប្រព័ន្ធទិន្នន័យសុខាភិបាលឌីជីថលសម្រាប់ការផ្តល់ដំណឹងអំពីកំណើតរស់ និងមរណភាព** (www.digitalncod.org)៖ ចាប់ពីពេលដាក់ឱ្យដំណើរការនៅក្នុងឆ្នាំ២០២៤ រហូតមកដល់ចុងខែតុលា ឆ្នាំ២០២៥ មូលដ្ឋានសុខាភិបាល ៣៥៩ កន្លែង ក្នុងនោះមូលដ្ឋានសុខាភិបាលសាធារណៈ ៣៣៤ កន្លែង (មន្ទីរពេទ្យ ៩៨កន្លែង និងមណ្ឌលសុខភាព ២៣៦ កន្លែង) និងមូលដ្ឋានសុខាភិបាលឯកជន ២៥ កន្លែង បានបញ្ចូលទិន្នន័យទៀងទាត់ប្រចាំថ្ងៃ ទៅក្នុងគេហទំព័រ www.digitalncod.org ។
- **ប្រព័ន្ធកត់ត្រាវេជ្ជសាស្រ្តអេឡិចត្រូនិក** ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០២៥ សម្រាប់សេវាជំងឺមិនឆ្លង ដោយក្នុងជំហានដំបូងសម្រាប់ជំងឺទឹកនោមផ្អែម ជំងឺលើសឈាម និងការពិនិត្យស្រាវជ្រាវដំបូងរកជំងឺមហារីកមាត់ស្បូន ខណៈដែលប្រព័ន្ធចុះបញ្ជិការជំងឺមហារីកទូទៅកំពុងត្រូវបានអភិវឌ្ឍ។
- **ប្រព័ន្ធអេឡិចត្រូនិចកត់ត្រាទិន្នន័យការផ្តល់ថ្នាំបង្ការ** ត្រូវបានបង្កើតឡើង ដាក់ឱ្យប្រើប្រាស់សាកល្បង និងពង្រីកការប្រើប្រាស់នៅមូលដ្ឋានសុខាភិបាលសាធារណៈ ទូទាំងប្រទេសនៅមុនដំណាច់ឆ្នាំ២០២៥ និងពង្រីកការប្រើប្រាស់ក្នុងផ្នែកសេវាសុខាភិបាលឯកជននៅក្នុងឆ្នាំ២០២៦។ ប្រព័ន្ធនេះត្រូវបានអភិវឌ្ឍនៅលើថ្នាលបច្ចេកវិទ្យានៃប្រព័ន្ធព័ត៌មានចាក់វ៉ាក់សាំងកូវីដ-១៩ ដែលបានបង្កើតឡើងកាលពីឆ្នាំ២០២០ នៅក្រោមកិច្ចសហការរវាងក្រសួងសុខាភិបាល និងក្រសួងប្រៃសនីយ និងទូរគមនាគមន៍។
- **ប្រព័ន្ធគ្រប់គ្រងព័ត៌មានសេវាសុខាភិបាលឯកជន** ត្រូវបានបង្កើតឡើង ហើយនឹងដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំ២០២៦ ក្រោមកិច្ចសហការរវាងក្រសួងសុខាភិបាល និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បី ពង្រឹងការគ្រប់គ្រងសេវាសុខាភិបាលឯកជន ទាក់ទងស្ថានភាពនៃការចុះបញ្ជិកា ការផ្តល់ ឬការបន្តសុពលភាពអាជ្ញាបណ្ណ ការបង្ហាញអំពីប្រភេទ កម្រិតធនធាន និងទីតាំងមូលដ្ឋានសុខាភិបាល (ក្រាហ្វិក ៦.៤.)។

**ក្រាហ្វិក ៦.៤.** ការបង្ហាញពីមុខងារសំខាន់ៗខ្លះ នៃប្រព័ន្ធព័ត៌មានគ្រប់គ្រងសេវាសុខាភិបាលឯកជន




**ខ. គុណភាពទិន្នន័យ៖** សន្ទស្សន៍មធ្យមគុណភាពទិន្នន័យ ដែលបានរាយការណ៍ដោយមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកគ្រប់កម្រិតទូទាំងប្រទេស នៅក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាលបានកើនឡើងពី ៩៥,៨% នៅឆ្នាំ២០២៤ ដល់ ៩៦,៤៩% នៅឆ្នាំ២០២៥ ដោយសម្រេចចំណុចដៅដែលបានកំណត់ (ក្រាហ្វិក ៦.៥.)។ រវាងឆ្នាំ២០០២៤ និងឆ្នាំ២០២៥ សន្ទស្សន៍មធ្យមគុណភាពទិន្នន័យនៃមណ្ឌលសុខភាពបានកើនពី ៩៦,៩៨% ទៅ ៩៧,៧២% (ខ្ពស់ជាងសន្ទស្សន៍មធ្យមទូទាំងប្រទេស) និងមន្ទីរពេទ្យបានកើនពី ៨៩,១១% ទៅ ៨៩,៨៣% (ទាបជាងសន្ទស្សន៍មធ្យមទូទាំងប្រទេស)។ សន្ទស្សន៍គុណភាពទិន្នន័យវាស់វែង ភាពពេញលេញនៃការបញ្ចូលទិន្នន័យ តាមកាលកំណត់៖

- របាយការណ៍ពេញលេញ (១០០% តាមទម្រង់របាយការណ៍ស្តង់ដារ) និងទាន់ពេល (បញ្ចូលទិន្នន័យគ្រប់មុនថ្ងៃទី១៦ នៃខែបន្ទាប់) មានចំនួន ១ ៤២៧ កន្លែង ឬស្មើនឹង ៩៩,១៧% នៃចំនួនសរុបនៃមណ្ឌលសុខភាពនិងមន្ទីរពេទ្យ។
- របាយការណ៍ពេញលេញ (១០០%) ប៉ុន្តែមិនទាន់ពេល (បញ្ចូលទិន្នន័យគ្រប់ ក្រោយថ្ងៃទី១៦ នៃខែបន្ទាប់) មាន ១៣ កន្លែង ឬស្មើ ០,៨៣%។

**ក្រាហ្វិក ៦.៥.** សន្ទស្សន៍គុណភាពទិន្នន័យ ២០២១-២០២៥ (%)




## ៦.៥.២. ការអភិវឌ្ឍប្រព័ន្ធឌីជីថលអន្តរប្រតិបត្តិការ និងសមាហរណ (Interoperability and integration)

ក. សមាហរណកម្ម និងអន្តរប្រតិបត្តិការប្រព័ន្ធ៖ ជាទូទៅ ប្រព័ន្ធព័ត៌មានឌីជីថលដែលកំពុងប្រើប្រាស់នៅក្នុងផ្នែកសុខាភិបាលសាធារណៈ មិនទាន់ជាប្រព័ន្ធអន្តរប្រតិបត្តិការនៅឡើយ ដោយសារមិនទាន់មានស្តង់ដាអន្តរប្រតិបត្តិការ ហេដ្ឋារចនាសម្ព័ន្ធឬថ្នាលបច្ចេកវិទ្យាព័ត៌មានរួម ឧ. និម្មាបនកម្មសហគ្រាសសុខាភិបាល (Health Enterprise Architecture) និងស្តង់ដាទិន្នន័យ។ វឌ្ឍនភាពក្នុងការចាប់ផ្តើម ដំណើរការធ្វើសមាហរណកម្ម និងអន្តរប្រតិបត្តិការប្រព័ន្ធ រួមមាន៖

- ការបង្កើតប្រព័ន្ធអេឡិចត្រូនិចកត់ត្រាទិន្នន័យការផ្តល់ថ្នាំបង្ការ (ដូចបានអធិប្បាយខាងលើ)
- ការផ្លាស់ប្តូរថ្នាលបច្ចេកវិទ្យានៃ **ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល** បច្ចុប្បន្ន ទៅប្រើថ្នាលបច្ចេកវិទ្យា DHIS2 (District Health Information Software Version 2) ដែលផ្តល់មូលនិធិដោយអង្គការ GAVI និងជំនួយបច្ចេកទេសពី អង្គការសុខភាពពិភពលោក UNICEF និង មូលនិធិ Clinton Health Access Initiative។ Software នេះ ជាកម្មវិធីអត់គិតថ្លៃ ដែលបង្កើតឡើងដោយសកលវិទ្យាល័យអូស្លូ ប្រទេសន័រវែស និងត្រូវបានប្រើប្រាស់ក្នុងប្រទេសជាង ៨០ ហើយអាចធ្វើអន្តរប្រតិបត្តិការជាមួយប្រព័ន្ធទិន្នន័យឌីជីថលដទៃទៀត ដូចជាប្រព័ន្ធគ្រប់គ្រងព័ត៌មានជំងឺគ្រុនចាញ់ មេរោគអេដស៍/ជំងឺអេដស៍ និងជំងឺរបេង ជាដើម តាមរយៈ Application Programming Interface (API) ជាផ្នែកសំខាន់មួយនៃនិម្មាបនកម្មសហគ្រាសសុខាភិបាល ឌីជីថលនៅកម្ពុជា។

ខ. ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា៖ ក្រសួងសុខាភិបាលបានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ធ្វើការបញ្ចប់ការវាយតម្លៃហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល (ផ្នែករឹង ផ្នែកទន់ និងបណ្តាញ) នៅទីស្តីការក្រសួងសុខាភិបាល មន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យខេត្តមួយចំនួន ដែលជាមូលដ្ឋានសម្រាប់ការរៀបចំផែនការកែលម្អហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំងបណ្តាញអ៊ីនធឺណិត និងការបំពាក់បណ្តាញ Telemedicine រវាងមន្ទីរពេទ្យជាតិ និងមន្ទីរពេទ្យខេត្ត នៅក្នុងឆ្នាំ២០២៦។ ក្រសួងសុខាភិបាលបានទទួលកុំព្យូទ័រ Desktop ៤៧ Laptop ១ ៧០៣ និង Tablet ១ ៦៧៣ ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ហើយបានចែកជូនទៅដល់អង្គភាពសុខាភិបាលគ្រប់លំដាប់ថ្នាក់។

### ៦.៥.៣. ការកសាងធនធានមនុស្សសុខាភិបាលឌីជីថល

ក. ការបណ្តុះបណ្តាលអំពីចំណេះដឹងឌីជីថល៖ ក្នុងឆ្នាំ២០២៥ ក្រសួងសុខាភិបាលបានបញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីសុខាភិបាល ចូលរួមក្នុងវគ្គបណ្តុះបណ្តាលដែលរៀបចំដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នៅបណ្ឌិតសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា សរុបចំនួន ២២៥ នាក់ ក្នុងនោះ៖ វគ្គជំនាញ ឌីជីថល ១៦២ នាក់ (ជំនាញឌីជីថលចាំបាច់ ១១២ នាក់ និងជំនាញបច្ចេកទេសឌីជីថល ៤២ នាក់) វគ្គឌីជីថលសម្រាប់ថ្នាក់ដឹកនាំ ១៣ នាក់ វគ្គអក្ខកម្មឌីជីថល ៣០ នាក់ (សន្តិសុខសាយប័រ ១០ នាក់ អក្ខរកម្មទិន្នន័យ ១០ នាក់ រូប និងអក្ខកម្មព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ) និង វគ្គជំរុញការប្រើប្រាស់ និងអភិបាលកិច្ចបញ្ញាសិប្បនិម្មិត ៤ នាក់។

ខ. ការបណ្តុះបណ្តាលអំពីប្រព័ន្ធទិន្នន័យឌីជីថល៖ នាយកដ្ឋានផែនការនិងព័ត៌មានសុខាភិបាល បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ មន្ទីរសុខាភិបាលរាជធានី ខេត្ត ស្រុកប្រតិបត្តិ និងមន្ទីរពេទ្យទូទាំងប្រទេស ស្តីពីការប្រើប្រាស់ប្រព័ន្ធព័ត៌មាន DHIS2 សរុបបានចំនួន ៣៩៦ នាក់ ដែលមានភារកិច្ចរៀបចំការបណ្តុះបណ្តាលបន្ត ដល់បុគ្គលិកមណ្ឌលសុខភាពនៅក្នុងឆ្នាំ២០២៦។ ជាមួយគ្នានេះ នាយកដ្ឋានក៏បានកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសុខាភិបាល និងបណ្តុះបណ្តាលដល់មន្ត្រីទទួលបន្ទុកហិរញ្ញប្បទានសុខាភិបាលនៅមន្ទីរពេទ្យជាតិ និងថ្នាក់រាជធានី ខេត្ត មន្ទីរពេទ្យបង្អែក សរុបចំនួន ២៤២ នាក់ (ស្រី ១១៨ នាក់) ដោយសហការជាមួយអង្គការសុខភាពពិភពលោក។ ដោយឡែក ទីភ្នាក់ងារជាតិបញ្ជាក់ចំណាយបានបណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចកត់ត្រា និងគ្រប់គ្រងទិន្នន័យអ្នកជំងឺ (Patient Management Registration System/PMRS) ជំនាន់ថ្មី ដើម្បីពង្រឹងការគ្រប់គ្រងទិន្នន័យប្រើប្រាស់សេវា និងការស្នើសុំទូទាត់ចំណាយមូលនិធិសមធម៌។

### ៦.៥.៤. ការពង្រឹងអនុលោមភាពគោលនយោបាយ និងនិយ័តកម្ម

ការពង្រឹងប្រព័ន្ធព័ត៌មានឌីជីថលក្នុងក្របខ័ណ្ឌពហុវិស័យ និងក្នុងវិស័យសុខាភិបាល ក្រសួងសុខាភិបាលបានចូលរួមផ្តល់យោបល់លើលិខិតបទដ្ឋានគតិយុត្ត និងរៀបចំតិវិធីស្តង់ដាពាក់ព័ន្ធមួយចំនួន ដូចខាងក្រោម៖

- សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការជូនដំណឹងកំណើតរស់ និងមរណភាពតាមរយៈគេហទំព័រ (www.digitalncod.org) រវាងក្រសួងមហាផ្ទៃ និងក្រសួងសុខាភិបាល និងសេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការផ្លាស់ប្តូរទិន្នន័យសុខាភិបាល រវាងក្រសួងសុខាភិបាល និងក្រសួងផែនការ។

- នីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការជូនដំណឹងអំពីកំណើតរស់ ជូនដំណឹងមរណភាព ការកត់ត្រាមូលហេតុមរណភាពនិងទារកស្លាប់កើត ត្រូវបានដាក់ឱ្យអនុវត្ត។
- សេចក្តីព្រាងនីតិវិធីប្រតិបត្តិស្តង់ដាសម្រាប់ការប្រើប្រាស់ Telemedicine
- យុទ្ធសាស្ត្រសុខាភិបាលឌីជីថល ២០២៦-២០៣៥ ត្រូវបានបញ្ចប់ និងគ្រោងប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅក្នុងឆ្នាំ២០២៦ ដើម្បីគាំទ្រដល់ការអនុវត្ត ផ.យ.ស.៤ និងគោលនយោបាយទាក់ទងនឹងបរិវត្តកម្មឌីជីថលរបស់រាជរដ្ឋាភិបាល។
- ការផ្តួចផ្តើមការអភិវឌ្ឍនិម្មាបនកម្មសហគ្រាសឌីជីថលសុខាភិបាល (Health Enterprise Architecture) ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ការធ្វើអន្តរប្រតិបត្តិការ និងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធទិន្នន័យនានាក្នុងវិស័យសុខាភិបាល និងវិស័យពាក់ព័ន្ធ។



# ៧ ទិសដៅការងារឆ្នាំ២០២៦ និងឆ្នាំបន្ត




៧.១. បង្កើនការទទួលបាន និងការគ្របដណ្តប់នៃសេវាថែទាំសុខភាព

៧.២. ការលើកកម្ពស់គុណភាព និងសុវត្ថិភាពនៃការថែទាំសុខភាព

៧.៣. ការគាំពារហិរញ្ញវត្ថុ

៧.៤. ការពង្រឹងសន្តិសុខសុខភាព

៧.៥. ការពង្រឹងសមត្ថភាព និងការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល

៧.៦. ក្របខ័ណ្ឌសូចនាករសម្រាប់ការតាមដាន និងការវាយតម្លៃ

# ៧. ទិសដៅការងារឆ្នាំ២០២៦ និងឆ្នាំបន្ត

## ៧.១. បង្កើនការទទួលបាន និងការគ្របដណ្តប់នៃសេវាថែទាំសុខភាព

- ជំរុញតួនាទីមន្ទីរពេទ្យបង្អែកក្នុងការពង្រឹងសេវាថែទាំសុខភាពបឋម ដោយបញ្ជ្រាបការថែទាំសុខភាពបឋម នៅក្នុងការផ្តល់សេវាក្នុងមន្ទីរពេទ្យ និងផ្តល់ការគាំទ្រដល់មណ្ឌលសុខភាពក្នុងការកែលម្អគុណភាព និងការពង្រីកសេវា។
- បង្កើនសកម្មភាពអប់រំលើកកម្ពស់សុខភាព ការបង្ការ និងគ្រប់គ្រងជំងឺ ដើម្បីគាំទ្រដល់បុគ្គល គ្រួសារ និងសហគមន៍ធ្វើការផ្លាស់ប្តូរឥរិយាបថប្រឈមហានិភ័យសុខភាព ដោយអនុវត្តរបៀបរស់នៅប្រកបដោយសុខភាពល្អ។
- ពង្រីកការគ្របដណ្តប់សេវាសុខភាព ជាពិសេសសេវាសារវ័ន្ត ដែលគុណភាពត្រូវបានកែលម្អជាប្រចាំ ឆ្ពោះទៅកាន់ការទទួលបានសេវាថែទាំសុខភាពជាសកល ដោយអភិវឌ្ឍសេវាសុខភាពដែលមានស្រាប់ និងបង្កើតសេវាអាទិភាពថ្មីៗ បន្ថែម នៅមណ្ឌលសុខភាព និងមន្ទីរពេទ្យ។
- ចុះផ្តល់សេវាសុខភាពតាមមូលដ្ឋាន នៅក្នុងតំបន់ជនបទ តំបន់ដែលប្រជាជនជួបការលំបាកក្នុងការមកទទួលសេវា (ឧ. ឧបសគ្គភូមិសាស្ត្រ ប្រជាជនចល័ត) យោងតាមសេចក្តីណែនាំស្តីពីការចុះផ្តល់សេវាមូលដ្ឋាន របស់ក្រសួងសុខាភិបាល។
- ជំរុញការចូលរួមរបស់សហគមន៍ក្នុងការអភិវឌ្ឍ ការតាមដាន និងការវាយតម្លៃការផ្តល់សេវា និងលើកកម្ពស់កិច្ចសហការពហុវិស័យ ក្នុងការដោះស្រាយកត្តាសង្គមដែលមានផលជះលើសុខភាព។

## ៧.២. ការលើកកម្ពស់គុណភាព និងសុវត្ថិភាពនៃការថែទាំសុខភាព

- បន្តពង្រឹងគុណភាពសេវានៅមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ កម្រិត៣ ត្រូវបានកែលម្អឱ្យប្រសើរឡើងជាលំដាប់ ដោយពង្រឹងយន្តការវាយតម្លៃ និងតាមដានការកែលម្អគុណភាព។
- ពង្រឹងប្រព័ន្ធបញ្ជូន នីតិវិធីនៃការបញ្ជូន និងការបណ្តុះបណ្តាល និងពង្រាយរថយន្តគិលានសង្គ្រោះ ក្នុងសមាមាត្រ រថយន្តគិលានសង្គ្រោះ ១ គ្រឿង សម្រាប់ ៥ មណ្ឌលសុខភាព។
- ពង្រឹងសមត្ថភាពមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ កម្រិត៣ ក្នុងការធ្វើរោគវិនិច្ឆ័យ និងផ្តល់ឱសថព្យាបាលស្របតាមពិធីសារគ្លីនិក។
- ពង្រីកការប្រើប្រាស់ប្រព័ន្ធកំណត់ត្រាវេជ្ជសាស្ត្រអេឡិចត្រូនិកសម្រាប់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកស្រុក ខេត្ត ដើម្បីលើកកម្ពស់ការផ្តល់សេវាឱ្យកាន់តែប្រសើរឡើង។
- ផ្តល់សេវា ២៤ម៉ោង/២៤ម៉ោង ៧ថ្ងៃ ក្នុង ១សប្តាហ៍ ដោយមានបុគ្គលិក តាមប្រភេទជំនាញ ស្របតាមនិយាមស្តង់ដារបុគ្គលិកផ្អែកតាមកត្តាភូមិសាស្ត្រ និងចំនួនប្រជាជនគ្របដណ្តប់។

- ចាត់ចែងការគ្រប់គ្រងសំណល់ នៅមូលដ្ឋានសុខាភិបាលដោយមានអនុលោមភាពតាមនិយាមបច្ចេកទេស ឬសេចក្តីណែនាំប្រតិបត្តិ។
- ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូរវេជ្ជសាស្ត្រផ្តល់សេវាធ្វើរោគវិនិច្ឆ័យ និងថែទាំព្យាបាលពីចម្ងាយក្នុងបណ្តាញមន្ទីរពេទ្យបង្អែក និងរវាងមន្ទីរពេទ្យបង្អែកនិងមណ្ឌលសុខភាព ដើម្បីគាំទ្រការផ្តល់សេវាថែទាំបឋមនិងការថែទាំព្យាបាលបន្ត។
- ពង្រឹងរចនាសម្ព័ន្ធ និងសមត្ថភាពស្ថាប័នសម្រាប់សកម្មភាពអភិបាលកិច្ចគ្លីនិក នៅកម្រិតប្រព័ន្ធ និងកម្រិតមូលដ្ឋានសុខាភិបាល ដើម្បីលើកស្ទួយគណនេយ្យភាពលើគុណភាព និងសុវត្ថិភាពខ្ពស់នៃសេវាថែទាំព្យាបាលដែលបានផ្តល់ជូនអ្នកជំងឺ។

## ៧.៣. ការគាំពារហិរញ្ញវត្ថុ

- បង្កើនការយល់ដឹងរបស់ប្រជាជនអំពីអត្ថប្រយោជន៍សុខភាព ព្រមទាំងអំពីនីតិវិធីនៃការផ្តល់សេវាថែទាំសុខភាព នីតិវិធីនៃប្រតិបត្តិការកម្មវិធីគាំពារសុខភាពសង្គម និងយន្តការពាក់ព័ន្ធដទៃទៀត (ឧ. ប្រព័ន្ធកំណត់សញ្ញាណកម្មក្រីក្រទុកជាមុន)។
- ពង្រឹងការផ្តល់សេវាថែទាំសុខភាពក្នុងប្រព័ន្ធគាំពារសុខភាពសង្គម ឱ្យមានអនុលោមភាពតាមនីតិវិធីលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬឧបករណ៍បច្ចេកទេស និងហិរញ្ញវត្ថុ។
- ធ្វើសមាហរណកម្ម និង/ឬអន្តរប្រតិបត្តិការ និងការចែករំលែកទិន្នន័យរវាងប្រព័ន្ធផ្តល់សេវាថែទាំសុខភាព និងប្រព័ន្ធគាំពារសង្គម/គាំពារសុខភាពសង្គម យោងតាមតម្រូវការជាក់ស្តែង។
- ធ្វើការតាមដាន និងវាយតម្លៃវឌ្ឍនភាព ឆ្ពោះទៅកាន់ការសម្រេចការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា រួមជាមួយនឹងការវិភាគដែលផ្តោតលើសមធម៌។

## ៧.៤. ការពង្រឹងសន្តិសុខសុខភាព

- ក្សោកិច្ចដំណើរការពេញលេញនៃប្រព័ន្ធប្រកាសគ្រោះអាសន្នសុខភាព និងប្រព័ន្ធអង្កេតតាមដាន នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីត្រៀមខ្លួន និងឆ្លើយតបចំពោះហានិភ័យនៃជំងឺឆ្លងដែលលេចឡើង ឬលេចឡើងសាជាថ្មី និងការគម្រាមកំហែងនៃគ្រោះអាសន្នសុខភាព។
- បង្ការ និងគ្រប់គ្រងផលប៉ះពាល់លើសុខភាពសាធារណៈ ដែលបណ្តាលភាពស៊ាំនៃមេរោគនឹងឱសថប្រឆាំងមេរោគ ជំងឺបណ្តាលមកពីទឹកនិងចំណីអាហារ ជំងឺឆ្លងពីសត្វមកមនុស្ស ហានិភ័យសុខភាពបរិស្ថាន បំរែបំរួលអាកាសធាតុ និងគ្រោះមហន្តរាយ។
- ជំរុញភាពប្រសើរឡើងនៃការសម្របសម្រួល និងការប្រាស្រ័យទាក់ទងហានិភ័យទូទាំងអង្គភាពសុខាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាថាព័ត៌មាន/សារមានខ្លឹមសារចុះសម្រុងគ្នា និងទប់ស្កាត់ព័ត៌មានក្លែងក្លាយ។

- ពង្រឹងប្រព័ន្ធគ្រប់គ្រងគុណភាពមន្ទីរពិសោធន៍វេជ្ជសាស្ត្រ រួមមានការវិនិយោគលើបច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធឱ្យមានលក្ខណៈទំនើប និងសមត្ថភាពធនធានមនុស្សរឹងមាំ។
- លើកកម្ពស់ការអនុវត្តវិធានការសុវត្ថិភាពនៃការបញ្ចូលឈាម និងផលិតផលឈាមតាមបទដ្ឋានគ្លីនិក និងធានាការផ្គត់ផ្គង់សមស្របតាមតម្រូវការ ជាពិសេស សម្រាប់ករណីសង្គ្រោះបន្ទាន់។
- លើកកម្ពស់កិច្ចសហការពហុវិស័យ និងសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ដើម្បីពង្រឹងភាពធន់ប្រព័ន្ធសុខាភិបាល រួមទាំងសន្តិសុខសុខភាពជាតិ រួមចំណែកដល់ការពង្រឹងភាពធន់តំបន់ និងសកល។

## ៧.៥. ការពង្រឹងសមត្ថភាព និងការធ្វើទំនើបកម្មប្រព័ន្ធសុខាភិបាល

### (១). ការអភិវឌ្ឍស្ថាប័ន និងអភិបាលកិច្ចសុខាភិបាល

- បន្តការរៀបចំប្រព័ន្ធ បែបបទ និងនីតិវិធី សម្រាប់ការអនុវត្តកិច្ចការរដ្ឋបាល ការងារគ្រប់គ្រង និងការងារបច្ចេកទេស ដើម្បីរក្សាជំហរស្ថាប័ននៅពីមុខសភាពការណ៍វិវត្តនៃឧស្សាហកម្មសុខភាព។
- ពង្រឹងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ ទូទាំងប្រព័ន្ធសុខាភិបាល លើកកម្ពស់ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃសមិទ្ធកម្មវិស័យសុខាភិបាល ព្រមទាំងការសិក្សាស្រាវជ្រាវសុខាភិបាល។
- ពង្រឹងសមត្ថភាព និងយន្តការនិយ័តកម្ម ដើម្បីធានាអនុលោមភាពច្បាប់ ស្តង់ដាបច្ចេកទេសនិងក្រមសីលធម៌ សំដៅលុបបំបាត់អាជីវកម្មគ្មានច្បាប់ក្នុងវិស័យសុខាភិបាល។
- លើកម្ពស់កិច្ចសហការអន្តរវិស័យ និងពហុវិស័យ ដោយរាប់បញ្ចូលទាំងវិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ក្នុងតំបន់ និងសកលលោក។

### (២). ការអភិវឌ្ឍធនធានមនុស្សសុខាភិបាល

- ពង្រឹងការរៀបចំ និងការអនុវត្តផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍធនធានមនុស្ស នៅកម្រិតប្រព័ន្ធ និងនៅកម្រិតមូលដ្ឋានសុខាភិបាល។
- លើកកម្ពស់គុណភាពនៃការបណ្តុះបណ្តាលអ្នកវិជ្ជាជីវៈសុខាភិបាល តាមរយៈនវានុវត្តវិធីសាស្ត្របង្រៀន និងរៀន ដែលផ្អែកលើសមត្ថភាពជាមូលដ្ឋាន និងជំរុញភាពប្រសើរឡើង នៃចំណេះដឹងអនុវត្តគ្លីនិក និងកម្មសិក្សាអនុវត្តគ្លីនិក និងការប្រឡង។
- រៀបចំ និងអនុវត្តគោលការណ៍ណែនាំបច្ចេកទេស សម្រាប់ការបណ្តុះបណ្តាលក្នុងពេលកំពុងបំរើការងារ ដើម្បីតាមរយៈការធ្វើស្តង់ដានីយកម្មការបណ្តុះបណ្តាល អភិក្រមបណ្តុះបណ្តាល និងការតាមដាន និងការវាយតម្លៃលទ្ធផលបណ្តុះបណ្តាល។
- លើកកម្ពស់ការជ្រើសរើស ការបែងចែក ការដាក់ឱ្យបំរើការងារ និងការរក្សាទុក បុគ្គលិកសុខាភិបាល ស្របតាមគោលដៅនៃការផ្តល់សេវាសុខាភិបាល និងការវិវត្តនៃការកែទម្រង់រដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ។

- ពង្រឹងយន្តការនិយ័តកម្មអ្នកវិជ្ជាជីវៈសុខាភិបាល ដើម្បីធានាសេវាថែទាំសុខភាព និងអន្តរាគមន៍សុខភាពសាធារណៈ មានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព។

### (៣). ការគ្រប់គ្រងហិរញ្ញវត្ថុ

- ជំរុញឱ្យប្រសើរឡើងនៃបែបបទរៀបចំថវិកាផ្អែកតាមកម្មវិធី ដោយតម្រង់ទិសធនធានឆ្ពោះទៅការផ្តល់សេវាថែទាំសុខភាពបឋម និងសេវាអាទិភាព/សារវន្ត ដើម្បីផ្សារភ្ជាប់រឹងមាំរវាងថវិកាវិភាជ និងអាទិភាពដែលផ្តោតលើប្រជាជន និងសេវាសុខភាព។
- តម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការ និងជំនួយអភិវឌ្ឍក្នុងវិស័យសុខាភិបាល ជាមួយអាទិភាពនៃកម្មវិធីនិងសេវា ព្រមទាំងសម្រួលរំហូរមូលនិធិទៅក្នុងផែនការថវិកា/ហិរញ្ញវត្ថុវិស័យសុខាភិបាល។
- ពង្រឹងសមត្ថភាពអង្គភាពថវិកា ក្នុងការសម្រេចចិត្តលើការរៀបចំថវិកា ការអនុវត្តថវិកា និងលើកកម្ពស់ការទទួលខុសត្រូវ/គណនេយ្យភាពលើលទ្ធផល។
- ធ្វើការតាមដានត្រួតពិនិត្យ និងសវនកម្មការគ្រប់គ្រងហិរញ្ញវត្ថុ ស្របតាមបែបបទ និងនិតិវិធី ជាធរមានដើម្បីលើកកម្ពស់សមិទ្ធកម្មគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### (៤). ផលិតផលសុខាភិបាល បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

- ធ្វើបច្ចុប្បន្នកម្មបញ្ជីឱសថសារវ័ន្តសម្រាប់ថ្នាក់ថផ្តល់សេវាថែទាំសុខភាពនីមួយៗ ផ្អែកលើគោលការណ៍មគ្គុទេសនៃការព្យាបាល និងប្រើប្រាស់បញ្ជីឱសថសារវ័ន្តសម្រាប់លទ្ធកម្ម ការបណ្តុះបណ្តាល អភិបាលកិច្ចឱសថ និងការទទួលជំនួយឱសថ។
- ជំរុញការផលិតនិងការចែកចាយឱសថសារវ័ន្តក្នុងស្រុក សម្ភារៈឧបករណ៍ពេទ្យ ដែលមានអនុលោមភាពជាមួយ Good Manufacturing Practice and Good Distribution Practice
- តាមដានត្រួតពិនិត្យ ធ្វើអធិការកិច្ច និងអង្កេតផលិតផលសុខភាពចរាចរលើទីផ្សារ ក្រោយពេលចុះបញ្ជិកា និងតាមដានប្រតិកម្មអវិជ្ជមានក្នុងការប្រើប្រាស់ផលិតផលសុខភាព ដើម្បីសុវត្ថិភាពអ្នកប្រើប្រាស់។
- បំពាក់ឧបករណ៍និងបច្ចេកវិទ្យាវេជ្ជសាស្ត្រសមស្រប ដល់មូលដ្ឋានសុខាភិបាល យោងតាមបញ្ជីស្តង់ដាឧបករណ៍ពេទ្យ និងជំរុញការប្រើប្រាស់ប្រកបដោយសន្ទិទានភាព។
- វិនិយោគលើឧបករណ៍វេជ្ជសាស្ត្រដែលមានបច្ចេកវិទ្យាខ្ពស់ផ្អែកលើការវិភាគចំណាយ-អត្ថប្រយោជន៍ ព្រមទាំងគិតគូរពិចារណាពីផលចំណេញសេដ្ឋកិច្ច តម្រូវការនៃការផ្តល់សេវា។
- ពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការព្យាករណ៍ពីតម្រូវ និងការតាមដានតម្រូវការ និងការផ្គត់ផ្គង់ឱសថ បរិក្ខារវ៉ាក់សាំង ប្រតិករ និងតាមដានស្ថានភាពស្តុក នៅក្នុងប្រព័ន្ធផ្គត់ផ្គង់ទាំងមូល។
- កែលម្អហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសុខាភិបាល ដូចជាការពង្រីកសំណង់អគារ បណ្តាញទឹកស្អាត អគ្គិសនី/ថាមពលបៃតង ប្រព័ន្ធបង្ហូរទឹកកង្វក់ ការគ្រប់គ្រងសំណល់។

### (៥). ការអភិវឌ្ឍទិន្នន័យ ការគ្រប់គ្រងព័ត៌មានសុខាភិបាល និងសុខាភិបាលឌីជីថល

- ធ្វើបច្ចុប្បន្នកម្មស្តង់ដាទិន្នន័យរួម និងរបាយការណ៍ ដើម្បីកែលម្អការប្រមូលទិន្នន័យទូទាំងប្រព័ន្ធនិងពីប្រភពផ្សេងៗគ្នា ព្រមទាំងផ្តល់ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងទិន្នន័យ។
- ធ្វើសមាហរណកម្ម និងអន្តរប្រតិបត្តិការនៃប្រព័ន្ធព័ត៌មានសុខាភិបាល ទៅក្នុងប្រព័ន្ធអេកូទិន្នន័យសុខាភិបាល ដើម្បីគាំទ្រដល់ការគ្រប់គ្រងទិន្នន័យ និងព័ត៌មានសុខាភិបាល។
- លើកកម្ពស់ការប្រើប្រាស់ថ្នាលឌីជីថល កែតម្រូវពីថ្នាលបច្ចេកវិទ្យាស្របតាមស្តង់ដាអន្តរជាតិ ជំរុញនវានុវត្តន៍និងការសម្របដំណោះស្រាយឌីជីថលឱ្យស្របតាមតម្រូវការ។
- ចាប់យកការប្រើប្រាស់បញ្ញាសប្បនិមិត្ត big data analytics និង machine learning នៅក្នុងការអនុវត្តគ្លីនិក ការងារគ្រប់គ្រង កិច្ចការរដ្ឋបាល ការសិក្សា និងការបណ្តុះបណ្តាលវេជ្ជសាស្ត្រ ការសិក្សាស្រាវជ្រាវសុខភាពសាធារណៈ និងក្នុងផ្នែកដទៃទៀត។
- បង្កើនចំណេះដឹងសុខាភិបាលឌីជីថល និងជំនាញក្នុងការវិភាគ និងការប្រើប្រាស់ទិន្នន័យ សម្រាប់ការអភិវឌ្ឍគោលនយោបាយ ផែនការ ការគ្រប់គ្រងធនធាន ការផ្តល់សេវាសុខាភិបាល អន្តរាគមន៍សុខភាពសាធារណៈ និងការតាមដាន និងវាយតម្លៃសមិទ្ធកម្ម។
- ពង្រឹងការផ្តល់ដំណឹងពីកំណើត និងមរណភាព (រួមទាំងមូលហេតុនៃការស្លាប់) ពីមូលដ្ឋានសុខាភិបាលសាធារណៈ និងឯកជន តាមប្រព័ន្ធអេឡិចត្រូនិច យោងតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

## ៧.៦. ក្របខ័ណ្ឌសូចនាករសម្រាប់ការតាមដាន និងការវាយតម្លៃ

| សូចនាករសំខាន់ៗ | ឯកតា | 2024 | 2025 | 2025 | 2026 | 2027 | សម្គាល់ |
|---|---|---|---|---|---|---|---|
| | | លទ្ធផល | | ចំណុចដៅ | | | |
| **១- កម្មវិធីសុខភាពបន្តពូជ មាតា ទារក និង កុមារ និងអាហារូបត្ថម្ភ** | | | | | | | |
| **1.** អត្រាប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបមួយក្នុងចំណោមស្ត្រីបានរៀបការអាយុ ១៥-៤៩ឆ្នាំ | % | 13.25 | 12.24 | 25 | 26 | 27 | NSDP/HSP4 |
| **2.** %ស្ត្រីមានគភ៌បានទទួលការថែទាំមុនសម្រាល ២លើក ដោយបុគ្គលិកសុខាភិបាល | % | 91.41 | 95.05 | 93 | 95 | 97 | HSP4 |
| **3.** ភាគរយនៃស្ត្រីមានគភ៌បានទទួលការថែទាំមុនសម្រាល ៤លើក ដោយបុគ្គលិកសុខាភិបាល | % | 72.02 | 73.04 | 75 | 78 | 82 | HSP4 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **4.** % ម្ដាយនិងទារកបានទទួលការពិនិត្យថៃទាំក្រោយសម្រាលលើកទី១ ក្នុងសប្ដាហ៍ទី១ ក្រោយសម្រាល ដោយបុគ្គលិកសុខាភិបាល | % | 51.8 | 51.48 | 59 | 73 | 77 | HSP4 |
| **5.** សមាមាត្រនៃការសម្រាលនៅមូលដ្ឋានសុខាភិបាលសាធារណៈ | % | 75.82 | 70.89 | 89 | 90 | 88 | HSP4 |
| **6.** សមាមាត្រនៃការសម្រាលដោយបុគ្គលិកសុខាភិបាល | % | 77.63 | 71.31 | 91 | 92 | 93 | NSDP/SDGs/ HSP4 |
| **7.** អត្រាសម្រាលដោយវិធីវះកាត់ | % | 11.96 | 13.84 | 11.5 | 12 | 12 | HSP4 |
| **8.** ភាគរយនៃទារកបានទទួលការបំបៅដោយទឹកដោះម្ដាយក្នុងអំឡុងមួយម៉ោងដំបូងនៃកំណើត | % | 72.73 | 76.28 | 74 | 76 | 77 | HSP4 |
| **9.** អត្រាគ្របដណ្ដប់នៃវ៉ាក់សាំងបង្ការកញ្ជ្រឹល-ស្អូច ដូសទី១ | % | 109.1 | 101.49 | > 95 | > 95 | > 95 | HSP4 |
| **10.** អត្រាគ្របដណ្ដប់នៃវ៉ាក់សាំង៣ដូស បង្ការជំងឺ ខាន់ស្លាក់ ស្វិតដៃជើង តេតាណូស រលាកសួត | % | 95.35 | 93.14 | > 95 | > 95 | > 95 | HSP4 |
| **11.** ករណីថ្មីពិនិត្យពិគ្រោះជំងឺក្រៅលើកុមារអាយុក្រោម៥ឆ្នាំម្នាក់ ក្នុងមួយឆ្នាំ | ចំនួនលើក | 1.63 | 1.77 | 1.69 | 1.71 | 1.73 | SDGs/HSP4 |
| **12.** ភាគរយស្ត្រីមានគភ៌បានទទួលគ្រាប់ថ្នាំជីវជាតិដែក/អាស៊ីតហ្វូលីក ៩០គ្រាប់ | % | 79.55 | 85.77 | 90 | 90 | 90 | NSDP/HSP4 |
| **13.** ភាគរយស្ត្រីក្រោយសម្រាលបានទទួលគ្រាប់ជីវជាតិដែក/អាស៊ីតហ្វូលិក៤២គ្រាប់ | % | 68.39 | 67.25 | 82 | 83 | 83.5 | HSP4 |
| **14.** ភាគរយកុមារអាយុពី១២ខែដល់៥៩ខែបានទទួលថ្នាំមេបង់ជាស្បុល ក្នុងអំឡុងពេល៦ខែចុងក្រោយនៃឆ្នាំ | % | 92.73 | 83.87 | 93 | 92 | 93 | HSP4 |
| **២- បង្ការ និងគ្រប់គ្រងជំងឺឆ្លង** | | | | | | | |
| **15.** ករណីឆ្លងថ្មីនៃមេរោគអេដស៍ក្នុងប្រជាជនដែលគ្មានផ្ទុកមេរោគអេដស៍ ១ ០០០នាក់ | ក្នុង 1 000 នាក់ | 0.07 | 0.07 | 0.07 | 0.06 | 0.06 | SDGs/HSP4 |

| | | | | | | | |
|---|---|---|---|---|---|---|---|
